បេតិកភណ្ឌ ពិភពលោក

លេខពិសេស

បេតិកភណ្ឌពិភពលោក នៅព្រះរាជាណាចក្រកម្ពុជា

United Nations Educational, Scientific and Cultural Organization

World Heritage Convention

9 789996 375842

WORLD HERITAGE

ទស្សនាវដ្តីបេតិកភណ្ឌលេខពិសេស
ស្តីអំពីបេតិកភណ្ឌពិភពលោកនៅព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្តីបេតិកភណ្ឌពិភពលោកលេខពិសេស ៦៨ ដែលមានអត្ថបទដើមជាភាសាបារាំង អង់គ្លេស និងអេស្ប៉ាញ៉ុលត្រូវបានបោះពុម្ពផ្សាយដោយអង្គការយូណេស្កូ នៅខែមិថុនា ឆ្នាំ២០១៣ សម្រាប់កិច្ចប្រជុំពេញអង្គលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលបានប្រព្រឹត្តិទៅនៅរាជធានីភ្នំពេញនិងទីក្រុងសៀមរាប។ កិច្ចប្រជុំត្រូវបានបើកជាផ្លូវការក្រោមអធិបតេយ្យភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចប្រជុំពេញអង្គត្រូវបានដឹកនាំដោយ ឯកឧត្តមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ២០១២-២០១៣។

ការបកប្រែនិងការបោះពុម្ពផ្សាយទស្សនាវដ្តីបេតិកភណ្ឌពិភពលោកលេខពិសេសជាភាសាខ្មែរត្រូវបានរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមគំនិតផ្តួចផ្តើមរបស់ឯកឧត្តមបណ្ឌិត សុខ អាន ។

អត្ថបទភាសាខ្មែរលេខពិសេសនេះត្រូវបានពិនិត្យនិងកែសម្រួលដោយរាជបណ្ឌិតសភានៃព្រះរាជាណាចក្រកម្ពុជា។

ទស្សនាវដ្ដីបេតិកភណ្ឌលេខពិសេស
ស្ដីអំពីបេតិកភណ្ឌពិភពលោកនៅព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្ដីបេតិកភណ្ឌពិភពលោកលេខពិសេស ៦៨ ដែលមានអត្ថបទដើមជាភាសាបារាំង អង់គ្លេស និងអេស្ប៉ាញ៉ុលត្រូវបានបោះពុម្ពផ្សាយដោយអង្គការយូណេស្កូ នៅខែមិថុនា ឆ្នាំ២០១៣ សម្រាប់កិច្ចប្រជុំពេញអង្គលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលបានប្រព្រឹត្តិទៅនៅរាជធានីភ្នំពេញនិងទីក្រុងសៀមរាប។ កិច្ចប្រជុំត្រូវបានបើកជាផ្លូវការក្រោមអធិបតេយ្យភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចប្រជុំពេញអង្គត្រូវបានដឹកនាំដោយ ឯកឧត្ដមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ២០១២-២០១៣។

ការបកប្រែនិងការបោះពុម្ពផ្សាយទស្សនាវដ្ដីបេតិកភណ្ឌពិភពលោកលេខពិសេសជាភាសាខ្មែរត្រូវបានរៀបចំឡើងដោយទីស្ដីការគណៈរដ្ឋមន្ត្រី ក្រោមគំនិតផ្ដួចផ្ដើមរបស់ឯកឧត្ដមបណ្ឌិត សុខ អាន ។

អត្ថបទភាសាខ្មែរលេខពិសេសនេះត្រូវបានពិនិត្យនិងកែសម្រួលដោយរាជបណ្ឌិតសភានៃព្រះរាជាណាចក្រកម្ពុជា។

បេតិកភណ្ឌពិភពលោក លេខពិសេស

អារម្ភកថា

ការចេញផ្សាយទស្សនាវដ្ដីបេតិកភណ្ឌពិភពលោកលេខពិសេសរៀងរាល់ឆ្នាំ ជាឱកាសបង្ហាញជូនមិត្តអ្នកអាននូវរមណីយដ្ឋាននានារបស់ប្រទេសដែលជាម្ចាស់ផ្ទះអ្នកទទួលរៀបចំសម័យប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ជាឱកាសពិនិត្យមើលតម្លៃដ៏ល្អឯកនៃរមណីយដ្ឋានបេតិកភណ្ឌទាំងនោះព្រមទាំងជាឱកាសស្វែងយល់អំពីកិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលបានធ្វើឡើងដើម្បីធានាការការពាររមណីយដ្ឋានទាំងនោះ។ លេខចុះផ្សាយនៅឆ្នាំ២០១៣នេះផ្តោតសំខាន់ទៅលើបេតិកភណ្ឌខ្មែរ។ លេខនេះបង្ហាញយើងទាំងអស់គ្នាអំពីការសិក្សាស្រាវជ្រាវដ៏គួរឲ្យស្ញប់ស្ញែងអំពីរមណីយដ្ឋានអង្គរនិងអំពីប្រាសាទព្រះវិហារ។

ឧទ្យានអង្គរគឺជារមណីយដ្ឋានបុរាណវិទ្យាដ៏ធំមួយក្នុងចំណោមរមណីយដ្ឋានបុរាណវិទ្យាធំៗទាំងឡាយនៅក្នុងពិភពលោកដែលគេកំពុងបើកឲ្យទស្សនា។ ប្រវត្តិឧទ្យានអង្គរគឺជាបដិរូបនៃអ្វីដែលអនុសញ្ញាបេតិកភណ្ឌពិភពលោកអាចសម្រេចបាន មិនត្រឹមតែក្នុងន័យទទួលស្គាល់បេតិកភណ្ឌប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងន័យប្រមែប្រមូលជំនាញ ធនធាននិងកិច្ចសហប្រតិបត្តិការទាំងឡាយដើម្បីធ្វើឲ្យកិច្ចការអភិរក្សសម្រេចទៅបាន។ ស្ថិតនៅក្នុងផ្ទៃដីប្រមាណជា៤០០គីឡូម៉ែត្រក្រឡា ឧទ្យានបុរាណវិទ្យាអង្គរពោរពេញទៅដោយសំណល់បុរាណវត្ថុដ៏ល្អឯកជាច្រើននៃរាជធានីផ្សេងៗរបស់អាណាចក្រខ្មែរដែលរះចិញ្ចែងចិញ្ចាច ចាប់តាំងពីសតវត្សទី៩ដល់សតវត្សទី១៥។ ដោយសារសង្គ្រាមនិងទុរភិក្សជាហូរហែដែលបានធ្វើឲ្យប្រទេសមួយនេះរង្គោះរង្គើក្នុងអំឡុងទសវត្សទី៧០នៃសតវត្សទី២០ ឧទ្យានអង្គរបានទទួលរងនូវការខូចខាតយ៉ាងដំណំ។ នៅឆ្នាំ១៩៩២ ឧទ្យានអង្គរត្រូវបានចុះក្នុងពេលដំណាលគ្នាក្នុងបញ្ជីបេតិកភណ្ឌពិភពលោកផងនិងក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងសភាពគ្រោះថ្នាក់ផង។ ដោយសារការបង្កើតឡើងនូវគណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ដែលហៅកាត់ថា អាយស៊ីស៊ី អង្គរ និងការបង្កើតអាជ្ញាធរអប្សរាដែលមានន័យពេញថា អាជ្ញាធរដើម្បីការការពាររមណីយដ្ឋាននិងការគ្រប់គ្រងតំបន់អង្គរនិងសៀមរាប ព្រមទាំងដោយសារកិច្ចខិតខំប្រឹងប្រែងជាប់ជាប្រចាំរបស់អ្នកជំនាញអន្តរជាតិ រមណីយដ្ឋានអង្គរត្រូវបានដកចេញពីបញ្ជីគ្រោះថ្នាក់នៅឆ្នាំ២០០៤។

ចំណែកឯប្រាសាទព្រះវិហារគឺជាប្រាសាទដែលឧទ្ទិសដល់ព្រះឥសូរ។ ប្រាសាទនេះស្ថិតនៅក្នុងស្ថានភាពអភិរក្សយ៉ាងល្អនិងត្រូវបានកសាងឡើងនៅសតវត្សទី៩។ ជាមហាស្នាដៃឯកនៃស្ថាបត្យកម្មខ្មែរ ប្រាសាទព្រះវិហារត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ២០០៨។

ទស្សនាវដ្ដីលេខពិសេសមួយនេះ ផ្តោតសំខាន់ទៅលើការអភិរក្សនៃរមណីយដ្ឋានដ៏ល្អឯកទាំងនេះ ព្រមទាំងទៅលើកិច្ចការគន្លឹះផ្សេងៗ ដូចជាការគ្រប់គ្រងទឹក ការថែរអភិរក្សប្រព័ន្ធធារាសាស្ត្របុរាណនិងការរីកចម្រើនផ្នែកទេសចរណ៍។ អ្នកជំនាញដែលទទួលបន្ទុកខាងការអភិរក្សគំនូរនៅលើជញ្ជាំងវត្តបាគង ហេដ្ឋារចនាសម្ព័ន្ធនៃក្រុងអង្គរធំ ប្រាសាទបន្ទាយក្ដីនិងប្រាសាទបាយ័ន ក៏ផ្តល់ជូនយើងផងដែរនូវព័ត៌មានដ៏ល្អៗអំពីបេតិកភណ្ឌទាំងនេះ។

អត្ថបទនិយាយពីទិដ្ឋភាពផ្សេងទៀតនៃវប្បធម៌ខ្មែរដូចជា របាំព្រះរាជទ្រព្យនិងល្ខោនស្រមោលស្បែកធំ បណ្ណសារនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលជាស្មារតីចងចាំនៃពិភពលោកនៅកម្ពុជាព្រមទាំងបឹងជីវៈចម្រុះទន្លេសាប ក៏ត្រូវបានចុះផ្សាយនៅក្នុងលេខពិសេសនេះដែរ ដើម្បីផ្តល់ជូននូវទិដ្ឋភាពមួយទូទៅគ្រប់ជ្រុងជ្រោយអំពីបេតិកភណ្ឌដ៏អស្ចារ្យទាំងនេះ។

ខ្ញុំសូមសម្ដែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានចូលរួមប្រកបដោយអត្ថន័យក្នុងការអនុវត្តអនុសញ្ញាបេតិកភណ្ឌពិភពលោក រួមទាំងពេលដែលកម្ពុជាធ្វើជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនាពេលបច្ចុប្បន្ននេះ ហើយខ្ញុំសូមអរគុណដល់កម្ពុជាដែលធ្វើជាប្រធាននិងទទួលរៀបចំសម័យប្រជុំលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលនឹងប្រព្រឹត្តិទៅនៅឆ្នាំនេះនៅទីក្រុងភ្នំពេញ។

គ្រប : អង្គរភាពលេចធ្លោនៃភាពចុះសម្រុងគ្នារវាងវប្បធម៌និងធម្មជាតិ (ប្រាសាទព្រះខ័ន) (ព្រះរាជាណាចក្រកម្ពុជា)



Cover: Angkor's magnificent harmony of art and nature (the temple of Preah Khan) (Cambodia)

Couverture :Magnifique harmonie entre l'art et la nature à Angkor (le temple de Preah Khan)

Portada:Hermosa armonía entre el arte y la naturaleza en Angkor (Preah Khan)

គីស័រ រ៉ាវ
នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

បេតិកភណ្ឌពិភពលោក

ទស្សនាវដ្ដីប្រចាំត្រីមាសត្រូវបានបោះពុម្ពជាភាសាអង់គ្លេស បារាំង និងអេស្ប៉ាញដោយអង្គការសហប្រជាជាតិសំរាប់(យូណេស្កូ)នៅទីក្រុងប៉ារីស ប្រទេសបារាំង សហការជាមួយក្រុមហ៊ុន Publishing For Development Ltd. នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។

នាយកនិពន្ធ
Kishore Rao
នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់យូណេស្កូ

អ្នកគ្រប់គ្រងការនិពន្ធទូទៅ
Vesna Vujicic-Lugassy

អ្នកគ្រប់គ្រងការនិពន្ធលេខពិសេសនេះ
Helen Jarvis

ជំនួយការនាយកនិពន្ធ
Helen Aprile, Gina Doubleday, Michael Gibson

អ្នកបោះពុម្ព
Richard Forster

អ្នករៀបចំការផលិត
Caroline Fort

អ្នកកែសម្រួល
Caroline Lawrence (អង់គ្លេស), Brigitte Straiss (បារាំង), Luisa Futoransky (អេស្ប៉ាញ)

ក្រុមប្រឹក្សារៀបចំការបោះពុម្ពផ្សាយ
ICCROM: Joseph King, ICOMOS: Regina Durighello, IUCN: Tim Badman, UNESCO World Heritage Centre: Giovanni Boccardi, Véronique Dauge, Guy Debonnet, Lazare Eloundou-Assomo, Feng Jing, Mechitld Rossler, Nuria Sanz, Petya Totcharova, UNESCO Publishing: Ian Denison

ជំនួយការរៀបចំការបោះពុម្ពផ្សាយ
Barbara Blanchard

អ្នកគ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្ម
Fernando Ortiz, Peter Warren

អ្នកគ្រប់គ្រងគ្រប
រូបភាព: Ross Huggett
រៀបរៀង: Recto Verso

បុគ្គលិករៀបចំការផ្សព្វផ្សាយ
World Heritage Centre, UNESCO, 7, Place de Fontenoy, 75007 Paris
Tel. (33.1) 45 68 16 60 –Fax (33.1) 45 68 55 70
E-mail: g.doubleday@unesco.org
INTERNET: http://whc.unesco.org

ការផលិតនិងពាណិជ្ជកម្ម
Publishing For Development,
5 St. John's Lane - London EC1M 4BH-UK
Tel: +44 2032 866610 -Fax: +44 2075 262173
E-mail: info@pfdmedia.com

ការជាវជាប្រចាំ
Jean De Lannoy, DL Services sprl -
Avenue du Roi 202 -B 1190 Brussels -Belgium
Tel: +32 25384308 –Fax: +32 25380841
E-mail: subscriptions@dl-servi.com

អ្នកនិពន្ធទទួលខុសត្រូវចំពោះការជ្រើសរើស និងបង្ហាញអត្ថាធិប្បាយដែលមាននៅក្នុងអត្ថបទរបស់ខ្លួន។ ម្យ៉ាងទៀតគំនិតយោបល់ក្នុងអត្ថបទទាំងឡាយពុំផ្តល់កាតព្វកិច្ចណាមួយទៅឲ្យអង្គការយូណេស្កូនេះឡើយ។ ការប្រើប្រាស់និងបង្ហាញពាក្យ ឬឈ្មោះជាលក្ខណៈធម្មានរូបតាមរយៈការបោះពុម្ពមិនបានបង្ហាញអំពីគំនិតណាមួយជារបស់អង្គការយូណេស្កូទាក់ទងទៅនឹងទិដ្ឋភាពច្បាប់ ទឹកដី ទីក្រុង តំបន់ដែនសមត្ថកិច្ច អំណាច ឬក៏ការកំណត់ពីព្រំដែន ឬក៏ព្រំប្រទល់នៃប្រទេសណាមួយឡើយ។

អត្ថបទជាភាសាខ្មែរ បោះពុម្ពដោយក្រុមហ៊ុន Graphic Roots នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ISBN 978-99963-758-4-2

© រក្សាសិទ្ធិដោយទីស្តីការគណៈរដ្ឋមន្ត្រី ២០១៣

មាតិកា







សាររបស់លោកជំទាវ អ៊ីរីណា បូកូវ៉ា អគ្គនាយិកាអង្គការយូណេស្កូ ៤

សារស្វាគមន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៥

បទសម្ភាសជាមួយ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ៦

ផែនទីបុរាណវិទ្យា ១០

ឧទ្យានអង្គរ ១២

- *ប្រាសាទនិងបុរាណវិទ្យា* ១៤
- *ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ* ១៨
- *បេតិកភណ្ឌនិងប្រជាជនក្នុងឧទ្យានអង្គរ* ២២
- *រូបគំនូរនៅលើជញ្ជាំងវត្តបាគង* ២៦
- *ប្រាសាទតាព្រហ្ម* ៣០
- *ការជួសជុលនិងពង្រឹងសំណង់ឥដ្ឋប្រាសាទប្រែរូប* ៣៤
- *ប្រាសាទបាយ័ន តើអត្ថន័យដ៏វិសេសវិសាលបានមកពីរូបចម្លាក់ឬក៏ស្ថាបត្យកម្ម?* ៣៨
- *ប្រាសាទបាពួន ប្រវត្តិនៃការរស់ឡើងវិញមួយ* ៤២
- *មរតកដ៏មានតម្លៃនៃប្រាសាទបន្ទាយក្តី* ៤៦
- *ប្លង់ឧជុកោណនៃរាជបុរីអង្គរធំ* ៥០
- *ការសិក្សាស្រាវជ្រាវថ្មីលើរមណីយដ្ឋានអង្គរ ភ្នំគូលែននិងកោះកែរ តាមបច្ចេកវិទ្យា LIDAR* ៥៤

បេតិកភណ្ឌពិភពលោក *លេខពិសេស*





ប្រាសាទព្រះវិហារ ៥៨

- *ព្រះវិហារ ប្រាសាទនៃភ្នំពិសិដ្ឋ* ៦០
- *ប្រព័ន្ធធារាសាស្ត្រនៃប្រាសាទព្រះវិហារ* ៦៤
- *ព្រះវិហារ និមិត្តរូបលោកធាតុសាស្ត្រតំបន់* ៧០
- *ព្រះឥសូរ - បរិស្ថានៈការជាប់ទាក់ទងរវាង ប្រាសាទព្រះវិហារ ប្រាសាទវត្តភូនិងរមណីយដ្ឋាន មីសិន ដែលសុទ្ធតែត្រូវបានចាត់បញ្ចូលក្នុងបញ្ជី បេតិកភណ្ឌពិភពលោក* ៧៤

តំបន់ក្នុងបញ្ជីបម្រុង ៧៨

- *កោះកេរប្រាសាទចិន និងចម្លាក់នៅក្នុងប្រាសាទនេះ* ៨០
- *រមណីយដ្ឋានសម្បូរព្រៃគុក ក្រុងប្រាសាទបុរាណ* ៨៤

បេតិកភណ្ឌអរូបីយ ៨៨

- *របាំព្រះរាជទ្រព្យនៃព្រះរាជាណាចក្រកម្ពុជា* ៩០
- *ស្បែកធំ ល្ខោនស្រមោលខ្មែរ* ៩២

ប្រវត្តិជោគជ័យនៃអាងជីវៈចម្រុះបឹងទន្លេសាប ៩៤

ស្មារតីចងចាំនៃពិភពលោករបស់កម្ពុជា ៩៦





ទស្សនាវដ្តីបេតិកភណ្ឌពិភពលោក សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មការជាតិយូណេស្កូកម្ពុជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា និងអ្នកនិពន្ធអត្ថបទទាំងអស់ ព្រមទាំងលោកជំទាវ តាន់ ធានី លោកសាស្ត្រាចារ្យ អាហ្សេឌីន បេសាអួស និងជាពិសេស លោកជំទាវ ហេឡិន ចារិស ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំទស្សនាវដ្តីលេខពិសេស ៦៨ នេះ។

សម្រាប់អត្ថបទជាភាសាខ្មែរ យើងខ្ញុំសូមសំដែងការកោតសរសើរចំពោះអ្នកបកប្រែអត្ថបទទាំងអស់ ជាពិសេស លោក លីម ប៊ុនហុក និង លោក អ៊ុង រដ្ឋា ដែលបានចូលរួមក្នុងការងារនេះ។

UNESCO Publishing

United Nations Educational, Scientific and Cultural Organization

World Heritage Convention

GRAPHIC ROOTS design

United Nations
Educational, Scientific and
Cultural Organization

សាររបស់ លោកជំទាវ អ៊ីរីណា បូកូវ៉ា អគ្គនាយិកាអង្គការយូណេស្កូ

បេតិកភណ្ឌវប្បធម៌កម្ពុជា ស្តែងចេញនូវគំនិតដ៏សំខាន់ដែលជាគ្រឹះនៃអនុសញ្ញាបេតិកភណ្ឌពិភពលោកនោះគឺភាពជឿជាក់យ៉ាងច្បាស់ថា រាល់រមណីយដ្ឋានទាំងឡាយដែលមានតម្លៃឯកជាសាកលត្រូវតែទទួលបាននូវការការពារនិងការលើកស្ទួយដើម្បីជាប្រយោជន៍របស់មនុស្សជាតិទាំងមូល។

ប្រាសាទព្រះវិហារជាប្រាសាទមួយដែលឧទ្ទិសដល់ព្រះឥសូរ។ ដោយស្ថិតក្នុងស្ថានភាពអភិរក្សល្អគួរឲ្យកត់សំគាល់ប្រាសាទនេះមានឈ្មោះល្បីដោយសារស្នាដៃស្ថាបត្យកម្មនិងចម្លាក់ថ្មដ៏ល្អផូរផង់។ ចំណែកឯឧទ្យានបុរាណវិទ្យាអង្គរ គឺពិតជាពោរពេញទៅដោយសំណល់បុរាណវត្ថុដ៏ល្អឯកជាច្រើននៃរាជបុរីផ្សេងៗរបស់អាណាចក្រខ្មែរដែលរះចិញ្ចែងចិញ្ចាចចាប់តាំងពីសតវត្សទី៩ ដល់សតវត្សទី១៥។ រមណីយដ្ឋានទាំងពីរនេះគឺជាសាក្សីដ៏សំខាន់បញ្ជាក់អំពីប្រវត្តិសាស្ត្រមួយដ៏សំបូរបែប គ្មានអ្វីមកជំនួសបានសម្រាប់គ្រប់សង្គមទាំងអស់។ រមណីយដ្ឋានទាំងពីរក៏រំលឹកយើងឡើងវិញផងដែរអំពីកាតព្វកិច្ចដែលយើងទាំងអស់គ្នាត្រូវចែករំលែក ដើម្បីអភិរក្សនិងលើកស្ទួយបេតិកភណ្ឌពិភពលោក។

ឧទ្យានអង្គរបង្ហាញនូវវិសាលភាពដ៏អស្ចារ្យនៃសមិទ្ធផលដែលសម្រេចបាន ដោយសារកិច្ចសហប្រតិបត្តិការអន្តរជាតិ។ វេទិកាវិទ្យាសាស្ត្រដែលបង្កើតឡើងជាពិសេសដោយគណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរអនុញ្ញាតជាអាទិ៍ឲ្យមានការរៀបចំប្រជុំនិងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងជាច្រើននៅក្នុងវិស័យផ្សេងៗ ដូចជាការជួសជុល ការអភិរក្ស ឬការស្រាវជ្រាវ ដោយផ្តល់ឱកាសឲ្យស្ថាបត្យករ វិស្វករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗផ្លាស់ប្តូរយោបល់ ព័ត៌មាន និងវិធីសាស្ត្រស្រាវជ្រាវរវាងគ្នាទៅវិញទៅមក។ ថ្វីត្បិតថានៅពេលនេះ បញ្ហាលំនឹងរចនាសម្ព័ន្ធប្រាង្គប្រាសាទអង្គរ ត្រូវបានដោះស្រាយរួចហើយក្តី ប៉ុន្តែបញ្ហាអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃរមណីយដ្ឋាន នៅតែជាបញ្ហាប្រឈមមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ មានជាអាទិ៍ អាជ្ញាធរអប្សរា ដែលមានពាក្យពេញថា អាជ្ញាធរដើម្បីការការពាររមណីយដ្ឋាននិងការគ្រប់គ្រងតំបន់អង្គរនិងសៀមរាប។ ខ្ញុំពិតជារីករាយជាអនេកចំពោះជោគជ័យដ៏ត្រចះត្រចង់ដែលទទួលបាននៅអង្គរ ក្រោមការគាំទ្រពីគណៈកម្មាធិការបេតិកភណ្ឌពិភពលោក តាំងពីពេលចុះរមណីយដ្ឋាននេះនៅឆ្នាំ១៩៩២ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនិងក្នុងបញ្ជីក្នុងសភាពគ្រោះថ្នាក់ហើយការលុបឧទ្យាននេះ ចេញពីបញ្ជីគ្រោះថ្នាក់ត្រូវបានធ្វើឡើងនៅឆ្នាំ២០០៤។

© UNESCO

បច្ចុប្បន្ននេះ ឧទ្យានអង្គរមិនត្រឹមតែជាគោលដៅទេសចរណ៍ដ៏ធំមួយ នៅក្នុងទ្វីបអាស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាចលករដ៏ខ្លាំងក្លាមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។ អង្គរក្លាយជាគំរូនៃការគ្រប់គ្រងរមណីយដ្ឋាន ដែលបានផ្តល់ជាគំនិតឲ្យបង្កើតឡើងនូវគម្រោងជួសជុលធំៗជាច្រើនផ្សេងទៀតនៅក្នុងពិភពលោក។ កិត្តិនាមដ៏ល្បីល្បាញនៅលើពិភពលោកនៃរមណីយដ្ឋាននេះក៏ជួយបំផុសឲ្យសាធារណជនយល់អំពីភាពផុយស្រួយនៃរមណីយដ្ឋានបេតិកភណ្ឌពិភពលោក ហើយរំលឹកយើងអំពីទំនួលខុសត្រូវរួមគ្នារបស់យើងក្នុងការធានាការការពាររមណីយដ្ឋានទាំងនេះ។ ការផ្សារភ្ជាប់ទំនាក់ទំនងរវាងវិស័យបេតិកភណ្ឌពិភពលោកនិងទេសចរណ៍ប្រកបដោយនិរន្តរភាពនៅពេលនេះ ពិតជាមានអត្ថន័យពិសេស ក្នុងការផ្តល់ព័ត៌មានជូនភ្ញៀវទេសចរនិងជួយអ្នកគ្រប់គ្រងរមណីយដ្ឋាននិងដៃគូទាំងឡាយនៅក្នុងវិស័យទេសចរណ៍ឲ្យស្វែងរកដំណោះស្រាយដែលសមស្របទៅនឹងស្ថានភាពនៅមូលដ្ឋាន។

ប៉ុន្តែនៅក្នុងទស្សនាវដ្តីលេខពិសេសមួយនេះពិតជាមានប្រធានបទផ្សេងៗច្រើនទៀតក្រៅពីបេតិកភណ្ឌពិភពលោក។ លេខនេះក៏ធ្វើឲ្យយើងបានយល់ផងដែរ អំពីប្រពៃណីវប្បធម៌ដ៏គួរឲ្យស្ញប់ស្ញែងដូចជា របាំព្រះរាជទ្រព្យខ្មែរនិងល្ខោនស្រមោលស្បែកធំ ជាទម្រង់សិល្បៈពីរដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ បឹងជីវៈចម្រុះទន្លេសាបខ្មែរ ដែលជារមណីយដ្ឋានដ៏ធំមួយសម្រាប់រក្សាតុល្យភាពអេកូឡូស៊ីនិងសេដ្ឋកិច្ចរបស់ប្រទេសនិងជាផ្នែកមួយនៃកម្មវិធីមនុស្សនិងជីវៈចម្រុះ របស់អង្គការយូណេស្កូ។ មានអត្ថបទមួយទៀតនិយាយអំពីបណ្ណសារសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ បណ្ណសារទាំងនេះត្រូវបានចាត់ចូលជាស្មារតីចងចាំពិភពលោករបស់អង្គការយូណេស្កូនិងពោរពេញទៅដោយកស្តុតាងក្នុងទម្រង់ជារូបថតនិងឯកសារផ្សេងៗនៅក្នុងអតីតមន្ទីរឃុំឃាំងនិងមណ្ឌលសួរចម្លើយដែលរបបខ្មែរក្រហមបានបង្កើតឡើងនៅទីនោះ។ ឯកសារទាំងនេះគឺជាសក្ខីកម្មដ៏សំខាន់នៃសម័យដ៏ងងឹតសូន្យសុងមួយក្នុងប្រវត្តិសាស្ត្រកម្ពុជានិងប្រវត្តិសាស្ត្រមនុស្សជាតិទាំងមូល។

ភាពសំបូរបែបនៃប្រធានបទទាំងនេះឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រគ្រោបរួមរបស់អង្គការយូណេស្កូ និងចង្អុលបង្ហាញអំពីភាពសំបូរបែបនិងភាពស្មុគស្មាញនៃបេតិកភណ្ឌវប្បធម៌ដែលគ្របដណ្តប់ទៅលើប្រាង្គប្រាសាទនិងរមណីយដ្ឋាន ទម្រង់សិល្បៈរស់រវើក ក៏ដូចជាបេតិកភណ្ឌឯកសារជាដើម។

ចាប់តាំងពីពេលផ្តល់សច្ចាប័នលើអនុសញ្ញាបេតិកភណ្ឌពិភពលោកនៅឆ្នាំ ១៩៩១ មក កម្ពុជាគឺជាដៃគូមួយដ៏សកម្មនិងជួយជ្រោមជ្រែងក្នុងការលើកស្ទួយការអនុវត្តអនុសញ្ញា។ នៅឆ្នាំ២០១៣ កម្ពុជានឹងបញ្ចប់អាណត្តិរបស់ខ្លួនជាសមាជិករបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក(២០០៩-២០១៣)និងទទួលធ្វើជាម្ចាស់ផ្ទះនៃសម័យប្រជុំលើកទី៣៧របស់គណៈកម្មាធិការនៅទីក្រុងភ្នំពេញ។ ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែងប្រកបដោយសណ្តានចិត្តថ្លៃថ្លា ដែលកម្ពុជាបានសម្តែងឲ្យឃើញក្នុងបណ្តាឆ្នាំកន្លងមក ដើម្បីធ្វើឲ្យបេសកកម្មនៃអនុសញ្ញាបេតិកភណ្ឌពិភពលោកដើរទៅមុខ ហើយខ្ញុំពិតជារីករាយនឹងបន្តកិច្ចសហការរបស់យើងក្នុងការការពារបេតិកភណ្ឌដ៏ល្អឯករបស់មនុស្សជាតិ ដើម្បីជាប្រយោជន៍របស់ប្រជាជាតិទាំងឡាយនៅលើផែនដីនាពេលបច្ចុប្បន្ននេះនិងទៅថ្ងៃអនាគត។

សារស្វាគមន៍របស់

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

© ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ព្រះរាជាណាចក្រ កម្ពុជា មានកិត្តិយសដ៏ឧត្តុង្គឧត្តមក្នុងការទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលនឹងប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញនិងនៅសៀមរាប-អង្គរ។

ដូច្នេះ រាជរដ្ឋាភិបាលបានចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីធានាជូនភ្ញៀវកិត្តិយសទាំងអស់នូវការស្នាក់អាស្រ័យ ប្រកបដោយលទ្ធផលជាផ្លែផ្កានិងចំណេះដឹងថ្មីៗ ព្រមទាំងភាពសប្បាយរីករាយផងដែរ។

សមាជិកនៃគណៈកម្មាធិការព្រមទាំងតំណាងនៃរដ្ឋសមាជិកទាំងអស់នៃអនុសញ្ញាឆ្នាំ១៩៧២ នឹងទទួលបាននូវបដិសណ្ឋារកិច្ចយ៉ាងកក់ក្ដៅនិងជួបប្រជុំពិភាក្សាការងារនៅក្នុង "វិមានសន្តិភាព" ដែលជាទីស្ដីការគណៈរដ្ឋមន្ត្រីនិងជាទីកន្លែងដែលធ្លាប់បានទទួលរៀបចំសន្និសីទអន្តរជាតិធំៗជាច្រើន ដូចជាកិច្ចប្រជុំកំពូលអាស៊ានកាលពីពេលថ្មីៗកន្លងទៅនេះដែលមានប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃមហាប្រទេសជាច្រើនលើពិភពលោកបានអញ្ជើញមកចូលរួម។

ស្ថិតនៅមិនឆ្ងាយពីឧទ្យានអង្គរដែលជារតនវត្ថុត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌរបស់មនុស្សជាតិ (យូណេស្កូ) ហើយក៏នៅចម្ងាយប្រមាណតែពីរឬបីម៉ោងប៉ុណ្ណោះពីប្រាសាទព្រះវិហារដែលស្ថិតនៅលើកំពូលភ្នំយ៉ាងខ្ពស់គួរឱ្យស្ញប់ស្ញែង ជាអាសនៈសម្រាប់ព្រះឥសូរដ៏សក្តិសមតាមបំណងរបស់ព្រះអង្គ ភ្ញៀវកិត្តិយសទាំងអស់ប្រាកដជានឹងទទួលបាននូវកម្លាំងចិត្តបន្ថែមនិងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនសំដៅជំរុញការអនុវត្តអនុសញ្ញានេះឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

ខ្ញុំសូមឱ្យការស្នាក់អាស្រ័យរបស់ភ្ញៀវទាំងអស់ មានភាពរីករាយមិនអាចបំភ្លេចបាន។ សូមឱ្យការងាររបស់លោកអ្នកទាំងអស់គ្នាជួយដល់ការពង្រឹងសាមគ្គីភាពវប្បធម៌អន្តរជាតិ ដើម្បីជាប្រយោជន៍នៃការសន្ទនានិងការយល់ដឹងអំពីតម្លៃនៃអរិយធម៌ពីគ្នាទៅវិញទៅមក!

ប្រសិនបើមានការយល់ដឹងច្បាស់និងមានការគោរពជាសកលនោះ បេតិកភណ្ឌរបស់មនុស្សជាតិ នឹងអាចក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លាយ៉ាងពិតប្រាកដសម្រាប់ការរក្សាសន្តិភាពពិភពលោក។

ប្រាសាទអង្គរវត្ត

© Ross Huggett

បទសម្ភាសជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន

© ទីស្ដីការគណៈរដ្ឋមន្ត្រី

ឯកឧត្តមបណ្ឌិត សុខ អាន ប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក(២០១២-២០១៣) ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីនិងសមាជិកសភាកម្ពុជា។ ឯកឧត្តមមានបទពិសោធយ៉ាងជ្រាលជ្រៅក្នុងវិស័យបេតិកភណ្ឌវប្បធម៌និងការទូត ដែលក្នុងនោះរួមមាន ឋានៈជាប្រធានទាំងគណៈកម្មាការជាតិសម្រាប់យូណេស្កូ ទាំងអាជ្ញាធរជាតិអប្សរា។

សម្ភាសដោយ ***អាហ្សេឌីន បេសធាអ៊ូច***

សាស្ត្រាចារ្យ អាហ្សេឌីន បេសធាអ៊ូច គឺជាបុរាណវិទូនិងជាសមាជិកបណ្ឌិតសភាបារាំងខាងសិលាចារឹកនិងអក្សរផ្ទង់។ លោកសាស្ត្រាចារ្យក៏ជាអតីតប្រធាន(ពីរលើក)និងជាអ្នករាយការណ៍(បួនលើក) នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។

សាស្ត្រាចារ្យ អាហ្សេឌីន បេសធាអ៊ូច :
តើឯកឧត្តមអាចមានប្រសាសន៍បែបណា ចំពោះលក្ខណៈពិសេសដាច់ដោយឡែកនៃអនុសញ្ញាបេតិកភណ្ឌពិភពលោកឆ្នាំ១៩៧២?

ឯកឧត្តមបណ្ឌិត សុខ អាន : *ជាបឋម ខ្ញុំអាចនិយាយបានថាអ្វីដែលធ្វើឱ្យដាច់ដោយឡែកពីគ្នាបំផុតនៃអនុសញ្ញាឆ្នាំ១៩៧២គឺ តថភាពដែលថាក្នុងការទទួលស្គាល់នូវសារៈសំខាន់នៃពហុភាពវប្បធម៌ វាផ្ដល់នូវទិដ្ឋភាពវប្បធម៌ដោយឡែកនៃសាកលភាវូបនីយកម្ម។ ក្នុងន័យនេះ អនុញ្ញាតឱ្យខ្ញុំរំលឹកជូនលោកសាស្ត្រាចារ្យនូវចំណុចមួយចំនួន។*

ឥឡូវនេះ យើងបានឃើញនូវការបញ្ចប់នៃភាពមិនអាចផ្សះផ្សាបានរវាងភាគីពីរនៃរាំងននដែកដែលបានខណ្ឌចែករវាងប្លុកលោកខាងកើតនិងលោកខាងលិច។ បន្តិចម្ដងៗ នៅទូទាំងពិភពលោក ច្រកនៃការសន្ទនានិងការស្វែងរកកិច្ចព្រមព្រៀងមួយត្រូវបានពង្រីង។ ថ្វីបើមានអតុល្យភាពសេដ្ឋកិច្ចនិងការមិនចុះសម្រុងសង្គមយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏ក្នុងពេលបច្ចុប្បន្ន មនុស្សជាតិភាគច្រើនបំផុតកំពុងត្រិះរិះពិចារណាជាថ្មីម្ដងទៀត ដើម្បីស្វែងរកផ្លូវនិងមធ្យោបាយក្នុងការកសាងសន្តិភាពក្នុងអារម្មណ៍បុរសនិងស្ត្រីដូចដែលបានដាក់ចេញក្នុងឯកសារជាមូលដ្ឋានរបស់យូណេស្កូ។ ជាលទ្ធផល តួនាទីរបស់យូណេស្កូត្រូវបានពង្រឹងផងដែរ ដោយសារកិច្ចប្រឹងប្រែងរួមនិងប្រកបដោយចីរភាពនៃរដ្ឋជាសមាជិកនិងគោលដៅនៃអគ្គនាយកដ៏ចំណានដែលបានបន្តវេនបន្តបន្ទាប់គ្នា។

ដូចដែលបានបង្ហាញយ៉ាងច្បាស់តាមរយៈការរិភាគនិងតាពងពេលវេលានៅក្នុងអំឡុងពេលប្រារព្ធខួបលើកទី៦៥របស់យូណេស្កូ ឥឡូវនេះ អង្គការអន្តរជាតិរបស់យើងបានក្លាយជាអង្គការសកលយ៉ាងពិតប្រាកដ។ ជាងនេះទៅទៀត អង្គការបានក្លាយជាកន្លែងដ៏ប្រសើរជាងគេក្នុងការចែករំលែកនូវចក្ខុវិស័យ ការស្នើឱ្យមាននវានុវត្តនិងជម្រើសនូវការផ្លាស់ប្ដូរ បើសិនជាមិនមានការចែករំលែកចំណេះដឹងនិងចំណេះធ្វើ។

ជាដំបូង ខ្ញុំអាចរំលឹកពីកិច្ចការជាសកលដែលសក្ដិសមបំផុតរបស់យូណេស្កូនោះ គឺជាការពន្លេចឡើងនូវគំនិតនៃសកលភាព ដែលជាការជំរុញទឹកចិត្តរបស់អ្នកទាំងឡាយដែលបានតាក់តែង ដោយផ្ចិតផ្ចង់នូវអនុសញ្ញាឆ្នាំ១៩៧២ឡើង។

យើងដឹងយ៉ាងច្បាស់ថា មុនពេលការអនុម័តលើអនុសញ្ញានេះដោយសម័យប្រជុំពេញអង្គយូណេស្កូនៅក្នុងសម័យប្រជុំលើកទី១៧របស់ខ្លួន នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧២ ការចាប់អារម្មណ៍បានផ្ដោតជាសំខាន់ទៅលើបូជនីយដ្ឋាននិងស្នាដៃសិល្បៈ។ បន្ទាប់ពីទទួលបទពិសោធផ្លូវចត់ពីសង្គ្រាមលោកលើកទីពីរ ចំណុចដែលបានផ្ដោតការយកចិត្តទុកដាក់នោះគឺភាពចាំបាច់នៃការការពារបូជនីយដ្ឋាននិងស្នាដៃសិល្បៈទាំងនេះនៅក្នុងព្រឹត្តិការណ៍នៃជម្លោះប្រដាប់អាវុធ(នេះគឺជាការបង្ហាញយ៉ាងច្បាស់នៃអនុសញ្ញាក្រុងឡាអេ ដែលបានអនុម័តនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤)។

ក្នុងឆ្នាំ១៩៧២ អនុសញ្ញាបេតិកភណ្ឌពិភពលោករបស់យើងបានណែនាំនូវនវានុវត្តជាដំបូងលើប្រធានបទ។ បន្ទាប់ពីនោះមក ទើបបេតិកភណ្ឌវប្បធម៌បានដាក់បញ្ចូលបូជនីយដ្ឋានក្រុមជាឈុត(គឺជាក្រុមនៃសំណង់ប្រវត្តិសាស្ត្រ)និងស្ថានីយ(មិនថាជាស្នាដៃរបស់មនុស្សជាតិឬរបស់ធម្មជាតិទាំងអស់នេះឬជាស្នាដៃរួមគ្នារបស់មនុស្សជាតិនិងធម្មជាតិឡើយ)។ ទោះជាយ៉ាងណា ខ្ញុំគិតថាសារៈសំខាន់របស់វាស្ថិតនៅកន្លែងផ្សេងទៀត។ តាមរយៈទស្សនវិជ្ជានិងការបង្កើតផ្លូវច្បាប់របស់វា អនុសញ្ញាណែនាំនូវវិធីសាស្ត្រថ្មីទាំងស្រុងមួយចំពោះ «បេតិកភណ្ឌ»។ អនុសញ្ញាបានរៀបចំខ្លួនឱ្យលេចឡើងនៅពីលើរបស់(គំនិត) ចាស់ ប៉ុន្តែនៅមានជាបន្តនូវភាពតានតឹងយ៉ាងខ្លាំងរវាងកម្លាំងតំណាងពីរ៖

- *ម្ខាង គឺជាការផ្សារភ្ជាប់ដែលមិនអាចកាត់ផ្ដាច់បាន(ដែលជាទីស្រឡាញ់ចំពោះប្រជាជននិងប្រទេសជាតិជាពិសេសនៅក្នុងតតីយលោក) រវាងសម្បត្តិវប្បធម៌និងអត្តសញ្ញាណវប្បធម៌។*
- *ម្ខាងទៀត គឺការកើនឡើងនៃសកលភាពរបស់សម្បត្តិវប្បធម៌ ដោយសារតថភាពដែលមានក្នុងក្រមសីលធម៌របស់ យូណេស្កូ មនុស្សជាតិបាននិងកាន់តែត្រូវបានកំណត់ន័យថាជាកម្លាំងប្រមូលផ្ដុំប្រកបដោយថាមពលនៃវប្បធម៌។*

រឿងមួយដែលច្បាស់នោះគឺ នៅចុងទសវត្សឆ្នាំ១៩៦០និងដើមទសវត្សឆ្នាំ១៩៧០ យូនីស្កូបានបោះជំហានទៅមុខយ៉ាងខ្លាំងមុនពេលវេលារបស់ខ្លួន។ នៅក្នុងគោលការណ៍ជាក់លាក់របស់ខ្លួន អនុសញ្ញាឆ្នាំ១៩៧២ បានត្រិះរិះពិចារណ៍នូវពហុភាពនៃវប្បធម៌មកពិចារណាអស់រយៈពេលជាយូរមកហើយ គឺមុនពេលអនុសញ្ញាជាក់លាក់ក្នុងឆ្នាំ២០០៥ ដែលបានឱ្យខ្ទីកម្រិតនៃភាពស្របច្បាប់នៃបញ្ញត្តិនេះនៅកម្រិតអន្តរជាតិ។

អ.ប. : *ក្នុងសុន្ទរកថាបើកពិធីរបស់ឯកឧត្តមនៅក្រុងក្យូតូ(ពីថ្ងៃទី៦ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២) នៅក្នុងឱកាសនៃពិធីបុណ្យរំលឹកខួបលើកទី៤០នៃអនុសញ្ញានេះ ឯកឧត្តមបានធ្វើការពន្យល់ពីអនុសញ្ញាដោយធ្វើការ*

សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃលក្ខខណ្ឌនៃការអនុវត្តរបស់វាផងដែរ។ អ្នកអានអំពីបេតិកភណ្ឌពិភពលោកអាចនឹងចាប់អារម្មណ៍ចំពោះសេចក្តីសង្ខេបនៃទិដ្ឋភាពចម្បងនៃវិធីសាស្ត្រផ្ទាល់ខ្លួនរបស់ឯកឧត្តម។

ស.អ. : *ការអនុវត្តដែលបានអនុញ្ញាតឱ្យប្រទេសជាច្រើនបានទទួលនូវភាពជាម្ចាស់កម្មសិទ្ធិនៃបេតិកភណ្ឌវប្បធម៌លើទឹកដីរបស់ខ្លួននិងដាក់បញ្ចូលនូវពហុភាពវប្បធម៌ទៅក្នុងបញ្ជីទ្រព្យសម្បត្តិជាតិរបស់ពួកគេ គឺជាលក្ខណៈមួយផ្សេងទៀតនៃអនុសញ្ញារបស់យើងដែលមិនអាចត្រូវបានសង្កត់ធ្ងន់ឱ្យគ្រប់គ្រាន់។ សូមលើកឧទាហរណ៍ពីករណីមួយរបស់ប្រទេសទុយនេស៊ី (Tunisia) ដែលខ្ញុំបានលើកឡើងនៅក្រុងក្យូតូ ហើយដែលខ្ញុំបានដឹងពីវាយ៉ាងច្បាស់ដោយសារលោក ដោយលោកបានរួមចំណែកជាមួយយើងក្នុងកិច្ចអភិរក្សនិងកែលម្អប្រាសាទអង្គរ។ អ្នកទាំងអស់គ្នាដឹងហើយថា ពេលនេះទុយនេស៊ីគឺជាប្រទេសមួយដ៏សំខាន់ចំពោះវប្បធម៌អារ៉ាប់និងអរិយធម៌ជនអ៊ីស្លាម។ បញ្ជីនៃទ្រព្យសម្បត្តិដែលបានចុះក្នុងបញ្ជីតាមសំណើរបស់ប្រទេសនេះ រួមមានស្ថានីយបុរាណវិទ្យានិងបូជនីយដ្ឋានប្រវត្តិសាស្ត្រ ពីយុគសម័យហ្វីនិក (Phoenician) រ៉ូម៉ាំងនិងគ្រីស្ត មានអាយុកាលជាច្រើនសតវត្សមុនពេលការមកដល់នៃសាសនាអ៊ីស្លាម។ គេអាចនិយាយបានដូចគ្នានេះដែរ ចំពោះ លីប៊ី អារ៉ាប់-ម៉ូស្លីម ជាស្ថានីយតាំងពីសម័យក្រិកនិងរ៉ូម៉ាំង ក៏ត្រូវបានគេមើលឃើញថាមានសារៈសំខាន់ដែរ។ នៅក្នុងប្រទេសអេហ្ស៊ីបដែលប្រកបដោយមោទនភាពបំផុតចំពោះបេតិកភណ្ឌ នៃសាសនាអ៊ីស្លាមរបស់ខ្លួន យើងកត់សម្គាល់ឃើញថា អរិយធម៌របស់ព្រះចៅផារ៉ាអុងគឺនៅតែជានិមិត្តរូបរបស់ប្រទេសដដែល។*

ជាមួយគ្នានេះដែរសូមអនុញ្ញាតឱ្យពួកយើងលើកយកនូវឧទាហរណ៍ជាគំរូនៃប្រទេសអេស្ប៉ាញ ដែលប្រទេសនេះបានទទួលយកវប្បធម៌គ្រីស្តអស់រយៈពេលជាច្រើនសតវត្ស។ ដោយគ្រាន់តែរាប់នូវឈ្មោះមួយចំនួន បញ្ជីបេតិកភណ្ឌរបស់គេរួមមានស្នាដៃនៃស្ថាបត្យកម្មអារ៉ាប់និងសិល្បៈរបស់ម៉ូស្លីម ជាមួយនឹង Cordoba, Granada, Toledo និង Seville។

ដូច្នេះ អនុសញ្ញានេះបានបំបែកខ្លួនចេញពីការបែងចែកនិងបានអនុញ្ញាតឱ្យមានការពិចារណាដោយសន្តិវិធីទៅលើព្រឹត្តិការណ៍នៅក្នុងអតីតកាល សូម្បីតែនៅពេលដែលពួកគេបានទទួលរងនូវការឈឺចាប់ក៏ដោយ។ ក្នុងពេលដំណាលគ្នា កិច្ចសន្ទនានេះបានក្លាយទៅជាការនិយាយជាសរុបនិងជាការត្រិះរិះពិចារណាផ្ទាល់ខ្លួន។

ការអនុវត្តចំពោះអនុសញ្ញានេះបានអនុញ្ញាតឱ្យប្រទេសជាច្រើនលើសលប់ទទួលបាននូវភាពជាម្ចាស់កម្មសិទ្ធិនៃបេតិកភណ្ឌវប្បធម៌លើទឹកដីរបស់ខ្លួននិងបានដាក់បញ្ចូលពហុភាពវប្បធម៌ទៅក្នុងបញ្ជីទ្រព្យសម្បត្តិជាតិរបស់ពួកគេ

អ.ប. : ប៉ុន្តែខ្ញុំឮលោកនិយាយថា ជម្លោះនិងភាពតានតឹងអន្តរជាតិគឺពិតជាមិនទាន់បានរលត់បាត់នៅឡើយ។ លោកប្រធាន បើតាមមតិរបស់លោក តើអ្វីជាការប៉ះទង្គិចដែលអាចកើតមានឬដែលអាចកត់សម្គាល់របស់វាចំពោះការអនុវត្តអនុសញ្ញានេះ?

ស.អ. : *វាមិនមែនជាការបដិសេធចំពោះតថភាពឬជាសុទិដ្ឋិនិយមដោយងងឹតងងល់ក្នុងការរំលឹកឡើងវិញថា អនុសញ្ញានេះបានអនុញ្ញាតឱ្យមានគម្លាតយ៉ាងជាក់ច្បាស់រវាងទិដ្ឋភាពដែលទំនងជាមិនចុះ សម្រុងគ្នាឬទិដ្ឋភាពរសើបនៅក្នុងទំនាក់ទំនងអន្តរជាតិ ក្នុងការរំលេចឡើងនូវកម្លាំងជានិមិត្តសញ្ញានៃបូជនីយដ្ឋាននេះឬបូជនីយដ្ឋាននោះទេ។*

ខ្ញុំមើលឃើញថា ឯកសារដាក់បញ្ចូលកោះហ្គោរ៉េ (Gorée) នៅក្នុងប្រទេសសេនេហ្គាល់ (Senegal) គឺជាឧទាហរណ៍ដ៏ល្អបំផុតមួយសម្រាប់រឿងនេះ។ ចំពោះមនសិការជាសាកល កោះហ្គោរ៉េ គឺជានិមិត្តរូបនៃជោគវាសនានៃប្រជាជនអាហ្វ្រិកស្បែកខ្មៅ "ក្នុងដំណើរជាក្បួនរបស់គេឆ្លងកាត់ទុក្ខវេទនា ទឹកភ្នែកនិងការស្លាប់បាត់បង់ជីវិត"។ វានៅតែជា "ឧទាហរណ៍ល្អបំផុតនៃទុក្ខវេទនារបស់ប្រជាជនស្បែកខ្មៅនៅគ្រប់សម័យកាល" និងជាកន្លែងដ៏ល្បីល្បាញខាងសោកសៅមួយនៅក្នុងប្រវត្តិសាស្ត្រនៃការធ្វើពាណិជ្ជកម្មទាសកររវាងទ្វីបអាហ្វ្រិកនិងអាមេរិក។ ក្នុងការស្នើដាក់បញ្ចូលរបស់ខ្លួន ប្រទេសសេនេហ្គាល់បានពន្យល់ថា កោះហ្គោរ៉េ គឺរោងមហោស្រពមួយនៃជម្លោះដែលគ្មានថ្ងៃបញ្ចប់រវាងមនុស្សនិងមនុស្ស។ ប្រទេសសេនេហ្គាល់ ក្នុងសម័យទំនើបប្រាថ្នាចង់ធ្វើឱ្យកន្លែងមួយនេះក្លាយជាទីជម្រកមួយនៃការផ្សះផ្សាប្រជាជនតាមរយៈការអត់ឱនទោស។

នៅក្នុងបរិបទនេះ ខ្ញុំក៏ចង់លើកឡើងពីការដាក់បញ្ចូលទីក្រុងបុរាណយេរូសាឡឹម(Jerusalem)និងកំពែងរបស់ទីក្រុងនោះនៅក្នុងបញ្ជីផងដែរ។ ដោយបានស្នើឡើងនៅក្នុងឆ្នាំ១៩៨០ពីសំណាក់រាជាណាចក្រហ្ស៊កដានី (Kingdom of Jordan) ដែលបានគ្រប់គ្រងទីក្រុងបុរាណនោះរហូតដល់វាត្រូវបានចូលកាន់កាប់នៅក្នុងឆ្នាំ១៩៦៧ ការរួមបញ្ចូលរបស់វាត្រូវបានជំរុញចិត្តឱ្យធ្វើឡើងជាដំបូងដោយសារស្ថានភាពនយោបាយ គឺជម្លោះនៅក្នុងតំបន់អារ៉ាប់-អ៊ីស្រាអែលនិងបញ្ហានៃការអនុវត្តអនុសញ្ញាឆ្នាំ១៩៥៤។

កន្លែងមួយដែលមានការប្រយុទ្ធតស៊ូដណ្តើមអត្តសញ្ញាណ ការប្រឈមមុខគ្នាក្នុងន័យជាប្រវត្តិសាស្ត្រនិងជាការចងចាំរួមជាមួយនឹងសមរភូមិមួយនៃការតស៊ូដែលគ្មានថ្ងៃបញ្ចប់រវាងជម្លោះដែលបានបង្ហាញពីរូបភាពពីអតីតកាល ទីក្រុងបុរាណយេរូសាឡឹមត្រូវបានដាក់បញ្ចូលក្នុងបញ្ជីដោយសារតែលក្ខណៈពិសេសជាសាកលរបស់វា។ ដោយមានការស្រុះស្រួលគ្នា សារៈសំខាន់ជានិមិត្តរូបនៃប្រវត្តិសាស្ត្ររបស់ខ្លួនត្រូវបានរំលេចឡើងជាមួយនឹងតម្រូវការក្នុងការឱ្យមានជាបន្តនូវការប្រសព្វគ្នាវប្បធម៌ជ្វីស គ្រីស្តនិងអ៊ីស្លាម នៅទីកន្លែងនោះ។

ករណីមួយទៀតដែលអាចនឹងត្រូវបានលើកឡើងនោះ គឺតំបន់ស្ពានចាស់នៃទីក្រុងបុរាណម៉ូស្តារ(Mostar) ក្នុងប្រទេសបូស្នៀ(Bosnia) និងហេហ្សេហ្គោវីណា(Herzegovina) នៅក្នុងការបង្ហាញថាតើលក្ខខណ្ឌដែលអនុសញ្ញាឆ្នាំ១៩៧២ ត្រូវបានអនុវត្តនោះ បានជំរុញចិត្តឱ្យមានការធ្វើកិច្ចការងាររួមគ្នាគួរឱ្យកត់សម្គាល់មួយរវាងមេដឹកនាំសហព័ន្ធនិងមេដឹកនាំតាមតំបន់នៅក្នុងប្រទេសនោះ។ គំនិតនៃការអំពាវនាវទៅយូណេស្កូឱ្យសាងសង់ស្ពានជាប្រវត្តិសាស្ត្រនោះឡើងវិញ បានផ្តល់ឱ្យពួកគេនូវក្តីសង្ឃឹមចំពោះការការដាក់បញ្ចូលវាក្នុងបញ្ជី។ ស្ពាននេះត្រូវបានបំផ្លាញដោយចេតនាពីសំណាក់ពួកជ្រុលនិយមក្នុងអំឡុងសង្គ្រាមស៊ីវិលនៅក្នុងអតីតប្រទេសយូហ្គោស្លាវីនិងត្រូវបានសាងសង់ឡើងវិញនៅក្នុងទ្រង់ទ្រាយត្រឹមត្រូវដូចដើម ហើយខ្ញុំនឹងនិយាយពីរឿងនេះ។ ដោយការធ្វើឱ្យស្ពានម៉ូស្តារ (Moster bridge) ក្លាយជាទ្រព្យសម្បត្តិរបស់បេតិកភណ្ឌសកលមួយ គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានធានានូវភាពជោគជ័យចំពោះក្រមសីលធម៌នៃសន្តិភាពនិងនិមិត្តរូបនៃការផ្សះផ្សារវាងអតីតគូបដិបក្ខ។

អ.ប. : ឯកឧត្តមសូមអនុញ្ញាតឱ្យខ្ញុំរំលឹកឯកឧត្តមថា នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ នៅសាន់តា ហ្វេ (Santa Fe) (សហរដ្ឋអាមេរិក) គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅសម័យប្រជុំទី១៦ របស់ខ្លួន បានធ្វើការសម្រេចចិត្តដោយស្រុះស្រួលគ្នាក្នុងការដាក់បញ្ចូលអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយឈរលើមូលដ្ឋាននៃលក្ខណវិនិច្ឆ័យបួនយ៉ាង (i , ii, iii, និង iv) ដោយមានផ្ទៃដីទំហំចំនួន ៤០ ១០០ហិកតា ចន្លោះពីតំបន់រលួសទៅភាគខាងត្បូងនិងពីតំបន់ប្រាសាទបន្ទាយស្រីនៅភាគខាងជើង។

ឥឡូវនេះ យើងបានឈានដល់ខួបលើកទី២០នៃការដាក់បញ្ចូលនេះ។ នៅក្នុងខួបឆ្នាំនេះ កម្ពុជាត្រូវបានជ្រើសតាំងជាប្រធាននៃគណៈកម្មាធិការ។ តើវាមិនមែនជារឿងដ៏គួរឱ្យកត់សម្គាល់យ៉ាងខ្លាំងខ្លួសទេឬ? ហើយចំពោះខួបលើកនេះ តើវាមានន័យយ៉ាងដូចម្តេចដែរចំពោះលោកប្រធាន?

ស.អ. : ក្រៅពីកិត្តិយសសម្រាប់ខ្លួនខ្ញុំផ្ទាល់ចំពោះការបោះឆ្នោតឱ្យរូបខ្ញុំ ខ្ញុំពិចារណាទៅលើតថភាពដែលថាប្រទេសកម្ពុជានឹងទទួលស្វាគមន៍ចំពោះសម័យប្រជុំលើកទី៣៧ ដ៏មានសារៈសំខាន់យ៉ាងខ្លាំងខ្លួសចំពោះគណៈកម្មាធិការបេតិកភណ្ឌពិភពលោកផ្ទាល់ ក្នុងខែមិថុនា ឆ្នាំ២០១៣ នេះ។ បច្ចុប្បន្ននេះ ប្រទេសរបស់យើងបានធ្វើការខិតខំគ្រប់បែបយ៉ាងដើម្បីធ្វើការអភិវឌ្ឍដោយខ្លួនឯង។ ដោយសារសកម្មភាពប្រកបដោយចីរភាពនៃរាជរដ្ឋាភិបាល កម្រិតជីវភាពនិងកម្រិតនៃការអប់រំក្នុងចំណោមប្រជាជនកំពុងបន្តធ្វើឱ្យមានភាពប្រសើរឡើង។

យើងបានបង្ហាញក្នុងពេលថ្មីៗនេះ នៅក្នុងកិច្ចប្រជុំកំពូលនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ថាយើងពិតជាមានសមត្ថភាពក្នុងការស្វាគមន៍ជនល្បីៗនៃពិភពលោកពីសហរដ្ឋអាមេរិកដល់ប្រទេសឥណ្ឌា ចិននិងជប៉ុន។ យើងអាចធ្វើការអះអាងយ៉ាងច្បាស់ថា អ្នកតំណាងនៃរដ្ឋភាគីទាំង១៩០ប្រទេសនៅក្នុងអនុសញ្ញាឆ្នាំ១៩៧២ នឹងត្រូវបានផ្តល់ជូននូវកិច្ចស្វាគមន៍ដ៏ល្អបំផុតមួយតាមដែលអាចធ្វើទៅបានទាំងនៅក្នុងរាជធានីភ្នំពេញនិងនៅសៀមរាបអង្គរ។ សណ្ឋាគារទាំងឡាយនឹងមិនធ្វើឱ្យអ្នកទាស់ចិត្ត ចំណែកហេដ្ឋារចនាសម្ព័ន្ធត្រូវបានគិតថាមានភាពល្អប្រសើរ។

ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយពីខួបម្ភៃឆ្នាំនៃការដាក់បញ្ចូលប្រាសាទអង្គរទៅក្នុងបញ្ជីបេតិក ភណ្ឌពិភពលោកវិញម្តង។

ខ្ញុំធ្វើការកត់សម្គាលជាដំបូងបំផុតថា តាមរយៈការសម្រេចចិត្តរបស់ខ្លួន ដែលត្រូវបានគេមើលឃើញថាមានភាពក្លាហានយ៉ាងខ្លាំងនិងជានវានុវត្តន៍មួយនៅពេលនោះ គឺគណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានត្រិះរិះពិចារណាពីស្ថានភាពដាច់ដោយឡែកមួយរបស់កម្ពុជា បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស២៣ តុលា ១៩៩១ និងបានមើលរំលងចំពោះលក្ខខណ្ឌមួយចំនួន ជាលើកដំបូងដែលបានកំណត់ដោយគោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការអនុវត្តអនុសញ្ញាបេតិកភណ្ឌពិភពលោកដែលរួមបញ្ចូលទាំងការការពារបេតិកភណ្ឌជាតិ។

នៅត្រង់ចំណុចនេះ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើការកត់សម្គាល់ថា ការដាក់បញ្ចូលប្រាសាទអង្គរគឺតម្រូវឱ្យមាននូវនីតិវិធីដ៏វែងអន្លាយមួយ ហើយរាជរដ្ឋាភិបាលបានចំណាយពេលយ៉ាងច្រើនដើម្បីពន្យល់ពីស្ថានភាពទៅដល់សមាជិកនៃគណៈកម្មាធិការ។ គណៈកម្មាធិការបានសម្រេចលើការដាក់បញ្ចូល រួមជាមួយនឹងបំណងចង់ប្រឈមនឹងសម្ពាធបញ្ហាដែលទទួចចង់បាននិងប្រសិទ្ធភាពនោះ (ខ្ញុំដកស្រង់អត្ថបទនៃសេចក្តីសម្រេចរបស់គណៈកម្មាធិការ) ហើយវាក៏រួមបញ្ចូលទាំងតំបន់អង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែលស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយត្រូវស្នើសុំអាជ្ញាធរកម្ពុជាចាត់វិធានការចាំបាច់ ក្នុងការបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោមក្នុងរយៈពេលបីឆ្នាំ (១៩៩៣-៩៥)។

(ក) ការប្រកាសឱ្យប្រើប្រាស់ច្បាប់ការពារបានគ្រប់គ្រាន់

(ខ) ការបង្កើតនៃទីភ្នាក់ងារជាតិការពារដែលមានបុគ្គលិកគ្រប់គ្រាន់

(គ) ការបង្កើតបញ្ជីអចិន្ត្រៃយ៍ ដោយផ្អែកលើគម្រោងរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (ឯកសារដោយ ZEMP-ផែនការគ្រប់គ្រងតំបន់បរិស្ថាន)

(ឃ) និយមន័យនៃសារៈសំខាន់តំបន់ទ្រនាប់

(ង) ការបង្កើតការអនុរក្សនិងការសម្របសម្រួលចំពោះកិច្ចខិតខំប្រឹងប្រែងអភិរក្សជាអន្តរជាតិ។

លក្ខខណ្ឌទាំងអស់នេះត្រូវបានបំពេញ ហើយយើងបានប្រារព្ធពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចប្រជុំលើកទី២៨ក្នុងទីក្រុង ស៊ូហ្ស៊ូ (Suzhou) (ប្រទេសចិន ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៤) គណៈកម្មាធិការបានសម្រេចដោយឥតសង្ស័យក្នុងការដកតំបន់អង្គរ ចេញពីបញ្ជីនៃបេតិកភណ្ឌពិភពលោកដែលស្ថិតនៅក្នុងគ្រោះថ្នាក់។

សព្វថ្ងៃនេះ យើងអាចពិចារណាអំពីសារៈសំខាន់ជាប្រវត្តិសាស្ត្រនៃសកម្មភាពរបស់យើងនារយៈកាលជាងម្ភៃឆ្នាំមកនេះ ទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ។

យើងយល់យ៉ាងច្បាស់ថាបូជនីយដ្ឋានអង្គរនឹងនៅឈរជានិមិត្តរូបរបស់ជាតិនិងប្រជាជនកម្ពុជា។ លើសពីនេះទៅទៀត ដោយការបង្ហាញពីអង្គរយ៉ាងទូលំទូលាយនៅក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនិងរចនាសម្ព័ន្ធរបស់យូណេស្កូ សហគមន៍អន្តរជាតិបានធ្វើការពិចារណាដោយឥតសង្ស័យអំពីតំបន់អង្គរនិងបូជនីយដ្ឋានជាប្រវត្តិសាស្ត្ររបស់ខ្លួនថាជាតំបន់បេតិកភណ្ឌវប្បធម៌មួយសំខាន់បំផុត ក្នុងចំណោមតំបន់បេតិកភណ្ឌវប្បធម៌នានានៅអាស៊ីនិងនៅក្នុងពិភពលោក។

ហេតុដូច្នេះហើយបានជាម្ភៃឆ្នាំក្រោយពីការដាក់បញ្ចូលអង្គរ គ្មាននរណាម្នាក់សង្ស័យថាកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការការពារនិងអភិវឌ្ឍអង្គរនិងតំបន់ជិតខាងក្រុងសៀមរាបគឺជាតំបន់ដែលកើនឡើងនូវសារៈសំខាន់ពិសេសពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំមានសេចក្តីរីករាយជាពិសេសនិងមានកិត្តិយសជាខ្លាំងផងដែរក្នុងនាមសម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនិងរាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវការទទួលស្គាល់របស់យើងចំពោះសកម្មភាពរបស់យូណេស្កូមកដល់សព្វថ្ងៃហើយយើងក៏សូមថ្លែងអំណរគុណជាអនេកកប្បការចំពោះប្រទេសទាំងឡាយ អង្គការក្នុងនិងក្រៅរដ្ឋាភិបាលនានា ដែលបានបន្តធ្វើកិច្ចការជាមួយនឹងអជ្ញាធរជាតិអប្សរានិងជាមួយនឹងបណ្តាស្ថាប័ននិងសេវាកម្មនានានៅខេត្តសៀមរាបក្នុងគោលបំណងបំពេញកិច្ចការអភិរក្សការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីនិងគម្រោងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនានា។

អ.ប. : លោកប្រធាន លោកទើបតែបានរំលឹកថា នៅខែធ្នូ ឆ្នាំ១៩៩៣ គឺជាកិច្ចប្រជុំលើកទីមួយនៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិ (ICC-Angkor)។ នៅខែធ្នូ ឆ្នាំ២០១៣ ឆ្នាំក្រោយគួរតែជាសម័យប្រជុំលើកទី២០នៃគណៈកម្មការនោះ។ វាមានរយៈពេលម្ភៃឆ្នាំហើយ! ច្បាស់ណាស់វាគឺជាដំណើរដ៏គួរឱ្យកត់សម្គាល់មួយនិងជាព្រឹត្តិការណ៍ឯកមួយនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់បេតិកភណ្ឌពិលោកលោក។ តើអ្វីដែលយើងត្រូវធ្វើដើម្បីពន្ទេចឱ្យឃើញនូវពិធីរំលឹកខួបដ៏ពិសេសនេះ?

ស.អ. : ជាបឋមខ្ញុំសូមកត់សម្គាល់ថា យើងពិតជាមានមោទនភាពខ្លាំងណាស់ក្នុងការទទួលយកនូវកិច្ចការដែលយើងបានធ្វើ។ យើងទាំងអស់គ្នាបានទទួលស្គាល់ថា នេះគឺជាកិច្ចការមួយដ៏អស្ចារ្យ។ យើងចង់បង្ហាញតាមរយៈការតាំងពិព័រណ៍និងប្រព័ន្ធផ្សព្វផ្សាយ ផ្លូវដ៏វែងឆ្ងាយបានធ្វើដំណើរតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ គឺនៅពេលដែលតំបន់ប្រមាណជា ៤០ ១០០ហិកតា ដែលជាតំបន់នៅមានគ្រាប់មីន ហើយបូជនីយដ្ឋានស្ថិតនៅក្នុងសភាពគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរនៅឡើយ។ បច្ចុប្បន្ននេះ បន្ទាប់ពីរយៈពេល២០ឆ្នាំនៃកិច្ចខិតខំប្រឹងប្រែងដែលមិនមានការកាត់ផ្តាច់ អង្គរកំពុងតែទទួលអំណររីករាយជាមួយនឹងការរស់ឡើងវិញដ៏ពេញលេញមួយ ដោយសារជោគជ័យនៃការបន្តប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធខុសច្បាប់និងការលួចប្លន់ដែលមានអង្គការចាត់តាំងតំបន់នេះបានឈប់ក្លាយជាទីកន្លែងជម្រើសក្នុងការជួបជុំគ្នារបស់អ្នកជួញដូរវត្ថុសិល្បៈខុសច្បាប់ទៀតហើយ។

ប្រទេសនិងអង្គការវិទ្យាសាស្ត្រនានាសរុបចំនួន២៣ ដែលតំណាងទ្វីបទាំងបួន បានធ្វើប្រតិបត្តិការលើគម្រោងចំនួនជិត៧០ ក្នុងចំនួនទឹកប្រាក់សរុបជាង២៥០លានដុល្លារសហរដ្ឋអាមេរិក។

ជាការពិតណាស់ យើងត្រូវតែផ្តល់ជំបូន្មានដល់មនុស្សគ្រប់គ្នាដែលស្របគ្នានឹងសាមគ្គីភាពដ៏ខ្លាំងក្លានិងកិច្ចការស្តារឡើងវិញនានាយើងបានទទួលនូវភាពជោគជ័យដ៏ត្រចះត្រចង់នៅក្នុងកិច្ចការស្រាវជ្រាវផ្នែកបុរាណវិទ្យា។ សាធារណជនសក្តិសមនឹងដឹងថា ការសិក្សាស្រាវជ្រាវកំពុងបង្រៀនពួកយើងយ៉ាងច្រើន អំពីប្រវត្តិអង្គរ ព្រមទាំងកាលប្រវត្តិនិងរចនាសម្ព័ន្ធរបស់វា។ ដូច្នេះហើយ បច្ចុប្បន្ននេះប្រវត្តិវិទូបានកំណត់កាលបរិច្ឆេទនៃតំបន់អង្គរថា បានចាប់ផ្តើមយ៉ាងហោចណាស់នៅសតវត្សទី៨ ជាជាងថាបានចាប់ផ្តើមនៅសតវត្សទី៩។

ឯកឧត្តមបណ្ឌិត សុខ អាន នៅប្រាសាទបាយ័ន

© ទីស្ដីការគណៈរដ្ឋមន្ត្រី

យើងមិនត្រូវមិនអើពើចំពោះសារៈសំខាន់នៃកិច្ចការទាំងអស់ដែលបានផ្លាស់ប្តូរមុខមាត់អង្គរ ជាពិសេសលើតំបន់ដែលនៅជុំវិញបូជនីយដ្ឋាននិងការធ្វើឱ្យប្រសើរឡើងនូវផ្លូវចូលនិងសន្តិសុខទេសចរ

នៅប្រាសាទអង្គរធំ កិច្ចការកំណាយដែលគួរឱ្យកត់សម្គាល់ បានជម្រះដំណាំនៅតំបន់ត្រពិច ដើម្បីប្រកាសឱ្យដឹងថាវាជារាជធានីមួយដែលបានអភិវឌ្ឍដោយយកចិត្តទុកដាក់ដោយស្ថាបនានៅលើគម្រោងការច្បាស់លាស់និងជាក់លាក់។ គំរូនៃការអភិវឌ្ឍនេះ ដោយផ្អែកលើគម្រោងផែនការដែលមានទំហំ៣គីឡូម៉ែត្រការ៉េ(និយាយម្យ៉ាងទៀតជារាជធានីដែលមានកំពែងព័ទ្ធជុំវិញទំហំ៩លានម៉ែត្រការ៉េ) ដែលធ្វើឱ្យមនុស្សមួយចំនួនហៅអង្គរថាជា "ក្រុងញូយកនាមជ្ឈិមសម័យ"។

ក្រៅពីនេះ ការសិក្សាដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី National Geographic នាឆ្នាំ២០០៩ ដែលមានចំណងជើងថា " ហេតុអ្វីបានជារាជធានីដ៏មហាស្ចារ្យនាមជ្ឈិមសម័យដួលរលំ? " បានកំណត់ចំនួនប្រជាជនរស់នៅតំបន់អង្គរនៅសម័យថ្កុំថ្កើងថាមានរហូតដល់១លាននាក់(ជាចំនួនដ៏សម្បើមសម្រាប់សម័យកាលនោះ)។

ស្របជាមួយគ្នានេះដែរ កិច្ចការរុករកនៅលើទីលាននិងការត្រួតពិនិត្យប្រព័ន្ធសំឡេងដោយបំពាក់បច្ចេកវិទ្យាចុងក្រោយបង្អស់ក្នុងការបកស្រាយរូបភាពដែលថតពីលើអាកាស បានបង្កើតឡើងជាលើកដំបូងនូវរបៀបនៃការសិក្សាផ្នែករូបសាស្ត្រអំពីថា តើទឹកដីអង្គរបានត្រូវគ្រប់គ្រងកាន់កាប់យ៉ាងដូចម្តេចខ្លះ។ ជាលទ្ធផល ទឹកដីនេះបានគ្របដណ្តប់លើតំបន់មួយដ៏ធំល្វឹងល្វើយជាង២ ០០០ គីឡូម៉ែត្រការ៉េ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់សង្កត់ធ្ងន់បំផុតលើសារៈសំខាន់នៃការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងជាង៥ឆ្នាំមកនេះអំពីប្រព័ន្ធធារាសាស្ត្រនៃរាជធានីចក្រភពខ្មែរ។ លោកបណ្ឌិតហង់ពៅដែលជាវិស្វករផ្នែកធារាសាស្ត្ររបស់យើងបានបញ្ជាក់ថាបារាយណ៍ (អាងស្តុកទឹកដ៏ធំ)និងអាងទឹក ទ្វារទឹកនិងព្រែកជីកនានាបានបង្កើតជាបណ្តាញតភ្ជាប់ដ៏ធំសម្បើមដែលទឹកភ្លៀងហូរចាក់ចែកចាយនិងរក្សាទុកទឹកសម្រាប់ប្រព័ន្ធស្រោចស្រពនិងការប្រើប្រាស់ក្នុងស្រុក។ នេះជាការរកឃើញដ៏ចម្បងមួយ។

ជាចុងក្រោយ ខ្ញុំសូមទាញការចាប់អារម្មណ៍លើទិដ្ឋភាពផ្សេងទៀតនៃសមិទ្ធផលរបស់យើង។ យើងមិនត្រូវមិនអើពើចំពោះសារៈសំខាន់នៃកិច្ចការ ទាំងពួងក្នុងអំឡុងពេលជាងម្ភៃឆ្នាំមកនេះដែលបានផ្លាស់ប្តូរមុខមាត់អង្គរ ជាពិសេសនៅក្នុងតំបន់ជុំវិញបូជនីយដ្ឋាននិងការធ្វើឱ្យប្រសើរឡើងផ្លូវចូលនិងសន្តិសុខទេសចរ។

ដោយហេតុផលទាំងអស់នេះនិងការត្រិះរិះពិចារណាមិនត្រឹមតែលើលទ្ធផលនិងលើភាពសុខដុមរមនាដែលជាទម្រង់រវាងក្រុមការងារអង្គរ យុទ្ធនាការអង្គរត្រូវបានគេមើលឃើញជាឯកច្ឆន្ទថាជាគំរូមួយ។ លើសពីនេះ ដួងព្រលឹងអង្គរ បានញ៉ាំងសហគមន៍អន្តរជាតិឱ្យអនុម័ត "ធម្មនុញ្ញអង្គរ" នាពេលថ្មីៗនេះ ដែលបានដាក់ជាគោលការណ៍ណែនាំដែលអាចមានប្រយោជន៍ដល់តំបន់ផ្សេងទៀត ដែលបានចុះបញ្ជីក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក។


ព្រះរាជាណាចក្រ ថៃ
ឧត្តរមានជ័យ
ព្រះវិហារ
បន្ទាយមានជ័យ
សៀមរាប
ព្រះខ័ន
បាត់ដំបង
បឹងទន្លេសាប
កំពង់ធំ
ពោធិសាត់
កំពង់ឆ្នាំង
កំពង់ចាម
កោះកុង
ភ្នំពេញ
កំពង់ស្ពឺ
កណ្ដាល
ព្រៃវែង
តាកែវ
ក្រុងព្រះសីហនុ
កំពត
ក្រុងកែប
ឈូងសមុទ្រ សៀម
0
50
kilomètres
Source fond de carte : Département de géograp
Le tracé des frontières ne fait pas aut

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សាលាបារាំងចុងបូព៌ា (EFEO)

តំបន់ប្រវត្តិសាស្ត្រនិងរមណីយដ្ឋានសំខាន់ៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ផែនទីបុរាណវិទ្យាប្រទេសកម្ពុជា
CARTE ARCHÉOLOGIQUE DU CAMBODGE

ការិយាល័យបញ្ជីសារពើភណ្ឌ
Bureau de l'inventaire

សញ្ញាផែនទី	LÉGENDE
ទីរួមខេត្ត	Chief-lieu de province
ព្រំសីមា	Frontières internationales
ផ្លូវជាតិ	Routes nationales
ព្រំប្រទល់ខេត្ត	Limites des provinces
ទន្លេ , ស្ទឹង , ព្រែក	Fleuves, rivières, canaux
វាលស្រែ	Rizière
ដីភូមិ	Village
ព្រៃ និង គុម្ពោត	Forêt
ក្រុមប្រាសាទ	Groupe monumental
ប្រាសាទទោល និង មានកំពែង	Sanctuaires et temples
បូជនីយដ្ឋានបុរាណផ្សេងៗ	Autres sites archéologiques
ផ្លូវបុរាណ	Anciennes chaussées

តុលា - ២០០៥
Octobre 2005

រៀបចំផែនទី		Réalisation	
ផាន់ ណាឌី	Phann Nady	សំរបសំរួលគំរោង	Coordination
ជ្រិន ណារ៉ុង	Chrin Narong	រៀបចំផែនទី	Cartographie
ចាន់ សុវិចិត្រា	Chan Sovichetra	ស្រាវជ្រាវ	Relevés
ចំរើន ចំរុង	Chamroeun Chamrong	ស្រាវជ្រាវ	Relevés
Bruno Bruguier		Responsable scientifique	

ឧទ្យានអង្គរ



ប៉មប្រាសាទបាយន័ទាំង ៥៤ ចាំងឆ្លុះពីក្នុងផ្ទៃទឹក

© Our Place – The World Heritage Collection



ប្រាសាទនិងបុរាណវិទ្យា

ឯកឧត្តម រស់ បូរ៉ាត
ស្ថាបត្យករ (ឌ.ភ.ល.ជ)
អគ្គនាយករងនៃអាជ្ញាធរអប្សរា
ទទួលបន្ទុកនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ

ប្រាសាទ ប៉មកណ្ដាលរបស់អង្គរវត្ត

© William Heylts

បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីស ក្នុងឆ្នាំ ១៩៩១ មក តំបន់បេតិកភណ្ឌជាតិអង្គរ មានការផ្លាស់ប្ដូរយ៉ាងខ្លាំងបន្ទាប់ពីបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាសម័យប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី១៦ នៅទីក្រុង សាន់តាហ្វេ សហរដ្ឋអាមេរិក នាខែធ្នូ ឆ្នាំ១៩៩២ ដែលតំបន់ទាំងមូលគ្របដណ្ដប់លើផ្ទៃដីទំហំ ៤០ ១០០ ហិកតា ជាមួយនឹងប្រាសាទសំខាន់ៗចំនួន៩១។

ចាប់តាំងពីអង្គ សន្និបាតនៅទីក្រុងតូក្យូ នាខែតុលា ឆ្នាំ១៩៩៣ និងជាបន្ទាប់មកបានរៀបចំនៅទីក្រុងប៉ារីសនាខែវិច្ឆកា ឆ្នាំ២០០៣ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីការអភិរក្សនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ(ហៅកាត់ថា ICC) ដែលមានប្រទេសបារាំងនិងជប៉ុនជាសហប្រធាន និងអង្គការ UNESCO ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ បានបង្កើតក្របខ័ណ្ឌសម្រាប់សកម្មភាពអន្តរជាតិមួយមានរយៈពេល២០ឆ្នាំក្នុងគោលដៅការពារនិងលើកតម្លៃអង្គរ។ សន្និបាតលើកទី៣ នៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីការអភិរក្សនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ត្រូវបានកំណត់កាលបរិច្ឆេទរៀបចំនៅទីក្រុងភ្នំពេញ នាខែធ្នូ ឆ្នាំ២០១៣ ខាងមុខនេះ។

ជាទូទៅ ប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរសាងឡើងពីថ្មភក់ ថ្មបាយក្រៀម ឬឥដ្ឋ ដែលប្រាសាទទាំងនេះបានលេចធ្លោឡើងតាមរយៈលក្ខណៈស្ថាបត្យកម្ម គួរឲ្យកត់សំគាល់ចំពោះភាពស្ថិតស្ថេរ រឹងមាំនិងភាពដូចៗគ្នា។ ថ្មភក់ជាវត្ថុធាតុដើមមានគុណភាពល្អតែងតែជាការពេញនិយមរបស់ជាងសម្រាប់ធ្វើរូបចម្លាក់ផ្សេងៗ និងធ្វើជាគ្រឿងលម្អស្ថាបត្យកម្ម។

ទំហំការងារដ៏ធំមួយត្រូវបានបង្កើតឡើងដើម្បីថែរក្សារមណីយដ្ឋាននិងជួយសង្គ្រោះដល់ប្រាសាទបុរាណជាច្រើន។ ការងារភាគច្រើនបានអនុវត្តដោយសាលាបារាំងចុងបូព៌ាប្រទេស(EFEO) នៅក្នុងចន្លោះឆ្នាំ១៩០៧ដល់ឆ្នាំ១៩៧៣។ ទោះបីជាស្ថិតក្នុងស្ថានភាពតានតឹងនិងគ្មានស្ថិរភាពពេញលេញយ៉ាងណាក៏ដោយ ក៏អង្គការស្រាវជ្រាវបុរាណវិទ្យារបស់ប្រទេសឥណ្ឌា(ASI) អាចដំណើរការអនុវត្តការងារជួសជុលនៅប្រាសាទអង្គរបានដែរនៅក្នុងចន្លោះឆ្នាំ១៩៨១ ដល់១៩៩២។ជាមួយនឹងការគាំទ្ររបស់អង្គការ UNESCO សកម្មភាពអន្តរជាតិបានទាក់ទងក្រុមអ្នកជំនាញការមកពី២០ប្រទេសផ្សេងគ្នាមកធ្វើជាអ្នកគ្រប់គ្រងគម្រោងដៃគូសហការណ៍ជាមួយអាជ្ញាធរអប្សរា។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃការងារបានអនុវត្តនៅក្នុងរមណីយដ្ឋានអង្គរ៖

ប្រាសាទអង្គរវត្ត

អង្គរវត្ត ជាប្រាសាទដ៏ល្អត្រកាលនិងធំជាងគេបំផុតនៅក្នុងចំណោមប្រាសាទរបស់ខ្មែរទាំងអស់បានសាងឡើងនៅចំកណ្ដាលរាជធានីអង្គរនៅរវាងពាក់កណ្ដាលទី១ នៃសតវត្សរ៍ទី១២ ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី២។ ទម្រង់នៃប្រាសាទទាំងមូលរួមនឹងកសិណមានទំហំទទឹង១៩០ម៉ែត្រព័ទ្ធជុំវិញផងនោះ បង្កើតបានជារាងចតុកោណដ៏ធំមួយមានទំហំ១ ៥០០ ម៉ែត្រ គុណនឹង ១ ៣០០ ម៉ែត្រ គ្របដណ្ដប់លើផ្ទៃដីប្រមាណជា៩ហិកតា។ លក្ខណៈសំខាន់របស់ប្រាសាទអង្គរវត្ត គឺសំណង់ជារាងសាជីជ្រុងមួយ តួប៉មប្រាំខ្វែងគ្នាដែលស្ថិតនៅចំកណ្ដាលរោងទងព័ទ្ធជុំវិញជាច្រើនជាន់។ ការងារជួសជុលនិងពង្រឹងឡើងវិញត្រូវបានដំណើរការឡើងនៅក្នុងគម្រោងអន្តរជាតិដ៏ធំមួយដែលទាក់ទងនឹងក្រុមការងារមកពីប្រទេសសហរដ្ឋអាមេរិក បារាំង អាឡឺម៉ង់ អ៊ីតាលីនិងជប៉ុន។

ចាប់តាំងពីឆ្នាំ ១៩៩៧មក គម្រោងអភិរក្សរូបចម្លាក់ទេពអប្សររបស់ប្រទេសអាឡឺម៉ង់(GACP) បាននិងកំពុងអនុវត្តដើម្បីអភិរក្សរូបចម្លាក់ទេពអប្សរ ទេវតានិងគ្រឿងលម្អនៅតាមផ្នែកផ្សេងៗទៀតរបស់ប្រាសាទ។ រូបចម្លាក់ទេវតាប្រមាណជា ២០% ស្ថិតក្នុងស្ថានភាពខូចខាតខ្លាំង បណ្ដាលមកពីសំណឹកមីក្រូសារពាង្គកាយ និងការជួសជុលមិនបានប្រសើរនាពេលអតីតកាលកន្លងមកដែលប្រការទាំងអស់នេះបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ទៅលើរូបចម្លាក់ទាំងនោះ។


រូបសំណាក់តាពជដែលបានផ្គុំឡើងវិញ

© Simon Warrack

ក្នុងការអនុវត្តការងារដ៏ប៉ិនប្រសប់និងលំបាកនេះអង្គការគម្រោងអភិរក្ស រូបចម្លាក់ទេពអប្សរ របស់ប្រទេសអាឡឺម៉ង់ បានធ្វើការវិភាគដ៏ជាក់លាក់ឥតខ្ចោះ ដោយប្រើវិធីសាស្ត្រសម្របសម្រួលនិងព្យាបាលដែលអាចជួយឲ្យចម្លាក់ទាំងនោះអាចរួចផុតពីការប្រឈមបានទាន់ពេលវេលា។

បដិមាតាពជ

បដិមាតាពជក្នុងទម្រង់ព្រះនារាយណ៍ដៃប្រាំបីស្ថិតនៅផ្នែកខាងត្បូងនៃក្លោងទ្វារខាងលិចគឺជាបដិមាមួយក្នុងចំណោមបដិមាសំខាន់ៗផ្សេងទៀតនៅក្នុងប្រាសាទអង្គរវត្ត។ ការពិតបដិមាតាពជត្រូវបានគេយកមកតម្កល់នៅក្នុងទីតាំងបច្ចុប្បន្ននេះក្នុងពេលជួសជុលប្រាសាទអង្គរវត្ត តាំងតែពីសតវត្សរ៍ទី១៦មកម្លេះហើយបានក្លាយទៅជាបដិមាដ៏សំខាន់យ៉ាងខ្លាំងចំពោះជំនឿតាមបែបជីវចលដែលត្រូវបានគេស្គាល់ថា ជាអ្នកតា។វាជាជំនឿដ៏មុតមាំបានជ្រួតជ្រាបទៅក្នុងបេះដូងនិងបានផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅរបស់សហគមន៍មនុស្សនៅជុំវិញប្រាសាទនិងសហគមន៍ផ្សេងៗដែលនៅឆ្ងាយអំពីប្រាសាទផងដែរ។

ការជួសជុលមិនបានត្រឹមត្រូវ ជាពិសេសគឺកិច្ចការប្ដូរផ្លាស់ព្រះកេសដើមនឹងដៃបាត់បង់មួយចំនួនដោយប្រើប្រាស់ស៊ីម៉ងត៍មកជំនួសគឺពុំបានអនុវត្តតាមបច្ចេកទេសសមរម្យដែលបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើរូបបដិមានេះ។



ប្រាសាទភ្នំបាខែង

© Allie Caulfield

ក្រោយមកដោយទទួលបានការគាំទ្រពីសហគមន៍ចំពោះការជួសជុលនិងជាពិសេសការនាំត្រឡប់ព្រះកេសដើម ដែលបានរក្សាទុកដោយសុវត្ថិភាពក្នុងសារៈមន្ទីរជាតិមកវិញនោះ កិច្ចព្រមព្រៀងនៃការជួសជុលមួយបានដំណើរការឡើងដោយប្រើប្រាស់វិធីសាស្ត្រនិងសម្ភារៈនៃការជួសជុលនិងបច្ចេកទេសជាច្រើនទៀតដោយពុំមានការរំខានចំពោះការប្រតិបត្តិជំនឿរបស់អ្នកស្រុកឡើយ។ ម្រ័ក្សណ៍ខ្មុកនៅជាប់លើរូបបដិមាត្រូវបានលាបឡើងវិញ ហើយដៃដែលបាត់បង់ក៏ត្រូវបានដាក់ជំនួសថ្មីដោយសមាសធាតុថ្មភក់ថ្មីដែរ។

ប្រាសាទបាយ័ន

ប្រាសាទបាយ័នស្ថិតនៅចំកណ្តាលបេះដូងនៃរាជធានីអង្គរធំបានសាងឡើងជាច្រើនដំណាក់កាល (ចាប់ផ្តើមក្នុងវង្វង់ឆ្នាំ១២០០ ដោយព្រះបាទជ័យវរ្ម័នទី៧) ហើយជាមួយនិងការកែប្រែនិងពង្រីកបន្ថែមផ្សេងៗទៀត បានធ្វើឲ្យប្រាសាទនេះមានលក្ខណៈពិសេសតំណាងដោយរចនាបថស្ថាបត្យកម្មតែមួយគត់។ វាជាប្រាសាទភ្នំសាងពីថ្មភក់ មានរូបរាងខុសប្លែកពីគេដោយសាតួប៉មចំនួន៣៧ ដែលភាគច្រើនឆ្លាក់ជារូបមុខបួន បែរទៅរកទិសសំខាន់ៗទាំងបួន។ យ៉ាងណាក៏ដោយ ប្រាសាទបាយ័នគឺជា ប្រាសាទមួយទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរនិងពិបាកជួសជុលជាទីបំផុត។

ប្រាសាទភ្នំបាខែងជាសំណង់ដ៏ស្រស់ស្អាតគួឲ្យចាប់អារម្មណ៍ដែលមានសាជីជារាងថ្នាក់ៗបួនជ្រុងនិងព័ទ្ធជុំវិញដោយតួប៉មចំនួន១០៨

កិច្ចការជួសជុលបានចាប់ផ្តើមអន្តរាគមន៍ជាបន្ទាន់នៅហោត្រៃពីរនៅជាប់នឹងក្លោងទ្វារចូលប្រាសាទដោយបានរក្សាសម្ភារៈដើមរបស់សំណង់បានជាច្រើននិងប្រើវិធីសាស្ត្រសាងសង់តាមរបៀបបុរាណ ដោយមានការយល់ព្រមពីគម្រោងគាំពារអង្គរ ជប៉ុន-អប្សរា (the Japan Apsara Safeguarding Angkor (JASA)) ដែលជាគម្រោងសហការរវាងក្រុមកម្ពុជា តំណាងដោយអាជ្ញាធរអប្សរានិងក្រុមជប៉ុនមកពីសាកលវិទ្យាល័យ វ៉ាសេដា។

ប្រាសាទបាយ័ន ក៏បានបង្ហាញឲ្យឃើញផងដែរអំពីបញ្ហានៃប្រព័ន្ធបង្ហូរទឹកហើយកិច្ចការជួសជុលនេះក៏បានអនុវត្ត ក្នុងគោលបំណងការពារកុំឲ្យមានទឹកជ្រាបចូលក្នុងគ្រឹះរបស់ខឿនប្រាសាទទៀត ដើម្បីកាត់បន្ថយបរិមាណសំណើមនៅក្នុងជញ្ជាំងកំពែងចម្លាក់រឿង។

ការសិក្សា ពីភូគព្ភសាស្ត្រក៏បានបង្ហាញអំពីតម្រូវការពង្រឹងអណ្តូងស្ថិតនៅក្នុងតួប៉មកណ្តាលនៃប្រាសាទបាយ័នមុនពេលយកបដិមាព្រះពុទ្ធដែលជានិមិត្តរូបដ៏សំខាន់របស់ប្រាសាទមកដាក់នៅទីតាំងដើមឡើងវិញ។

ប្រាសាទភ្នំបាខែង

ប្រាសាទភ្នំបាខែង ជាប្រាសាទសម្រាប់រាជដំបូងបង្អស់នៃរាជធានីអង្គរ សាងឡើងនៅចុងសតវត្សរ៍ទី៩ ដោយព្រះបាទយសោវរ្ម័នទី១ និងជាសំណង់ដ៏ស្រស់ស្អាតគួឲ្យចាប់អារម្មណ៍ ដែលមានសាជី ជារាងថ្នាក់ៗបួនជ្រុងនិងព័ទ្ធជុំវិញដោយតួប៉មចំនួន១០៨។

ការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យានិងស្ថាបត្យកម្មនៅប្រាសាទភ្នំបាខែងចាប់ផ្តើមនៅក្នុងឆ្នាំ២០០៤និងកំពុងតែបន្តសកម្មភាពមករហូតមកទល់ពេលបច្ចុប្បន្ននេះ។ គម្រោងការងារគ្រប់គ្រងមួយបានរៀបចំឡើងដោយក្រុមការងារមកពីស្ថាប័នមូលនិធិប្រាសាទពិភពលោក (World Monument Fund)និងអាជ្ញាធរអប្សរាដើម្បីវាយតម្លៃទៅលើបញ្ហានិងរៀបចំផែនការការងារជាបន្ទាន់មួយ។

ប្រាសាទបាពួន

ប្រាសាទបាពួនជាប្រាសាទដ៏ធំសម្បើមមួយសាងឡើងនៅពាក់កណ្តាលសតវត្សរ៍ទី១១ដែលមានសាជីធំមួយជារាងថ្នាក់ៗប្រាំជាន់កម្ពស់២៥ម៉ែត្រនិងទំហំបាត១៣០ម៉ែត្រ គុណនិង១០៤ម៉ែត្រ។

ប្រាសាទព្រះគោ

© Anandajoti Bhikkhu

ក្រោមការដឹកនាំដោយលោក B. P. Groslier ជាបុរាណវិទូនៃសាលាបារាំងចុងបូព៌ាប្រទេស (EFEO) និងលោក Jacques Dumarçay ជាស្ថាបត្យករ បានធ្វើការជួសជុលប្រាសាទបាពួន ដោយប្រើប្រាស់វិធីសាស្ត្រអាណាស្ទីឡូជាលើកដំបូងដើម្បីពង្រឹងគ្រឹះប្រាសាទដ៏ធំនេះ ហើយបន្ទាប់មកក៏បានជួសជុលថ្មកក់យកមកដាក់ឲ្យដូចនឹងស្ថានភាពដើមរបស់គ្រឹះវិញ។ ផ្នែកខ្លះនៃការជួសជុលនេះបានបញ្ចប់ជាស្ថាពរ ហើយពេលក្រោយៗមកទៀតគំរូនៃការជួសជុលនេះគឺជាវិធីសាស្ត្រមានលក្ខណៈសមរម្យសម្រាប់ការងារជួសជុលថ្មយកទៅដាក់តាមទីតាំងដើមនីមួយៗរបស់សំណង់វិញ។ កិច្ចការនេះបានបន្តអនុវត្តអស់រយៈ១៦ឆ្នាំដោយលោក Pascal Royère ជាស្ថាបត្យករមកពីសាលាបារាំងចុងបូព៌ាប្រទេស ដែលបានធ្វើឲ្យប្រាសាទទាំងមូលមានលំនឹងឡើងវិញ ព្រមទាំងបានអភិរក្សទុកនូវដំណាក់កាលសំខាន់ៗទាំងពីររបស់ប្រវត្តិប្រាសាទ គឺសម័យកាលទាក់ទងនឹងព្រហ្មញ្ញសាសនាជាពិសេស គឺរូបចម្លាក់នៅតាមជញ្ជាំងរៀបរាប់ពីរឿងរាមកេរ្តិ៍និងសម័យកាលពុទ្ធសាសនាមានរូបព្រះពុទ្ធចូលព្រះនិព្វាន។

ប្រាសាទព្រះគោ

ប្រាសាទព្រះគោសាងអំពីឥដ្ឋយ៉ាងស្រស់ស្អាតមានតួប៉មចំនួន៦ សង់ជាក្រុមនៅលើខឿនតែមួយព័ទ្ធជុំវិញដោយកសិណទំហំ៥០០ម៉ែត្រគុណនិង៤០០ម៉ែត្រ សាងឡើងដោយព្រះបាទឥន្ទ្រវរ្ម័នទី១ នៅចុងសតវត្សរ៍ទី៩។

ការងារជួសជុលដំបូង[illegible]ក្រុមអាឡឺម៉ង់-ហាំងគ្រី[illegible]ការងារជួសជុល[illegible]ខ្មែរពីរូបនិងកម្ពុជ[illegible]ជាច្រើនរូបទៀត។ [illegible]លើបង្អួចនិង[illegible]អាទ្រូណ៍[illegible]ដោយសារ[illegible]មកពីធម្មជាតិនិងមនុស្ស។

ប្រាសាទតាព្រហ្ម

តាមពិតប្រាសាទតាព្រហ្ម [illegible]ព្រះពុទ្ធសាសនានិងជាប្រាសាទមួយក្នុងចំណោមប្រាសាទសំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧ សាងឡើងនៅចុងសតវត្សរ៍ទី១២ដល់ដើមសតវត្សរ៍ទី១៣។

ការងារអភិរក្សនៅប្រាសាទតាព្រហ្មបានប្រឈមនឹងបញ្ហាធ្ងន់ធ្ងរជាច្រើនដែលបង្កឡើងដោយសារលក្ខខណ្ឌបរិស្ថាននៅជុំវិញប្រាសាទនេះ។ [illegible]ត្រូវបានអនុវត្ត[illegible]ដើម្បីការពារនិង[illegible] ក្នុងការស្រាវជ្រាវ[illegible] (Archaeological Survey of India) [illegible]ឯកសារលម្អិត[illegible]ផ្សេងៗរបស់ប្រាសាទ[illegible]។ ការ[illegible]ត្រូវបានអនុវត្តទៅលើ[illegible]នៅក្នុងគ្រឹះ ហើយ[illegible]និងកម្រាលថ្ម[illegible]។

[illegible]កិច្ចការជួសជុលចំនួន ៤ ក្នុងចំណោម[illegible]ជាស្ថាពរ។ ឬសឈើ[illegible]ព័ទ្ធជុំវិញថ្មប្រាសាទបានរួមចំណែកបង្កើតឲ្យមាន[illegible]ពិសេសមួយនៅក្នុងប្រាសាទនេះ ដែល[illegible]មិនអាចអនុញ្ញាតឲ្យមានការពង្រឹងនិងជួសជុលគ្រប់ទីតាំងខូចខាតទាំងអស់នៅក្នុងប្រាសាទនេះបានឡើយ គឺត្រូវរក្សាស្ថានភាពធម្មជាតិរបស់វាជាបន្តទៀត មានន័យថាទិដ្ឋភាពទាំងនេះគឺជាលទ្ធផលនៃការបាក់បែកខូចខាតជាច្រើនសតវត្សរ៍។

ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ

បណ្ឌិត ហង់ ពៅ
អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក
អាជ្ញាធរអប្សរា



កសិណទឹកខាងលិចឈៀងខាងជើងផ្លូវធំចូលអង្គរវត្ត

© Eric Moina

ការគ្រប់គ្រងទឹកបានយ៉ាងប្រសើររបស វិស្វករខ្មែរនៅសម័យបុរាណត្រូវបានឆ្លុះបញ្ចាំងតាមរយៈរចនាសម្ព័ន្ធធារាសាស្ត្រជាច្រើនស្មុគស្មាញនៅអង្គរមានដូចជា បារាយណ៍ កសិណទឹក ទំនប់សំណង់បង្វែរធ្វើពីថ្មបាយក្រៀម ស្ពានថ្មបាយក្រៀមអាងទឹកនិងប្រឡាយតូចធំជាដើម។

ដោយសារមូលហេតុនៃកំណើនចំនួនភ្ញៀវទេសចរកើនឡើងរាល់ឆ្នាំនិងកំណើនចំនួនប្រជាជននៅក្នុងតំបន់សៀមរាបទាំងមូល តម្រូវការផ្នែកទឹកក៏កាន់តែកើនឡើងខ្លាំងណាស់ដែរដែលធ្វើឲ្យការងារគ្រប់គ្រងទឹកនៅក្នុងតំបន់សៀមរាបអង្គរក្លាយជាបញ្ហាមួយដ៏ធំចំពោះការអភិរក្សប្រាង្គប្រាសាទនិងការអភិវឌ្ឍប្រកបដោយចីរភាព។ បញ្ហាប្រឈម គឺត្រូវធ្វើយ៉ាងណាឆ្លើយតបឲ្យបានទាន់ពេលចំពោះតម្រូវការទឹកប្រចាំថ្ងៃហើយទន្ទឹមនឹងនោះក៏ត្រូវប្រុងប្រយ័ត្នជានាឲ្យមានស្ថិរភាពចំពោះប្រាង្គប្រាសាទអង្គរដែលសាងសង់នៅលើគ្រឹះខ្សាច់ហើយដែលគ្រឹះខ្សាច់ពាក់ព័ន្ធទៅនឹងស្រទាប់ទឹកក្រោមដី។

នាយកដ្ឋានគ្រប់គ្រងទឹករបស់អាជ្ញាធរអប្សរាបានធ្វើការងារត្រៀមរៀបចំផ្នែកទ្រឹស្តីនិងអនុវត្តជាក់ស្តែងចាំបាច់នានាក្នុងការស្តារប្រព័ន្ធធារាសាស្ត្របុរាណក្នុងសម័យអង្គរ ដើម្បីធ្វើឲ្យតួនាទីដ៏សំខាន់នៃប្រព័ន្ធទឹកទាំងនោះដំណើរការឡើងវិញក្នុងការអភិរក្សប្រាង្គប្រាសាទនិងចូលរួមជាផ្នែកមួយនៃទេសភាពវប្បធម៌និងបរិស្ថានឧទ្យានជាទូទៅ។ កម្មវិធីនេះពិតជាត្រូវអនុវត្តដោយប្រើពេលវែងនិងលំបាកហើយយើងអាចអនុវត្តបានក៏ដោយសារមានធនធានបច្ចេកទេសនិងហិរញ្ញវត្ថុរបស់អាជ្ញាធរអប្សរាដែរ។ គម្រោងនេះផ្តោតជាពិសេសលើការប្រៀបធៀបរវាងការវិភាគនិងសេចក្តីសន្និដ្ឋានដំបូងនិងទិន្នន័យដ៏សំបូរបែបដែលមិនធ្លាប់មានពីមុនមក ជាពិសេសដោយសារទឹកជំនន់នៅ ឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១។

ការស្តារឡើងវិញនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ

កិច្ចការសំខាន់ដែលត្រូវធ្វើដំបូងមុននឹងអាចចាប់ផ្តើមការងារស្តារឡើងវិញនោះ គឺការវិភាគធារទឹកតាំងពីកន្លែងប្រភពដើមដែលចេញពីអាងផ្ទៃរងទឹកភ្លៀងនៅលើភ្នំគូលែនរហូតដល់កន្លែងដែលទឹកហូរទៅចាក់នៅក្នុងបឹងទន្លេសាបដែលនៅតាមផ្លូវនោះទឹកហូរទៅក្នុងអាងផ្ទៃរងទឹកភ្លៀងចំនួនបី គឺមានស្ទឹងពួកនៅខាងលិចស្ទឹងសៀមរាបនៅកណ្តាលនិងស្ទឹងរលួសនៅខាងកើត។ មើលទៅ ស្ទឹងពួកនិងស្ទឹងរលួស គឺដូចជាស្ទឹងដែលកើតមានតាមធម្មជាតិចំណែកឯស្ទឹងសៀមរាប គឺដូចជាផ្លូវទឹកសិប្បនិម្មិតមានន័យថាជាផ្លូវទឹកដែលគេបង្កើតឡើងដើម្បីបង្វៀងទឹកពីភ្នំគូលែន ដោយសំណង់បង្វៀរទឹកនៅបំពេញរាជដែលធ្វើអំពីថ្មបាយក្រៀមមានទទឹង ៦០ម៉ែត្រនិងបណ្តោយ៣០០ម៉ែត្រ កសាងឡើងនៅសតវត្សទី៩។

ប្រាសាទនាគព័ន្ធនៅចំកណ្តាលអាងទឹក

បញ្ហាប្រឈមគឺត្រូវធ្វើយ៉ាងណាឆ្លើយតបឲ្យបានទាន់ពេលចំពោះតម្រូវការទឹកប្រចាំថ្ងៃ ហើយទន្ទឹមនឹងនោះក៏ត្រូវប្រុងប្រយ័ត្នជានាឲ្យមានស្ថិរភាពចំពោះប្រាង្គប្រាសាទអង្គរដែលសាងសង់នៅលើគ្រឹះខ្សាច់ ហើយដែលគ្រឹះខ្សាច់ពាក់ព័ន្ធទៅនឹងស្រទាប់ទឹកក្រោមដី

ដោយសារលទ្ធផលនៃការស្រាវជ្រាវជាក់ស្តែងស្តីអំពីប្រព័ន្ធធារាសាស្ត្របុរាណអស់រយៈពេលជាង៨ឆ្នាំកន្លងមកធ្វើឡើងដោយនាយកដ្ឋានគ្រប់គ្រងទឹករចនាសម្ព័ន្ធបុរាណមួយចំនួនដែលបានកសាងឡើងក្នុងសម័យអាណាចក្រខ្មែរអង្គរដោយវិស្វករធារាសាស្ត្រត្រូវបានជួសជុលឡើងវិញជាស្ថាពរ។

ស្រះស្រង់

ស្រះស្រង់មានទឹកដោយសារទឹកភ្លៀងនិងទឹកជ្រាបពីក្រោមដីចេញពីបារាយណ៍ខាងកើត និងទឹកក្រោមដីដែលនៅជុំវិញស្រះនោះ។ ប៉ុន្តែដោយសារបារាយណ៍ខាងកើតរីងស្ងួតហួតហែងអស់ទៅហើយនិងដោយសារកម្រិតទឹកក្រោមដីបានស្រកចុះ ទឹកក្នុងស្រះស្រង់ក៏បានចាប់ផ្តើមរីងស្ងួតដែរនៅរដូវប្រាំងរហូតដល់គ្មានទឹកទាល់តែសោះនៅខែមេសា ឆ្នាំ២០០៤។ នៅខែមិនា ឆ្នាំ២០០៥នាយកដ្ឋានគ្រប់គ្រងទឹកបានរៀបចំបង្កើតប្រព័ន្ធបន្ថែមមួយដើម្បីបង្ហូរទឹកចូលក្នុងស្រះស្រង់ដោយយកទឹកចេញពីម្តុំភ្នំបូកនិងរលួស។

កសិណទឹកអង្គរធំ

អាងដ៏ធំមួយនេះអាចផ្ទុកទឹកបានជិត២លានម៉ែត្រគូប វាជាកសិណទឹកដែលមានប្រវែង ១២គីឡូម៉ែត្រព័ទ្ធជុំវិញកំផែងក្រុងអង្គរធំ។ កាលពីពេលថ្មីៗនេះមានតែកសិណទឹកផ្នែកខាងត្បូងឈៀងខាងលិចប្រមាណ៣០០០ម៉ែត្រប៉ុណ្ណោះដែលមានទឹក ខណៈដែលផ្នែកខាងត្បូងឈៀងខាងកើតនៃកសិណគ្មានទឹកទៀតឡើយនៅរដូវប្រាំង។ បន្ទាប់ពីយើងបានធ្វើការជួសជុលរួចមក ចាប់តាំងពីឆ្នាំ២០១០ កំណាត់នៃកសិណខាងត្បូងឈៀងខាងកើតប្រវែង៣០០០ម៉ែត្រមានទឹកជាប់ជាប្រចាំពេញមួយឆ្នាំ។ ទាំងក្នុងរដូវប្រាំងនិងរដូវវស្សា។ ចាប់ពីឆ្នាំ២០១២ មក កសិណទឹកទាំងមូលប្រវែង១២គីឡូម៉ែត្រក៏មានទឹកជាប់ជាប្រចាំឡើងវិញដែរ។

កសិណទឹកប្រាសាទអង្គរវត្ត

មុនឆ្នាំ២០១០ប្រព័ន្ធបង្ហូរទឹកបំពេញកសិណទឹកប្រាសាទអង្គរវត្ត គឺមានប្រឡាយមួយដែលគេកសាងឡើងនៅចន្លោះកសិណទឹកអង្គរធំខាងត្បូងឈៀងខាងលិចរហូតដល់ត្រពាំងសេះធ្វងកាត់ខាងក្រោយកន្លែងបង្ហោះបាឡុងក្នុងសម័យថ្មីនេះ។ បច្ចុប្បន្នយើងបានស្តារប្រព័ន្ធបុរាណឡើងវិញដោយភ្ជាប់កសិណទឹកអង្គរធំផ្នែកខាងត្បូងឈៀងខាងកើតទៅកសិណទឹក អង្គរវត្តផ្នែកខាងជើងឈៀងខាងលិចផ្ទាល់ ដោយធ្វងកាត់តាមកសិណទឹកភ្នំបាខែងនិងអូរសំពៅលូន។ ប្រព័ន្ធនេះបានធ្វើឲ្យកម្រិតទឹកក្នុងកសិណអង្គរវត្តកើនបានកម្ពស់១ម៉ែត្រ បើប្រៀបធៀបទៅនឹងកម្រិតទឹកអតិបរមារបស់វានៅពេលមុន។

បារាយណ៍ខាងជើង (ជ័យតដាក)

បារាយណ៍នេះមានបណ្តោយ៣៦០០ម៉ែត្រនិងទទឹង៩៣០ម៉ែត្រនិងមានសមត្ថភាពផ្ទុកទឹកពីដំបូងបានរហូតដល់៥លានម៉ែត្រគូប។ ទឹកនៅក្នុងបារាយណ៍នេះមិនត្រូវបានគេប្រើដើម្បី

យកទៅស្រោចស្រពដំណាំដូចទឹកបារាយណ៍ផ្សេងទៀតនៅក្នុងតំបន់នេះឡើយ ប៉ុន្តែគេរក្សាទឹកក្នុងបារាយណ៍នេះសម្រាប់ប្រើនៅក្នុងក្រុងអង្គរធំ ក្រុងព្រះខ័ននិងនាគព័ន្ធ។ បារាយណ៍នេះបានរីងស្ងួតហួតហែងអស់ជាង៥០០ ឆ្នាំមកហើយ ម្យ៉ាងទៀត អ្នកស្រាវជ្រាវមួយចំនួនមិនគិតថាការធ្វើឲ្យបារាយណ៍ខាងជើងនេះមានទឹកជាថ្មីឡើងវិញនឹងអាចទៅរួចនោះឡើយ។ ប៉ុន្តែនៅឆ្នាំ២០០៧ អ្នកស្រាវជ្រាវខ្មែរបានជួសជុលប្រព័ន្ធបង្ហូរទឹកដែលគេបានរកឃើញនៅឆ្នាំ២០០៥ ហើយនៅឆ្នាំ២០០៨ទឹកក៏ចាប់ផ្តើមហូរចូលក្នុងបារាយណ៍នេះវិញ។ ការបង្ហូរទឹកចូលបំពេញក្នុងបារាយណ៍ខាងជើងត្រូវបានធ្វើឡើងដូចតទៅនេះ៖ ចំនួន៧០០ ០០០ម៉ែត្រគូបនៅឆ្នាំ២០០៨ ចំនួន៣ ០០០ ០០០ម៉ែត្រគូបនៅឆ្នាំ២០០៩ ចំនួន ៣ ៦៧៨ ០០០ម៉ែត្រគូបនៅឆ្នាំ២០១០និងចំនួន ៥ ០០០ ០០០ម៉ែត្រគូបនៅឆ្នាំ២០១១និងឆ្នាំ២០១២។

នាគព័ន្ធ

នាគព័ន្ធ គឺជាប្រាសាទនៅលើកូនកោះតូចមួយ ចំកណ្តាលបារាយណ៍ខាងជើង ប្រៀបដូចជាប្រាសាទមេបុណ្យក្នុងបារាយណ៍ផ្សេងទៀតដែរ ប៉ុន្តែនៅសម័យបុរាណនាគព័ន្ធមានមុខងារផ្សេងមួយទៀតគឺថាវាជាមន្ទីរពេទ្យដែលប្រើប្រាស់រុក្ខជាតិជាឱសថបុរាណ។ នៅជុំវិញប្រាសាទនេះមានអាងចំនួន៥ដែលនៅក្នុងសម័យក្រោយមកបានរីងស្ងួតអស់ពេញមួយឆ្នាំ លើកលែងតែអាងកណ្តាលដែលមានទឹករយៈពេលតែប៉ុន្មានខែប៉ុណ្ណោះក្នុងមួយឆ្នាំនៅរដូវវស្សា។ ប៉ុន្តែ ចាប់តាំងពីបារាយណ៍ខាងជើងមានទឹកសាជាថ្មីឡើងវិញមកអាងទាំងប្រាំនេះក៏មានទឹកពេញឡើងវិញគ្រប់រដូវដែរ។ អាងទាំងនេះដែលភ្ជាប់ទៅនឹងបារាយណ៍ខាងជើង គឺជាការឆ្លុះបញ្ចាំងយ៉ាងល្អជាងគេអំពីប្រព័ន្ធធារាសាស្ត្រនៅក្នុងឧទ្យានអង្គរដែលត្រូវបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ប្រាសាទព្រះខ័ន

នៅក្នុងសម័យបុរាណដូចស្រះស្រង់ដែរ កសិណទឹកប្រាសាទព្រះខ័នគ្មានប្រព័ន្ធទឹកបង្ហូរចូលបំពេញនោះទេ។ នៅសម័យបច្ចុប្បន្នកសិណនេះមានទឹកតែក្នុងមួយរយៈពេលណាប៉ុណ្ណោះក្នុងមួយឆ្នាំប៉ុន្តែតាំងពីបារាយណ៍ខាងជើងមានទឹកសាជាថ្មីឡើងវិញមកកសិណប្រាសាទព្រះខ័នក៏មានទឹកឡើងវិញមួយឆ្នាំពេញមួយឆ្នាំដែរ។ បាតុភូតនេះបង្ហាញថា បារាយណ៍ខាងជើងនិងព្រះខ័នមានទំនាក់ទំនងគ្នាតាមរយៈទឹកក្រោមដី ប៉ុន្តែវាក៏បង្ហាញផងដែរថាកសិណប្រាសាទព្រះខ័នដែលមានទឹកឡើងវិញនេះគឺជាលទ្ធផលនៃ

ទស្សនីយភាពប្រាសាទព្រះខ័ន
© Tushar Dayal

ការកើនឡើងនៃកម្រិតទឹកក្រោមដីដោយសារតែបារាយណ៍ខាងជើងមានទឹកឡើងវិញសាជាថ្មី។

បារាយណ៍ខាងលិច

នៅក្នុងទសវត្សឆ្នាំ៦០ ដើម្បីបំពេញទឹកក្នុងបារាយណ៍ខាងលិច ទឹកស្ទឹងសៀមរាបត្រូវបានគេបង្វែរទៅនៅត្រង់ជ្រុងខាងជើងឈៀងខាងកើតនៃក្រុងអង្គរធំតាមរយៈប្រឡាយមួយដែលគេជីកនៅខាងក្នុងកសិណអង្គរធំតែម្តង (កសិណខាងជើងនិងខាងជើងឈៀងខាងលិច) មានបណ្តោយប្រវែង៤៥០០ម៉ែត្រ ភ្ជាប់ទៅនឹងប្រឡាយមួយនៅតាមបណ្តោយផ្លូវចូលក្លោងទ្វារតាកាវដែលជាក្លោងទ្វារខាងលិចនៃអង្គរធំ។ ប្រឡាយទាំងនេះបានធ្វើឲ្យកសិណនេះនិងផ្នែកខាងកើតនៃបារាយណ៍ខាងលិចគោកគ្មានទឹក ដែលធ្វើឲ្យគេគិតថាការគោកនេះគឺបណ្តាលមកពីមានដីកកនៅក្នុងបារាយណ៍។ នៅឆ្នាំ២០១០ នាយកដ្ឋានគ្រប់គ្រងទឹក បានរកឃើញប្រព័ន្ធបង្ហូរទឹកបំពេញនៅក្នុងបារាយណ៍ខាងលិចពីសម័យដើមដែលនៅក្នុងនោះមានអាងច្រោះទឹកបុរាណមួយនិងអូរមួយលាតសន្ធឹងដល់ជ្រុងខាងជើងឈៀងខាងលិចនៃកសិណអង្គរធំ។ នៅឆ្នាំ២០១១ អាជ្ញាធរអប្សរាបានបើកអូរសម័យដើមបង្ហូរទឹកបំពេញបារាយណ៍ខាងលិច ដើម្បីស្រូបយកទឹកជំនន់និងការពារភូមិអ្នកស្រុក។ នៅឆ្នាំ២០១២ អាជ្ញាធរអប្សរាបានស្តារប្រព័ន្ធបង្ហូរទឹកបំពេញបារាយណ៍នេះទាំងមូលឡើងវិញ ហើយសព្វថ្ងៃបារាយណ៍ខាងលិចអាចមានទឹកពេញផ្ទៃរបស់វាបែបនេះវាដើរតួយ៉ាងពេញទំហឹងនៅក្នុងការគ្រប់គ្រងទឹកជំនន់។

ការការពារភាពរាំងស្ងួតនិងទឹកជំនន់

គ្មានសិលាចារឹក នៅសម័យអាណាចក្រខ្មែរណាមួយដែលនិយាយអំពីទឹកជំនន់ឬភាពរាំងស្ងួតនៅក្នុងតំបន់អង្គរឡើយ។ ប្រជាជនខ្មែរក៏មិនបានផ្តែផ្តាំពីជំនាន់មួយទៅជំនាន់មួយតាមរយៈរឿងព្រេងនិទាននូវការចងចាំ អំពីគ្រោះធម្មជាតិណាមួយនោះដែរ។ ដូច្នេះ គេហាក់ដូចជាមានអារម្មណ៍ថាបញ្ហាទាំងនេះមិនបានកើតមានឡើងនៅក្នុងអតីតកាលទេ បញ្ជាក់ថាប្រព័ន្ធគ្រប់គ្រងទឹក នៅក្នុងសម័យបុរាណអាចមានលទ្ធភាពគ្រប់គ្រងធនធានទឹកបានយ៉ាងប្រសើរបំផុត។ ប៉ុន្តែ ដោយសារប្រព័ន្ធទឹកបុរាណមិនដំណើរការអស់រយៈពេលយូរពេកនោះនៅឆ្នាំ២០០៤ យើងបានជួបប្រទះភាពរាំងស្ងួតនៅក្នុងកសិណអង្គរវត្ត ស្រះស្រង់ក៏រីងទឹកអស់បន្ទាប់មកមានទឹកជំនន់នៅឆ្នាំ២០០៩ ឆ្នាំ២០១០និងឆ្នាំ២០១១។

គេអាចយល់បានដោយចាប់ផ្តើមពីការពិនិត្យមើលរំហូរទឹកនៅនឹងកន្លែងផ្ទាល់តែម្តងដោយស្វែងរកផ្លូវទឹកផ្សេងៗនិងបណ្តាញតភ្ជាប់គ្នារបស់វានិងការរៀបចំជាទូទៅនៃប្រព័ន្ធធារាសាស្ត្រក្នុងឧទ្យានអង្គរ រួមមានស្ទឹង បារាយណ៍ កសិណទឹក អូរ អាងទឹកនិងប្រឡាយតូចធំផ្សេងៗ។ ការសិក្សាស្រាវជ្រាវនៅនឹងទីកន្លែងផ្ទាល់បានបង្ហាញថាផ្នែកខាងជើងឈៀងខាងកើតនៃបារាយណ៍ខាងជើងមានទំនប់មួយដែលគេសង់ក្នុងទិសពីកើតទៅលិចនិងមានស្ពានបុរាណមួយធ្វើពីថ្មបាយក្រៀមដែលមានរាងដូចស្ពានកំពង់ក្តី មានប្រឡោះបង្ហូរទឹកជាច្រើននៅលើស្ទឹងសៀមរាបដែលអាចប្រើប្រាស់សម្រាប់គ្រប់គ្រងធារទឹកនិងលំហូរទឹក។ ដោយសារប្រព័ន្ធចែកចាយនិងអូរប្រទាក់ក្រឡាជាច្រើននេះហើយដែលយើងអាចបង្វែរទឹកសំដៅទៅទិសខាងលិច (មានបារាយណ៍ខាងជើងបារាយណ៍ខាងលិចនិងស្ទឹងពួក) សំដៅទៅទិសខាងកើត (មានស្ទឹងរលួស) និងសំដៅទៅទិសខាងត្បូង (មានកសិណទឹកអង្គរធំ អង្គរវត្ត និង ស្ទឹងសៀមរាប)។ នៅឆ្នាំ២០១២ ផ្នែកសំខាន់នៃប្រព័ន្ធនេះត្រូវបានស្តារឡើងវិញនិងអនុញ្ញាតឲ្យឧទ្យានអង្គរនិងក្រុងសៀមរាបអាចជៀសផុតពីទឹកជំនន់ក្នុងរដូវវស្សា។ បើគ្មានការងារទាំងនេះទេក្រុងសៀមរាបត្រូវទទួលរងគ្រោះដោយទឹកជំនន់យ៉ាងតិចចំនួនបួនដាប់ៗគ្នា។ លទ្ធផលនេះបញ្ជាក់ថា

ប្រព័ន្ធធារាសាស្ត្របុរាណក្នុងសម័យអង្គរ មិនត្រឹមតែអាចគ្រប់គ្រងនូវធនធានទឹកបានយ៉ាងល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់បានទៀតផង។

យើងជឿជាក់ថានៅក្នុងសម័យអង្គរដ៏រុងរឿង រាជបុរីមួយនេះប្រាកដជាមានប្រព័ន្ធធារាសាស្ត្រដ៏មានប្រសិទ្ធភាពស៊ីចង្វាក់គ្នានិងស្វ័យប្រវត្តិ។

គម្រោងនៅអនាគតកាល

នៅពេលបច្ចុប្បន្ននេះបារាយណ៍ខាងលិច (មានសមត្ថភាពផ្ទុកទឹក៥៦លានម៉ែត្រគូប) បារាយណ៍ខាងជើង(មានសមត្ថភាពផ្ទុកទឹក៥លានម៉ែត្រគូប) កសិណទឹកអង្គរធំ(មានសមត្ថភាពផ្ទុកទឹក២លានម៉ែត្រគូប)កសិណទឹកអង្គរវត្ត (មានសមត្ថភាពផ្ទុកទឹកជាង១លានម៉ែត្រគូប) ទាំងអស់អាចផ្ទុកទឹកបានជាង៦៥លានម៉ែត្រគូបទៅហើយ។ ក្នុងពេលទឹកជំនន់ឆ្នាំ២០១២ អាងផ្ទុកទឹកទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រូបយកទឹកជាបណ្ដោះអាសន្នជួយសម្រួលក្នុងការគ្រប់គ្រងទឹកជំនន់។ អាជ្ញាធរអប្សរាគ្រោងនឹងស្ដារបារាយណ៍ខាងកើតឡើងវិញ (មានសមត្ថភាពផ្ទុកទឹកជាង៣៦លានម៉ែត្រគូប)និងបារាយណ៍លលៃ (មានសមត្ថភាពផ្ទុកទឹក១០លានម៉ែត្រគូប) ដែលនៅក្នុងពេលបច្ចុប្បន្ននេះបារាយណ៍ទាំងពីរបានរីងស្ងួតទាំងស្រុង។ បើបារាយណ៍ទាំងពីរនេះត្រូវបានជួសជុលឡើងវិញ នោះសមត្ថភាពផ្ទុកទឹកសរុបទាំងអស់នឹងកើនដល់ប្រមាណជា១១១លានម៉ែត្រគូបនិងធានាបាននូវការគ្រប់គ្រងទឹកជារួមនិងការពារកុំឲ្យមានទឹកជំនន់នៅក្នុងតំបន់អង្គរ។

ចាប់ពីពេលនេះតទៅយើងពិតជាយល់ច្បាស់អំពីប្រព័ន្ធធារាសាស្ត្រអង្គរ ហើយយើងបានរកឃើញផ្លូវនិងអាងទឹកជាច្រើននៅតាមទឹកកន្លែងផ្សាល់។ការងារផ្សេងៗទៀតក៏ចាំបាច់ត្រូវធ្វើដែរ ដើម្បីជួសជុលប្រព័ន្ធទាំងមូលនេះឡើងវិញនិងធានានូវចីរភាពនៃការថែទាំរបស់វា។

កម្មវិធីនេះ គឺជាគំរូមួយនៃការអភិរក្សនិងការស្ដារឡើងវិញ។ ទំនើបកម្មនៃប្រព័ន្ធធារាសាស្ត្រអង្គរហាក់ដូចជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពនិងទទួលផលចំណេញជាងគេបំផុតក្នុងការចូលរួមប្រកបដោយនិរន្តរភាពក្នុងការអភិវឌ្ឍតំបន់អង្គរសៀមរាបនិងកាត់បន្ថយភាពក្រីក្រ។

អាងទទួលទឹកទាំងបីពីភ្នំគូលែន : ស្ទឹងពួក ស្ទឹងសៀមរាបនិងស្ទឹងរលួស (ពីឆ្វេងទៅស្ដាំ)

នៅឆ្នាំ២០១២ ផ្នែកសំខាន់នៃប្រព័ន្ធនេះត្រូវបានស្ដារឡើងវិញនិងអនុញ្ញាតឲ្យឧទ្យានអង្គរនិងក្រុងសៀមរាបអាចចៀសផុតពីទឹកជំនន់ក្នុងរដូវវស្សា

ប្រព័ន្ធធារាសាស្ត្រសម័យបុរាណក្នុងឧទ្យានអង្គរ



បេតិកភណ្ឌនិងប្រជាជនក្នុងឧទ្យានអង្គរ

ឯកឧត្តម ឃួន ឃុននាយ
ស្ថាបត្យករនិងនគរូបនីយករ
អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា



មណ្ឌលលំនៅឋានខ្មែរក្នុងឧទ្យានអង្គរ

© ឃួន ឃុននាយ

អង្គរ មានលក្ខណៈពិសេសណាស់ព្រោះជាឧទ្យានបុរាណវិទ្យាមួយដ៏សំខាន់ពោរពេញទៅដោយប្រាង្គប្រាសាទធំៗ ល្អអស្ចារ្យគួរឲ្យស្ញប់ស្ញែង ក្នុងទេសភាពវប្បធម៌ស្រស់បំព្រង និងមានប្រជាជនរស់នៅជាសហគមន៍ ហើយក៏ជាទិសដៅទេសចរណ៍អន្តរជាតិដ៏ល្បីល្បាញផងៗ

ឧទ្យានអង្គរ លាតសន្ធឹងលើផ្ទៃដីចំនួន ៤០ ១០០ហិកតា ដែលមានប្រជាជនរស់នៅតាំងពីយូរមកហើយក្នុង១១២ភូមិនៃតំបន់ការពារ។ នៅជាប់នឹងឧទ្យានមានទីក្រុងមួយដែលកំពុងតែរីកដុះដាលប្រកបដោយអាកាសយានដ្ឋានអន្តរជាតិ សណ្ឋាគារនិងផ្ទះសំណាក់ជាង១០០ ព្រមទាំងភោជនីយដ្ឋានទីផ្សារជាច្រើនហើយក៏ជាទីរួមខេត្តសៀមរាបទាំងមូល។ រាជរដ្ឋាភិបាលមានសមានចិត្តមោះមុតក្នុងការអនុញ្ញាតឲ្យប្រជាជនដែលក្នុងឆ្នាំ២០១០មានចំនួនប្រហែល ១២០ ០០០ នាក់រស់នៅក្នុងសភាពដដែលតរៀងមក ដោយបានប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណី ហើយបានក្លាយខ្លួនទៅជាបេតិកភណ្ឌទៅហើយ។ ក៏ប៉ុន្តែនេះក៏ជាបញ្ហាប្រឈមមួយក្នុងការគ្រប់គ្រងថែរក្សាឧទ្យានដែរ។ ដូច្នេះគោលបំណងដ៏សំខាន់ គឺធ្វើយ៉ាងណាឲ្យប្រជាជនចូលរួមចំណែកក្នុងការគ្រប់គ្រងឧទ្យានអង្គរដោយបានទទួលផលប្រយោជន៍ពីទេសចរណ៍ផង។ កិច្ចការនេះអាចសម្រេចទៅបានលុះត្រាតែសហគមន៍មូលដ្ឋានចូលរួមសហការក្នុងការគាក់តែងផែនការគ្រប់គ្រងឲ្យបានគ្រប់ដំណាក់កាល រហូតដល់ការអនុវត្តទៀតផង។

តាំងពីប៉ុន្មានឆ្នាំមកហើយអាជ្ញាធរជាតិអប្សរាដែលជាអង្គការគ្រប់គ្រងឧទ្យានអង្គរបានបង្កើតនាយកដ្ឋានបីថ្មីបន្ថែមទៀតដើម្បីបំពេញភារកិច្ចខាងសហគមន៍គឺនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅឋានក្នុងឧទ្យានអង្គរនាយកដ្ឋានគ្រប់គ្រងទឹកនិងព្រៃឈើដែលត្រូវបានបំបែកជានាយកដ្ឋានពីរដាច់គ្នានៅឆ្នាំ២០០៨និងនាយកដ្ឋានប្រជាសាស្ត្រនិងកសិកម្ម។

លក្ខណៈប្រជាជន

ចំនួនប្រជាជនដែលរស់នៅក្នុងតំបន់ការពារនៃឧទ្យានអង្គរបានរីកធំឡើងៗយ៉ាងខ្លាំង គឺតាំងពីពេលដែលសន្តិភាពបានវិលត្រឡប់មកវិញនិងសន្តិសុខត្រូវបានធានាពេញផ្ទៃនៃព្រះរាជាណាចក្រ ដោយប្រជាជនពីខេត្តនានា បាននាំគ្នាចូលមកតាំងទីក្នុងឧទ្យានអង្គរដើម្បីប្រកបជីវិតក្នុងវិស័យទេសចរណ៍។ នៅក្នុងពេលឆ្នាំ១៩៩២-២០០៨ អត្រាកំណើតមនុស្សទូទៅទាំងប្រទេសមានកម្រិតត្រឹមតែ ៣,១% ប៉ុណ្ណោះ ក៏ប៉ុន្តែអត្រាកំណើននៅក្នុងឧទ្យានបូករួមជាមួយការហូរចូល

ការដង្ហែរពិធីបុណ្យទានតាមប្រពៃណីសាសនា នៅតែបន្តរហូតដល់បច្ចុប្បន្ននៅអង្គរវត្ត

© យូន យុននាយ

គោលការណ៍នៃការអភិវឌ្ឍដោយផ្អែកលើសហគមន៍ តម្រូវឲ្យសហគមន៍មូលដ្ឋានចូលរួមសហការក្នុងការចាត់ចែងផែនការគ្រប់គ្រងឲ្យបានគ្រប់ដំណាក់កាលរហូតដល់ការអនុវត្តទៀតផង

នៃប្រជាជនថ្មីឡើងដល់ទៅ៩,៥០%។ ហើយតាំងតែពីឆ្នាំ១៩៩២ទៀត ចំនួនប្រជាពលរដ្ឋក៏រឹតតែឡើងទៀតដូចមានតួលេខបង្ហាញខាងក្រោមនេះ ៖

- ស្ថិតិធ្វើដោយអង្គការសហប្រជាជាតិឆ្នាំ ១៩៩២ : ២២ ០០០ នាក់
- ស្ថិតិជាតិឆ្នាំ១៩៩៨ : ៨៤ ០០០ នាក់
- ស្ថិតិអាជ្ញាធរជាតិអប្សរាឆ្នាំ២០០៥ : ១០០ ០០០ នាក់(១៨ ៥០០ គ្រួសារ)
- ការប៉ាន់ស្មានឆ្នាំ២០១០ : ១២០ ០០០នាក់ (២១ ៥០០ គ្រួសារ)។

គ្រួសារនីមួយៗមានដីធ្លីជាមធ្យមចំនួន១ហិកតា។ ផលស្រូវដែលធ្វើបានមិនគ្រប់គ្រាន់ទេ ជាពិសេសនៅខែកញ្ញានិងតុលា។

ប្រជាពលរដ្ឋប្រកបមុខរបរជាចម្បងដូចតទៅ៖

- ការរកអុស(២៧%)
- ការធ្វើស្រែ(២០%)
- ការងារផ្សេងៗ(៣៦%) ក្នុងនោះមានធ្វើជាឆ្មាំប្រាសាទ កម្មករក្នុងផ្ទៃអាជ្ញាធរជាតិអប្សរា
- ការងារគ្មានជំនាញ(១៧%)

ប្រជាជនភាគច្រើនដាច់ខាត(៦០%) ជាអ្នកក្រីក្រ។ ការសិក្សាស្រាវជ្រាវមួយពីឆ្នាំ២០០៧ បានបង្ហាញថាប្រាក់ចំណូលមធ្យមក្នុងមួយខែសម្រាប់ម្នាក់ៗ មានត្រឹមតែ២០-៣០$ តែប៉ុណ្ណោះ។

ភូមិធម្មជាតិរុនតាឯក

ដើម្បីកាត់បន្ថយសម្ពាធនៃកំណើនប្រជាពលរដ្ឋក្នុងឧទ្យានអង្គរនិងដើម្បីថែរក្សាទេសភាពវប្បធម៌នៃឧទ្យានអង្គររាជរដ្ឋាភិបាលបានខិតខំធ្វើយ៉ាងណាឲ្យចំនួនប្រជានស្ថិតនៅដដែលឬយ៉ាងហោចណាស់ក៏បន្ថយជាអតិបរមានៃកំណើនដោយហាមឃាត់មិនឲ្យមានការលក់ដូរដីធ្លីឲ្យទៅអ្នកមកពីក្រៅ ហើយបញ្ញត្តិមិនឲ្យសាងសង់ផ្ទះថ្មីបន្ថែម។ នេះមិនមែនជាការងារស្រួលនោះទេព្រោះកូនប្រជាជននឹងធំពេញវ័យហើយត្រូវរៀបការប្តីប្រពន្ធនិងមានកូនចៅជាបន្ត ដូច្នោះនឹងតម្រូវឲ្យមានផ្ទះសម្បែងរស់នៅបែកពីឪពុកម្តាយ។ ដំណោះស្រាយមួយដែលបានកំណត់យក គឺអញ្ជើញឲ្យគ្រួសារថ្មីថ្មោងទាំងនោះទៅតាំងទីនៅក្រៅតំបន់ការពារនៃឧទ្យានអង្គរតាមការស្ម័គ្រចិត្តឥតមានបង្ខិតបង្ខំអ្វីទេ។ អាជ្ញាធរជាតិអប្សរាបានទិញដីមួយកន្លែងទំហំ១ ០១២

ហិកតា ដែលស្ថិតនៅក្នុងឃុំរុនតាឯក ខាងក្រៅតំបន់ការពារចម្ងាយត្រឹមតែប្រមាណកន្លះម៉ោងពីក្រុងសៀមរាបតាមផ្លូវជាតិនិងផ្លូវខេត្ត។ ភូមិថ្មីនេះត្រូវបានរៀបចំឡើងយ៉ាងផ្ចិតផ្ចង់ ដើម្បីឲ្យអ្នកភូមិអាចថែរក្សាស្ថានភាពជីវភាពដដែលដោយមានសកម្មភាពសេដ្ឋកិច្ចដូចដើម។ ហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ សេដ្ឋកិច្ច (វិធីសម្រាប់ផលិតកម្ម ប្រឡាយទឹកស្រោចស្រព មីក្រូក្រេឌីត....)និងសង្គមកិច្ច (សាលារៀន ស្ថាប័នអប់រំវិជ្ជាជីវៈ វត្តអារាម) ត្រូវបានបង្កើតមួយចំនួនរួចហើយនិងត្រូវបំពេញបន្ថែមទៀត។ ផែនការរៀបចំភូមិធ្វើទៅតាមមូលដ្ឋានបរិស្ថានដូចជាការប្រើប្រាស់ថាមពលព្រះអាទិត្យ រហាត់ខ្យល់សម្រាប់បូមទឹក កសិកម្មនិងទេសចរណ៍ធម្មជាតិ។ ហេតុដូច្នេះហើយបានជាត្រូវបានដាក់ឈ្មោះថា ភូមិធម្មជាតិរុនតាឯក នោះ។

លំនៅឋានត្រូវបានរៀបចំជាចង្កោមនៅជុំវិញបឹងធម្មជាតិតូចៗចំនួន៥។ ភូមិរុនតាឯកទាំងមូលអាចទទួល៨៥០គ្រួសារ គឺប្រមាណប្រជាជន៥ ០០០នាក់។ គ្រួសារនីមួយៗទទួលបានដីមួយហិកតាសម្រាប់សាងសង់ផ្ទះសម្បែងនិងសម្រាប់កសិកម្ម។នាពេលបច្ចុប្បន្ននេះគ្រួសារចំនួន៩០ បានតាំងទីរស់នៅរួចហើយ។ អគារសិក្សាមួយខ្នងមាន៥បន្ទប់ ត្រូវបានសាងសង់រួចរាល់ហើយ។ រីឯស្ថានីយកសិកម្មទៀតសោតក៏បានដំណើរការដែរ ដោយបានជ្រើសរើសយកអ្នកភូមិថ្មីៗនេះឲ្យធ្វើការដោយបានផ្តល់ជាប្រាក់បៀវត្សនិងការហ្វឹកហ្វឺនខាងកសិកម្មធម្មជាតិទៀតផង។

ការគ្រប់គ្រងលំនៅឋាន

លក្ខណៈមួយដែលពិសេសនៃជីវភាពប្រជាជននៅក្នុងតំបន់អង្គរគឺរចនាបែបបទបុរាណនៃផ្ទះសម្បែងដែលត្រូវតែរក្សាទុកឲ្យបានគង់វង្សតទៅ។ អាជ្ញាធរជាតិអប្សរាបានរៀបចំឲ្យមានអង្គភាព ពិសេសមួយក្នុងផ្នែនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅឋានដើម្បីធ្វើការពិគ្រោះណែនាំសហគមន៍ព្រមទាំងវត្តអារាម ក្នុងការជួសជុលសាងសង់ផ្ទះសម្បែងនិងអគារសាសនាដោយមិនមានតម្រូវឲ្យបង់ថ្លៃសេវាកម្មអ្វីទាំងអស់។ អង្គភាពនេះបានធ្វើការសិក្សាលំអិតពីបច្ចេកទេសសាងសង់បែបបុរាណខ្មែរហើយដាក់ជូនសហគមន៍ប្រើប្រាស់ជាលំនាំ។ ក្រដាសផ្ទត់ចំនួន៤ បែបស្តីពីគោលការណ៍សំណង់ក្នុងឧទ្យានអង្គរក៏ត្រូវបានតាក់តែងឡើង ហើយបោះពុម្ពផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងតំបន់ការពារទី១និងទី២នៃឧទ្យានអង្គរទៀត។

ការសាងសង់មណ្ឌលលំនៅឋានខ្មែរមានគោលបំណងពីរយ៉ាង។ ទី១ មណ្ឌលនេះ ដែលមានទីតាំងនៅក្នុងភូមិរហាល ត្រង់ផ្លូវកែងដែលនាំទៅប្រាសាទធំៗនេះជាការសម្រួលដល់ទេសចរអន្តរជាតិឲ្យអាចបានចូលទស្សនានិងបានយល់ដឹងពីលំនៅឋានប្រជាជនដែលជាលក្ខណៈពិសេសនៃទេសភាពវប្បធម៌។ ទី២ គឺដើម្បីបង្ហាញដល់សហគមន៍ពីការរៀបចំទីលានភូមិឋានមានសួនដំណាំនិងការធ្វើជីកំប៉ុស្តដើម្បីលើកតម្កើងជីវភាព។

ទេសចរចូលចិត្តជិះរទេះគោកម្សាន្តក្នុងឧទ្យានអង្គរ

© យូន យុននាយ

ការចូលរួមពីសហគមន៍

មានគម្រោងជាច្រើន ដែលកំណត់ឲ្យមានការបង្កើនសមត្ថភាពរបស់សហគមន៍ឲ្យអាចចូលរួមជាសកម្មក្នុងការអភិវឌ្ឍប្រកបដោយចីរភាព លើកតម្កើងជីវភាពប្រជាជនផងនិងថែរក្សាឧទ្យានអង្គរផង។

មុនដំបូងមានគម្រោងមួយដែលមានឈ្មោះថា " ការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីប្រជាពលរដ្ឋនិងការលើកកម្រិតជីវភាពគ្រួសារ" ដែលរៀបចំឡើងដោយអាជ្ញាធរជាតិអប្សរា ដោយមានសហការណ៍ពីប្រទេសញូវហ្សឺឡែន។ គម្រោងនេះចង់ធានាឲ្យមានសមភាពក្នុងការទទួលផលពីឧទ្យាន ហើយផ្តល់ឱកាសឲ្យសហគមន៍មានលទ្ធភាពរកការងារប្រកបជីវភាពដោយមានបើកវគ្គហ្វឹកហ្វឺនអំពីមុខរបរដែលទាក់ទងនឹងទេសចរណ៍វប្បធម៌មានសិប្បកម្ម កសិកម្មជាដើម ដោយធ្វើយ៉ាងណាឲ្យប្រជាជនទាក់ទងផ្ទាល់ជាមួយអតិថិជនកាត់បន្ថយឈ្មួញកណ្តាល។

ម្យ៉ាងទៀតអាជ្ញាធរជាតិអប្សរាបានសហការជាមួយអង្គការដាណឺមាក់ ADDA ដើម្បីអនុវត្តគម្រោងសន្តិសុខស្បៀងនៅជុំវិញក្រុងសៀមរាបក្នុងភូមិចំនួន៣០ ដែលក្នុងនោះមានភូមិ២០ស្ថិតនៅក្នុងតំបន់ការពារឧទ្យានអង្គរ។ គម្រោងនេះបានចាប់ផ្តើមពីខែមីនា ឆ្នាំ២០១១ រហូតដល់ខែសីហា ឆ្នាំ២០១៤ ហើយមានគោលដៅលើកកម្ពស់ជីវភាពនិងជាពិសេសក្នុងវិស័យស្បៀងនិងមុខរបរ។

ទីបញ្ចប់អាជ្ញាធរជាតិអប្សរាបានសហការជាមួយអង្គការជប៉ុនមួយឈ្មោះ NFUAJ ក្នុងការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ដើម្បីពង្រីកវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈនិងអប់រំក្រៅប្រព័ន្ធ។

គ្រប់គ្រងឧទ្យានអង្គរដែលមានទំហំធំធេងដូចអង្គរនេះ ជាកិច្ចការពិបាកខ្លាំងណាស់ជាពិសេសចំពោះប្រទេសកម្ពុជាដែលទើបនឹងបានឆ្លងកាត់របបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩)និងអសន្តិសុខតំបន់ក្នុងរយៈជាច្រើនសិបឆ្នាំនេះដែលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងធនធានមនុស្សព្រមទាំងរចនាបទសង្គមទាំងមូល។

ការដែលឧទ្យានអង្គរស្ថិតនៅជាប់នឹងក្រុងសៀមរាបដែលកំពុងតែអភិវឌ្ឍរីករាលពេញទំហឹងបែបនេះបង្កើតជាបញ្ហាសង្គមនិងប្រជាសាស្ត្របន្ថែមទៅទៀតដល់ការគ្រប់គ្រងឧទ្យានអង្គរ។

ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី អាជ្ញាធរអប្សរានិងភាគីពាក់ព័ន្ធទាំងអស់មានអាជ្ញាធរមូលដ្ឋាននិងជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរត្រូវបន្តនិងពង្រឹងសហការឲ្យបានជិតស្និតដើម្បីគ្រប់គ្រងឧទ្យានអង្គរឲ្យបានគង់វង្សតរៀងទៅសម្រាប់ជំនាន់ក្រោយៗទៀតជាមរតកជាតិនិងពិភពលោក។

កិច្ចប្រជុំពេញអង្គលើកទី ៣៧
នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

រូបថតអនុស្សាវរីយ៍រវាងសម្តេចតេជោ ហ៊ុន សែន ជាមួយថ្នាក់ដឹកនាំនិងប្រតិភូរដ្ឋសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

© ទីស្តីការគណៈរដ្ឋមន្ត្រី

សម្តេចតេជោ ហ៊ុន សែន ជាមួយឥស្សរជនជាន់ខ្ពស់ក្នុងពិធីបើកកិច្ចប្រជុំជាផ្លូវការ

© ទីស្តីការគណៈរដ្ឋមន្ត្រី

រូបគំនូរនៅលើជញ្ជាំងវត្តបាគង

លោកជំទាវ ចៅសុន គិរិយា ទីប្រឹក្សាអាជ្ញាធរអប្សរា
និងលោក វិត្តូរីយ៉ូ រ៉ូវេដា អ្នកជំនាញផ្នែករូបគំនូរព្រះពុទ្ធសាសនានៅកម្ពុជា
និងជាអ្នកស្រាវជ្រាវផ្នែកសិល្បៈនិងបុរាណវិទ្យានៃស្ថាប័ន SOAS សាកលវិទ្យាល័យឡុងដុង



វត្តបាគងស្ថិតនៅជិតប្រាសាទបាគងដែលត្រូវបានកសាងឡើងនៅសតវត្សទី៩

© ចៅសុន គិរិយា



រូបគំនូរព្រះពុទ្ធនិងព្រះសង្ឃដង្ហែព្រះអង្គត្រឡប់ទៅកាន់ក្រុង កបិលវត្ថុ - មុនជួសជុល

© ចៅសុន គិរិយា

យ៉ាងតិចប្រហែលជាចាប់ពីសតវត្សទី១៦មកវត្តបាគងគឺជាវត្តព្រះពុទ្ធសាសនាមួយដ៏សកម្មដែលដំបូងឡើងត្រូវបានកសាងឡើងអំពីឈើនៅក្នុងបរិវេណប្រាសាទបាគងក្នុងសម័យអង្គរ។ ប្រាសាទបាគងត្រូវបានកសាងឡើងនៅសតវត្សទី៩ក្នុងភូមិរលួសចម្ងាយ ១៦គីឡូម៉ែត្រខាងកើតសៀមរាប។ នៅឆ្នាំ១៩៣៨ ដើម្បីជួយសម្រួលឲ្យសាលាបារាំងចុងបូព៌ាប្រទេសជួសជុលប្រាសាទបាគង វត្តបាគងក៏ត្រូវបានផ្លាស់ទីនិងសាងសង់អំពីថ្មមានដំបូលប្រក់ក្បឿងនៅខាងជើងប្រាសាទ។ បន្ទាប់មកគេបានពង្រីកវត្តនេះជាច្រើនដងមានគំនូរលំអយ៉ាងស្មុគស្មាញនៅលើជញ្ជាំងនិងពិដាន។

ការស្រាវជ្រាវបានបង្ហាញថា គំនូរលើជញ្ជាំងត្រូវបានគូរក្នុងទសវត្សឆ្នាំ១៩២០ ដោយជាងគំនូរម្នាក់ឈ្មោះ សំ ឈុន រួមជាមួយគ្រួសាររបស់លោកនិងជំនួយការជាច្រើនផ្សេងទៀតរបស់លោក។ រូបគំនូរទាំងនោះមិនធ្លាប់បានគេជួសជុល ឬគូរឡើងវិញឡើយ ហើយបានជៀសផុតពីការបំផ្លិចបំផ្លាញរបស់ពួកខ្មែរក្រហម។ រូបទាំងនោះក៏មិនត្រូវបានជំនួសដោយរូបផ្សេងដែរ។ នៅប្រទេសកម្ពុជាគេតែងឃើញញឹកញាប់នូវការជំនួសរូបចាស់ដោយរូបថ្មី។

ភាគច្រើននៃរូបគំនូរលើជញ្ជាំងទាំងនេះរៀបរាប់អំពីជីវិតរបស់ព្រះពុទ្ធ ដូចដែលមាននៅក្នុងសាច់រឿងជាតក ដូចនៅក្នុងវត្តខ្មែរផ្សេងទៀតដែរ ប៉ុន្តែគំនូរនៅវត្តបាគងមានលក្ខណៈច្បាស់ៗនិងស៊ីចង្វាក់គ្នាយ៉ាងអស្ចារ្យបំផុត

ភាគច្រើននៃរូបគំនូរលើជញ្ជាំងទាំងនេះរៀបរាប់អំពីជីវិតរបស់ព្រះពុទ្ធដូចដែលមាននៅក្នុងសាច់រឿងជាតក ដូចនៅក្នុងវត្តខ្មែរផ្សេងទៀតដែរប៉ុន្តែគំនូរនៅវត្តបាគងមានលក្ខណៈច្បាស់ៗនិងស៊ីចង្វាក់គ្នាយ៉ាងអស្ចារ្យបំផុត។ រូបគំនូរខ្លះគឺជារូបទេសភាពនៅក្នុងស្រុក រៀបរាប់អំពីជីវិតនិងព្រឹត្តិការណ៍ប្រចាំថ្ងៃព្រមទាំងមានរូបគំនូរយន្តហោះទៀតផង ប្រហែលជាវាតំណាងឲ្យយន្តហោះចម្បាំងអាមេរិកកាំងក៏មិនដឹងគេថែមទាំងឃើញមានរូបគំនូរចម្បាំងនៅលើអាកាសនិងកងទ័ពកាន់កាំភ្លើងវែងខ្វីជាដើម។ រូបគំនូរលើជញ្ជាំងដែលបង្ហាញនូវឥទ្ធិពលស្ទីលសិល្បៈបច្ចិមប្រទេសនិងអ៊ីស្លាម ត្រូវបានកសាងឡើងជាពីរជួរក្នុងនោះមានទាំងរូបសត្វត្រុឌទៀតផងនៅជួរខាងក្រោម។ នៅលើជញ្ជាំងខាងក្រោយអាសនៈរូបសត្វត្រុឌត្រូវបានជំនួសដោយមនុស្សដែលមានសក់និងពុកមាត់បែបមនុស្សមកពីខាងបច្ចិមចំណែកឯនៅលើពិដានមានរូបគំនូរប្រចៀវជាច្រើនដែលជាលក្ខណៈធម្មជាតិនៃជីវិតក្នុងខេត្តសៀមរាប។

រូបគំនូរចំនួន៣ផ្ទាំងត្រូវបានជ្រើសរើសយកមកពិនិត្យលំអិតនៅក្នុងអត្ថបទនេះ៖

ព្រះពុទ្ធនិងព្រះសង្ឃដង្ហែព្រះអង្គទៅកាន់ក្រុង កបិលវត្ថុ

នៅលើផ្ទាំងនេះមានរូបគំនូរព្រះសង្ឃមួយជួរដឹកនាំដោយព្រះគ្រូធំមួយព្រះអង្គ គឺព្រះពុទ្ធ។ ព្រះសង្ឃទាំងអស់និមន្តសំដៅទៅពួកអភិជនមួយក្រុម ប្រហែលជាស្តេច សុទ្ធោទននិងព្រះអគ្គមហេសីព្រះអង្គព្រះនាមសិរិមហាមាយាដែលកំពុងសោយរាជ្យនៅក្នុងព្រះបរមរាជវាំងដូចដែលមានរៀបរាប់នៅក្នុងអក្សរចារឹកនៅពីក្រោម "(...) ព្រះពុទ្ធ "..." ទៅលេងព្រះបិតារបស់ព្រះអង្គនៅ កបិលវត្ថុ "និងរៀបរាប់បន្ថែមថាគំនូរជញ្ជាំងនេះគឺអ្នកភូមិក្អែកជាអ្នកឲ្យកសាង។

ព្រះពុទ្ធបានត្រឡប់ទៅស្រុកកំណើតរបស់ព្រះអង្គវិញនៅ កបិលវត្ថុ បន្ទាប់ពីអវត្តមានរយៈពេល៧ឆ្នាំ។ ព្រះអង្គ សុទ្ធោទន បានផ្ញើសំបុត្រអញ្ជើញមួយ ទៅបុត្រារបស់ព្រះអង្គតាមរយៈអ្នករត់សំបុត្រម្នាក់។ ព្រះពុទ្ធបានយល់ព្រមត្រឡប់ទៅ កបិលវត្ថុ ដោយធ្វើដំណើរតាមផ្លូវដ៏វែងឆ្ងាយមួយតាំងពីក្រុងរាជគ្រឹះមក។ អត្ថបទប្រវត្តិរូបសង្ខេបរបស់ព្រះពុទ្ធរៀបរាប់ថា យោងតាមប្រវត្តិសាស្ត្រ ព្រះមហាក្សត្រនៅតែមានការសោកស្តាយយ៉ាងខ្លាំងដែលបុត្រារបស់ព្រះអង្គបានយាងចាកចេញពីព្រះអង្គកាលពី៧ឆ្នាំមុន។ ព្រះមហាក្សត្រក៏ព្រួយព្រះទ័យដែរដោយដឹងថា មានព្រះសង្ឃបិណ្ឌបាតនៅក្នុងរាជបុរីរបស់ព្រះអង្គ ហើយព្រះសង្ឃមួយអង្គក្នុងចំណោមព្រះសង្ឃទាំងអស់ អាចជាបុត្រារបស់ព្រះអង្គទៀតផង។ អ្នករត់សំបុត្រនិងជាមិត្តដ៏ស្មោះស្ម័គ្រម្នាក់របស់ព្រះអង្គឈ្មោះ ឧទ័យិន បានពន្យល់ព្រះអង្គថា នោះគឺជាមហាព្រះកិត្តិយសដ៏ធំធេងណាស់ដែលព្រះអង្គ គឺជាព្រះបិតារបស់ព្រះសង្ឃប្រកបដោយគតិបណ្ឌិតបែបនេះ។ ស្តេចផែនដី ព្រះបាទ សុទ្ធោទន ក៏បានយល់ស្របហើយបានរៀបចំពិធីមួយយ៉ាងគគ្រឹកគគ្រេង ទទួលស្វាគមន៍នូវការវិលត្រឡប់មកវិញរបស់ព្រះពុទ្ធ។ ព្រះគ្រូធំដឹងថា ព្រះអង្គត្រូវគោរពតាមពិធីការមួយចំនួនដើម្បីបានចូលគាល់ព្រះរាជបិតារបស់ព្រះអង្គ ដែលជាព្រះមហាក្សត្រ។ ព្រះអង្គមិនអាចនៅខ្ពស់ជាងមន្ត្រីវាំងផ្សេងទៀតបានទេ ប៉ុន្តែព្រះអង្គក៏មិនអាចឱនឲ្យទាបជាងគេបានដែរ ពីព្រោះព្រះអង្គជាក្សត្រមានគតិបណ្ឌិត។ ព្រះអង្គបានដោះស្រាយបញ្ហានេះដោយគង់ប្រថាប់យ៉ាងសង្ហានៅលើ

រាទមួយខ្ពស់ជាប្រជារាស្ត្រទាំងអស់។ ព្រះមហាក្សត្រ សុទ្ធោទន បានសព្វព្រះរាជហឫទ័យនិងស្រឡាញ់បុត្រារបស់ព្រះអង្គយ៉ាងខ្លាំងជាទីបំផុត។

សុបិនរបស់ព្រះសិរិមហាមាយា

ព្រះបិតានិងព្រះមាតារបស់ព្រះពុទ្ធ គឺព្រះមហាក្សត្រ សុទ្ធោទន និងព្រះមហេសី ព្រះសិរិមហាមាយា។ ព្រះមហាក្សត្រគឺជារាជវង្ស គោតម ព្រះរាជាបក្សសម្ព័ន្ធសាក្យៈសោយរាជសម្បត្តិនៅនគរ កបិលវាស្តុ ក្នុងប្រទេសនេប៉ាល់បច្ចុប្បន្ន។ ព្រះមហាក្សត្រនិងព្រះអគ្គមហេសីចង់បានបុត្រាមួយអង្គ ហើយនៅរាត្រីមួយនោះ ព្រះមហេសី មាយា បានសុបិន្តថាមានដំរីសមួយក្បាលបានចូលទៅចាប់កំណើតក្នុងផ្ទៃរបស់ព្រះអង្គ។ នៅថ្ងៃបន្ទាប់ ព្រាហ្មណ៍៦៤រូប បានជានាប្រាប់ព្រះអង្គថា បុត្រាមួយអង្គបានចាប់កំណើតហើយ ហើយព្រះអង្គនឹងក្លាយជាព្រះមហាក្សត្រនៃភពទាំងមូល (ចក្រពត្តិ) ឬព្រះពុទ្ធ។

ការថ្វាយស្បូវនិងការត្រាស់ដឹង

ដោយគង់នៅតែព្រះអង្គឯងបន្ទាប់ពីបានសម្រាកមួយថ្ងៃនៅក្នុងព្រៃប្រឹក្សា ព្រះសិទ្ធត្ថ បានយាងទៅគង់ក្រោមដើមពោធិព្រឹក្សមួយ។ ស្តេចនាគ មហាកលា បានឮសំរិបព្រះបាទព្រះអង្គ ហើយក៏បានទូលថ្វាយព្រះអង្គថា ព្រះអង្គនឹងក្លាយជាព្រះពុទ្ធដោយគ្មានការសង្ស័យឡើយ។ បន្ទាប់មក ព្រះអង្គបានជួបព្រាហ្មណ៍ម្នាក់ដែលកំពុងកាត់ស្បូវសម្រាប់ប្រារព្ធពិធីវេទ។ ព្រាហ្មណ៍រូបនោះបានថ្វាយស្បូវទៅព្រះសិទ្ធត្ថ។ ព្រះអង្គបានក្រាលស្បូវនៅក្រោមដើមពោធិ៍ធ្វើជាកម្រាលគង់ពែនភ្នែនពីលើ ដែលជាឥរិយាបទមួយដ៏ល្អបំផុតសម្រាប់ទប់លំនឹងព្រះកាយ។ ព្រះអង្គបានបែរព្រះភក្ត្រទៅទិសបូព៌ា ហើយបានសម្រេចព្រះទ័យថាគង់នៅលើ "រតនបល្ល័ង្ក" ជាស្បូវនេះមិនកំរើករហូតដល់ព្រះអង្គសម្រេចព្រះរាជបំណងរបស់ព្រះអង្គគឺបានត្រាស់ដឹង។ មានរឿងខ្លះរៀបរាប់ថា ព្រះអង្គបានគង់នៅលើរតនបល្ល័ង្កដែលបានផុសចេញពីដី។ ព្រះឥន្ទ ព្រាហ្មណ៍ និងព្រះជាច្រើនទៀតបានថ្វាយអំណោយនិងសម្តែងការអបអរចំពោះព្រះអង្គ។ ពួកគេបានអបអរព្រះអង្គដោយប្រគំតន្ត្រីស្ងួតមួយយ៉ាងពីរោះរណ្តំ។

ការជួសជុលវត្តបាគងនិងគំនូរលើជញ្ជាំង

ការងារជួសជុលបានទទួលជំនួយហិរញ្ញប្បទានពីក្រុមហ៊ុន ហូលស៊ីមនិងត្រូតពិនិត្យដោយអង្គការ អ្នកជួសជុលគ្មានព្រំដែន រួមជាមួយនឹងអាជ្ញាធរអប្សរា សាកលវិទ្យាល័យភូមិន្ទវិចិត្រ

រូបគំនូរបង្ហាញពីការប្រយុទ្ធគ្នានៅលើអាកាសកំឡុងពេលសង្គ្រាមលោកលើកទី២

© ចៅសុខ គិរិយា

សិល្បៈនិងព្រះសង្ឃមួយអង្គនៅវត្តបាគង។ ការងារស្ថាបត្យកម្មនិងវិស្វកម្មសំខាន់ៗបានធ្វើរួចរាល់នៅឆ្នាំ២០១០ ខណៈដែលការងារជួសជុលគំនូរលើជញ្ជាំងនៅបន្តរហូតដល់ពេលបច្ចុប្បន្ននេះ។ វត្តត្រូវបានបើកទ្វារឡើងវិញនៅឆ្នាំ២០១១ បន្ទាប់ពីត្រូវបានសម្ពោធបើកឲ្យប្រើប្រាស់ក្រោមអធិបតីភាពរបស់ឧបនាយករដ្ឋមន្ត្រី ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ក្នុងនាមជាប្រធានអាជ្ញាធរអប្សរា។

ដោយសារវត្តស្ថិតនៅក្នុងតំបន់១នៃឧទ្យានអង្គរ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គេត្រូវធ្វើការប្រុងប្រយ័ត្នជាពិសេសមុនពេលមុនជួសជុលនិងក្នុងពេលជួសជុលជាអាទិ៍ ត្រូវធ្វើកិច្ចការលើរូបគំនូរ បុរាណវិទ្យាបង្កា ការស្រាវជ្រាវនិងកំណាយផ្សេងៗ។ វាក៏សំខាន់ដែរដែលត្រូវគោរពតាមជំនឿសាសនាខ្មែរបុរាណ។ ដូច្នេះ ពិធីសាសនាមួយត្រូវបានរៀបចំឡើងដោយបាននិមន្តព្រះសង្ឃនិងអញ្ជើញប្រជាជនមកចូលរួម ដើម្បីសុំការអនុញ្ញាតអំពីព្រលឹងដែលថែរក្សាទឹកដីជាទីសក្ការៈនៅក្នុងវត្ត។

ភាគច្រើននៃដំបូលគ្រឹះជញ្ជាំងនិងសសរវត្តបាគង ត្រូវបានកសាងឡើងវិញជាចាំបាច់ដោយសាររាំមានសភាពទ្រុឌទ្រោមខ្លាំងពេកដែលគំរាមកំហែងដល់រូបគំនូរដ៏ល្អៗ នៅតាមជញ្ជាំង។ គំនូរទាំងនោះត្រូវបានដោះចេញនិងជួសជុលឡើងវិញ។ ផ្ទាំងគំនូរនីមួយៗត្រូវបានពិនិត្យ លាងសំអាតយ៉ាងផ្ចិតផ្ចង់និងជួសជុល ឬគូរបំពេញបន្ថែមប្រសិនបើចាំបាច់មុននឹងបិទទៅនឹងជញ្ជាំងវិញ។ ពិដានក៏ត្រូវបានជួសជុលដូចគ្នាដែរ ប៉ុន្តែគឺជួសជុលផ្ទាល់តែម្តង។

កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់អាជ្ញាធរអប្សរា និងក្រុមហ៊ុន ហូលស៊ីម មិនត្រឹមតែសំដៅទៅស្រោចស្រង់វត្តអំពីការខូចខាតនិងផ្តល់ជីវិតឡើងវិញដល់គំនូរជញ្ជាំងទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ធ្វើឲ្យវត្តមានមុខងារឡើងវិញសម្រាប់សហគមន៍ក្នុងស្រុក សម្រាប់ព្រះសង្ឃនិងមនុស្សជំនាន់ក្រោយៗទៀត។

គំរូនៃកិច្ចសហប្រតិបត្តិការនេះការយោគយល់គ្នារវាងអ្នកស្រុកនិងអង្គការអន្តរជាតិ គឺជាកញ្ចក់សម្រាប់បង្ហាញដល់អនាគតអ្នកទេសចរនិងអ្នកស្នេហាសិល្បៈ អ្នកស្នេហាស្ថាបត្យកម្មបុរាណ អ្នកដែលចាប់អារម្មណ៍ទៅលើការងារ ជួសជុលក្នុងតំបន់បេតិកភណ្ឌដែលមានមនុស្សរស់នៅ ឬអ្នកដែលចង់ឃើញទីសក្ការៈនិងកន្លែងគោរពសាសនាមានជីវិតរស់ឡើងវិញសម្រាប់ជាប្រយោជន៍ដល់សហគមន៍ដែលជាញឹកញាប់តែងចែករំលែកទីកន្លែងសាសនាជាមួយទេសចរដែលមកកម្សាន្តនៅទីកន្លែងទាំងនោះ។

ផ្ទាំងគំនូរ ព្រះពោធិសត្វ(ខាងឆ្វេង)និងសុបិន្តរបស់ព្រះសិរិមហាមាយា(នៅខាងស្តាំ)មុននិងក្រោយការជួសជុល

© ចៅសុខ គិរិយា

កិច្ចប្រជុំពេញអង្គលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

ការថ្លែងសុន្ទរកថាបើកកិច្ចប្រជុំជាផ្លូវការ

សម្តេចតេជោ ហ៊ុន សែន

© ទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តមបណ្ឌិត សុខ អាន

© ទីស្តីការគណៈរដ្ឋមន្ត្រី



លោកជំទាវ អ៊ីរីណា បូកូវ៉ា

© ទីស្តីការគណៈរដ្ឋមន្ត្រី

លោកជំទាវ អាឡិចសាន់ដ្រា គូមីស

© ទីស្តីការគណៈរដ្ឋមន្ត្រី

ប្រាសាទតាព្រហ្ម

លោក ឌីអេស ស៊ូដ D.S. Sood
មេការរងនិងវិស្វករបុរាណវិទ្យានៃក្រុមការងារបុរាណវិទ្យាឥណ្ឌា (ASI)
មេការគម្រោងជួសជុលប្រាសាទតាព្រហ្ម



ប្រាសាទតាព្រហ្ម

© Lin Mei



ឫសដើមឈើបានចាក់ចូលទៅក្នុងគ្រោងប្រាសាទ

© Lin Mei

ប្រាសាទតាព្រហ្មត្រូវបានគេស្គាល់ច្រើនថាជាប្រាសាទដើមឈើ ស្ថិតនៅក្នុងព្រៃនិងមានកសិណទឹកព័ទ្ធជុំវិញពីរជាន់

គម្រោងជួសជុលប្រាសាទតាព្រហ្មត្រូវបានចាប់ផ្តើមអនុវត្តជាផ្លូវការដោយក្រុមការងារបុរាណវិទ្យាឥណ្ឌា ហៅកាត់ជាភាសាអង់គ្លេសថា ASI នៅខែកុម្ភៈ ឆ្នាំ២០០៤ ក្នុងគោលបំណងលើកតម្លៃយថាភាពបុរាណភាពនិងការអភិរក្សលក្ខណៈចម្រុះដ៏ល្អឯកនៃដើមឈើនិងសំណង់ថ្មនៅប្រាសាទតាព្រហ្មក្នុងឧទ្យានអង្គរព្រមទាំងរក្សាកេរដំណែលនេះទុកជូនមនុស្សជំនាន់ក្រោយៗ ប្រាសាទតាព្រហ្មត្រូវបានគេស្គាល់ច្រើនថាជាប្រាសាទដើមឈើស្ថិតនៅក្នុងព្រៃនិងមានកសិណទឹកព័ទ្ធជុំវិញពីរជាន់ៗ ដើមឈើជាច្រើនដុះនៅខាងក្នុងប្រាសាទនិងខាងលើកំពូលប្រាសាទមានឫសចាក់ចូលទៅដល់ក្នុងគ្រឹះនិងជ្រៀតចូលតាមជញ្ជាំងធ្វើឲ្យថ្មប្រេះឃ្លាតពីគ្នារចនាសម្ព័ន្ធប្រាសាទទ្រុឌទ្រោមៗ

រក្សាបុរាណភាពនិងយថាភូតភាពឲ្យបានច្រើនបំផុត

ការអភិរក្សប្រាសាទតាព្រហ្មពិតជាមានភាពស្មុគស្មាញដោយសារបរិស្ថានជុំវិញនិងលក្ខណៈសំណង់នៃប្រាសាទនេះៗ ការជួសជុលប្រាសាទតាព្រហ្មត្រូវប្រើវិធីសាស្ត្រពហុជំនាញដែលមានការចូលរួមពីស្ថាប័នជំនាញនៅក្នុងវិស័យផ្សេងៗជាច្រើនដូចជាវិទ្យាស្ថានឥណ្ឌាស្រាវជ្រាវអំពីព្រៃឈើ ហៅកាត់ថា FRI ជាអ្នកទទួលបន្ទុកការងារអភិរក្សនិងថែទាំដើមឈើក្រុមហ៊ុនជំនាញផ្នែកទឹកនិងថាមពល ហៅកាត់ថា Wapcos ជាអ្នកទទួលបន្ទុកការងារសិក្សាអំពីទឹក វិទ្យាស្ថានឥណ្ឌាផ្នែកបច្ចេកវិទ្យា ហៅកាត់ថា IIT ជាអ្នកទទួលបន្ទុកការងាររចនាសម្ព័ន្ធនិងក្រុមហ៊ុន Larsen & Tubro ហៅកាត់ថា L&T ទទួលបន្ទុកផ្គត់ផ្គង់សម្ភារៈជំនាញនិងរន្ទាៗ ដើម្បីការពារបូរណភាពនិងយថាភាពនៃប្រាសាទ ស្ថាប័ន ASI បានសម្រេចប្រើបច្ចេកទេសរុះរើនិងរៀបថ្មឡើងវិញដូច្នេះ ក៏បានកត់ត្រាយ៉ាងលំអិតអំពីថ្មនីមួយៗត្រង់ផ្នែកដែលត្រូវជួសជុលៗ

ទ្រនល់ទល់ទ្របណ្តោះអាសន្នត្រូវបានដាក់ដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរក៏ដូចជារក្សាលំនឹងថ្មនិងដើមឈើនៅត្រង់កន្លែងណាដែលរចនាសម្ព័ន្ធមានសភាពទ្រុឌទ្រោមអាចនឹងបាក់ធ្លាក់ចុះមកក្រោមៗ នៅពេលដែលអាចធ្វើទៅបានថ្មដើមត្រូវបានយកមកប្រើឡើងវិញ ហើយមានការប្រើថ្មថ្មីយ៉ាងតិចបំផុតៗ ប្រព័ន្ធបង្ហូរទឹកពីបុរាណដែលត្រូវបានរកឃើញក្នុងពេលកំណាយបុរាណវិទ្យាត្រូវបានរក្សាទុកនៅនឹងកន្លែងដើមជូនភ្ញៀវទស្សនា ដើម្បីឲ្យភ្ញៀវយល់អំពីប្រព័ន្ធបង្ហូរទឹកចេញពីប្រាសាទៗ នៅពេលដែលការងារអភិរក្សបញ្ចប់ទៅផែនទីមួយត្រូវបានរៀបចំឡើងដើម្បីទុកធ្វើការសិក្សាប្រៀបធៀបៗ

ដីនៅខាងក្រោមគ្រឹះប្រាសាទក៏ដូចជាខ្សាច់ដែលចាក់បំពេញនៅក្នុងគ្រឹះត្រូវបានធ្វើការចាត់ចែងជាពិសេសយ៉ាងសមស្រប ចំណែកឯផ្តាំងថ្មភក់ធំៗដែលក្រាលនៅក្នុងប្រាសាទ ក៏ដូចជាផ្តាំងថ្មនៅតាមជញ្ជាំងគ្រឹះត្រូវបានរៀបទៅតាមកន្លែងដើមវិញៗ ផ្តាំងថ្មក្រាលបាតក្រោមនិងសសរក៏ដូចជាថ្មដំបូលត្រូវបានជួសជុលនិងរៀបដាក់ទៅវិញដោយប្រើប្រាស់សម្ភារៈសមស្របបន្ទាប់ពីបានផ្ទៀងផ្ទាត់មើលយ៉ាងល្អិតល្អន់រួចមកៗ ការសិក្សាតាមរយៈវិធីសាស្ត្រប្រើរ៉ាដាថតក្រោមដីត្រូវបានធ្វើឡើងមុននឹងសំអាតធ្វើកំណាយដើម្បីរកឲ្យឃើញច្បាស់កន្លែងដែលមានឫសឈើក្នុងដីៗ ផ្តាំងថ្មដែលគ្មានលំនឹងនៅតាមកំពូលប្រាសាទចន្លោះកំផែងទី២និងកំផែងទី៣ នៅតាមបណ្តោយផ្លូវកណ្តាលនិងនៅតាមកំផែងទី៥ផ្នែកខាងលិចត្រូវបានរុញទៅកន្លែងដើមវិញនិងចងផ្តោបដោយប្រើខ្សែកាបថ្លាស្ទិចដើម្បីតាមដានមើលពីចលនារបស់វាៗ

ឧបករណ៍វាស់អាកាសធាតុ វាស់លំអៀង

ផ្លូវចូលមុនពេលរៀបចំឡើងវិញ

© D.S.Sood



ផ្លូវចូលក្រោយពេលរៀបចំឡើងវិញ

© D.S.Sood

ជញ្ជាំងនិងគំលាតប្រេះស្រាំនៃថ្មត្រូវបានដាក់នៅតាមទីតាំងនានាក្នុងប្រាសាទដើម្បីសិក្សាអំពីចលនានៃរចនាសម្ព័ន្ធដែលអាចកើតមាន។ ជណ្តើរនិងក្តារក្រាលធ្វើពីឈើត្រូវបានរៀបចំដាក់នៅតាមទីតាំងផ្សេងៗដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរកុំឲ្យប៉ះពាល់ដល់ឫសឈើចាស់ៗ។ សិក្ខាសាលាត្រូវបានរៀបចំឡើងរៀងរាល់ឆ្នាំដោយមានការគាំទ្រពីស្ថាប័ន FRI ដើម្បីបណ្តុះបណ្តាលបុគ្គលិកអាជ្ញាធរអប្សរាក្នុងការព្យាបាលនិងថែទាំដើមឈើមិនល្អ ហើយវិញ្ញាបនប័ត្រត្រូវបានប្រគល់ជូនសិក្ខាកាមដោយតំណាងអង្គការយូណេស្កូ។ កម្មវិធីបណ្តុះបណ្តាលផ្សេងៗទៀតក៏ត្រូវបានរៀបចំឡើងដែរ សម្រាប់បុរាណវិទូក្នុងស្រុកនិងអ្នកគ្រប់គ្រងប្រាសាទ។

កន្លែង៤ក្នុងចំណោមកន្លែងទាំង៥នៃគម្រោងអភិរក្សនិងជួសជុលប្រាសាទតាព្រហ្មបានធ្វើចប់រួចរាល់ហើយរួមមាន៖

រោងទំងនៃកំផែងទី៣ ផ្នែកខាងកើតស្លាបខាងត្បូង

រោងទំងនេះ មានរាងចតុកោណកែងបណ្តោយប្រវែង៤១,១៥ម៉ែត្រនិងទទឹង៤,៨៥ម៉ែត្រ។ កំពូលនៅតាមជ្រុងនីមួយៗនិងដំបូលបានរងការខូចខាតទាំងស្រុង។ បន្ទាប់ពីបានពង្រឹងគ្រឹះរួចមកផ្នែកនេះត្រូវបានជួសជុលដោយប្រើថ្មដើមហើយក្នុងករណីចាំបាច់ក៏ប្រើថ្មថ្មីខ្លះៗដែរ។

ស្ពានហាលនៅចន្លោះរោងទំងខាងលិចទី៣និងទី៤

ស្ពានហាលដែលមានក្តារបែនភ្ជាប់ទៅក្លោងទ្វារចូលនៅត្រង់កំផែងទី៣និងទី៤ ផ្នែកខាងលិច គឺជាផ្នែកមួយដ៏សំខាន់នៃការងារអភិរក្សប្រាសាទនេះ។ ស្ពានហាលនេះមានប្រវែងបណ្តោយ៤៣,៦០ម៉ែត្រ ទទឹង៤,៦០ម៉ែត្រនិងកម្ពស់០,៩០ម៉ែត្រ វាស្ថិតនៅក្នុងស្ថានភាពទ្រុឌទ្រោមយ៉ាងដំណំ។ ថ្មគ្រឹះនៃស្ពានហាលនេះត្រូវបានរើយកចេញម្តងមួយៗនិងរៀបចូលទៅវិញយ៉ាងផ្ចិតផ្ចង់បំផុត។ បង្កាន់ដៃមានរាងជាខ្លួននាគក៏ត្រូវបានជួសជុលឡើងវិញដែរដោយប្រើប្រាស់ថ្មដើមច្រើនបំផុតដែលអាចធ្វើទៅបាន។

គោបុរៈនៅកំផែងទី៤ខាងលិច

គោបុរៈនៃកំផែងទី៤ ពិតជាមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង។ ដំបូលរោងទំងខាងជើងនិងខាងត្បូង ព្រមទាំងផ្លូវដើរខាងកើតនិងខាងលិចបានបាក់ធ្លាក់រប៉ាត់រប៉ាយ ចំណែកឯថ្មដំបូលក្នុងទិសពីកើតទៅលិចក៏ស្ទើរតែបាក់ធ្លាក់ដែរដោយសារ ថ្មឃ្លាតចេញពីគ្នាអស់ទៅហើយ។ គ្រប់ដុំថ្មនៃសសរ ដំបូលនិងថ្មក្រាលផ្ទៃក្រោមត្រូវបានរុះរើចេញនិងជួសជុលប្រកបដោយការប្រុងប្រយ័ត្នបំផុត។ បន្ទាប់ពីរៀបចំពង្រឹងគ្រឹះរួចហើយ គោបុរៈត្រូវបានជួសជុលឡើងវិញដោយរៀបថ្មចាស់ដាក់នៅកន្លែងដើមវិញ។

គោបុរៈនៅត្រង់កំផែងទី៥ខាងលិច

ថ្មនិងទម្រង់នៃគោបុរៈនេះត្រូវបានកត់ត្រាក្នុងឯកសារយ៉ាងលំអិត។ គ្រប់ដុំថ្មទាំងអស់ដែលរង្គោះចេញទាំងខាងក្នុងនិងខាងក្រៅកំពូលត្រូវបានជួសជុលម្តងមួយៗ មុននឹងយកវាទៅរៀបដាក់ត្រង់កន្លែងដើមវិញដើម្បីបញ្ចៀសរាល់ការបាក់ធ្លាក់ចុះមក។ គ្រប់ដុំថ្មបាក់បែកទាំងអស់ត្រូវបានតភ្ជាប់គ្នាឡើងវិញដើម្បីធានាឲ្យមានសុវត្ថិភាពកាន់តែប្រសើរ។ ដែកថែបទ្រទល់ដែលគេអាចដកចេញវិញពេលណាក៏បានត្រូវបានដាក់ទល់ខាងក្នុងគោបុរៈ ដើម្បីបញ្ចៀសកុំឲ្យមានចលនារំកិលចុះឡើងតាមទិសផ្តេក។ ថ្មបាយក្រៀមក្រាលបាតក្រោមក៏ត្រូវបានរៀបចំឲ្យដូចទម្រង់ដើមវិញដែរ។

ជញ្ជាំងកំផែងខាងក្រៅ

គ្រឹះនៃជញ្ជាំងដែលទ្រេតធ្វើពីថ្មបាយក្រៀមត្រូវបានជួសជុលយ៉ាងប្រុងប្រយ័ត្នបំផុត។ គ្រឹះត្រូវបានពង្រឹងតាមរយៈការចាក់បំពេញដោយល្បាយកំបោរនិងដីខ្សាច់បុកបញ្ចូលគ្នា។ ដុំថ្មបាយក្រៀមថ្មីៗមួយចំនួនត្រូវបានយកមកជំនួសដុំថ្មដែលបានបាត់បង់ទៅដោយគោរពទៅតាមខ្សែបណ្តោយនិងកម្ពស់ដើមនៃជញ្ជាំងកំផែង។

សាលរបាំ

ការងារអភិរក្សសាលរបាំកំពុងបន្តអនុវត្តនៅពេលនេះ។

ដើមឈើដ៏ធំបានបន្ថែមនូវភាពអាថ៌កំបាំង ប៉ុន្តែបានគំរាមកំហែងប្រាសាទ

© Yeowatzup

ការជួសជុលនិងពង្រឹងសំណង់ឥដ្ឋប្រាសាទប្រែរូប

សាស្ត្រាចារ្យ វាលធើ មារីយាសានតូរ៉ូ Valter Maria Santoro
សកលវិទ្យាល័យរ៉ូម
ទទួលខុសត្រូវបេសកកម្មបច្ចេកទេសប្រទេសអ៊ីតាលីសម្រាប់ស្ថាបនាថ្មឡើងវិញនៅអង្គរវត្ត



រូបភាពទីធ្លាប្រាសាទប្រែរូបថតពីបន្ទាយកណ្តាល

© Tushar Dayal

ការស្ដាប្បនាឡើងវិញកំពុងធ្វើនៅប្រាសាទប្រែរូប

© Allie Caulfield

ប្រាសាទប្រែរូបត្រូវបានកសាងឡើងក្នុងឆ្នាំ៩៦១ ក្នុងរាជស្តេចដែលស្រលាញ់សន្តិភាពគឺព្រះរាជជិន្រ្ទាវរ្មន័ដែលជារាជធានីនៃចក្រភពខ្មែរ ដែលពោរពេញដោយការរីកចម្រើន

ដោយ មានការគាំទ្រពីអង្គការយូណេស្កូ និងជំនួយថវិកាពីប្រទេសអ៊ីតាលីក្នុងគំរោងការការពារនិងអភិរក្សសម្បត្តិបេតិកភ័ណ្ឌពិភពលោក ប៉មធំៗរបស់ប្រាសាទប្រែរូបជាទិសដៅដែលត្រូវបានសិក្សាស៊ីជម្រៅពីខែតុលា ឆ្នាំ១៩៩៥រហូតដល់ខែធ្នូ ឆ្នាំ២០០៤។ ការសិក្សាដំបូងមានដូចជាការសិក្សាពីលក្ខណៈ Geometry ការវិភាគទៅកន្លែងដែលមានការខូចខាតព្រមទាំងតាមដាននូវការផ្លាស់ទីឬការប្រែប្រួលនៃតួប្រាសាទនិងធ្វើការពិសោធន៍ទៅលើសំភារៈដែលបានប្រើប្រាស់សម្រាប់ការសាងសង់ប្រាសាទ។ ព័ត៌មានលំអិតជាច្រើនសម្រាប់យកមកធ្វើការ Design រួមមានការពង្រឹងគ្រោងបង្គុំទូទៅ (ដូចជាការភ្ជាប់ឡើងវិញ តាមរយៈកម្ពស់នៃជញ្ជាំងការពង្រឹកទំហំគ្រឹះនិងការDesign ផ្សេងៗទៀត អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃតួប្រាសាទនីមួយៗ)។

ការរៀបចំឯកសារដែលជាលទ្ធផលការងារនៅការដ្ឋានត្រូវបានចាប់ផ្តើមពីខែមករា ឆ្នាំ១៩៩៩ ហើយឯកសារទាំងនោះត្រូវបានរក្សាទុកសម្រាប់ការជួសជុលប្រាសាទដ៏ទៃទៀតនៅក្នុងតំបនអង្គរដែលមានលក្ខណៈដូចគ្នានឹងប្រាសាទប្រែរូបនេះ។

ប្រាសាទប្រែរូបមានទីតាំងស្ថិតនៅខាងត្បូងអាងបារាយណ៍ខាងកើតមានចម្ងាយ១៥គីឡូម៉ែត្រខាងជើងក្រុងសៀមរាបតាមឯកសារបារាំងហៅជាធម្មតាថា(វង់ធំ) ប្រាសាទនេះត្រូវបានសាងសង់ពីឆ្នាំ៩៦១ ក្នុងរជ្ជកាលស្តេចរាជជិន្រ្ទាវរ្មន័ដែលជារាជាធានីនៃចក្រភពខ្មែរដែលពោរពេញដោយការរីកចម្រើន។ បួងទូទៅរបស់ប្រាសាទមានរាងជាចតុកោណកែងស្មើដែលជ្រុងនិមួយៗមានប្រវែង១២០ម៉ែត្រហើយប្រាសាទនេះជាសំណង់សិល្បៈបែបសាសនា ហើយជាប្រាសាទលើភ្នំដែលមានលក្ខណៈជាសំណង់ប្រាសាទដំបូងនៃអាណាចក្រខ្មែរ។ នៅផ្នែកខាងក្នុងនៃប្រាសាទត្រូវបានបិទដោយជញ្ជាំងជុំវិញពីខាងក្រៅហើយនៅតាមបណ្តោយជ្រុងខាងកើតក្នុងបរិវេណប្រាសាទមានប៉មចំនួនប្រាំដែលសង់ពីឥដ្ឋ។ ហើយនៅជ្រុងនៃផ្លូវចូលធំមានប៉មប្រាសាទឥដ្ឋចំនួនប្រាំទៀតដែលស្ថិតនៅផ្នែកខាងលើ។ ការសាងសង់ប្រាសាទនេះនៅមិនទាន់ចប់រួចរាល់ទាំងស្រុងនៅឡើយដោយយោងតាមរូបចម្លាក់មិនទាន់រួចរាល់ដែលគេឆ្លាក់នៅលើផ្តែរថ្មភក់របស់ទ្វារនៃប៉មប្រាសាទទាំងនោះជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់។ ក្នុងកំឡុងពេលប្រាសាទនេះត្រូវបានបោះបង់ចោលអស់រយៈពេលលើពីរាប់ពាន់ឆ្នាំ ក្រោមការប្រែប្រួលនៃអាកាសធាតុក្តៅហើយសើមពីតំបន់ត្រូពិចនិងការប្រែប្រួលនៃកម្រិតកម្ពស់ទឹកក្រោមដីអាស្រ័យទៅតាមរដូវប្រាំងនិងរដូវវស្សាធ្វើអោយប្រាសាទនេះក៏ដូចជាប្រាសាទដ៏ទៃទៀតនៃអាណាចក្រខ្មែររងការខូចខាតយ៉ាងខ្លាំងក្រោមអំពើរលាយឡំគ្នានៃកំលាំងមេកានិក កំលាំងរូបសាស្ត្រនិងកម្លាំងគីមីសាស្ត្រ។ ហើយការខូចខាតទាំងនោះយើងអាចមើលឃើញយ៉ាងច្បាស់នូវទ្រង់ទ្រាយរបស់

ទិដ្ឋាប្រាសាទប្រែរូប

© Christian Haugen



គ្រឹះប្រាសាទដែលទន់ជ្រាយ

© Valter Maria Santoro

ឃ្នាបភ្ជាប់ជញ្ជាំងប្រាសាទ

© Valter Maria Santoro

តាមការយល់ដឹងបច្ចេកទេសដំបូងមិនធន់នឹងដំណើររបស់អាកាសធាតុ ចំនួនប្រាសាទជាច្រើនក្នុងតំបន់អង្គរ គឺជាកម្មវត្ថុបណ្តាលឲ្យមានអន្តរាគមនិងការកែរប្រែឲ្យល្អប្រសើជាប្រចាំតទៅក្នុងប្រវត្តិសាស្រ្តរបស់ខ្មែរ

វាដូចជា (ការប្រេះមានលក្ខណៈទ្រេតរីត្រង់ផ្នែកខ្លះដែលបានបាតបង់ស្រទាប់ពាសខាងក្រៅនៃជញ្ជាំងត្រូវបានបាត់បង់អស់ដែរ) ។ល។

ជាបន្តទៅទៀតដោយមានការពង្រីកនិងអភិវឌ្ឍន៍គេឃើញថាមានការលើកយកបញ្ហាទាំងអស់នោះមកបង្ហាញនិងពន្យល់នៅក្នុងប្រវត្តិសាស្ត្រខ្មែរប្រាសាទជាច្រើននៃឯកសារប្រវត្តិសាស្រ្តខ្មែរក្នុងករណីនេះប្រាសាទប្រែរូប។

ការសន្ទត់ជាដំបូងរបស់ប្រាសាទប្រែរូបក្រោយពីការបោះបង់និងគ្មានការថែរទាំអស់ជាងមួយសតវត្សមកក្នុងរយៈពេលនេះប៉មប្រាសាទក្នុងតំបន់នៃប្រាសាទប្រែរូបចាប់ផ្តើមរងការទ្រុតទ្រោមនិងខូចខាតដោយសារការស្រុតដីនិងសមត្ថភាពទ្រទ្រង់របស់គ្រឹះត្រូវបានធ្លាក់ចុះអាស្រ័យទៅតាមកម្រិតរយៈកម្ពស់ទឹកក្រោមដី។ ក្រោមកត្តាអាកាសធាតុធ្វើឲ្យរុក្ខជាតិដុះយ៉ាងច្រើននៅលើប្រាសាទហើយឫសរបស់វាបានរុញផ្ទៃជញ្ជាំងនិងសត្វទាំងឡាយបានធ្វើសំបុកស្ទើរគ្រប់ប្រហោងឥដ្ឋដែលធ្វើឲ្យជញ្ជាំងឥដ្ឋមានភាពសឹករិចរិល។ ឥដ្ឋត្រូវបានបាក់បែកនិងខូចខាតព្រមទាំងគុណភាពធ្លាក់ចុះទាំងលក្ខណៈគីមីនិងលក្ខណៈមេកានិក។ ផ្នែកខ្លះនៃក្បាច់របស់ខ្មែរត្រូវរងការខូចខាតដោយសារការហែកចេញនៃជញ្ជាំងហើយការហែកចេញនៃជញ្ជាំងនេះក៏ជាកត្តាជំរុញធ្វើឲ្យផ្ទៃរងការខូចខាតផងដែរ ហើយជញ្ជាំងប៉មប្រាសាទទាំងអស់ត្រូវបានរត់ខុសជួរគ្នាដោយមិនមានការខាំស៊ីគ្នា។ ដោយមានការរៀបចំទូវឯកសារសិក្សាស្រាវជ្រាវផ្តោតទៅលក្ខណៈភូគព្ភសាស្ត្រ (géologie) នៃតំបន់និងការសិក្សាពីលក្ខណៈរបស់ដីនៅការដ្ឋានផ្ទាល់ព្រមទាំងស្ថានភាពនៃគ្រោងបង្អុំទូទៅនៃប៉មប្រាសាទជាអតិភាពធ្វើយើងអាច Design បានទូវប្លង់ចុងក្រោយសម្រាប់សិក្សាស្ថានភាពក្នុងការជួសជុល។

ការសិក្សាលំអិតទាំងនោះរួមមានការវិភាគតាមក្រហ្វិច វិភាគលក្ខណៈរបស់ដីនៅការដ្ឋានលក្ខណ: Geometry របស់តួប៉ម ការតាមដានការខូចខាតនៃគ្រោងបង្អុំ(ការអប) តាមដានការបាត់បង់ផ្នែកខ្លះនៃគ្រោងបង្អុំការវិភាគទៅលើប្រភេទនៃសំភារៈនៃគ្រឹះ។

គោលបំណងចំបងសម្រាប់ការជួសជុលប្រាសាទនេះគឺការជួសជុលគ្រឹះរបស់ប្រាសាទដែលបាត់បង់ស្ថានភាពលំនឹងដោយពង្រីកទំហំគ្រឹះឬយើងធ្វើការភ្ជាប់គ្នាឡើងវិញនូវផ្នែកផ្សេងៗនៃជញ្ជាំងរបស់ប៉ម។

សម្រាប់ប៉មប្រាសាទមួយដែលរងការខូចខាតខ្លាំងគឺស្ថិតនៅទិសខាងត្បូងឈៀងខាងកើតសម្រាប់ការជួសជុលប៉មមួយនេះគឺយើងបានធ្វើធ្នឹមបេតុងភ្ជាប់រវាងជញ្ជាំងនិងជញ្ជាំងនៅផ្នែកខាងក្នុងនៃប៉មដែលធ្នឹមបេតុងនោះត្រូវបានកប់នៅក្នុងដី។ ហើយប៉មប្រាសាទមួយផ្សេងទៀតដែលស្ថិតនៅខាងលើស្ថិតនៅទិសខាងត្បូងឈៀងខាងកើតការភ្ជាប់របស់វាត្រូវបានប្រើប្រាស់នូវបច្ចេកទេសថ្មីហើយសម្ភារៈទំនើប ដូចជា Synthetic Rod ដោយបញ្ចូលទៅក្នុងប្រហោងដែលមានអង្កត់ផ្ចិតតូចៗ។ ការប្រើប្រាស់ថ្មីទាំងនេះត្រូវបានអនុញ្ញាតិដោយក្រុមអ្នកបច្ចេកទេសជាតិនិងអន្តរជាតិចៀសវាងការប៉ះពាល់ទៅលើប្រាសាទនៅពេលជួសជុលហើយធានាបានទាំងលក្ខណៈដើម លក្ខណៈគីមីនិងលក្ខណៈមេកានិច ជាពិសេសសម្ភារៈទាំងនោះមានលក្ខណៈល្អប្រសើរសមស្របជាមួយនឹងសំណង់បុរាណ។



ជណ្តើរកណ្តាលប្រាសាទប្រែរូប

© Robert Young



ប្រាសាទបាយ័ន តើអត្ថន័យដ៏វិសេសវិសាលបានមកពីរូបចម្លាក់ឬក៏ស្ថាបត្យកម្មរបស់ប្រាសាទ ?

សាស្ត្រាចារ្យ តាកេស៊ី ណាកាហ្គាវ៉ា Takashi Nakagawa
សកលវិទ្យាល័យវ៉ាសេដា
នាយកប្រចាំនៅកម្ពុជានៃគម្រោងការពារឧទ្យានអង្គរ ជប៉ុន-អប្សរា

ព្រះភក្ត្រដ៏ទាក់ទាញរបស់ព្រះអាទិទេពបានសម្លឹងទៅកាន់ពិភពលោកអស់រយៈពេលមួយពាន់ឆ្នាំ

© Benjamin Vander Steen



រូបភាពកាត់នៃប្រាសាទបាយ័នបង្ហាញពីកន្លែងអង្គុយរបស់ព្រះពុទ្ធស្ថិតក្នុងទម្រង់ដើម នៅចំកណ្ដាលប៉ម

© Takeshi Nakagawa, Katsushi Ikeuchi and Ichita Shimoda



ប៉មមួយក្នុងចំណោមមបន្ទាយទាំងអស់របស់ប្រាសាទបាយ័ន

© Lin Mei

បំនួន ដ៏ច្រើននៃព្រះភក្ត្រធំៗរបស់អាទិទេពគឺពិបាកនឹងកំណត់ថាតើវាជាចម្លាក់ឬក៏ជាស្ថាបត្យកម្ម។ មិស្សភាគបីជ្រុងនិងការផុសឡើងមកយ៉ាងគ្រាស់ឃ្មឹករបស់ព្រះភក្ត្រដែលត្រដែតចេញពីលំហដ៏ចង្អៀតធ្វើឱ្យមនុស្សភាគច្រើនមានអារម្មណ៍ភ្ញាក់ផ្អើលនិងខ្សៀវរឿងរូបភាពនៃចម្លាក់ក្រឡោតទាបដែលពិពណ៌នាពីឆាកជីវិតរស់នៅប្រចាំថ្ងៃនិងចក្ខុវិស័យដ៏ធំធេងនៃប្រវត្តិសាស្ត្រ។ វាមិនមានការពណ៌នាដ៏ល្អណាមួយចំពោះព្រះភក្ត្រដ៏គួរឱ្យទាក់ទាញរបស់ប្រាសាទបាយ័ននេះបានឡើយ។ តើមានសំនួនណាមួយពីការពិពណ៌នាឱ្យបានពេញលេញចំពោះទិដ្ឋភាពដ៏អាថ៌កំបាំងនៅក្នុងអគារខ្វាត់ខ្វែងរបស់ប្រាសាទបាយ័នទាំងមូល ដែលផ្ដល់នូវសុភវិនិច្ឆ័យដ៏ល្អិតល្អន់នៃតុល្យភាពរវាងនិស្លាបនិកម្មនិងសមថភាព។ ស្ទើរតែជាងពាក់កណ្ដាលនូវចំនួនដុំថ្មនៃតួប្រាង្គកណ្ដាលបានរលំធ្លាក់ ប៉ុន្តែទោះយ៉ាងនេះក្តីវានៅតែឈរត្រង់ឆ្ពោះទៅកាន់ផ្ទៃមេឃនិងគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើការមើលឃើញដ៏ល្វឹងល្វើយទៅកាន់ទីឆ្ងាយ។ ពិតណាស់ដែលគ្រប់កន្លែងនៃរចនាសម្ព័ន្ធសំណង់ដ៏ស្មុគស្មាញរបស់ប្រាសាទបាយ័ន ដូចជា ដំបូលនិងជញ្ជាំងដែលរៀបពីថ្មមួយដុំៗ គឺប្រឈមនឹងការដួលរលំហើយនិងនាំមកនូវវិចិកោសល្យចំពោះហេតុការណ៍ដែលសូម្បីតែថ្មក៏ពុកផុយ។ សូម្បីតែអារម្មណ៍ពិតប្រាកដចំពោះការគេចផុតពីគ្រោះថ្នាក់ ក៏ស្ថិតនៅក្នុងភាពមន្ទិលសង្ស័យ។ អារម្មណ៍បែបនេះគឺជាដើមចមដ៏ធំមួយនៃការព្រួយបារម្ភហើយវាជាការប្រាកដដែលថាការព្រួយបារម្ភនេះ បាននាំឱ្យមានការចាប់ផ្ដើមឡើងនូវគម្រោងរបស់យើងក្នុងការជួសជុលនិងថែរក្សាប្រាសាទបាយ័ននេះ។ យើងបានសិក្សាស្រាវជ្រាវពីប្រាសាទបាយ័នក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញជាច្រើន។ ម៉្យាងទៀត អាថ៌កំបាំងជាច្រើនរបស់វាក៏បន្តកាន់តែជ្រៅទៅៗតែយើងក៏បានរកឃើញចំណុចនៃការចាប់អារម្មណ៍របស់វាជាច្រើនផ្សេងទៀតដែលពុំដែលធ្លាប់បានបរិយាយពីមុនមកទេ។

ទស្សនៈនិងអត្ថន័យនៃប្រាសាទបាយ័ន

បាយ័នគឺជាប្រាសាទកណ្ដាលទីក្រុងអង្គរធំ។ រចនាសម្ព័ន្ធសំណង់សំខាន់នៃប្រាសាទនេះគឺមានរានហាលដ៏ធំមួយនៅមុខ ខាងកើតនិងបួងបាតរាងបួនជ្រុងដែលមានប្រវែងប្រមាណ១៣០ម៉ែត្រវាស់នៅជ្រុងខាងមុខនិង១៤០ម៉ែត្រវាស់ជ្រុងចំហៀង។ វាត្រូវបានហ៊ុំព័ទ្ធដោយរោងទងខាងក្រៅពន្ធារាងកាកបាទនិងរោងទងខាងក្នុងជាផ្នែកក្រោយបង្អស់ ដែលបានសាងសង់នៅប៉ុន្មានឆ្នាំចុងក្រោយនិងមានរួមផ្សំជាមួយរោងទងជាច្រើននៅជ្រុងកែង។ តួប្រាង្គកណ្ដាលដែលមានកម្ពស់៤៣ម៉ែត្រនិងមានបួងបាតរាងពងក្រពើ បានភ្ជាប់ជាមួយក្រុមបន្ទប់និងប្រាង្គជាច្រើនហើយស្ថិតនៅលើឃឿនថ្មបីជាន់ដែលបានសាងសង់យ៉ាងល្អិតល្អន់ ហើយការរៀបចំបួងខ្លះមានរបៀបត្រង់ជួរក្នុងទិសដៅទាំងបួន គឺ ជើង ត្បូង កើតនិងលិច ហើយប្រាង្គផ្សេងទៀតស្ថិតនៅក្នុងបួនទិសរណបផ្សេងទៀត។ ការរៀបចំបែបនេះបានប្រត្យក្សឡើងនូវទិដ្ឋភាពព្រះភក្ត្រ ១៧៣ របស់រូបទេវៈ ទេព្តានិងអសុរៈ (ច្រើនជាង ១៨១ ព្រះភក្ត្រកាលពីពេលចាប់ផ្ដើមសាងសង់ហើយ) ដែលបានឆ្លាក់នៅលើប្រាង្គសរុបចំនួន៥២ ។ ព្រះភក្ត្រនីមួយៗមិនគ្រាន់តែមានការខុសគ្នាលើទំហំ ទីតាំង កម្ពស់និងកិនភាគទេ ប៉ុន្តែទិដ្ឋភាពនៃការខូចខាតក៏មានការខុសគ្នាច្រើនផងដែរ។ ភាពផ្សេងៗគ្នានៃព្រះភក្ត្រនិងការកត់សំគាល់ទាំងនេះធ្វើឱ្យអ្នកទស្សនាជាច្រើនមានអារម្មណ៍វង្វេងក្នុងទីធ្លាល្ហល្ហេវគ្មានទិសដៅ។ វាក៏មានរូបភាពប្លែកដែលបានបង្ហាញនៅទីនេះផងដែរ



ព្រះភក្ត្រដ៏ធំមួយក្នុងចំណោមព្រះភក្ត្រធំ ១៧៣

© Lin Mei



ចម្លាក់ដែលឆ្លាក់ជាជុំៗយកទៅរៀបនៅប្រាសាទបាយ័ន

© Tushar Dayal

នៅដំណាក់កាលសាងសង់ដំបូងក្នុងសម័យបាយ័ន។

អាទិទេពទ្វារបាលទាំងបី

"កូរសមុទ្រទឹកដោះ" នៅលើជញ្ជាំងរោងទង ប្រាសាទអង្គរវត្ត គឺជាចម្លាក់ក្រឡោតទាបដ៏ល្បីល្បាញដែលឆ្លុះបញ្ចាំងពីប្រពៃណីបុរាណរបស់ជនជាតិខ្មែរនិងតណ្ហាក្នុងការបង្កើតពិភពលោកថ្មីមួយតាមរយៈការផ្សំធាតុខុសៗគ្នាដោយឡែកនៅប្រាសាទបាយ័នវិញ អាទិទេពទាំងបីរួមមាន ទេវៈ ទេព្ដានិងអសុរៈ ដែលជានិមិត្តរូបប្រពៃណីដូចគ្នានោះត្រូវបានរៀបចំយ៉ាងប៉ិនប្រសប់ក្នុងអគារខ្វេតខ្វែងនិងនៅច្រកចូលទៅកាន់ប្រាសាទដើម្បីបង្កើតនូវរចនាបថសំណង់ថ្មីមួយដែលស្តែងចេញជាលក្ខណៈអាទិទេពទ្វារបាលទាំងឡាយ។ ម៉្យាងទៀត មុខងាររបស់អាទិទេពទាំងបីត្រូវបានញែកដាច់ពីគ្នាផងដែរ ដូចយ៉ាង ទេព្ដា ជាអាទិទេពការពារអាទិទេពធំដែលដាក់ដម្កល់នៅក្នុងប្រាង្គកណ្ដាលរបស់ប្រាសាទបាយ័ន អសុរៈ ជាអាទិទេពការពារបរិវេណជុំវិញប្រាសាទនិងទេវៈជាអាទិទេពការពារនៅចន្លោះកណ្ដាល។ ដូចនេះហើយ ប្រាសាទបាយ័នតំណាងឱ្យពិភពលោកច្រើនស្រទាប់សម្រាប់ការពារចក្រភពពិភពលោករបស់វាដោយអាទិទេពទាំងនេះ។

ចម្លាក់ទាបឆ្លាក់នៅលើជញ្ជាំងរោងទងខាងក្នុងនិងខាងក្រៅ ចង្អុលបង្ហាញពីចរិតលក្ខណៈរបស់ប្រាសាទបាយ័ន ហើយវាក៏មានអត្ថន័យសំខាន់ផងដែរ

អំណាចរាជវង្សត្រូវបានទទួលស្គាល់ថាជាច្បាប់

ចម្លាក់ក្រឡោតទាបដែលឆ្លាក់នៅលើជញ្ជាំងរោងទងខាងក្នុងនិងក្រៅចង្អុលបង្ហាញពីលក្ខណៈសំគាល់របស់ប្រាសាទបាយ័នក៏មានអត្ថន័យយ៉ាងសំខាន់។ ដោយគង់នៅចំកណ្ដាលចម្លាក់ គឺព្រះបាទជ័យវរ្ម័នទី៧ ខ្លួនឯង (ព្រះអង្គគ្រប់គ្រងរាជ្យក្នុងកំឡុងឆ្នាំ១១៨១ រហូតដល់ ១២១៩) និងរាជវង្សរបស់ព្រះអង្គ ឯចម្លាក់នៅលើជញ្ជាំងពីមុខនៃរោងទងខាងក្នុងបង្ហាញពីភាពជោគជ័យរបស់ព្រះរាជានិងការធ្វើច្បាប់របស់ពួកគេសម្រាប់ការគ្រប់គ្រងនិងអំណាច។ ជញ្ជាំងខាងជើងនិងខាងលិចពណ៌នាឈុតឆាករឿងៗខ្លួនប្រកបដោយក្បូរក្បាច់យ៉ាងល្អវិចិត្រដែលមានទំនាក់ទំនងទៅនឹងរឿងព្រេងនិទានជាច្រើនរបស់ព្រះសិវៈ (ព្រះឥសូរ) និងវិស្ណុ (ព្រះនារាយណ៍) និងជញ្ជាំងខាងត្បូងត្រូវបានពិចារណាថានឹងជារឿងរ៉ាវពាក់ព័ន្ធនឹងព្រះពុទ្ធ។ ចម្លាក់ទាំងនេះគឺជាការបរិយាយយ៉ាងច្បាស់ក៏ដោយការមានវិចារណៈញ្ញាណចំពោះប្រពៃណីធំទាំងបីដែលមាននៅក្នុងអាណាចក្រអង្គរនៅខណៈនោះ។ ជាពិសេសឆាកជាច្រើនអំពីជីវិតរស់នៅប្រចាំថ្ងៃដែលកម្រត្រូវបានជួបប្រទះណាស់នៅក្នុងប្រាសាទនានាបានឆ្លាក់នៅក្នុងរោងទងខាងក្រៅលេចចេញនូវការរំជួលចិត្តដែលពោរពេញទៅដោយថាមពល ស្នេហានិងសំណើច។ ជារួមការលាតត្រដាងមិនទឹកស្អាននូវរឿងរ៉ាវទាំងនេះ គឺជាការជ្រើសរើសនិងការគូររូបពណ៌នានូវឈុតឆាកឯកត្តភូតនិងភាពប្លែកនៃអង្គប្រកបរូបភាពទាំងឡាយហើយទាំងនេះរួមគ្នាជាដើមចមមួយនៃទំនាក់ទំនងរបស់ប្រាសាទបាយ័ន ក៏ដោយ

ប៉ម ៥២ នៃប្រាសាទបាយ័នជារឿយៗព្រះសង្ឃនិមន្តទៅទស្សនា

© Kyle Taylor

ភាពទាក់ទាញដែលមានរហូតមកដល់ពេលបច្ចុប្បន្ន។

ស្មុគ្រីប្រាថ្នាឆ្ពោះទៅកាន់អាណាចក្រទាំងមូល

ទោះយ៉ាងណាក្តីនេះមិនមែននិយាយថាប្រាសាទបាយ័នមានសភាពស្មុគស្មាញនិងរចនាសម្ព័ន្ធចេញពីការចាប់ផ្តើមដំបូងបង្អស់នោះទេ។ គិតទៅដល់ការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រនៃប្រាសាទបាយ័នទស្សនៈជាច្រើនត្រូវបានបង្ហាញឱ្យឃើញដោយលោកសាស្ត្រាចារ្យ ក្លូដ ហ្សាក់ ដែលពឹងផ្អែកលើបទពិសោធជាច្រើនឆ្នាំក្នុងការសិក្សាពីសិលាចារឹកខ្មែរសមនឹងទទួលបានការយកចិត្តទុកដាក់។ ប៉ុន្តែខណៈគិតដល់ស្នាកស្នាមពិតប្រាកដដែលរកឃើញនៅក្នុងអគារវិញនោះទ្រឹស្តីសាងសង់អន្តរកាលដំណាក់កាលទី៤ របស់លោកសាស្ត្រាចារ្យ ហ្សាក់ ឌុយម៉ាក្សី ថាជាការសាងសង់ដោយប្រតិបត្តិទៅតាមជំនឿសាសនា។ វិនិច្ឆ័យដោយស្នាកស្នាមនៅសល់ជុំវិញប្រាង្គកណ្តាលប្រាសាទបាយ័នគឺជាប្រាសាទសាសនាហិណ្ឌូនៅពេលសាងសង់ដំបូងតែក្រោយមកក៏បានផ្លាស់ប្តូរជាប្រាសាទសាសនាព្រះពុទ្ធ ហើយបន្ទាប់មកប្តូរមកជាប្រាសាទសាសនាហិណ្ឌូជាថ្មីម្តងទៀត។ ម្យ៉ាងទៀត អាណាចក្រអង្គរបានពង្រីកទឹកដីរបស់ខ្លួនក្នុងកំឡុងពេលនាសម័យអង្គរដោយរាប់បញ្ចូលជាងពាក់កណ្តាលនៃតំបន់ទាំងមូលដែលបង្កើតបានជាតំបន់អាស៊ីភាគអាគ្នេយនាពេលបច្ចុប្បន្ននិងបានសាងសង់ផ្លូវក្សត្រដែលតភ្ជាប់ពីតំបន់នានារបស់អាណាចក្រមកកាន់ទីក្រុងអង្គធំទៀតផង។ ប្រាសាទធំៗត្រូវបានសាងសង់ក្នុងទីក្រុងកណ្តាលតំបន់ហើយរូបថតស្រាវជ្រាវកំពុងបញ្ចាញឱ្យឃើញជាលំដាប់នូវសំណង់សាលាសំណាក់ សណ្ឋាគារនៃទីក្រុងក្រោយមកទៀតនិងហេដ្ឋារចនាសម្ព័ន្ធជាច្រើនផ្សេងទៀតក្នុងទីតាំងខ្លះៗ ១០២ កន្លែងនៅទូទាំងព្រះរាជអាណាចក្រ។ ការអភិវឌ្ឍនេះបង្ហាញឱ្យឃើញថាអាណាចក្រអង្គរបាននិងកំពុងធ្វើដំណើរឆ្ពោះទៅរកចក្រភពពិភពលោកមួយប្រកបដោយក្តីសង្ឃឹមដែលកម្រមាននៅក្នុងប្រវត្តិសាស្ត្រនៃអំណាចវាយដណ្តើមយកទឹកដីនៅក្នុងតំបន់អាស៊ីភាគអាគ្នេយនេះ។ នៅពេលគិតអំពីទំនាកទំនងចាក់ឫសរវាងចក្រភពពិភពលោក ទីក្រុងរាជារបស់អង្គរធំ ប្រាសាទកណ្តាលរបស់បាយ័ននិងព្រះពុទ្ធបដិមាព្រះក្នេនដែលជាអាទិទេពចម្បងរបស់ប្រាសាទនោះវាគួរឱ្យជឿបានថាសារៈសំខាន់ជាពិសេសត្រូវបានផ្សារភ្ជាប់ទៅនឹងផ្លូវចិត្តនៃពុទ្ធសាសនិកជន។ គ្រាន់តែជាជំនឿមួយនៅភូមិភាគអាស៊ីដើម្បីអភិវឌ្ឍខ្លួនឆ្ពោះទៅកាន់ការបូជាចំពោះទេវរូបនៃពិភពលោកក្រោមគំនិតជាសាកលដែលបង្កើតជាស្នូលទីក្រុងសក្តិសិទ្ធិនៃអង្គរធំ ហើយដែលប្រាសាទពិសិដ្ឋរបស់វាគឺប្រាសាទបាយ័ន។ ព្រះបាទជ័យវរ្ម័នទី៧ មានព្រះបញ្ញាញាណយល់ពីសាកលភាពថ្មីមួយដែលសូម្បីតែខណៈមានការប្រារព្ធពិធីទំនៀមទម្លាប់។ ប្រហែលជាព្រះអង្គបានគិតពីសុខដុមនីយកម្មរវាងសាសនាទាំងពីរជាគ្រឹះនៃការគ្រប់គ្រងអាណាចក្រអង្គរ។ គឺប្រហែលដូចការគិតនេះគំនូរឫងរបស់ព្រះអង្គជាភស្តុតាងនៃភាពប្លែករបស់ទីតាំងប្រាសាទបាយ័ននិងស្តែងចេញនូវការមិនច្បាស់លាស់រវាងភាពច្របូកច្របល់និងសណ្តាប់ធ្នាប់។ នៅក្នុងកិច្ចខិតខំរបស់ព្រះអង្គនិងធ្វងកាត់ពេលវេលាហេដ្ឋារចនាសម្ព័ន្ធរបស់បាយ័ននិងផ្នែកផ្សេងទៀតនៃហេដ្ឋារចនាសម្ព័ន្ធទាំងនោះ គឺជាប្រធានបទនៃការផ្លាស់ប្តូរជាច្រើន រួមមានការបង្រួមការពង្រីកនិងការតាំងសំណង់ថ្មី ហើយទាំងនេះចុងក្រោយនាំឱ្យមានភាពប្លែកនិងភាពទាក់ទាញដែលប្រាសាទបាយ័នបញ្ចាញឱ្យឃើញមកដល់សព្វថ្ងៃ។

ប្រាសាទបាពួននៅអង្គរ ប្រវត្តិនៃការរស់ឡើងវិញមួយ

បណ្ឌិត ប៉ាស្កាល់ រ៉ូយ៉េរ Pascal Royère
នាយកនៃការសិក្សានៃសាលាបារាំងចុងបូព៌ាប្រទេស



ផ្លូវចូលប្រាសាទបាពួន

© Tushar Dayal

ប្រាសាទដែលជួសជុលរួច

© Ross Huggett

ប្រាសាទបាពួនមានរចនាសម្ព័ន្ធជារាងពីរ៉ាមីតដ៏ធំស្គឹមស្គៃ ហើយបច្ចុប្បន្នប្រាសាទបាពួនជាផ្នែកមួយនៃទេសភាពប្រាង្គប្រាសាទនៅក្នុងរាជបុរីអង្គរធំ

នៅក្នុងអំឡុងប៉ុន្មានថ្ងៃដំបូងនៃខែកក្កដា ឆ្នាំ២០១១ ព្រះករុណា ព្រះបាទ នរោត្តម សីហមុន្នី និងនាយករដ្ឋមន្ត្រីបារាំង លោក ហ្វ្រង់ស័រ ហ្វីយ៉ុង បានព្រះរាជអញ្ជើញ និងអញ្ជើញជាអធិបតីក្នុងពិធីបិទបញ្ចប់ការដ្ឋានជួសជុលប្រាសាទបាពួននិងបើកឲ្យភ្ញៀវទេសចរចូលទស្សនាឡើងវិញ ដូច្នេះពិធីនេះក៏បិទបញ្ចប់ជាផ្លូវការនូវកម្មវិធីជួសជុលដ៏យូរមួយនៅអង្គរចាប់តាំងពីការបង្កើតអភិរក្សដ្ឋានអង្គរនៅដើមសតវត្សទី២០មក។ ប្រាសាទបាពួនគឺជាប្រាសាទមួយសំខាន់ជាងគេនៅក្នុងសតវត្សទី១១ដែលឧទ្ទិសដល់ព្រះឥសូរ។ ប្រាសាទនេះមានរចនាសម្ព័ន្ធជារាងពីរ៉ាមីតដ៏ធំស្កឹមស្កៃហើយបច្ចុប្បន្នប្រាសាទបាពួនជាផ្នែកមួយនៃទេសភាពប្រាង្គប្រាសាទនៅក្នុងរាជបុរីអង្គរធំ។ ចាប់ពីពេលនេះតទៅប្រាសាទបាពួនត្រូវបានស្រោចស្រង់ឲ្យរួចផុតពីគ្រោះថ្នាក់ដែលបណ្ដាលមកពីពេលវេលា អាកាសធាតុនិងមនុស្ស។

ក្រោយពីការបញ្ឈប់ជួសជុលរយៈពេល ២៤ឆ្នាំ គឺពីឆ្នាំ១៩៧១ដល់ឆ្នាំ១៩៩៥និងក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះបរមរតនកោដ្ឋ សម្ដេចឪ នរោត្តម សីហនុ ការចាប់ផ្ដើមជួសជុលសាជាថ្មីនៅឆ្នាំ១៩៩៥ មិនមែនថាគ្មានការលំបាកនិងបញ្ហានោះឡើយ។ ដើម្បីស្វែងយល់អំពីការលំបាកទាំងនេះគួររំលឹកឡើងវិញអំពីបរិបទនៃគម្រោងនេះតាំងពីដំបូងមក។

គម្រោងមួយដែលមានរយៈពេលយូរអង្វែង

ចាប់តាំងពីដើមសតវត្សទី២០ ការងារកាប់សំអាតដើមឈើបានបង្ហាញឲ្យឃើញនូវប្រាសាទមួយដែលលក្ខណៈស្ថាបត្យកម្មស្កឹមស្កៃ គ្មានប្រាសាទណាផ្សេងអាចប្រៀបបានឡើយជាមួយនឹងលក្ខណៈដើមនៃរចនាសម្ព័ន្ធប្រាសាទ។ រចនាសម្ព័ន្ធរាងពីរ៉ាមីតដែលមានបីជាន់ មានថែវ តួកំពូលនៅតាមជ្រុង គោបុរៈនិងបូជនីយដ្ឋានដ៏សំខាន់មួយដែលគេសង់ឡើងនៅចំកណ្ដាលខាងលើកំពូលបានបង្ហាញថាប្រាសាទពិតជាស្ថិតនៅក្នុងស្ថានភាពអភិរក្សដ៏អាក្រក់មួយ។

មូលហេតុនៃការខូចខាតត្រូវបានស្វែងយល់និងដឹងយ៉ាងលឿនបំផុត។ យើងដឹងច្បាស់ថាប្រាសាទបាពួន មិនត្រូវបានសាងសង់ល្អឡើយ។ គ្រឹះដ៏ខ្ពស់ដែលធ្វើអំពីថ្មភក់មានចាក់ដីខ្សាច់បំពេញសម្រាប់សាងសង់កម្ពស់បីជាន់ទៅលើពិតជាមិនសក្ដិសមសម្រាប់ធានានូវលំនឹងរបស់ប្រាសាទក្នុងរយៈពេលយូរនោះឡើយ។ ដូច្នេះក្នុងរយៈពេលដ៏ខ្លីក្រោយមកស្ថានភាពនេះបានបង្កជាបញ្ហាដ៏ធំ ដែលបណ្ដាលឲ្យមានការខូចខាតជញ្ជាំង ទ្រេត បាក់បែក ហើយពេលខ្លះក៏ធ្លាក់ថ្មចុះមកក្រោម។ ការខូចខាតរចនាសម្ព័ន្ធ នេះកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀតដោយសារទឹកភ្លៀងជ្រាបចូលនិងការកែកុនតួប្រាសាទដែលគេបានធ្វើឡើងនៅក្នុងប្រវត្តិរបស់វា។ មហាប្រាសាទដ៏ធំដែលឧទ្ទិសដល់ព្រះឥសូរនៅក្នុងពេលដែលមានរិទ្ធិអំណាចកំពូលនោះ ព្រះមហាក្សត្រ ឧទ័យទិត្យាវរ្ម័នទី២ ក៏បានឲ្យគេសាងសង់លិង្គធ្វើអំពីមាសមួយនៅលើកំពូលប្រាសាទ ហើយនៅក្នុងអំឡុងសតវត្សទី១៦ ប្រាសាទនេះត្រូវបានគេផ្លាស់ប្ដូររូបរាងដោយការសាងសង់ចម្លាក់ព្រះពុទ្ធរូបដ៏ធំមួយដែលផ្ដុំនៅលើជញ្ជាំងខាងលិចនៅជាន់ទី២។

នៅពេលដែលលោក ហ្សង់ គូម៉ែ នៅពេលនោះជាអ្នកអភិរក្សនៅអង្គរបានចាប់ផ្ដើមបោសសំអាតប្រាសាទបាពួនដំបូងនៅឆ្នាំ១៩០៨ ការងាររបស់លោកបានអនុញ្ញាតឲ្យគេឃើញប្រាសាទមួយដែលមានរចនាសម្ព័ន្ធ ខូចខាតធ្ងន់ធ្ងរនិងឃើញដំណាក់កាលនៃការប៉ះពាល់ប្រាសាទម្ដង ហើយម្ដងទៀតនៅក្នុងប្រវត្តិរបស់វា។ តួកំពូលកណ្ដាលនិងថែវនៅជាន់ទីបីបានបាត់បង់ទាំងស្រុង គ្រឹះក៏បានស្រុតនៅជាន់ទី២ក៏ដូចគ្នាដែរ។ ចំណែកឯរចនាសម្ព័ន្ធនៅជាន់

ព្រះកេសនិងស្មារបស់ព្រះពុទ្ធបដិមាទ្រេតដ៏ធំនៅប្រាសាទបាពួន

© Allie Caulfield

ទី១ ក្រៅពីគោបុរៈខាងកើតដែលជាច្រកចូលសំខាន់ឡើងទៅជាន់ទី១ អ្វីៗសុទ្ធតែខូចខាតទាំងស្រុង...

កិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើងដោយលោក ហ្សង់ កូម៉ៃ ដើម្បីបោសសំអាតនិងអភិរក្សប្រាសាទទាំងមូលនេះជួយជំរុញឲ្យមានការប្ដេជ្ញាចិត្តរបស់អ្នកដែលបន្តវេនលោកក្រោយៗមកទៀត។ បន្ទាប់ពីអ្នកអភិរក្សដំបូងនេះទទួលមរណភាពយ៉ាងលឿននៅឆ្នាំ១៩១៦ អ្នកអភិរក្សក្រោយមកទៀតក៏បានធ្វើការអស់ពីកម្លាំងកាយចិត្ត មិនមែនថាមិនជួបការលំបាកនោះឡើយ ដើម្បីពន្យឺតដំណើរខូចខាតដ៏គួរឲ្យព្រួយបារម្ភនៅប្រាសាទបាពួន។ ជាអកុសលបញ្ហាមានច្រើនអនេក ហើយពេលខ្លះវាជាបញ្ហាគ្រោះមហន្តរាយយ៉ាងពិតប្រាកដ។ ជាអាទិ៍សភាពបាក់ធ្លាក់ថ្មដ៏ច្រើនសន្ធឹកសន្ធាប់នៅផ្នែកខាងជើងកើតឡើងនៅឆ្នាំ១៩២៣ ដែលក្នុងរយៈពេលតែមួយយប់ប៉ុណ្ណោះធ្វើឲ្យតួប្រាសាទប្រមាណមួយភាគបួន បានបាក់ធ្លាក់មកទាំងអស់ ហើយម្យ៉ាងទៀតនៅឆ្នាំ១៩២៩ ថ្មក៏បានបាក់ធ្លាក់ចុះមកយ៉ាងច្រើនដូចគ្នាដែរនៅផ្នែកខាងកើត។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងណាក្ដី ប្រាសាទបាពួននៅតែជាសំណង់មួយប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ធំបំផុតដែលពេលខ្លះយើងពិនិត្យឃើញមានក្ដីសង្ស័យនៅក្នុងរបាយការណ៍សកម្មភាពការងាររបស់អ្នកអភិរក្ស។

ដោយមានបំណងរៀបចំរចនាសម្ព័ន្ធនៃការអភិរក្សប្រាង្គប្រាសាទអង្គរឡើងវិញនៅឆ្នាំ ១៩៦០ បុរាណវិទូលោក ហ្គ្រោលីយេ បានធ្វើសេចក្ដីសង្ខេបនៃការសង្កេតរបស់អ្នកដែលធ្លាប់ធ្វើការងារកន្លងមកហើយក៏បានរៀបចំការដ្ឋានជួសជុលដ៏ធំជាងគេនៅអង្គរ។ មធ្យោបាយដែលគេប្រើនៅពេលនោះសក្ដិសមសម្រាប់ដោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងខាងលើនេះ ដូចជាការពង្រឹងក្រុមបច្ចេកទេសនិងវិទ្យាសាស្ត្រនៃសាលាបារាំងចុងបូព៌ាប្រទេសមានជំនួយពីសិប្បករជំនាញរាប់រយនាក់ ហើយទាំងអស់គ្នាសុទ្ធតែមានសម្ភារៈបរិក្ខារសមស្របដែលអនុញ្ញាតឲ្យគេចាប់ផ្ដើមសាកល្បងស្រោចស្រង់ប្រាសាទនេះជាលើកចុងក្រោយម្ដងទៀត។ គេបានគ្រោងពង្រឹងគ្រឹះប្រាសាទដែលមានលក្ខណៈទន់ខ្សោយដោយរុញដីគ្រឹះចូលទៅក្នុងវិញតាមរយៈមធ្យោបាយចាក់ថ្មបេតុងអាមេជុំវិញផ្ទៃខាងក្នុងនៃជញ្ជាំងគ្រឹះប្រាសាទ។ ដើម្បីសម្រេចឲ្យបាននូវបច្ចេកទេសដ៏ខ្ពស់បែបនេះ គេចាំបាច់ត្រូវរុះរើថ្មនៅមុខទាំងបួននៃប្រាសាទជាបណ្ដោះអាសន្នសិន ដោយរៀបចំកត់ត្រាទុកជាមុននូវទីតាំងនៃដុំថ្មនីមួយៗនៅក្នុងប្រាសាទទាំងមូល។ នៅឆ្នាំ១៩៧០គម្រោងបានដំណើរការទៅមុខយ៉ាងល្អ ប៉ុន្តែសង្គ្រាមដែលបានរាលដាលដល់តំបន់ប្រាសាទបានធ្វើឲ្យវាសនាប្រាសាទបាពួនធ្លាក់ទៅក្នុងជ្រោះដ៏ងងឹតសាជាថ្មី។ ការដ្ឋានជួសជុលក៏ត្រូវបានបញ្ឈប់ជាបន្ទាប់ដែលនោះជាលើកទីមួយហើយបន្ទាប់ពីគេចាប់ផ្ដើមជួសជុលបានរយៈពេលដ៏ខ្លី ហើយការបិទការដ្ឋានជួសជុលជាបន្ទាន់នោះត្រូវបានធ្វើឡើងចុងក្រោយនៅឆ្នាំ១៩៧១។

មហាប្រាសាទដ៏ធំដែលឧទ្ទិសដល់ព្រះឥសូរ នៅក្នុងអំឡុងសតវត្សទី១៦ ប្រាសាទនេះត្រូវបានគេផ្លាស់ប្តូររូបរាងដោយការសាងសង់ចម្លាក់ ព្រះពុទ្ធរូបដ៏ធំមួយ ដែលផ្ទុំនៅលើជញ្ជាំងខាងលិចនៅជាន់ទី២

ការចាប់ផ្ដើមជាថ្មីនូវគម្រោងមួយដែលមិនអាចទៅរួច?

នៅទីបំផុតនៅឆ្នាំ១៩៩៥ ចេតនារួមគ្នានៃសាលាបារាំងចុងបូព៌ាប្រទេសនិងក្រសួងការបរទេស ព្រមទាំងក្រសួងវប្បធម៌នៃរដ្ឋាភិបាលបារាំង រួមគ្នាជាមួយនឹងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុញ្ញាតឲ្យគម្រោងដ៏ស្មុគស្មាញមួយនេះបានចាប់កំណើតឡើងសាជាថ្មីម្ដងទៀត។

ពិតណាស់ថាបែបបទពិតជាមិនសាមញ្ញនោះឡើយ ពោលគឺសំណុំឯកសារអំពីការដ្ឋានដែលគេរក្សាទុកជាហូរហែកន្លងមកក្នុងបណ្ដាទសវត្សឆ្នាំ៦០ ត្រូវបានគេគរលើគ្នា ហើយខ្លះត្រូវគេបំផ្លាញចោលនៅក្នុងការិយាល័យសាលាបារាំងចុងបូព៌ាប្រទេសនៅខែមេសា ឆ្នាំ១៩៧៥ ធ្វើឲ្យប្រាសាទបានក្លាយទៅជាគំនរថ្មបាក់បែកមួយដ៏ធំដែលគំរូដើមរបស់វាបានបាត់បង់ទាំង

ជាន់ទីពីរ

© Tushar Dayal



ផ្លូវចូលដែលជួសជុលរួច

© Lin Meil

ក្រោយពីចំណាយពេលជាច្រើនខែ ដើម្បីកត់ត្រាដុំថ្មដែលនៅរាយប៉ាយ ម្ដុំប្រាសាទនៅក្នុងផ្ទៃដីដែលមានព្រៃឈើដុះទ្រុបទ្រុល ប្រមាណជា ១០ហិកតា ក្រុមដែលទទួលបានការបណ្ដុះបណ្ដាលជាពិសេស នៅនឹងប្រាសាទផ្ទាល់តែម្ដង ទីបំផុតថ្មីៗនេះតថាមានលក្ខណៈ មិនប្រាកដប្រជាជាច្រើនក៏ដោយ ក៏បានធ្វើឲ្យប្រាសាទដ៏ធំខុសប្លែកពី គេមួយនេះចេញជារូបរាងដើមបានយ៉ាងជោគជ័យ

ស្រុងតែម្ដងៗនិងចុងក្រោយមួយទៀត គឺថា ដើមឈើបានដុះគ្របដណ្ដប់ទាំងស្រុងទៅលើ ផ្នែកដែលគ្មានលំនឹងនៅលើប្រាសាទបណ្ដាល ឲ្យមួយភាគបួននៃផ្នែកខាងជើងឈៀងខាងលិច នៅជាន់ទី២និងជាន់ទី៣បានបាក់ធ្លាក់ចុះមក យ៉ាងច្រើនបំផុត។

ក្រោយពីចំណាយពេលជាច្រើនខែដើម្បី កត់ត្រាដុំថ្មដែលនៅរាយប៉ាយម្ដុំប្រាសាទនៅក្នុង ផ្ទៃដីដែលមានព្រៃឈើដុះទ្រុបទ្រុលប្រមាណជា ១០ហិកតា ក្រុមដែលទទួលបានការបណ្ដុះ បណ្ដាលជាពិសេសនៅនឹងប្រាសាទផ្ទាល់តែម្ដង ទីបំផុតថ្មីៗនេះតថាមានលក្ខណៈមិនប្រាកដប្រជា ជាច្រើនក៏ដោយក៏បានធ្វើឲ្យប្រាសាទដ៏ធំខុស ប្លែកពីគេមួយនេះចេញជារូបរាងដើមបានយ៉ាង ជោគជ័យ។ ជាការពិតការលំបាកពិតជាមាន ច្រើនអនេកៈ តើត្រូវចាប់ផ្ដើមពីត្រង់ណាមក ចំពោះការដ្ឋានមួយដែលគេបានបោះបង់ចោល រយៈពេល២៤ឆ្នាំទៅហើយ ថែមទាំងមានការ បាត់បង់ឯកសារនិងការប្រឈមនឹងបញ្ហាបច្ចេក ទេសនៃការជួសជុលដែលតាំងពីពេលនោះមក មានការវិវត្តប្រែប្រួលយ៉ាងច្រើនទៅហើយនោះ? តើធ្វើដូចម្ដេចដើម្បីរក្សាគុណភាពវាំងដំណាក់ កាលប្រវត្តិសាស្ត្រទាំងពីរនៃការកែកុនប្រាសាទ (ដំណាក់កាលជំនឿលើព្រះឥសូរនិងដំណាក់កាល ជំនឿលើព្រះពុទ្ធសាសនា) ដែលក្នុងនោះជំនឿ មួយបានបញ្ចេញប្រតិកម្មធ្វើឲ្យខូចខាតដល់ជំនឿ មួយទៀត?

នៅចុងបញ្ចប់អស់រយៈពេល១៦ឆ្នាំកន្លង មកនេះការងារទាំងឡាយដែលបានធ្វើកន្លង មកជាងមួយសតវត្សបានឈានដល់ទីបញ្ចប់ ហើយដូច្នេះវាក៏ដល់ពេលដែលត្រូវធ្វើតុល្យការ ឡើងវិញដែរ។ ដំបូងគេសង្កេតឃើញនូវសារ ប្រយោជន៍នៃឯកសារអំពីប្រាសាទដែលគេបាន ជួសជុលរួច។ ការជួសជុលរចនាសម្ព័ន្ធរាងពីរ៉ាមីត ដំបូងដោយប្រើប្រាស់ទាំងស្រុងនូវគំរូចាក់ពុម្ព ចម្លាក់លំអផ្សេងៗនៅអង្គរពិតជាមានសារៈសំខាន់ បំផុត។ នៅទីនេះ ការជួសជុលបែបនេះបង្ហាញ លក្ខណៈស្ថាបត្យកម្មដ៏សំខាន់ដែលក្នុងប្រវត្តិ សាស្ត្រវាជាចំណុចចាប់ផ្ដើមប្រើប្រាស់ជាទូទៅ នូវថ្មភក់នៅក្នុងសិល្បៈនៃការសាងសង់ប្រាង្គ ប្រាសាទនៅអង្គរ។

ការជួសជុលគោបុរៈនៅជាន់ទី២ដែលជា ផ្នែកតែមួយគត់របស់ប្រាសាទដែលគេមិនបាន ប៉ះពាល់ក្នុងពេលប្ដូរទៅជឿលើសាសនាព្រះពុទ្ធ នៅសតវត្សទី១៦ក៏បង្ហាញនូវអត្ថប្រយោជន៍ ដ៏ពិតប្រាកដមួយដែរ។ ធ្លាក់នៅលើជញ្ជាំងដែល រៀបចំដូចជារូបគំនូរនៅក្នុងសៀវភៅតុក្កតាចម្លាក់ លបដែលលំអនៅតាមជញ្ជាំងខាងក្រៅប្រហែល ជាកស្តុតាងដ៏ចំណាស់ជាងគេអំពីវិធីរៀបរាប់ បែបនេះនៅអង្គរ ចម្លាក់ទាំងនេះក៏ត្រូវបាន ជួសជុលឲ្យដូចដើមវិញដែរហើយអនុញ្ញាតឲ្យ ភ្ញៀវទេសចរឃើញនូវការសាកល្បងបច្ចេកទេស ចម្លាក់រៀបរាប់បែបនេះដែលត្រូវបានគេកែច្នៃ ឲ្យកាន់តែល្អជាហូរហែនៅអង្គរក្នុងសតវត្ស ក្រោយៗមកទៀត។

ជាសេចក្ដីសន្និដ្ឋានគួររំលឹកឡើងវិញថា ការចុះតាមដានមើលប្រចាំថ្ងៃក្នុងរយៈពេល ជាច្រើនឆ្នាំក្នុងការដ្ឋានបែបនេះបានផ្ដល់ឲ្យយើង នូវឱកាសដ៏ល្អកម្ររកបានក្នុងការពិនិត្យនិងស្វែង យល់អំពីការលំបាកដែលអ្នកកសាងប្រាសាទនៅ ក្នុងសម័យអង្គរបានជួបប្រទះ។ វាក៏បានអនុញ្ញាត ផងដែរឲ្យយើងរកឃើញនូវដំណាក់កាលពីរបន្ត បន្ទាប់គ្នា នោះគឺសម័យនៃជំនឿលើព្រះឥសូរ (ពីសតវត្សទី១១ដល់សតវត្សទី១៦) និងសម័យ ជំនឿលើព្រះពុទ្ធសាសនា (សតវត្សទី១៦)។

មរតកដ៏មានតម្លៃនៃប្រាសាទបន្ទាយក្តី

សាស្ត្រាចារ្យ យូស៊ីអាគី អ៊ីស៊ីស្សាវ៉ា Yoshiaki Ishizawa
អ្នកដឹកនាំនៃបេសកកម្មស្រាវជ្រាវអន្តរជាតិដើម្បីអង្គរនៃសាកលវិទ្យាល័យសូហ្វីយ៉ា

ប៉មកណ្តាលនៃប្រាសាទបន្ទាយក្តី

© Lin Mei

ប្រាសាទ បន្ទាយក្ដី ស្ថិតនៅភាគ ឦសានចម្ងាយ ៦គ.ម ពីប្រាសាទអង្គរវត្ត។ ប្រាសាទនេះសាងឡើងនៅសតវត្សទី១២ ដើម្បីឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន។ ថ្មីៗនេះ បេសកកម្មសូហ្វីយ៉ាបានធ្វើកំណាយរកឃើញព្រះពុទ្ធបដិមាជាច្រើននៅប្រាសាទនេះដែលនេះជារបកគំហើញថ្មីមួយពុំធ្លាប់មានពីមុននៅក្នុងប្រទេសកម្ពុជា។ របកគំហើញព្រះពុទ្ធបដិមា ដ៏អស្ចារ្យនេះ ឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃសាសនាចាប់ពីស.វទី១០ ដល់ទី១៣ តាមរយៈការផ្លាស់ប្តូរអ្នកដឹកនាំ។

ការកប់ទុករយៈពេល៨០០ឆ្នាំ

ព្រះពុទ្ធបដិមាទាំងនោះយើងបានរកឃើញនៅក្នុងរណ្តៅមួយចម្ងាយ១៥០ម ពីផ្លូវចូលខាងកើត នៅពីមុខសំណង់តូចមួយបែរមុខទៅរកវានហាលនៃប្រាសាទបន្ទាយក្តី។ បដិមាទាំងនោះតម្រៀបគ្នាចន្លោះពី២០ស.មទៅ១,៨ម។ យើងក៏រកឃើញព្រះពុទ្ធរូបធ្វើអំពីសំរិទ្ធតូចៗពីរនៅទីនោះផងដែរ។

យើងរកឃើញបដិមាទាំងនោះនៅក្នុងជម្រៅដីពី១,៨មនិងទំហំ២ ម៉ែត្រការេ។ យើងបានរកឃើញព្រះពុទ្ធពេញជំហរតូចៗនិងព្រះកេសជាច្រើន ហើយរួមមានទាំងវត្ថុសិល្បៈធ្វើអំពីថ្មធំៗនិងបំណែកខ្លួននៃព្រះពុទ្ធរូបផងដែរ។ បដិមាទាំងនោះបោះចូលទៅក្នុងរណ្តៅជាន់ពីលើគ្នា ហើយព្រះកេសព្រះពុទ្ធរូបគឺបង្ហាញថាគេបំបែកហើយបានដាក់កប់ទៅក្នុងរណ្តៅ។ ក្នុងស្ថានភាពនេះ យើងចង់បញ្ជាក់ថាបដិមាទាំងនោះពិបាកនឹងជួសជុលឲ្យដូចភាពដើមវិញណាស់។

ថ្វីត្បិតបដិមាទាំងនោះ កប់ទុកក្នុងរយៈពេល៨០០ឆ្នាំក្តី ក៏បដិមាទាំងនោះស្ថិតនៅក្នុងបរិស្ថានមួយដែលមានកម្រិតកម្តៅនិងសំណើមថេរ ដូច្នោះហើយរូបទាំងអស់មានស្ថានភាពល្អគួរឲ្យកត់សម្គាល់។ បដិមាទាំងនេះ យើងគិតថាធ្វើនៅចាប់ពីសតវត្សទី១០ដល់ទី១៣។ យោងទៅលើការលម្អ ព្រះភ័ក្ត្រមានលក្ខណៈលម្អរួមនៃរចនាបថបាភួនក្នុងស.វទី១០និងអង្គរវត្តក្នុងស.វទី១២ ហើយក៏បង្ហាញពីភាពច្បាស់លាស់មួយនៃសិល្បៈក្នុងរចនាបថបាយ័ន ចាប់ពីស.វទី១៣ផងដែរ។ បដិមាដែលពេញជំហរមានលម្អខ្លួននាគគ្របពីលើ ដោយមានភ្នែនបីនិងក្បាលប្រាំពីរព័ទ្ធជុំវិញដើម្បីការពារព្រះពុទ្ធក្នុងពេលសមាធិ។

តាមរយៈរបកគំហើញដំបូងនេះ យើងបានពង្រីកការធ្វើកំណាយ ហើយរកឃើញព្រះពុទ្ធបដិមាសរុបទាំងអស់ចំនួន២៧៤អង្គ រួមមានថ្មគោលព្រះពុទ្ធសាសនាដែលមានឆ្លាក់ព្រះពុទ្ធរូបទ្រង់អង្គុយចំនួន១០០០អង្គ នៅគ្រប់ផ្នែកទាំងបួន។



ការរកឃើញថ្មីៗនូវរូបសំណាកនិងរូបរបស់ព្រះពុទ្ធនៅប្រាសាទបន្ទាយក្ដីធ្វើឡើងដោយមហាវិទ្យាល័យសូហ្វីយ៉ា ដែលស្វែងរកឃើញដំបូងនៅកម្ពុជា

ព្រះពុទ្ធធ្វើសមាធិការពារដោយនាគរាជ

© Sophia Asia Center for Research and Human Development, Sophia University

ព្រះពុទ្ធរូបប្រក់នាគ

បដិមាដែលរកឃើញពីការធ្វើកំណាយភាគច្រើនជាព្រះពុទ្ធរូបប្រក់នាគ ហើយរចនាបថនេះរីកសាយខ្លាំងនៅក្នុងសិល្បៈខ្មែរ។ ព្រះពុទ្ធរូបប្រក់នាគទាំងនេះបង្ហាញនៅពេលមួយដែលមានភ្លៀងធ្លាក់ខ្លាំងដូចជាទឹកជ្រោះក្នុងរយៈពេលមួយអាទិត្យនៅពេលដែលព្រះពុទ្ធព្រះអង្គទ្រង់ធ្វើសមាធិចំនួនប្រាំពីរថ្ងៃដើម្បីយាងទៅបរមនិព្វាន។ នៅពេលនោះ ស្តេចនាគឈ្មោះ“មចិលិន្ទ”ផុសចេញពីដីហើយមកការពារព្រះពុទ្ធដោយយកក្បាលទាំងប្រាំពីរមកគ្របពីលើនិងព័ទ្ធខ្លួនព្រះពុទ្ធ។

បដិមាដែលសំខាន់ជាងគេនៃព្រះពុទ្ធរូបប្រក់នាគជាទូទៅបាត់ក្បាលនៅពេលគេកប់ទុក ប៉ុន្តែក្រោយមកយើងរកឃើញហើយយកមកជំនួស។ ព្រះពុទ្ធទ្រង់អង្គុយដោយដាក់ដៃស្តាំលើបាតដៃឆ្វេង ហើយបិទព្រះនេត្រ គឺបង្ហាញពីលក្ខណៈសមាធិ។ព្រះពុទ្ធរូបមានកម្ពស់១២៥ស.មនិងទំហំ៤៧ស.ម។

ទោះបីជាព្រះពុទ្ធប្រក់នាគធ្វើដំបូងនៅរវាងពាក់កណ្តាលសតវត្សទី១០ ក្តី ប៉ុន្តែ បង្ហាញពីការទទួលឥទ្ធិពលបដិមាដែលជាទេពក្នុងព្រហ្មញ្ញសាសនានៅសម័យកាលនោះ។ ទំនោរនៃការលម្អបែបលាយបញ្ចូលសាសនានេះអាចឃើញមាននៅលើក្នុងសក់ព្រះពុទ្ធ ដែលប្តូរពីសក់រួញកណ្តាញ់មកជាលាតដោយមានរាងជាម្កុដ។ព្រះពុទ្ធបដិមាខ្លះបង្ហាញពីភាពស្រដៀងគ្នាទៅនឹងរចនាបថអង្គរវត្តដែលយើងសន្និដ្ឋានថាមានការទទួលឥទ្ធិពលពីការលម្អបែបព្រះពុទ្ធសាសនានៅសម័យនោះ។



សសរដែលមានរូបដិមាព្រះពុទ្ធអង្គុយចំនួនមួយពាន់

© Sophia Asia Center for Research and Human Development, Sophia University

នៅពេលដែលសាសនាព្រះពុទ្ធបានចូលមកកម្ពុជានៅសតវត្សរ៍ទី៦ មានរូបបដិមាព្រះពុទ្ធមួយចំនួនត្រូវបានឆ្លាក់ ប៉ុន្តែនេះជាការរកឃើញទីមួយអំពីសសរដែលមានឆ្លាក់រូបព្រះពុទ្ធចំនួនមួយពាន់

ថ្មគោលព្រះពុទ្ធសាសនា

ពេលព្រះពុទ្ធសាសនាចូលមកប្រទេសកម្ពុជានៅស.វទី ៦ គេឆ្លាក់ព្រះពុទ្ធរូបជាច្រើន ប៉ុន្តែ ការរកឃើញថ្មគោលព្រះពុទ្ធសាសនានេះគឺជាលើកទីមួយ។ ក្រៅពីរូបព្រះពុទ្ធតូចៗចំនួន១ ០០០អង្គ នៅគ្រប់ជ្រុងទាំងបួនផ្នែកខាងលើមានត្រៃរូបព្រះពុទ្ធសាសនា។ ថ្មគោលព្រះពុទ្ធសាសនានេះមានកម្ពស់១២០ស.ម និងទំហំ ៤៥ស.ម។ ស្រដៀងនឹងករណីទាំងនេះ គឺរូបព្រះពោធិសត្វលោកេស្វរ នៅសម័យដូចគ្នាដែលគេរកឃើញនៅបាកាន (ព្រះខ័នកំពង់ស្វាយ)។ បដិមានេះបង្ហាញអំពីចំណង់មួយផ្នែកនៃរូបលោកេស្វរ ដែលសាយភាយនូវគុណធម៌និងចិត្តមេត្តាចំពោះមនុស្សទាំងជិតទាំងឆ្ងាយ។

ឧទាហរណ៍ ផ្សេងទៀត ដែលទាក់ទងនឹងប្រវត្តិសិល្បៈនៃវត្ថុសិល្បៈទាំងនេះ គឺថ្មគោល ព្រះនារាយណ៍នៅពាក់កណ្តាលទី ២ នៃសតវត្សទី ១២ ។ គេរកឃើញបដិមារូបព្រះនារាយណ៍ ចំនួន១០២០អង្គនៅថ្មគោលតម្រៀបជា១៥ជួរផ្តេកនិង១៧ជួរបញ្ឈរ ហើយឆ្លាក់គ្រប់ជ្រុងទាំងបួនដូចថ្មគោលព្រះពុទ្ធសាសនារកឃើញនៅស្រុកខ្មែរដែលបង្ហាញអំពីការទទួលឥទ្ធិពលពីសិល្បៈបែបព្រហ្មញ្ញសាសនា។ លើសពីនេះរូបលោកេស្វរ ដែលរកឃើញនៅបាកានមានឆ្លាក់រូបព្រះពុទ្ធតូចៗ នៅផ្នែកចន្លោះពីក្បាលនិងដងខ្លួនផ្នែកខាងលើ គឺ មានលក្ខណៈស្រដៀងគ្នានឹងថ្មគោលព្រះពុទ្ធសាសនា។

ហេតុអ្វីបានជាគេកប់ទុកចោលព្រះពុទ្ធបដិមាទាំងនេះ? នៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (រវាងឆ្នាំ ១១៨១ ដល់ ១២១៩) គេបានសង់ប្រាសាទព្រះពុទ្ធសាសនាជាច្រើននិងមានភាពរីកចម្រើនខ្លាំង។ គេគិតថាស្តេចគ្រងរាជ្យបន្ទាប់ពីព្រះបាទជ័យវរ្ម័ន ទី ៧ គឺព្រះបាទជ័យវរ្ម័ន ទី ៨ (១២៤៣ ដល់១២៩៥) ជាស្តេចដែលគោរពព្រហ្មញ្ញសាសនា ហើយហាក់បីដូចជាបានបញ្ជាឲ្យគេដាប់ ឬបំផ្លាញរូបព្រះពុទ្ធទាំងនោះ។

ឥឡូវនេះ យើងយល់ច្បាស់នូវមូលហេតុនៃការបំផ្លាញព្រះពុទ្ធបដិមាទាំងនោះ។ អ្វីដែលគេមិនចង់ថែរក្សាព្រះពុទ្ធរូបទាំងនោះ គឺឲ្យអ្នកស្រាវជ្រាវបុរាណវិទ្យាយល់អំពីជម្រៅរួមរបស់ប្រវត្តិសាស្ត្រនៃការប្រគួតប្រជែងរវាងសមាជិករាជវង្សមុនហើយនិងអ្នកមានជ័យជំនះដែលបានការពារឈ្មោះសម្រាប់រាជបល្ល័ង្ករបស់ពួកគេ។

កិច្ចប្រជុំពេញអង្គលើកទី ៣៧
នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក
ពិធីបំពាក់គ្រឿងឥស្សរិយយស

លោកជំទាវ អ៊ីរីណា បូកូវ៉ា

© ទីស្តីការគណៈរដ្ឋមន្ត្រី

លោក កូអ៊ីឈី ម៉ាតស៊ូរ៉ា

© ទីស្តីការគណៈរដ្ឋមន្ត្រី

សាស្ត្រាចារ្យ អាហ្សេឌីន បេសចាអ៊ូច

© ទីស្តីការគណៈរដ្ឋមន្ត្រី

លោក គីស័រ រ៉ាវ

© ទីស្តីការគណៈរដ្ឋមន្ត្រី

លោកជំទាវ អានឡឺម៉ែត្រ

© ទីស្តីការគណៈរដ្ឋមន្ត្រី

ប្លង់ឧជុកោណនៃរាជបុរីអង្គរធំ

លោក ហ្សាក់ ហ្គោសេ Jacques Gaucher
សាស្ត្រាចារ្យសាលាបារាំងចុងបូព៌ាប្រទេស
ប្រធានបេសកកម្មបុរាណវិទ្យាបារាំងនៅអង្គរធំ



ក្លោងទ្វារខាងត្បូងនិងស្ពានហាលចូលអង្គរធំ

© Anne Roberts

អង្គរធំ (ផ្នែកខាងត្បូងនៃអង្គរធំ នៅរូបផ្នែកខាងស្ដាំ) មានព្រំប្រទល់ខណ្ឌចែកដោយកសិណខាងត្បូង បារាយណ៍ខាងលិចនិងភ្នំបាខែង ដែលជាស្នាដៃដ៏ធំទាំងបីនៃទីក្រុងក្នុងឧទ្យានអង្គរ

© Jacques Gaucher

វាលទំនាបអង្គរបានឆ្លងកាត់ដំណាក់កាលនគរូបនីយកម្មតាមបែបទម្រង់មួយដ៏ថ្មីស្រឡាងនៅចន្លោះពីសតវត្សទី១១ដល់សតវត្សទី១៣

នៅពាក់កណ្ដាលផ្លូវពីភ្នំគូលែន នៅខាងជើងទៅបឹងទន្លេសាបនៅខាងត្បូង វាលទំនាបអង្គរបានឆ្លងកាត់ដំណាក់កាលនគរូបនីយកម្មតាមបែបទម្រង់មួយដ៏ថ្មីស្រឡាងនៅចន្លោះពីសតវត្សទី១១ដល់សតវត្សទី១៣។ ការប្រមូលផ្ដុំអំណាចនិងស្ថិរភាពនៃព្រះរាជាណាចក្រខ្មែរនាពេលនោះ បានអនុញ្ញាតឲ្យមានការអភិវឌ្ឍក្រុងមួយដែលនៅក្នុងប្រវត្តិសាស្ត្រនៃការរៀបចំក្រុងនៅក្នុងសង្គមបុរេឧស្សាហកម្មមានលក្ខណៈពិសេសប្លែក ដោយសារទំហំការរៀបចំសំណង់ស្ថាបត្យកម្មធំតូចទាំងឡាយសភាពស៊ុចង្វាក់គ្នានៃសំណង់ដែលគេកសាងឡើងជាបន្តបន្ទាប់នៅក្នុងប្រវត្តិសាស្ត្រ។ ព័ទ្ធជុំវិញទៅដោយដីកសិកម្មដ៏ធំល្វឹងល្វើយនិងមានភូមិឋានរបស់អ្នកស្រុកដែលបង្ហាញថាជាតំបន់សម្បូរទៅដោយស្រូវស្រែ ទីប្រជុំជនក្នុងឧទ្យានអង្គរពិតជាមានសំណង់ធំតូចនិងមនុស្សរស់នៅជាច្រើននោះគឺអង្គរធំ។

ស្នាដៃនៃកំពូលព្រះមហាក្សត្រមួយព្រះអង្គ

ចាប់តាំងពីឆ្នាំ១៩០៩មក ការងាររបស់បុរាណវិទូសាលាបារាំងចុងបូព៌ាប្រទេសបានឈានទៅដល់ការផ្ដុំឡើងវិញជាលើកដំបូងនូវភាពប្រទាក់ក្រឡាគ្នានៃសំណង់ធំៗទាំងឡាយក្នុងទីក្រុងនេះ។អង្គរធំនៅសម័យនោះប្រហែលជាមានលក្ខណៈស្រដៀងគ្នាទៅនឹងអ្វីដែលភ្ញៀវទេសចរឃើញនាពេលបច្ចុប្បន្ននេះ។ ទីក្រុងដែលមានកំផែងខ្ពស់ព័ទ្ធជុំវិញមួយនេះ មានរាងការ៉េ ដែលជ្រុងនីមួយៗមានប្រវែង៣ គីឡូម៉ែត្រ និងព័ទ្ធជុំវិញទៅដោយកសិណទឹក មានចម្ងាក់លំអ ទទឹង១០០ម៉ែត្រ ឆ្លងកាត់ដោយស្ពានហាលចំនួន៥ បង្កើតជាផ្លូវចូលដែលមានក្លោងទ្វារធំៗចំនួន៥ដែរ។ នៅខាងក្នុងក្រុងនេះត្រូវបានរៀបចំឡើងជុំវិញចំណុចកណ្ដាលចំនួន២។ ម្យ៉ាងគឺនៅចំកណ្ដាលក្រុងមានប្រាសាទមួយឧទ្ទិសដល់ព្រះពុទ្ធសាសនានោះគឺប្រាសាទបាយ័នដែលកំណត់រចនាសម្ព័ន្ធក្រុងជាទម្រង់ខ្វែង មានផ្លូវធំៗចំនួន៤កាត់ខ្វែងគ្នា បង្កើតបានជាផ្ទៃការ៉េចំនួនបួនផ្សេងទៀត។ ម្យ៉ាងទៀត ផ្ដើមចេញពីការ៉េខាងជើងឈៀងខាងលិច ដែលជាទីតាំងព្រះបរមរាជវាំងជាប់នឹងផ្លូវដ៏ធំមួយនាំទៅកាន់បារាយណ៍ខាងកើតក្រៅកំផែងមានរចនាសម្ព័ន្ធក្រុងសមប្បមាណមួយទៀតជាដើមចមនៃទីលានកណ្ដាលដ៏ធំមួយដែលធ្វើឲ្យសំណង់ធំៗក្នុងទីក្រុងមានលក្ខណៈស៊ុចង្វាក់គ្នា។ ថ្វីបើកាលបរិច្ឆេទនៃព្រះបរមរាជវាំងគឺនៅចុងសតវត្សទី១០ផ្ទុយទៅវិញ កសិណ ជញ្ជាំងកំផែង ក្លោងទ្វារ ប្រាសាទនៅចំកណ្ដាលព្រមទាំងសំណង់ធំៗផ្សេងទៀតត្រូវបានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។ នៅសម័យនោះ អង្គរធំគឺជាស្នាដៃឯកនៃមហាក្សត្រអង្គនេះ ហើយតាមរយៈក្រសែចក្ខុដែលមាននៅលើកំពូលខ្ពស់ៗនៃប្រាសាទដែលរំលេចទៅដោយព្រះភក្ត្រធំៗតាមរយៈចម្លាក់អាទិទេពនិងយក្សប្រយុទ្ធគ្នាគ្មានទីបញ្ចប់នៅក្នុងការបង្កើតភពផែនដី វាគឺជាលក្ខណៈចម្បងនៃការកសាងសាជាថ្មីនូវអាណាចក្រខ្មែរនៅដំណាច់សតវត្សទី១២។

លក្ខណៈថ្មីនៃទីក្រុង

មានតែទេវកថាឥណ្ឌាដែលនិទានអំពីលោកសន្និវាសប៉ុណ្ណោះដែលរៀបរាប់ចំៗអំពីលក្ខណៈជានិមិត្តរូបទាំងនេះ ថ្វីបើលក្ខណៈទាំងនេះស្ដែងឡើងក្នុងអាណាចក្រដែលមានលក្ខណៈដូចភពនៃទេវកថា ប៉ុន្តែលក្ខណៈទាំងនេះក៏ដោះស្រាយបានផងដែរនូវបញ្ហានៃការរៀបចំក្រុងថ្មីមួយ ដែលមានផ្ទៃដីខាងក្នុងកំផែងប្រមាណជា៩ លានម៉ែត្រក្រឡា គ្របដណ្ដប់ទៅដោយព្រៃឈើហើយរហូតមកដល់បច្ចុប្បន្ននេះគេនៅមិនទាន់ដឹងច្បាស់នៅឡើយទេ។ តើការរៀបចំរូបីនិងអរូបី ការរៀបចំរូបសាស្ត្រនិងការរៀបចំ

សង្គមមានទម្រង់យ៉ាងដូចម្តេច? រចនាសម្ព័ន្ធដ៏ពិសេសនិងក្លោងទ្វារបិទបើកអង្គរធំត្រូវបានកាត់ផ្តាច់ពីទីប្រជុំជនក្នុងក្រុងអង្គរ ទាំងមូលនិងពីតំបន់ជុំវិញឬយ៉ាងណា? តើវាមានដំណើរការយ៉ាងដូចម្តេច ទើបធ្វើឲ្យមនុស្សអាចរស់នៅក្នុងក្រុងនេះបាន? តើអ្វីដែលប្រវត្តិសាស្ត្រនៃរមណីយដ្ឋាននេះបញ្ជាក់ឲ្យឃើញនូវការកសាង ទីក្រុងថ្មីមួយនោះគឺរាជបុរីរបស់ព្រះបាទជ័យវរ្ម័នទី៧ ឬក៏ជាការកសាងទីក្រុងនៅក្នុងទស្សនវិស័យរយៈពេលវែង? កម្រមានប្រភពឯកសារណាដែលអាចឆ្លើយនឹងចំណោទសំណួរទាំងនេះបានណាស់។ ដូច្នេះហើយទើបវាគឺជាការងារស្នូលនៃកម្មវិធីបុរាណវិទ្យាក្រុងដែលកំពុងត្រូវបានអនុវត្តនៅក្នុងក្របខណ្ឌ កិច្ចសហប្រតិបត្តិការរវាងសាលាបារាំងចុងបូព៌ាប្រទេស និង អាជ្ញាធរអប្សរា នោះ គឺបេសកកម្មបុរាណវិទ្យា បារាំងនៅអង្គរធំ ហៅកាត់ថា MAEE។ ការសិក្សាលើកដំបូងទៅលើទួល ដីបុរាណ នៅក្នុងក្រុង ទាំងស្រទាប់ដីលើ ទាំងជម្រៅខាងក្រោម នៅតាមទីតាំងផ្សេងៗបានអនុញ្ញាតឲ្យយើងធ្វើការរៀបចំប្លង់អង្គរធំថ្មីឡើងវិញ។ ធ្វើឡើងដោយប្រើមាត្រដ្ឋាន ១/២០០០ ប្លង់នេះ ស្រដៀងគ្នានឹងប្លង់សុរិយោដីផូស៊ីលដែលមានបន្ថែមព័ត៌មានបុរាណវិទ្យានិងព័ត៌មានស្រទាប់ដីនៃការធ្វើកំណាយជាង៣០០ កន្លែងនៅក្នុងក្រុងនេះ។

ប្លង់ឧជុកោណនៃរាជបុរីអង្គរធំ ដូចដែលបានរៀបចំឡើងវិញដោយ ហ្សាក់ ហ្គោសេ ឆ្នាំ២០០៧

© Jacques Gaucher

នៅចំកណ្តាលក្រុងមានប្រាសាទមួយឧទ្ទិសដល់ព្រះពុទ្ធសាសនានោះគឺប្រាសាទបាយ័នដែលកំណត់រចនាសម្ព័ន្ធក្រុងជាទម្រង់ខ្វែង មានផ្លូវធំៗចំនួន៤កាត់ខ្វែងគ្នាបង្កើតបានជាផ្ទៃការ៉េចំនួនបួនផ្សេងទៀត

ក្រៅអំពីបន្ទាយខាងក្នុង មានផ្ទៃដីប្រមាណជា៩០ហិតា ដែលនៅក្នុងនោះព្រះបរមរាជវាំងត្រូវបានកសាងឡើងជាប់ជាមួយនឹងប្រព័ន្ធទឹកដ៏ធំមួយនិងស្មុគស្មាញបំផុត។ ប្លង់ថ្មីនេះបង្ហាញគំនូសផ្សេងៗដែលមាននៅលើផ្ទៃដីនៃការ៉េទាំង៤ក្នុងក្រុងមានទម្រង់ដូចជាចង្អូរៗ។ចង្អូរទាំងនេះមានរាងត្រង់គឺជាទម្រង់សំណល់ដី។ នៅក្នុងប្លង់ជាទូទៅ ចង្អូរទាំងនេះ មើលទៅដូចជាដាច់ៗ ប៉ុន្តែនៅពេលជីកដីមើលជាក់ស្តែងវាគឺជាស្រទាប់លើនៃរចនាសម្ព័ន្ធដែលកប់បាត់ឬក៏ត្រូវគេលុបដីពីលើ។ ទទឹងរបស់វាអាចមានពី៧ទៅ២០ម៉ែត្រ។ ក្រោយពីរៀបចំផ្គុំឡើងវិញរួចហើយបណ្តោយនៃចង្អូរទីមួយៗត្រូវនឹងទំហំនៃការ៉េមួយ ពោលគឺមធ្យមប្រមាណជា១៤០០ម៉ែត្រ។ រចនាសម្ព័ន្ធចង្អូរទាំងនេះមានទិសស្របគ្នាឬក៏រាងឧជុកោណជាទូទៅសំដៅទៅតាមទិសធំៗទាំងបួននិងបន្តពីការ៉េមួយទៅការ៉េមួយ នៅតាមខ្សែបន្ទាត់តែមួយៗ

ដូច្នេះ ការរៀបចំក្រុងអង្គរធំគោរពទៅតាមខ្សែបន្ទាត់ពីរ។ ទីមួយ ពាក់ព័ន្ធនឹងការកសាងក្រុងទៅតាមទិសកើត-លិច។ ជាទូទៅការរៀបចំបែបនេះមានលក្ខណៈស៊ីចង្វាក់គ្នាទៀងទាត់និងផ្អែកទៅលើឡូទីមួយៗ៩០ម៉ែត្រ។ការខណ្ឌចែកដីបែបនេះ គេពុំឃើញមាននៅផ្នែកខាងកើតនៃក្រុងទេ ទីតាំងខាងកើត គឺទល់មុខនឹងព្រះរាជបន្ទាយដែលនៅទីនោះមានសំណង់តិចតួចនៅម្តុំប្រាសាទបាពួន។ ផ្ទុយទៅវិញការស្រាវជ្រាវដំបូងៗបានឲ្យដឹងថា ការខណ្ឌចែកដីបែបនេះពិតជាធ្លាប់កើតមាននៅត្រង់ទីតាំងនេះមែន វាជាសម្មតិកម្មដែលកាន់តែគួរឲ្យជឿជាក់ថែមទៀតតាមរយៈរបកគំហើញនៃរចនាសម្ព័ន្ធទឹកមួយដែលកប់ក្នុងដីជម្រៅ៣ម៉ែត្រនៅតាមទិសនៃចង្អូរដែលគួរមានៗកំណាយលើកទី២ នៅក្នុងអង្គរធំត្រូវបានធ្វើឡើងទៅតាមទិសជើង-ត្បូង។ គំនូសចង្អូរមិនសូវមានច្រើនទេហើយក៏មិនសូវមានលក្ខណៈថេរដែរ ផ្ទុយទៅវិញគំនូសខ្លះបង្កើតបានជាទម្រង់ថេរដែលត្រូវនឹងទំហំឡូមួយប្រវែង៣៦០ម៉ែត្រ។ សរុបទាំងអស់នៅខាងក្នុងការ៉េទាំងបួន គំនូសខ្វាត់ខ្វែង ដែលបច្ចុប្បន្នបានរកឃើញនៅក្នុង ក្រុងអង្គរធំដោយភាពប្រាកដប្រជា គឺផ្គុំឡើងដោយចង្អូរចំនួន ៧១ (២៤ទិសជើង-ត្បូង ៤៧ ទិសកើត-លិច) ហើយបន្ថែមពីលើនោះ មានចង្អូរ៦ទៀតនៅក្នុងទិសកើត-លិច ដែលកប់បាត់ ពោលគឺសរុបទាំងអស់មានចង្អូរតភ្ជាប់គ្នាជាង ១០០ គីឡូម៉ែត្រដែលខណ្ឌចែកផ្ទៃដីសម្រាប់រស់នៅប្រមាណជា ៣០០ឡូ។

ប្រព័ន្ធផ្លូវទឹក

ការសិក្សាបុរាណវិទ្យាដំបូងៗដែលបានធ្វើឡើងទៅលើចង្អូរមួយចំនួនបានអនុញ្ញាតឲ្យរកឃើញនូវរចនាសម្ព័ន្ធក្រុងពីរប្រភេទ នោះគឺប្រព័ន្ធផ្លូវថ្នល់និងប្រព័ន្ធផ្លូវទឹក៖ ផ្លូវនានាដែលពេលខ្លះអមទៅដោយប្រឡាយនិងផ្លូវទឹកតូចធំ ការពារមិនឲ្យមានចរាចរណ៍តាមទូក។ មុខងារនេះពិតជាមានដំណើរការល្អ។ គំនូសខ្លះបង្ហាញលក្ខណៈថេរតាំងពីដំបូងមក។ ចំណែកឯគំនូសផ្សេងទៀតផ្ទុយទៅវិញគួរគួសបញ្ជាក់ថាចំណេះដឹងបុរាណវិទ្យាពិតប្រាកដអំពីប្រវត្តិរបស់វាមានលក្ខណៈស្មុគស្មាញ ដោយសារសម្ភារភាពការខូចខាតក្នុងពេលកន្លងមកការផ្លាស់ប្តូរមុខងាររបស់វាដែលអាចមានក្នុងពេលវិវត្តកន្លងមកឬក៏ការប្រែប្រួលមុខងារដែលអាចកើតឡើងនៅក្នុងសម័យដដែលទៅលើគំនូសតែមួយៗ គំនូស

ផ្លូវនិងផ្លូវទឹករបស់អង្គរធំ

© Jacques Gaucher

ប្លង់នេះបង្ហាញនូវស្នាដៃគំរូនៃការកសាងក្រុងមួយដ៏សមស្រប ប្រកបដោយទេពកោសល្យខ្ពស់ វាគឺជាការប្រមូលផ្តុំនូវចំណេះដឹងដំបូង ជាការពិពណ៌នាដំបូងនៃអត្តសញ្ញាណទីក្រុង

ខណ្ឌចែកទាំងនេះត្រូវបានកសាងឡើងនៅកន្លែងដែលមានខ្សាច់មិនសូវរឹងនិងមានការវិវត្តបែបធម្មជាតិបន្តរហូតមកនៅក្នុងទឹកដីនៃក្រុងដែលត្រូវបានផ្លាស់ប្តូរអស់ជាច្រើនសតវត្សរ៍។

កំណាយចំនួនពីរត្រូវបានធ្វើឡើងនៅខាងចុងនីមួយៗ នៃគំនូសមួយបានបង្ហាញអំពីស្ថានភាពបុរាណវិទ្យានិងលក្ខណៈខុសៗគ្នាយ៉ាងខ្លាំង ព្រមទាំងបានរកឃើញផ្លូវទឹកនៅខាងចុងនៃគំនូសមួយ ហើយអាចឲ្យយើងប៉ាន់ស្មានបានថាមានផ្លូវចរាចរណ៍ទៅខាងចុងម្ខាងទៀត។ ម្យ៉ាងវិញទៀត នៅអាស៊ីអាគ្នេយ៍ ការបែងចែកខុសគ្នារវាងថ្នល់ដែលទប់ទឹកភ្លៀងនិងផ្លូវទឹកដែលអាចរីងស្ងួតនៅពេលណាមួយក្នុងឆ្នាំ ឬក៏នៅពេលណាមួយក្នុងប្រវត្តិរបស់វា ហើយដែលត្រូវបានគេប្រើជាផ្លូវចរាចរណ៍ គឺកម្រមានណាស់។ ការវិភាគតែម្យ៉ាងទៅលើសាច់ដីកំណាយនៅតាមទីតាំងផ្សេងៗមិនអាចអនុញ្ញាតឲ្យយើងសន្និដ្ឋានបានអំពីមុខងារណាមួយនោះទេ ដូច្នេះ ត្រូវគិតដល់លក្ខណៈបរិបទផ្សេងទៀតដើម្បីបញ្ជាក់អំពីអត្តសញ្ញាណមួយឬអត្តសញ្ញាណច្រើននៃគំនូសណាមួយក្នុងប្រវត្តិរបស់វា។ ប៉ុន្តែទោះបីវាជាផ្លូវថ្នល់ក្តី ឬផ្លូវទឹកក្តី គំនូសទាំងនេះគឺជាហេដ្ឋារចនាសម្ព័ន្ធចម្រុះនៃប្រព័ន្ធផ្គត់ផ្គង់ចែកចាយស្បៀងបង្ហូរទឹកចេញនិងចូលក្នុងក្រុង។ ជាមួយហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដែលយើងបានរកឃើញ (ស្ពាន អូរ ស្រះទឹក) វាបង្កើតបានជាសំណុំមួយដែលអនុញ្ញាតឲ្យយើងយល់អំពីគោលការណ៍នៃប្រព័ន្ធ ធារាសាស្ត្រដែលគេបង្កើតឡើងនៅក្នុងក្រុងអង្គរធំ។

គំរូក្រុងរបៀបប៉ែកខាងកើតសុទ្ធសាធ

ប៉ុន្តែ ប្រសិនបើការខណ្ឌចែកដ៏ខ្វាត់ខ្វែងនៅអង្គរធំបញ្ជាក់យ៉ាងច្បាស់ អំពីបែបផែននៃការរៀបចំបច្ចេកទេសនិងមុខងារសំខាន់ៗក្នុងក្រុង ទស្សនាទាននៃការបង្កើតទីក្រុងនេះពិតជាគោរពទៅតាមគោលការណ៍និងគំនិតផ្សេងទៀត។ បើនិយាយដល់ក្រុងទាំងមូល ការលេចឡើងនូវរូបភាពដែលមានលក្ខណៈថេរផ្អែកទៅលើទំហំដីដូចៗគ្នាបង្កើតព្រំសីមាខណ្ឌចែកជាលក្ខណៈទៀងទាត់។ ក្រៅអំពីភាពមិនល្អឥតខ្ចោះមួយចំនួន វាកំណត់នូវរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នាផ្តុំឡើងដោយការ៉េចំនួន៦៤ ដែលជ្រុងនីមួយៗមានប្រវែង៣៦០ម៉ែត្រ។ ការខណ្ឌចែកដ៏ច្បាស់លាស់នេះគឺជាលក្ខណៈមួយក្នុងចំណោមលក្ខណៈគំរូល្អឥតខ្ចោះនៃរាជធានីឥណ្ឌាដែលគេកសាងឡើងទៅតាមគោលការណ៍នៃក្រឡាចាក់ត្រង់ ដែលមានទីតាំងច្បាស់លាស់សម្រាប់ទេវៈនៃអង្គនីមួយៗនៅក្នុងរមណីយដ្ឋានដែលមានរាងជាឧជុកោណ ហើយដែលក្នុងគោលគំនិតដំបូង គេតែងតែកសាងបូជនីយដ្ឋានបែបនេះទុកជាកន្លែងទីសក្ការៈ។ ការធ្វើបែបនេះជំនួសឲ្យការខណ្ឌចែកបែបសក្ការៈនៃទីតាំងមានលក្ខណៈជាក្រុងបន្ថែមទៅលើទម្រង់រាងការ៉េនៃអង្គរធំដែលគោរពដល់ទិសខាងកើតទៅលើទំហំហេដ្ឋារចនាសម្ព័ន្ធដ៏ធំជាក្រឡាកាត់ខ្វាត់ខ្វែងទៅលើការសាងសង់សំណង់ផ្សេងៗ នៅក្នុងប្លង់និងទៅលើទិសសំខាន់ជាងគេនៃសំណង់ទាំងនោះគឺទិសខាងកើត ទាំងនេះ សុទ្ធតែជាលក្ខណៈក្រុងសំខាន់ៗក្នុងគោលការណ៍លំនៅឋានរបស់ឥណ្ឌា។

នៅសល់ចំនុចមួយទៀតដែលថាប្រសិនបើលក្ខណៈថេរនៃប្លង់អង្គរធំ គឺជារឿងមួយដែលប្រាកដប្រជាហើយនោះ លក្ខណៈថេរនេះមិនអាចចាត់ទុកថាមានភាពម៉ឺងម៉ាត់ពេក ដូចទីក្រុងផ្សេងទៀតនៅអាស៊ីឡើយ ជាអាទិ៍មានទីក្រុងឆាងអាន ឬណារ៉ា ជាដើម។ ក្រោយពីការវិភាគលំអិត វាបង្ហាញឲ្យឃើញភាពមិនប្រក្រតីជាច្រើន។ ប្លង់មិនមែនមានរាងការ៉េឥតខ្ចោះ នោះឡើយ ទិសពីជើងទៅត្បូង មិនត្រូវបានគេកំណត់ចំកណ្តាលក្រុងនោះទេ វាពាក់ព័ន្ធនឹងសំណង់ផ្សេងៗជាច្រើន មានរួមបញ្ចូលទាំងគំលាតពីជួរតិចតួច ប៉ុន្តែគម្លាតនេះពិតជាមានន័យ។ មានសញ្ញាជាច្រើនដែលផ្តល់ជាគំនិតថាប្លង់ខ្វាត់ខ្វែងរាងការ៉េនៅអង្គរធំមិនត្រូវបានកសាងឡើងដោយទឹកដៃតែមួយនោះទេ ប៉ុន្តែគឺជាប្រតិបត្តិការនៃការរៀបចំផែនការបន្តបន្ទាប់តគ្នាមក។ នៅក្នុងន័យនេះ ប្លង់នេះបង្ហាញនូវស្នាដៃគំរូនៃការកសាងក្រុងមួយដ៏សមស្របប្រកបដោយទេពកោសល្យខ្ពស់ វាគឺជាការប្រមូលផ្តុំនូវចំណេះដឹងដំបូងជាការពិពណ៌នាដំបូងនៃអត្តសញ្ញាណទីក្រុងមួយដែលចាប់ពីពេលនេះតទៅ បុរាណវិទ្យាចាំបាច់ដាច់ខាតត្រូវស្រាវជ្រាវឲ្យកាន់តែខ្លាំងឡើងនៅក្នុងពេលតទៅមុខទៀត។

ការសិក្សាស្រាវជ្រាវថ្មីលើ រមណីយដ្ឋានអង្គរ ភ្នំគូលែន និងកោះកេរ តាមរយៈបច្ចេកវិទ្យា LiDAR ឆ្នាំ២០១២

បណ្ឌិត ដេមាន អេវ៉ាន Damian Evans
នាយកមជ្ឈមណ្ឌលស្រាវជ្រាវរូបីតក្រិសធី សៀមរាប

សាស្ត្រាចារ្យ រ៉ូឡែន ផ្លិចឈើរ Roland Fletcher
សាស្ត្រាចារ្យនៃសកលបុរាណវិទ្យានិងទ្រឹស្តីនៃសកលវិទ្យាល័យស៊ីដនី
នាយកនៃគម្រោងមហាអង្គរ

ឯកឧត្តម គាន ប៊ុនសួយ
អគ្គនាយករងទទួលបន្ទុកឧកសាលានៃអាជ្ញាធរជាតិអប្សរា



ស្លាកស្នាមនៃសណ្ឋានដីបង្ហាញអំពីរចនាសម្ព័ន្ធនៃនគរូបនីយកម្មសម័យអង្គរ ដែលស្ថិតនៅខាងក្នុងនិងខាងក្រៅកសិណាអង្គរវត្ត

© Damian Evans and Kasper Hanus

នៅខែមេសាឆ្នាំ២០១២បច្ចេកវិទ្យាLiDAR បានត្រូវយកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវបុរាណវិទ្យានៅលើផ្ទៃដីដែលមានទំហំប្រមាណ ៣០០គម² ដើម្បីថ្មុះមើលពីលើគ្រប់ផ្នែកកណ្តាលនៃឧទ្យានអង្គរ កោះកែរនិងភ្នំគូលែន ក្នុងគោលបំណងដើម្បីទទួលបានរូបភាពច្បាស់សុក្រឹតនិងមានទំហំពិតប្រាកដ (រូបថតទី១)។

កន្លងមកបច្ចេកវិទ្យានេះធ្លាប់បានយកមកប្រើនៅរមណីយដ្ឋានប្រវត្តិសាស្ត្រដទៃទៀតនានាដែរ។ យ៉ាងណាមិញដូចជា ឧទាហរណ៍មួយដែលគេធ្លាប់ប្រើ LiDAR ហើយបានទទួលលទ្ធផលគួរជាទីគាប់ចិត្តក្នុងការសិក្សាស្រាវជ្រាវនៅតំបន់ត្រូពិចដែលមានព្រៃគ្របដណ្តប់ដូចយើងដែលនោះគឺ ស្ថិតនៅទ្វីបអាមេរិកខាងត្បូង ឈ្មោះរមណីយដ្ឋានប្រវត្តិសាស្ត្រ ម៉ាយ៉ា នៃប្រទេស Belize។ ជាងនេះទៅទៀត LiDAR ត្រូវបានគេបង្កើតឡើងជាដំបូងសម្រាប់យកមកទៅធ្វើជាមធ្យោបាយស្រាវជ្រាវអំពីព្រៃឈើការប្រើប្រាស់ដីធ្លី ធនធានរ៉ែ និងធនធានទឹកផងដែរ។

នេះជាលើកដំបូងដែលបច្ចេកវិទ្យា LiDAR បានយកមកប្រើនៅអាស៊ី ហើយក៏ជាលើកដំបូងដែរដែលគេយកប្រើសម្រាប់ការសិក្សាស្រាវជ្រាវលើវិស័យបុរាណវិទ្យានៅស្ថានីយ៍ដែលមានទ្រង់ទ្រាយធំជាងគេក្នុងសកលលោក។

បច្ចេកវិទ្យានេះបានអនុញ្ញាតឱ្យអ្នកស្រាវជ្រាវគូរផែនទីលម្អិតបង្ហាញនូវរចនាសម្ព័ន្ធដែលមានលើដី ជាពិសេសរូបភាពដែលអាចមើលឃើញបានជាទម្រង់ 3D របស់ស្ថានីយ៍មួយនិងអាចថ្មុះទម្លុះគម្របព្រៃដែលបិទបាំងរមណីយដ្ឋានអង្គរទៀតផង។

របកគំហើញថ្មីនៃអង្គរ

LiDAR ប្រើកាំរស្មីឡាស៊ែរ(laser)ដែលបំពាក់ក្នុងប្រអប់ធំមួយចាប់ភ្ជាប់នឹងឧទ្ធម្ភាគចក្រសម្រាប់បាញ់ថ្មុះមកដី។ កាំរស្មីនេះពេលបញ្ចាំងថ្មុះមកដី ហើយក៏ថ្វាតពន្លឺចាំងត្រឡប់ឡើងទៅវិញនាំមកជាមួយនូវរូបភាពថតទាំងឡាយ ហើយចម្លងរូបភាពដូចដើមរក្សាទុកក្នុងឧបករណ៍ដែលបំពាក់ជាមួយនឹងឧទ្ធម្ភាគចក្រនោះ។ ការថ្មុះថតដោយប្រើកាំរស្មីតាមរយៈកែវពិសេសរបៀបនេះអនុញ្ញាតឱ្យអ្នកស្រាវជ្រាវគូរផែនទីដែលមាន ៣ទម្រង់3Dនៃសណ្ឋានដីព្រមទាំងរុក្ខជាតិដែលដុះពីលើផងដែរ។ ដើម្បីទទួលបានផែនទីបុរាណវិទ្យានៃរមណីយដ្ឋានអង្គរ ប្រកបដោយភាពសុក្រឹតខ្ពស់។ យើងបានកំណត់ប្រព័ន្ធ ទីតាំងភូមិសាស្ត្រ GPS ពីផ្កាយរណបព្រមទាំងកំណត់ផ្លូវហោះហើរដ៏ជាក់លាក់ដោយប្រៀបនឹងចំណុចគោលដែលបានបោះជាអចិន្ត្រៃយ៍នៅលើដី Bench mark។

នៅឆ្នាំ២០១២ មានស្ថាប័នស្រាវជ្រាវជាតិនិងអន្តរជាតិចំនួន៨(ប្រាំបី) បានចូលរួមសហប្រតិបត្តិការមួយយ៉ាងធំដែលមិនធ្លាប់មាននៅអង្គរនិងមានតំណាងប្រទេសចំនួន៧ ព្រមទាំងបានចូលថវិការួមគ្នាដើម្បីនាំយកបច្ចេកវិទ្យា LiDAR មកប្រើប្រាស់។ គម្រោងនោះមានឈ្មោះកាត់ថា KALC (Khmer Archaeology LiDAR Consortium)។

គម្រោងនេះត្រូវបានផ្តួចផ្តើមរៀបចំនិងទទួលខុសត្រូវបច្ចេកទេសដោយលោក Damian Evans តំណាងសាកលវិទ្យាល័យស៊ីដនីប្រទេសអូស្ត្រាលី ហើយនិងបានការចូលរួមសហការពីក្រុមអ្នកបច្ចេកទេសរបស់អាជ្ញាធរអប្សរាដឹកនាំដោយឯកឧត្តម តាន់ ប៊ុនស៊ុយ។

ជាការធម្មតានៅតំបន់អង្គរ មិនមានការអនុញ្ញាតឱ្យមានយន្តហោះណាមួយហោះហើរកាត់ពីលើឡើយតែគម្រោងនេះបានទទួលការអនុញ្ញាតពិសេសមួយដើម្បីអាចហោះហើរថ្មុះថតយករូបភាពពីខាងលើតំបន់នេះបានតាមរយៈកិច្ចព្រមព្រៀងពិសេស ដែលមានបួនភាគីផ្សេងគ្នាបានចុះហត្ថលេខាលើអនុស្សរណៈលើការយោគយល់គ្នាមួយ។ ភាគីទាំងនោះរួមមាន ៖ ក្រុមហ៊ុន PT McElhanney (ក្រុមហ៊ុនរបស់ប្រទេសកាណាដា ដែលមានសាខានៅប្រទេស ឥណ្ឌូនេស៊ី) ក្រុមសេវាត្រួតពិនិត្យផ្លូវអាកាស CATS ក្រុមហ៊ុនគ្រប់គ្រងព្រលានយន្តហោះ SCA និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល SSCA។

ចំណែកគ្រឿងបរិក្ខាសម្រាប់ថ្មុះស្ទង់ត្រូវបានបំពាក់ជាប់ជាមួយឧទ្ធម្ភាគចក្រមួយគ្រឿងដែលជួលពីក្រុមហ៊ុនឯកជននៅសៀមរាបឈ្មោះ Helistar Cambodia។ LiDAR បានផ្តល់លទ្ធផលហួសពីការស្មាន។ ទិន្នន័យសំខាន់ៗដែលទទួលបានមករួមមាន ៖

- ការហូរច្រោះដីយ៉ាងខ្លាំងនៅសម័យអង្គរ
- ការពង្រីកក្រុងយ៉ាងធំជុំវិញអង្គរវត្ត
- រចនាសម្ព័ន្ធព្រមទាំងទំនប់ទឹកជាច្រើននៅរមណីយដ្ឋានភ្នំគូលែន
- ការរៀបចំដីកសិកម្មនិងវិស្វកម្មស្របទៅតាមស្ថានភាពដីនៅកោះកែរ។

ក្នុងតំបន់ទាំង៣ គឺអង្គរ ភ្នំគូលែន កោះកែរ ដែលបានធ្វើការថ្មុះស្ទង់ យើងមើលឃើញស្ថានីយបុរាណជាច្រើន មានដូចជា ប្រាសាទ ការដ្ឋានយកថ្ម និងរចនាសម្ព័ន្ធក្រុងដែលយើងពុំបានស្គាល់ពីមុនមក។

ហេដ្ឋារចនាសម្ព័ន្ធមុនរាជព្រះបាទជ័យវរ្ម័នទី៧

នៅតំបន់អង្គរ អ្វីដែលយើងរកឃើញជាពិសេស គឺហេដ្ឋារចនាសម្ព័ន្ធផ្នែកកណ្តាលនៃ

នៅឆ្នាំ២០១២ ស្ថាប័នជាតិនិងអន្តរជាតិចំនួន៨ បានចូលរួមសហប្រតិបត្តិការមួយយ៉ាងធំដែលមិនធ្លាប់មាននៅអង្គរ តំណាងប្រទេសចំនួន៧ ហើយបានចូលថវិការួមគ្នាដើម្បីនាំយកបច្ចេកវិទ្យា LiDAR មកប្រើប្រាស់ ដែលគម្រោងនោះមានឈ្មោះកាត់ថា KALC

ក្រុមស្រាវជ្រាវអន្តរជាតិ KALC ក្នុងកម្មវិធីសិក្សាស្រាវជ្រាវ LiDAR

- អាជ្ញាធរជាតិសម្រាប់ការគ្រប់គ្រងនិងការពារអង្គរនិងតំបន់សៀមរាប (អប្សរា)
- សាលាបារាំងចុងបូព៌ាប្រទេស មជ្ឈមណ្ឌលសៀមរាប (EFEO)
- សកលវិទ្យាល័យស៊ីដនី មជ្ឈមណ្ឌលស្រាវជ្រាវ របៃតក្រិសធី សៀមរាប
- លេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (SCA)
- ក្រុមហ៊ុន Hungarian Indochina (HUNNICO)
- កម្មវិធីភ្នំគូលែន Archaeology & Development Found (ADF)
- ជប៉ុននិងអាជ្ញាធរអប្សរា ការការពារប្រាសាទអង្គរ (JASA)
- មូលនិធិរមនីយដ្ឋានពិភពលោក (WMF)

តួរលេខការសិក្សាស្រាវជ្រាវ LiDAR

- រយៈពេលហោះហើរគឺចាប់ពីថ្ងៃទី១៦ដល់ថ្ងៃទី២២ខែមេសាឆ្នាំ២០១២
- ចំនួនផ្ទៃក្រឡាសរុប៣០០គម២
- ចំនួនម៉ោងហោះហើរសរុបគឺ២០ម៉ោង
- ចម្ងាយហោះហើរសរុបគឺ១១៦៥គម
- កម្ពស់ហោះហើរជាមធ្យម ៨០០ម
- ឧបករណ៍ដែលបានប្រើប្រាស់មានម៉ាស៊ីន Leica ALS60 ជាមួយ class 4 laser ដែលមានប្រព័ន្ធសុវត្ថិភាពសម្រាប់ការពារភ្នែក
- ចំនួនចំណុចសរុបគឺ៤កោដិ
- កម្រិតលំអៀង <១៥សម ទាំងផ្ទៃរាបនិងបញ្ឈរ
- ចំនួនរូបថតសរុប៥ ០០០រូប
- Resolution របស់រូបថត១០សម
- ការបញ្ជូនទិន្នន័យទាំងអស់ទៅការិយាល័យអាជ្ញាធរអប្សរានៅទីក្រុងភ្នំពេញនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២

ទីក្រុងអង្គរដែលលាតសន្ធឹងឆ្ពោះទៅ ៖

- ខាងជើងឆ្ងាយហួសពីប្រាសាទព្រះខ័ន
- ខាងត្បូងឆ្ងាយហួសអង្គរវត្ត
- ហើយខាងកើតឆ្ងាយហួសប្រាសាទតាព្រហ្ម (រូប ថតទី២)។

រហូតមកទល់ពេលនេះលោកសាស្ត្រាចារ្យ Jacques Gaucher បានរកឃើញនូវការរៀបចំក្រុងអង្គរធំដែលមានបណ្តាញត្រូវបានបែងចែកខ្វាត់ខ្វែងជាក្រឡាចត្រង្គ មានផ្លូវ ប្រឡាយទឹក ស្រះតូចៗ នៅតាមគ្រប់ក្រឡា។ ទិន្នន័យថ្មីរបស់ LiDAR បានបង្ហាញឱ្យឃើញថាហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈដូចការស្រាវជ្រាវខាងលើហើយ ទំនងជាមានមនុស្សរស់នៅយ៉ាងច្រើនកុះករក្នុងក្រុងអង្គរធំ និងរីកសាយហួសឆ្ងាយពីកំពែងអង្គរធំទៅទៀត។ ប៉ុន្តែ មានករណីខ្លះក្រឡាចត្រង្គនៅក្នុងបរិវេណអង្គរធំមិនស៊ីគ្នាជាមួយក្រឡាចត្រង្គខាងក្រៅកំពែងទេ។ យើងក៏រកឃើញកស្តុតាងផងដែរដែលបង្ហាញថាហេដ្ឋារចនាសម្ព័ន្ធខាងក្នុងបានត្រូវស្ថាបនាឡើងមុនការកសាងកំពែងរបស់ប្រាសាទតាព្រហ្មនិងបន្ទាយក្តី។ បណ្តាញក្រឡាចត្រង្គចាស់ពុំមានព្រំដែនកំណត់ឡើយហើយរលាយចូលគ្នាជាមួយការរីកសាយនៃទីប្រជុំជនទៅខាងក្រៅក្រុង ដែលមានជាគោលដូចជា នៅស្រុកត្រពាំងប្រាសាទនិងទីវាលនៅជុំវិញប្រាសាទប្រែរូបនិងតំបន់អង្គរទាំងមូល។

អាស្រ័យដូច្នេះហើយ ដែលយើងអាចសន្និដ្ឋានបានថា ការរៀបចំទីក្រុងអង្គរធំរបស់ព្រះបាទជ័យវរ្ម័នទី៧ បានធ្វើឡើងនៅពីលើហេដ្ឋារចនាសម្ព័ន្ធ ដែលបានរៀបចំហើយនៅផ្នែកកណ្តាលនៃក្រុងអង្គរ។ LiDAR ក៏បានផ្តល់នូវទិន្នន័យដ៏សំខាន់មួយទៀតទាក់ទងនឹងសណ្ឋានដីដែរ។ ឧទាហរណ៍ នៅជាប់នឹងតំបន់ខាងលិចប្រាសាទតាព្រហ្ម យើងឃើញ កស្តុតាងនៃការហូរច្រោះដីយ៉ាងខ្លាំង តាមរយៈ ព្រែកដីកមួយហូរឆ្ពោះមកស្ទឹងសៀមរាបដែលនៅពេលនោះមាន រយៈកម្ពស់ដើមខ្ពស់ជាងស្ទឹងសៀមរាបសព្វថ្ងៃ(រូបថតទី៣)។

សារៈសំខាន់នៃសណ្ឋានរយៈកម្ពស់ដីថ្មី

លទ្ធផលចម្បងមួយទៀតរបស់LiDAR គឺបានបង្ហាញឱ្យឃើញនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធដ៏លម្អិតក្នុងអង្គរវត្ត។ កំពែងមិនមែនមានតែ ១ ទេគឺមាន៣ជាប់ៗគ្នាហើយកំពែងនីមួយៗសំខាន់ព័ទ្ធដោយកសិណ(គូទឹក) (វចនានុក្រម ជួន ណាត បោះពុម្ពឆ្នាំ១៩៦៨ ទំព័រ១៣៨) ដែលគេធ្លាប់ស្គាល់មកថាមានស្រះខ្លះៗនិងផ្លូវនោះពេលនេះបង្ហាញឱ្យឃើញជាបណ្តាញប្រព័ន្ធផ្លូវពេញលេញនិងស្រះទឹកជាហែរៗអមសងខាង ហើយបែងជាក្រឡាចត្រង្គ។ នៅខាងត្បូងកសិណ(គូទឹក)អង្គរវត្តយើងមើលឃើញរូបភាពដ៏អស្ចារ្យមួយដែលយើងមិនដឹងថាជាអ្វីនិងមិនធ្លាប់ស្គាល់ពីមុនគឺជារចនាសម្ព័ន្ធនៃទំនួលដីរត់ព័ទ្ធចុះឡើងជារាងគូទខ្យងស្ថិតក្នុងបរិវេណបួនជ្រុងទ្រវែងមួយដែលយើងក៏មិនធ្លាប់បានឃើញនៅអង្គរនិងបង្ហាញក្នុងវិស័យបដិមាសាស្ត្រ។ រចនាសម្ព័ន្ធនេះមានរាងចតុកោណកែង ដែលរងនីមួយៗនៃទំនួលដីមានទទឹង ១០ម៉ែត្រ និងបណ្តោយរាប់រយម៉ែត្រតម្រៀបគ្នាជាច្រើនជួរស្របៗគ្នា ហើយកន្លែងខ្លះរត់ព័ទ្ធជុំវិញត្រពាំងតូចៗ។ នៅចន្លោះរងយើងឃើញមានប្រឡាយទំហំស្មើរងដី។ រចនាសម្ព័ន្ធនេះបានផ្តុំឡើងជា៣កន្លែងផ្សេងគ្នាប៉ុន្តែមានតែផ្នែកខាងកើតទេដែលមើលឃើញច្បាស់។ រីឯផ្នែកកណ្តាលនិងខាងលិចត្រូវលុបអស់ជាច្រើនប្រហែលជាដោយសារការសាងសង់នូវបណ្តាញផ្លូវទឹកយ៉ាងធំរត់ពីលិចទៅកើតដែលអ្នកស្រុកសព្វថ្ងៃហៅថា «វាលសេរី» ហើយក៏មានគេធ្លាប់សង្ស័យថា ជាកសិណរបស់រាជធានីយសោធនៅចុងសតវត្សទី៩។

អ្វីដែលធ្វើឱ្យយើងភ្ញាក់ផ្អើលមួយទៀតគឺទិន្នន័យរបស់ LiDAR ស្តីពីសណ្ឋានរយៈកម្ពស់ដីលម្អិតដែលផ្តល់នូវភស្តុតាងជាមូលដ្ឋានថ្មីអាចឱ្យយើងដឹងពីអាយុកំណើតរបស់វា។ កសិណជុំវិញអង្គរវត្តប្រហែលជាបានត្រូវកែលម្អនៅពេលរៀបចំទីក្រុងអង្គរធំ៖

- ក្នុងបរិវេណអង្គរវត្តមានរៀបជាបណ្តាញផ្លូវនិងត្រពាំងដែលមានលក្ខណៈមិនខុសគ្នាពីបឹងមាលាដែលសង់មុនអង្គរវត្តជាង ៥០ឆ្នាំ
- លើសពីនេះទៅទៀត ក្នុងបរិវេណអង្គរវត្តដដែលនៅតំបន់ដែលជាទីតាំងមនុស្សរស់នៅស្ថិតនៅលើទួលខាងជើងនិងទួលខាងលិច។ នៅជុំវិញផ្នែកខាងក្រៅមានស្លាកស្នាមសំណង់ប្រាសាទតូចៗជាច្រើនដែលយើងពុំទាន់បានចុះបញ្ជីនៅឡើយ។

អាស្រ័យដោយហេតុដូច្នេះហើយយើងត្រូវសិក្សាស្រាវជ្រាវរចនាសម្ព័ន្ធនៅអង្គរវត្តនិងតំបន់ជុំវិញបន្ថែមបន្តទៀត។

ទីសក្ការៈរបស់មហេន្ទ្របព៌ត

ឯចំណែកនៅភ្នំគូលែនវិញការពិនិត្យរូបភាពជុំវិញប្រាសាទរង់ចិន(រូបថតទី៥) បានបង្ហាញឱ្យឃើញថាខ្នងរាបនៃខ្នងភ្នំត្រូវបានកែប្រែទ្រង់ទ្រាយកំណើតយ៉ាងខ្លាំងដោយការរៀបចំប្រព័ន្ធគ្រប់គ្រងទឹកបណ្តាញក្រឡាចត្រង្គនៃការរៀបចំដែនដីបណ្តាញទួលរៀបចំជាជួរៗហើយនិងសំណង់សាសនាជាច្រើនទៀតដែលមានទ្រង់ទ្រាយធំៗជាច្រើនហើយយើងពុំធ្លាប់ស្គាល់រហូតមកទល់ពេលនេះ។ ក្រុម Archaeology & Development Foundation កំពុងចុះមើលផ្ទៀងផ្ទាត់តាមស្ថានីយ៍មួយៗដោយផ្អែកតាមទិន្នន័យ ពី LiDAR។

តាមលទ្ធផល LiDAR បានបង្ហាញពីបូជនីយដ្ឋានជាទីសក្ការៈមហេន្ទ្របព៌តដែលយើងបានដឹងឮយូរមកហើយតាមសិលាចារឹកជាច្រើន។ បុរាណដ្ឋាននេះមានទ្រង់ទ្រាយធំគ្រប់ដណ្តប់ស្ទើរតែពេញខ្នងភ្នំគូលែន។ យោងតាមទិន្នន័យ LiDAR នេះហើយនាំឱ្យយើងអាចសន្និដ្ឋានបានថាភ្នំគូលែនពិតជាទីតាំងនៃរមណីយដ្ឋានដែលជាបុរីដ៏ចំណាស់មួយនៃមរតកវប្បធម៌ដ៏ធំមួយក្នុងចំណោមបុរីធំៗដែលមាននៅលើលោកយើងនេះ។

លើរូបថតទី៦ LiDAR បានបង្ហាញនូវការរៀបចំដីធ្លីដ៏មានទេពកោសល្យនិងមានសារសំខាន់ធំធេងនៃនគរូបនីយកម្មបុរាណមួយដែលស្ថិតនៅក្នុងខេត្តព្រះវិហារសព្វថ្ងៃ។ យើងមើលឃើញទំនប់ទឹកជាច្រើនដែលសង់នៅតាមចន្លោះស្ទឹងខាងជើងនិងកណ្តាលតំបន់កោះកេរដែលបញ្ជាក់ថាការសាងសង់នេះបានធ្វើឡើងដោយមនុស្សជាច្រើនជំនាន់។ លើសពីនេះទៅទៀតយើងមើលឃើញបណ្តាញភ្លឺស្រែយ៉ាងវែងដែលសព្វថ្ងៃបានត្រូវព្រៃគ្របដណ្តប់ជិតមិនអាចមើលឃើញនឹងភ្នែកបាន។

កស្តុតាងថ្មីបញ្ជាក់ថាកោះកេរមិនមែនជាទីអាស្រ័យនៅបណ្តោះអាសន្នទេប៉ុន្តែគឺជាក្រុងមួយដែលបានរៀបចំយ៉ាងហ្មត់ចត់សម្រាប់ការរស់នៅក្នុងរយៈពេលយូរ។ នៅកោះកេរ LiDAR បានបង្ហាញការធ្វើវិស្វកម្មគ្រប់គ្រងទឹកមិនចាញ់នៅអង្គរទេ។

វិសាលភាពបេសកកម្មធ្លុះស្ទង់នៃបច្ចេកវិទ្យា LiDAR នៅឆ្នាំ ២០១២

© Damian Evans

បេសកកម្មនៅអង្គរ ភ្នំគូលែន កោះកេរ នាឆ្នាំ២០១២ បានបង្ហាញពីសារសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យា LiDAR នៅក្នុងវិស័យស្រាវជ្រាវបុរាណវិទ្យានៅស្រុកខ្មែរក៏ដូចនៅអាស៊ីអាគ្នេយ៍ដែរ។ LiDAR បានផ្តល់នូវកស្តុតាងនៃលទ្ធភាពរបស់បច្ចេកវិទ្យាថ្មីដើម្បីឆ្លុះមើលស្ថានីយ៍បុរាណវិទ្យានៅក្នុងតំបន់ត្រូពិចរាប់ពីតំបន់មានព្រៃគ្របដណ្តប់រហូតដល់ទីវាលស្រឡះនៃវាលស្រែ។ តួយ៉ាងដូចអង្គរវត្តដ៏ល្បីល្បាញដែលធ្លាប់មានការសិក្សាស្រាវជ្រាវកន្លងមកជាច្រើនក៏គង់នឹងត្រូវធ្វើការសិក្សាបន្ថែមទៀត។ ទេសភាពទាំងមូលនៅជុំវិញភ្នំគូលែននិងកោះកេរ បានបង្ហាញទិដ្ឋភាពថ្មីៗដ៏គួរឱ្យភ្ញាក់ផ្អើលជាច្រើន ហើយបានបើកផ្លូវឱ្យអ្នកស្រាវជ្រាវធ្វើការបន្តទៅអនាគត ។

ប៉ុន្មានឆ្នាំកន្លងមកហើយការស្រាវជ្រាវនានានៅតំបន់អង្គរបានបង្ហាញនូវលទ្ធផលសំខាន់ៗជាច្រើនមកហើយ។ ដោយឡែកទិន្នន័យថ្មីដែលទើបនឹងទទួលបាននេះ តម្រូវឱ្យយើងបង្កើតផែនទីបុរាណវិទ្យានៃឧទ្យានអង្គរនិងតំបន់អង្គរទាំងមូលឡើងវិញក៏ដូចជានៅតំបន់កោះកេរជាបន្ទាន់សម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ និងការគ្រប់គ្រងបេតិកភណ្ឌក្នុងគោលដៅដើម្បីអភិរក្សនិងការពារអារ្យធម៌អង្គរដ៏អស្ចារ្យដែលកំពុងនៅមានស្លាកស្នាមនៅនឹងកន្លែងនៅឡើយប៉ុន្តែសំណល់ស្លាកស្នាមទាំងនោះកំពុងប្រឈមនឹងការបាត់បង់ជាបន្តបន្ទាប់។

ស្ថានភាពផ្ទៃដីនៅពីក្រោមគម្របព្រៃឈើក្នុងតំបន់កណ្តាលនៃឧទ្យានអង្គរ



© Damian Evans and Kasper Hanus

រូបបង្ហាញប្រព័ន្ធធារាសាស្ត្រសម័យអង្គរ យ៉ាងជាក់លាក់នៅជិតជ្រុងឦសាននៃក្រុងអង្គរធំ



© Damian Evans and Kasper Hanus

ការរៀបចំទ្រង់ទ្រាយធំរបស់មនុស្ស ផ្លាស់ប្តូរទេសភាពជុំវិញប្រាសាទរង់ចិន នៅភ្នំគូលេន



© Damian Evans and Kasper Hanus

ស្ថានភាពផ្ទៃដីនៅពីក្រោមគម្របព្រៃឈើ នៅតំបន់កោះកេរ



© Damian Evans and Kasper Hanus

ប្រាសាទព្រះវិហារ



គោបុរៈទី៣

© C. Frank Starmer

ប្រាសាទព្រះវិហារ
ប្រាសាទនៃភ្នំពិសិដ្ឋ

ឯកឧត្តម ផុច ភឿន
បុរាណវត្ថុវិទូ
ប្រធានអាជ្ញាធរជាតិសម្រាប់ការការពារប្រាសាទព្រះវិហារ
រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ច្រកខាងជើងទៅកាន់គោបុរៈទី៤

© Fabien Billaud

ប្រាសាទ ព្រះវិហារបានកសាងនៅលើខ្ពង់រាបដែលស្ថិតនៅលើទីវាលរាបរបស់ប្រទេសកម្ពុជាដើម្បីឧទ្ទិសដល់ព្រះឥសូរ(សិវៈ)។ប្រាសាទនេះកសាងនៅក្នុងទីតាំងដែលជាចំណុចកំពូលនៃចំរាក់ភ្នំដ៏ធំទូលាយ ហើយមានកម្ពស់ប្រមាណ៦២៥ម បើប្រៀបទៅនឹងកម្ពស់ទឹកសមុទ្រ។ ប្រាសាទព្រះវិហារបានកសាងនៅក្នុងទេសភាពដែលទាក់ទាញអារម្មណ៍មនុស្សយ៉ាងច្រើន ហើយស្ថិតនៅទិសខាងកើតបន្តិចនៃផ្នែកកណ្តាលរបស់ជួរភ្នំដងរែក។ ប្រាសាទនេះមានទីតាំងក្នុងទិសពាយព្យរបស់ខេត្តព្រះវិហារ ក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត មានចម្ងាយប្រមាណ ៤១២គ.ម ពីរាជធានីភ្នំពេញ។

មុននឹងបរិយាយពីការស្រាវជ្រាវ ហើយនិងការងារដែលបានធ្វើរួចហើយក្នុងបរិវេណរបស់ប្រាសាទនាពេលថ្មីៗនេះយើងសូមរំលឹកដល់ទិន្នន័យខ្លះៗស្តីពីប្រវត្តិសាស្ត្រនិងបុរាណវិទ្យា។

ការវិវឌ្ឍនៃប្រវត្តិសាស្ត្រ

ប្រាសាទព្រះវិហារ (ដែលមានន័យថាប្រាសាទនៃភ្នំពិសិដ្ឋ) ត្រូវបានចាត់ទុកដូចជារតនៈវប្បធម៌ដ៏ពិតមួយនៃប្រទេសកម្ពុជា។ ប្រវត្តិសាស្ត្រនៃប្រាសាទនេះបានឆ្លងកាត់រយៈពេលពាន់ឆ្នាំនាសម័យចក្រភពខ្មែរ។ ក្នុងរយៈពេលប្រមាណ១២០០ឆ្នាំប្រាសាទព្រះវិហារគ្របដណ្តប់បណ្តាខ្ពង់រាបនានាដែលស្ថិតក្នុងទីជិតខាងគ្នា។ ប្រវត្តិនៃប្រាសាទនេះកើតឡើងក្នុងសតវត្សរ៍ទី ៩ នៃ គ.ស ក្នុងពេលដែលរាជបុត្រព្រះនាមឥន្ទ្រាយុធ នៃព្រះបាទជ័យវរ្ម័នទី២ បានផ្តើមកសាងអាស្រមសម្រាប់ឧទ្ទិសដល់ទេពហិណ្ឌូនាមព្រះឥសូរ(សិវៈ) ក្នុងនាមនៃសិក្ខរេស្វរៈ (ស្តេចនៃទីខ្ពស់)។ ព្រះរាជបុត្រអង្គនេះបានតម្កល់លិង្គដ៏ធំមួយក្នុងទីនោះ (និមិត្តរូបលិង្គព្រះសិវៈ) ដែលនាំយកពីវត្តភូដែលជាប្រាសាទមួយបច្ចុប្បន្នស្ថិតនៅក្នុងទឹកដីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ផ្តើមចេញពីហេតុការណ៍នេះ សិលាចារឹកលេខ K៥៨៣ (រកឃើញក្នុងតំបន់អង្គរ) បានប្រាប់យើងថា នាភាគខាងដើមនៃសតវត្សទី៩ រាជបុត្រនាមឥន្ទ្រាយុធ បានទទួលបញ្ជាពីទេពព្រះឥសូរដើម្បីនាំយកលិង្គមួយមកតម្កល់នៅក្នុងរមណីយដ្ឋានព្រះវិហារដែលជាលិង្គដាប់យកពីថ្មភ្នំដ៏ធំនៃវត្តភូឈ្មោះថា ទីក្រុងរបស់ព្រះឥន្ទ្រ។ គឺលិង្គនេះហើយដែលបានទទួលនាមថា សិក្ខរេស្វរៈ "ស្តេចនៃទីខ្ពស់"។ សិលាចារឹកលេខK៣៨០ បានបញ្ជាក់បន្ថែមថា«ស្រីកទ្រេស្វរៈនៃលិង្គបុរី (វត្តភូ) បានយាងមកចាប់បដិសន្ធិជាថ្មីនៅក្នុងទីតាំងស្រីសិក្ខារេស្វរៈ (ព្រះវិហារ)... ដើម្បីសំដែងនូវអំណាចរបស់ទ្រង់ឱ្យគេអាចមើលឃើញ គឺធ្វើយ៉ាងណាឱ្យពិភពលោកទាំងមូលអាចមើលឃើញទ្រង់បាន»។

សសរស្តម្ភសម្គាល់ផ្លូវទៅកាន់ប្រាសាទព្រះវិហារ
© ChrisSteph LewisBoegeman

ប្រាសាទព្រះវិហារត្រូវបានចាត់ទុកថាជារតនវប្បធម៌ពិតប្រាកដក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនិងប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំនៃអាណាចក្រខ្មែរ

ប្រភពនានានៃប្រាសាទព្រះវិហារទំនងជាមានការពាក់ព័ន្ធទៅនឹងការមកតាំងទីពីខាងដើមនៃអាស្រមសមាធិនៅលើទីតាំងភ្នំនេះ។ អាស្រមនៃឥន្ទ្រាយុធអាចជាសំណង់អំពីឈើ។ សំណង់នេះគឺជាការបកស្រាយដោយភាពជឿនលឿននៃគំនិតដោយកិត្យានុភាពនយោបាយកើនឡើង ហើយនិងការវិវឌ្ឍសេដ្ឋកិច្ចនៃចក្រភពខ្មែរ។ ការងារកសាង ការសញ្ជឹងគិត ហើយនិងការពង្រីកដែលមានរយៈពេលជិត៣០០ឆ្នាំ ព្រមជាមួយនិងការរៀបចំឡើងវិញជាច្រើនផង ក្រោមរជ្ជកាលមហាក្សត្រនានាដូចជា ព្រះបាទសូរិយវរ្ម័នទី១ (១០០២ - ១០៥០) ហើយនិងព្រះរាជបុត្រនាមឧទយទិត្យវរ្ម័នទី២(១០៥០ - ១០៦៨)។

សិលាចារឹកខ្មែរនិងសំស្ក្រឹតចំនួន៤ នៃរមណីយដ្ឋាននេះជាសមាភាគដ៏ប្រពៃសម្រាប់ការកំណត់កាលបរិច្ឆេទ ពីព្រោះសិលាចារឹកទាំងនេះបញ្ជាក់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងព្រះបាទសុរិយវរ្ម័នទី១ ហើយនិងសំណង់ប្រាសាទព្រះវិហារបច្ចុប្បន្ន។ ព្រះអង្គបានកសាងលិង្គជាច្រើននៅក្នុងទឹកដីដ៏ធំទូលាយដោយដាក់ព្រះនាមនិងឋានៈរបស់ព្រះអង្គថា សុរិយវរមេស្វរៈ (ទេពសុរិយវរ្ម័ន)។ នៅក្នុងចំណោមនោះ លិង្គមួយត្រូវបានតម្កល់នៅប្រាសាទព្រះវិហារនាដើមសតវត្សទី១១ ហើយឧទ្ទិសដល់ព្រះសិវៈ។ លិង្គនោះស្ថិតនៅពីមុខក្បែរប្រាសាទដែលត្រូវបានសង់ឡើងជាថ្មីអំពីថ្មក្នុងក្របខណ្ឌរួមនៃកម្មវិធីពង្រីក ហើយនិងការជួសជុលដែលឈរលើមូលដ្ឋានដើមរបស់ប្រាសាទ។ ព្រះបាទជ័យវរ្ម័នទី៦(១០៨០-១១០៧) ព្រះបាទធរនិន្ទ្រវរ្ម័នទី១ (១១០៧ - ១១១២) ហើយនិងព្រះបាទសុរិយវរ្ម័នទី២(១១១៣-១១៥០) ក៏បានកសាងបំពេញបន្ថែមដល់រចនាសម្ព័ន្ធរបស់ប្រាសាទ។ ការពង្រីកទំហំការងារបានធ្វើឱ្យផ្លាស់ប្តូរអាស្រមតូចដំបូងទៅជាប្រាសាទខ្មែរដ៏ធំមួយក្នុងចំណោមប្រាសាទធំៗទាំងឡាយគ្រប់សម័យកាល។

ដោយខុសប្លែកអំពីប្រាសាទខ្មែរផ្សេងទៀតដែលត្រូវបានបោះបង់ចោលប្រាសាទព្រះវិហារបានទទួលរាជប្រយោជន៍មិនដាច់ក្នុងរយៈពេលបួនសតវត្ស(ទី៩ដល់ទី១២) ដូចដែលមានបង្ហាញជូននៅក្នុងដំណាក់កាលខុសៗគ្នាក្នុងការសាងសង់ហើយនិងនៅក្នុងការវិវឌ្ឍផ្នែកស្ថាបត្យកម្ម។ អ្វីដែលបានលើកឡើងពីខាងដើមពន្ធេចនូវសារ

គោបុរៈទី២

© Fabien Billaud

សំខាន់ដោយឡែកនៃរមណីយដ្ឋានក្នុងនាមនៃប្រាសាទដែលលេចចេញពីស្មារតីរបស់គម្រោងទី១ នៅក្នុងអធិរាជាណាចក្រ។

ប្លង់របស់ប្រាសាទព្រះវិហារខុសប្លែកពីប្រាសាទដ៏ច្រើនក្នុងតំបន់អង្គរដែលកសាងឡើងតាមប្លង់ (plan concentrique) ប្លង់ប្រាសាទព្រះវិហារកសាងលើផ្ទៃដីធម្មជាតិហើយរត់តាមរយៈកម្ពស់នៃខ្សែបណ្តោយ។ ការកសាងរបៀបនេះដើម្បីឱ្យប្រាសាទព្រះវិហារមានកម្ពស់ចំនួនបួននិងទីធ្លាចំនួនបួនដែលមានខ្លោងទ្វារចំនួនប្រាំ។ ក្នុងពេលដែលយើងឡើងទៅកាន់ប្រាសាទខាងក្នុងនៃប្រាសាទព្រះវិហារកម្ពស់នីមួយៗបង្ហាញនូវលក្ខណៈស្ថាបត្យកម្មផ្ទាល់របស់ប្រាសាទនេះដែលផ្តល់ទស្សនិកជននូវអារម្មណ៍មួយខុសៗគ្នា។ ប្រាសាទព្រះវិហារកសាងឧទ្ទិសដល់ព្រះសិវៈហើយតំណាងឱ្យភ្នំកៃលាសដែលជាលំនៅឋានរបស់ព្រះអង្គ។ ប្រាសាទព្រះវិហារបានក្លាយទៅជាបូជនីយដ្ឋាននិងជាទីតាំងសាសនាសម្រាប់ព្រះរាជានិងប្រជារាស្ត្ររបស់ព្រះអង្គ។

ក្នុងចំណោមសិលាចារឹកនានាដែលគេបានរកឃើញនៅព្រះវិហារសិលាចារឹកដែលមានប្រយោជន៍ខ្លាំងជាងសិលាចារឹកដទៃដែលគេបានស្គាល់ក្រោមឈ្មោះថាសិលាចារឹកព្រះវិហារឬសិលាចារឹករបស់ទិវករដែលសរសេរជាភាសាសំស្ក្រឹតនិងភាសាខ្មែរហើយទំនងជាស្ថិតនៅក្នុងចន្លោះឆ្នាំ១១១៩និង១១២១គ.ស។ សិលាចារឹក

ប្រភពនានានៃប្រាសាទព្រះវិហារទំនងជាមានការពាក់ព័ន្ធទៅនឹងការមកតាំងទីពីខាងដើមនៃអាស្រមសមាធិនៅលើទីតាំងភ្នំនេះ

នេះសរសេរនៅលើសន្ទឹកថ្មមួយផ្ទាំងដោយបានរៀបរាប់អំពីរាជបញ្ជានៃព្រះបាទសុរិយវរ្ម័នទី២ទៅកាន់រាជគ្រូប្រដៅសាសនានាមទិវករដើម្បីបំពេញនូវពិធីបូជាយញ្ញហើយនិងដើម្បីរៀបចំជាថ្មីនិងការជួសជុលប្រាសាទព្រះវិហារ។ អក្សរចារឹកនៅខ្លោងទ្វារទី២បានរៀបរាប់អំពីប្រវត្តិរបស់មនុស្សក្នុងស្រុកម្នាក់ឈ្មោះថាសុកវ្ម័ន(Sukarman) ដែលទទួលនាទីជាបណ្ណសាររក្សារបស់ប្រាសាទ។ អក្សរចារឹកមួយទៀតបានរៀបរាប់ពីនាយរបស់ទីអាស្រមដែលបានធ្វើអំណោយដល់សិក្ខាវេស្វរៈដែលជាទេពចម្បងនៃប្រាសាទព្រះវិហារនេះ។ អក្សរចារឹកមួយទៀតដែលបានមកពីប្រាសាទព្រះវិហារនេះដែរមានកាលបរិច្ឆេទឆ្នាំ១០២៧ក៏មានជាប់ទាក់ទងទៅនឹងព្រះបាទសុរិយវរ្ម័នទី១។ បច្ចុប្បន្នអក្សរចារឹកនេះស្ថិតនៅក្នុងសារមន្ទីរជាតិនៃទីក្រុងបាងកក។

ស្ថាបត្យកម្មនៃប្រាសាទព្រះវិហារ

ទីតាំងពិសិដ្ឋនៃប្រាសាទស្ថិតនៅលើថ្មភ្នំខ្ពស់នៃភ្នំដងរែក(ស្ថិតនៅក្នុងកម្ពស់ ៥២៧ម ពីលើវាលរាបនៃប្រទេសកម្ពុជា) ហើយស្ថិតនៅក្បែរខ្សែព្រំដែនបច្ចុប្បន្នជាមួយប្រទេសថៃឡង់ដ៍។ ទម្រង់ជាទូទៅនៃថ្មភ្នំនេះមានរាងជាត្រីកោណហើយខណ្ឌដោយចំរាក់ភ្នំយ៉ាងចោត។ ចុងខាងត្បូងលយទៅខាងមុខបង្កើតបានជារបាំងការពារធម្មជាតិមួយ ទីនេះជាតំបន់ពិសិដ្ឋដែលស្ថិតនៅពីលើទេសភាពដ៏ធំមួយ៖ វិសាលភាពដ៏ធំទូលាយនៃផ្ទៃដីលាតសន្ធឹងនាផ្នែកខាងត្បូងរហូតដល់ភ្នំគូលែនដែលជាប្រភពនៃអារ្យធម៌ខ្មែរ។ ផ្នែកខាងជើងរបស់ភ្នំបង្កើតបានជាទីរាបរបស់ភ្នំដែលមានបណ្តោយ១០០ម ពីខាងជើងទៅខាងត្បូងហើយនិងទទឹង៥០ម ដែលជាផ្លូវចូលមកកាន់ប្រាសាទហើយក៏ជាផ្លូវភ្ជាប់ទៅកាន់ភូមិនៃភ្នំគូលែនដែរ។

ប្រាសាទព្រះវិហារមានក្រុមប្រាសាទជាច្រើនដែលភ្ជាប់ពីមួយទៅមួយដោយប្រព័ន្ធព្រះថ្កល់និងជណ្តើរដែលរត់ជាជួរក្នុងរយៈចម្ងាយ៨០០មតាមអ័ក្សជើង-ត្បូង។ ចំណុចនេះមិនមែនជាទម្លាប់មួយទេប្រសិនបើគេគិតថាប្រាសាទនានាក្នុងតំបន់អង្គរជាទូទៅបែរមុខទៅទិសខាងកើត។

យើងឡើងទៅកាន់ប្រាសាទព្រះវិហារទៅតាមជណ្តើរចំនួនពីរ មួយទៅទិសខាងកើតហើយមួយទៀតទៅទិសខាងជើង។ ប្រាសាទព្រះវិហារ

រូបចម្លាក់នៅគោបុរៈទី២

© Fabien Billaud

មានទីតាំងបែរទៅទិសកើត-លិចនិងទិសជើង-ត្បូង។ នៅទិសខាងជើង ជណ្ដើរឡើងមកកាន់ប្រាសាទ មានប្រវែង៥២ម ហើយមានកាំជណ្ដើរចំនួន ១៥៩កាំ ភ្ជាប់មកកាន់ព្រះថ្នល់ (Chaussée) ប្រវែង ២៥ម ហើយអមដោយនាគលូនធំៗចំនួនពីរ។ ផ្ដើមចេញពីទីនោះ យើងមកដល់ខ្លោងទ្វារទី៥ (រាប់ពីក្នុងមកក្រៅ)។ ខ្លោងទ្វារទី៥នេះមានរាង ជាកាកបាទដែលពីមុននោះមានប្រក់ដំបូលឈើទ្រ ដោយសសរច្រើន។ ផ្លូវចំនួនពីរភ្ជាប់មកខ្លោងទ្វារ ទី៥នេះ ជណ្ដើរមួយមកពីទិសខាងជើង ហើយ មួយទៀតមកពីទិសខាងកើតដែលចេញពីវាលរាប នៃប្រទេសកម្ពុជា។ ជណ្ដើរនេះត្រូវបានកសាង ដោយដាប់ថ្មភ្នំក្នុងផ្នែកខ្លះ ហើយផ្នែកខ្លះទៀត កសាងដោយដុំថ្មភក់ដែលមានទទឹង១០មនិង បណ្ដោយ១ ២០០ម។ នៅកន្លែងខ្លះជណ្ដើរនេះ ចោតខ្លាំងប្រមាណ២០០ម នៅទិសខាងកើត។ ជណ្ដើរខាងកើតនេះបានជួសជុលរួចរាល់ភាគ ច្រើនដោយជណ្ដើរអំពីឈើ។

លំអស្ថាបត្យកម្ម

ការតុបតែងលំអដែលបានធ្លាក់រួចរាល់ ច្រើនជាងគេគឺស្ថិតនៅលើខ្លោងទ្វារទាំងឡាយ របស់ប្រាសាទ។ ក្បាច់លំអទាំងនេះជាទូទៅមាន ស្ថានភាពល្អប្រសើរដែលគេអាចមើលឃើញ។ ការតុបតែងនៃចម្លាក់ ពិសេសចម្លាក់នៅលើផ្ដែរទ្វារ សសរទិងសសរផ្ដោបមានទម្រង់ខុសៗគ្នាច្រើនបែប

ការតុបតែងលំអដែលបានធ្លាក់រួចរាល់ច្រើនជាងគេ គឺស្ថិតនៅលើខ្លោងទ្វារទាំងឡាយរបស់ប្រាសាទ។ ក្បាច់លំអទាំងនេះជាទូទៅមានស្ថានភាពល្អប្រសើរដែលគេអាចមើលឃើញ

ច្រើនយ៉ាង ហើយល្អផូរផង់។ ចម្លាក់ទាំងនេះ បង្ហាញនូវទេពធំពីរអង្គ គឺព្រះសិវៈនិងព្រះ វិស្ណុ ព្រមទាំងព្រះឥន្ទនិងអវតារនៃព្រះវិស្ណុ គឺ ព្រះក្រិស្ណៈ។

គុណភាពនៃស្ថាបត្យកម្មចម្លាក់ដ៏គួឱ្យកត់ សម្គាល់និងនិមិត្តរូបនៃទេសភាពធ្វើឱ្យប្រាសាទ ព្រះវិហារមានតម្លៃសម្រាប់ការចុះបញ្ជីនៅក្នុងបញ្ជី បេតិកភណ្ឌរបស់អង្គការយូណេស្កូ។ សេចក្ដីសម្រេច នៃការចុះបញ្ជីបានប្រាប់អំពីតម្លៃជាសាកល ពិសេសដែលស្ថិតនៅក្នុងបរិបទមួយដែលថា «ប្រាសាទព្រះវិហារជាស្នាដៃឯកនៃស្ថាបត្យកម្ម ខ្មែរគួរកត់សម្គាល់។ ទម្រង់ដ៏ "ល្អ" នៃប្រាសាទ ក៏ដូចជាការផ្ចិតផ្ចង់នៅក្នុងការតុបតែងលំអ »។

តម្លៃផ្សេងទៀតនៅក្នុងតំបន់ព្រះវិហារ

សហគមន៍ជនជាតិភាគតិចកួយដែលមាន របៀបរបបរស់នៅគួរកត់សម្គាល់ ហើយនិងខុស គ្នាពីសហគមន៍ដទៃដោយចំណេះដឹងជាប្រពៃណី និងចំណេះធ្វើដោយរាប់បញ្ចូលទាំងបច្ចេកទេស ផង រស់នៅក្បែរប្រាសាទផង។ ក្រៅពីភាសានៃ សហគមន៍នេះកួយបានបន្តប្រពៃណីខាងតន្ត្រី និងរបាំ ដូចជារបាំអ្នកធ្វើសឹកព្រមទាំងសិល្បៈ និងប្រពៃណីស្ថាបត្យកម្មយ៉ាងសាមញ្ញ។ សហគមន៍ កួយត្រូវបានគេស្គាល់ថាពួកគាត់ធ្លាប់មានទំនាក់ ទំនងដោយឡែកជាមួយនឹងព្រះមហាក្សត្រខ្មែរ ក្នុងឋានៈជាជាងដែកផលិតអាវុធនិងអាវក្រោះ ហើយនិងការទាក់និងផ្សាំងដំរីព្រៃ។

សារមន្ទីរនៅព្រះវិហារ

ស្ថិតនៅចំភាគកណ្ដាលនៃព្រះរាជាណា ចក្រកម្ពុជា។ តំបន់ប្រាសាទព្រះវិហារជាមណ្ឌល វប្បធម៌ដែលមានភាពខុសប្លែកពីតំបន់ដទៃ ដោយសារអត្ថិភាពនៃពពួកសត្វនិងរុក្ខជាតិ រួមនិងប្រវត្តិធម្មជាតិដ៏យូរលង់។ សារមន្ទីរមួយ ដែលមានលក្ខណៈរួម (Global) ក្នុងនោះការរុករក នានាផ្នែកបុរាណវិទ្យានិងវត្ថុខាងជាតិពន្ធុវិទ្យា ត្រូវបានដាក់តាំងបង្ហាញអំពីប្រវត្តិធម្មជាតិនេះ។ ឈានជិតដល់ការបញ្ចប់សារមន្ទីរនេះមានការ ចូលរួមវិភាគទានដោយឡែកៗរបស់អង្គការ យូណេស្កូ។

ប្រព័ន្ធធារាសាស្ត្រ នៃប្រាសាទព្រះវិហារ

បណ្ឌិត **ហង់ ពៅ**
អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក
អាជ្ញាធរអប្សរា

កម្រិតទឹកនៅខែវិច្ឆិកា ក្នុងអាងទី៥

© ហង់ ពៅ

ប្រាសាទ ព្រះវិហារស្ថិតនៅលើកំពូលជួរភ្នំដងរែកខាងជើងប្រទេសកម្ពុជា។ ឧទ្ទិសដល់ព្រះសិវៈ ប្រាសាទនេះត្រូវបានកសាងឡើងពីសតវត្សទី ៩ ដល់សតវត្សទី១២ សំខាន់គឺនៅក្នុងសម័យសោយរាជ្យនៃស្តេចខ្មែរព្រះនាម សុរិយវរ្ម័នទី១ (ពីឆ្នាំ១០០២ ដល់ឆ្នាំ១០៥០) និងព្រះបាទសុរិយវរ្ម័នទី២ (ពីឆ្នាំ១១១៣ ដល់ឆ្នាំ១១៥០)។ ប្រាសាទនេះត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ២០០៨និងស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិសម្រាប់ការពារប្រាសាទព្រះវិហារ ដែលហៅកាត់ថា ANPV ។ ប្រាសាទព្រះវិហារត្រូវបានកសាងឡើងនៅលើស្រទាប់ផ្ទាំងថ្ម ផ្ទុយពីប្រាសាទខ្មែរផ្សេងទៀតនៅក្នុងតំបន់អង្គរ ឬនៅតាមតំបន់វាលទំនាបដែលប្រាសាទផ្សេងៗទាំងនោះត្រូវបានកសាងឡើងនៅលើស្រទាប់ដីខ្សាច់ធ្វើឲ្យប្រាសាទមានទំនាក់ទំនងផ្ទាល់ទៅនឹងការផ្លាស់ប្តូរកម្រិតទឹកក្រោមដី ឬក៏កម្រិតផ្ទៃតនៃដីខ្សាច់។ ទោះបីប្រាសាទនេះមិនមានបញ្ហាគ្រឹះដែលទាក់ទងនឹងទឹកក៏ដោយក៏ទឹកនៅតែជាបញ្ហាប្រឈមដ៏ធំសម្រាប់ការគ្រប់គ្រងប្រាសាទព្រះវិហារនេះក៏ដូចជានៅតាមទឹកន្លែងផ្សេងទៀតក្នុងពិភពលោកដែរ។ នៅក្នុងអត្ថបទនេះយើងនឹងនិយាយផ្តោតទៅលើប្រព័ន្ធគ្រប់គ្រងទឹក រួមទាំងការប្រើប្រាស់ទឹកនិងការបង្ហូរទឹកចេញ។ តើនៅក្នុងសម័យបុរាណបុព្វបុរសខ្មែរប្រើប្រាស់ទឹកសម្រាប់គោលដៅអ្វីហើយតើពួកគាត់គ្រប់គ្រងទឹកយ៉ាងដូចម្តេចដែរ?

ប្រព័ន្ធធារាសាស្ត្រសំខាន់ៗទាំងពីរត្រូវបានកសាងឡើងសម្រាប់ប្រាសាទនេះកាលពីសម័យបុរាណនៅខាងលើកំពូលភ្នំ (ជុំវិញប្រាសាទ) និងមួយទៀតនៅឯជើងភ្នំ (នៅលើដីទំនាប)។

អាងផ្ទុកទឹកនិងប្រព័ន្ធធារាសាស្ត្រ

ប្រាសាទព្រះវិហារមិនត្រូវការទឹក ដើម្បីរក្សាលំនឹងឬដើម្បីជាការលំអរបស់ខ្លួនឡើយ ប៉ុន្តែគេត្រូវការទឹកសម្រាប់ការគ្រប់គ្រងប្រាសាទនិងសម្រាប់អ្នកដែលមកទស្សនាប្រាសាទនេះ។ ដោយសារថាប្រាសាទនេះត្រូវបានកសាងឡើងនៅលើកំពូលដែលខ្ពស់ជាងគេនៃជួរភ្នំនេះ ដូច្នេះគ្មានប្រភពទឹកណាមួយដែលអាចហូរទៅដល់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃនោះឡើយ។

ដើម្បីដោះស្រាយបញ្ហានេះអាងទឹកចំនួន ៦ត្រូវគេបានកសាងឡើងដើម្បីត្រងយកទឹកក្នុងរដូវវស្សាហើយអាងទាំង៦នោះត្រូវបានឲ្យឈ្មោះទៅតាមទិសដៅនៃទឹកហូរពីខ្ពស់ (ខាងត្បូង) ទៅទាប (ខាងជើង)។ អាងទឹកទាំងអស់មានលក្ខណៈដូចៗគ្នា៖ បាតក្រោមជាប់នឹងស្រទាប់ផ្ទាំងថ្មរីឯជញ្ជាំងធ្វើពីដីដែលគេបង្ហាប់យ៉ាងណែន

សំណាក់រចរិលនៅចន្លោះអាងទី១និងគោបុរៈទី២

© ហង់ ពៅ

ប្រព័ន្ធធារាសាស្ត្រសំខាន់ៗទាំងពីរ ត្រូវបានកសាងឡើងសម្រាប់ប្រាសាទនេះកាលពីសម័យបុរាណនៅខាងលើកំពូលភ្នំ (ជុំវិញប្រាសាទ) និងមួយទៀតនៅឯជើងភ្នំ (នៅលើដីទំនាប)

ហើយអាងទាំងអស់មានក្រាលដោយថ្មកក់ដើម្បីការពារកុំឲ្យស៊ីកដីនិងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ដឹងអំពីកម្រិតទឹកដែលនៅសល់ក្នុងអាង ហើយអាចចុះទៅដងទឹកមកប្រើប្រាស់បានពីខាងណាក៏បាន។ គេអាចគិតថាជម្រាបទឹកពីលើទៅក្រោមគឺគ្មានទាល់តែសោះ ពីព្រោះអាងទាំងនេះត្រូវបានកសាងឡើងដោយមានបាតជាប់នឹងស្រទាប់ផ្ទាំងថ្មផ្ទាល់តែម្តង។ ដូច្នេះ ការបាត់បង់ទឹកនៅក្នុងអាងសំខាន់ គឺបណ្តាលមកពីជម្រាបទឹកទៅតាមជញ្ជាំង ពីព្រោះជញ្ជាំងអាងគ្មានការថែទាំអស់រយៈពេលជាច្រើនឆ្នាំមកហើយបណ្តាលមកពីសង្គ្រាមអស់ជាច្រើនសតវត្សនិងដោយសារប្រព័ន្ធបង្ហូរទឹកមិនធ្លាប់ត្រូវបានជួសជុល ឬថែទាំឡើយ។

ក្រៅអំពីមុខងារឆ្លើយតបទៅនឹងតម្រូវការទឹកប្រចាំថ្ងៃអាងទាំងនេះក៏មានប្រយោជន៍សម្រាប់កាត់បន្ថយលំហូរទឹកភ្លៀងនៅក្នុងប្រាសាទផងដែរដើម្បីកុំឲ្យមានសំណឹកនិងជះឥទ្ធិពលទៅលើលំនឹងរបស់ប្រាសាទ។ ប៉ុន្តែ ដោយសារមូលហេតុដែលថាប្រព័ន្ធបង្ហូរទឹកនេះបានខូចខាតអស់ទៅហើយនោះទឹកភ្លៀងក៏ហូរពាសវាលពាសកាលដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ។ ដូច្នេះ ផ្នែកខ្លះនៃប្រាសាទក៏បានបាក់បែក ខូចខាត ហើយផ្នែកខ្លះទៀតក៏ទ្រេតទ្រោតទ្រោម ហើយផ្នែកទាំងនោះនឹងដួលរលំដូចគ្នាប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយជាបន្ទាន់នោះទេ។

ប្រាសាទព្រះវិហារមានគោបុរៈចំនួន៥ហើយគោបុរៈទាំងនោះក៏ត្រូវបានឲ្យឈ្មោះពីទឹកន្លែងខ្ពស់ (នៅខាងត្បូង) ទៅកន្លែងទាប (នៅខាងជើង) ដូចគ្នាដែរ។

នៅក្នុងគោបុរៈទី ១ តួប៉មកណ្តាលបានបាក់បែកធ្លាក់ ហើយរោងទងខាងត្បូងឈៀងខាងកើតក៏ខូចខាតទាំងស្រុងដែរ ដោយសារប្រព័ន្ធបង្ហូរទឹកបុរាណបានស្ទះហើយទឹកភ្លៀងអាចអស់ពីកន្លែងនេះបានតាមតែជ្រាបនិងហួតតែប៉ុណ្ណោះ។ ផ្នែកខ្លះនៃប្រឡាយដោះទឹកយើងអាចមើលឃើញនៅឡើយ ប៉ុន្តែ ភាគច្រើននៃប្រឡាយដោះទឹកទាំងនោះគឺមានដីកកពេញអស់ទៅហើយ។ អាជ្ញាធរព្រះវិហារកំពុងខិតខំដោះស្រាយបញ្ហានេះ។

អាងទី ១ នៅខាងកើតគោបុរៈទី ២ ប្រើសម្រាប់ផ្ទុកទឹកភ្លៀងនិងទឹកដែលហូរពីតំបន់ខាងត្បូងមកនិងមួយផ្នែកធំពីគោបុរៈទី១។ អាងនេះមើលទៅដូចជាត្រូវបានកសាងឡើងក្រោយពីគេសាងសង់ប្រាសាទរួច។ វាក៏អាចដែរថាអាងនេះត្រូវបានកសាងឡើងដោយសង់ជញ្ជាំងបន្ថែមឲ្យខ្ពស់ដើម្បីពង្រីកសមត្ថភាពផ្ទុកទឹកព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទឹកសម្រាប់ការគ្រប់គ្រងប្រាសាទ។ ក្រោយមកគេឃើញមានការចាក់ដីបន្ថែមដើម្បីបង្កើតជាជម្រេលមួយរវាងអាងនិងប្រាសាទដើម្បីកាត់បន្ថយទឹកហូរទៅគ្រឹះប្រាសាទ។ ប៉ុន្តែ ដំណោះស្រាយនេះ

រូបភាពកាត់ទទឹងនៃអាងបុរាណ



ប្រព័ន្ធបង្ហូរទឹកចេញនៅខាងក្នុងគោបុរៈទី១



ទិសដៅទឹកហូរ អាងទី១ អាងទី២និងកន្លែងនៃសំណឹក



ទិសដៅទឹកហូរនិងទីតាំងអាងទី៣ អាងទី៤និងអាងទី៥



អាងទី៥និងទិសដៅទឹកហូរ



មិនគ្រប់គ្រាន់ឡើយសម្រាប់បង្ហូរទឹកភ្លៀងចេញឲ្យអស់ ហើយការដក់ទឹកនៅតាមគ្រះបានធ្វើឲ្យដីនៅខាងក្រោមរំកិលអស់ជាច្រើនសង់ទីម៉ែត្រ និងបណ្តាលឲ្យផ្នែកខាងលើនៃប្រាសាទបាក់ធ្លាក់ចុះមក។

អាងទី២ នៅខាងជើងនៃអាងទី១ មានប្រយោជន៍សម្រាប់ត្រងទឹកភ្លៀងនិងទឹកដែលនៅសល់ពីអាងទី១ ព្រមទាំងសម្រាប់កាត់បន្ថយកម្លាំងធារទឹកដែលហូរសំដៅទៅបណ្ណាល័យនៃគោបុរៈទី៣ ។ ដោយសារគ្មានការជួសជុលឬថែទាំអស់រយៈពេលជាច្រើនមកនោះ អាចម៍ដីដែលហូរពីខាងលើមកក៏បណ្តាលឲ្យមានទឹកច្រើនត្រូវដក់នៅខាងមុខបណ្ណាល័យខាងលិចនិងខាងកើត។ ទឹកដក់នេះក៏ជ្រាបចូលទៅខាងក្រោមដីហើយបណ្តាលឲ្យបណ្ណាល័យត្រូវទ្រេត។

អាងទី៣ មានប្រយោជន៍សម្រាប់ត្រងទឹកភ្លៀងនិងទឹកដែលហូរមកពីខាងកើតនៃគោបុរៈទី៣។ ទឹកដែលហូរមកពីខាងលិចនៃគោបុរៈទី៣ ពីមុនហូរតាមបណ្តោយស្ពានហាលធំនិងតាមវាលស្មៅ ប៉ុន្តែផ្លូវទឹកហូរនេះត្រូវបានស្ទះដោយសំណង់ចំណតឧត្តម្ភាចក្រ។ នៅពេលបច្ចុប្បន្ន ផ្លូវហូរទឹកនេះត្រូវបានពង្វៀងនិងឆ្លងកាត់ស្ពានហាលធំនៅជិតគោបុរៈទី៤ ដើម្បីបង្ហូរទឹកបញ្ចូលទៅក្នុងអាងទី៥។ ដោយសារមូលហេតុនេះ អាងនេះមានទឹកច្រើនជាងអាងផ្សេងទៀតនៅរដូវវស្សា ប៉ុន្តែវាមិនអាចរក្សាទឹកបានយូរទេដោយសាររំហួត។

ភាគច្រើននៃទឹកដែលហូរមកពីទិសខាងកើតបានទៅដល់អាងទី៣ ហើយទឹកដែលនៅសល់ទាំងប៉ុន្មានក៏ហូរទៅតាមបណ្តោយស្ពានហាលធំរហូតដល់អាងទី៥។ មានតែទឹកមួយផ្នែកតូចដែលហូរមកពីអាងទី៣ ត្រង់ជ្រុងខាងជើងនិងទឹកភ្លៀងប៉ុណ្ណោះដែលអាចបំពេញអាងទី៤។

អាងទី៦ នៅខាងជើងឈៀងខាងលិចនៃគោបុរៈទី៥ គឺជាអាងដែលធំជាងគេនៅប្រាសាទព្រះវិហារ។ វាមានប្រយោជន៍សម្រាប់ទទួលផ្ទុកទឹកដែលហូរមកពីប៉ែកខាងលិចចន្លោះគោបុរៈទី៤និងគោបុរៈទី៥ ។ ដើម្បីត្រងយកទឹកភ្លៀងដែលហូរមកនេះ វិស្វករខ្មែរសម័យបុរាណបានកសាងកូនទំនប់ទឹក(លិចកើត) មួយធ្វើពីថ្មភក់ដែលមានកូនប្រឡាយតាមបណ្តោយទំនប់ភ្ជាប់ទៅនឹងកូនលូតូចមួយកាត់ក្រោមទំនប់នេះដើម្បីប្តូរទិសនៃទឹកហូរ បង្វែរទឹកដែលហូរមកតាមបណ្តោយទំនប់នេះឲ្យសំដៅទៅអាងទី៦ វិញ។ ប្រឡាយទឹកនៅតាមបណ្តោយទំនប់នេះមានកន្លែងខ្លះត្រូវមានរណ្តៅសម្រាប់បន្ថយល្បឿនទឹកនិងត្រងយកកំណកដីដែលហូរពីខាងលើមកព្រមទាំងការពារអាងទី៦ កុំឲ្យមានកំណកដីហូរចូល។ ទំបន់នេះក៏ត្រូវបានគេហៅថាផ្លូវបុរាណដែរ ពីព្រោះគេប្រើវាជាផ្លូវឡើងទៅប្រាសាទពីទិសខាងលិច។ នៅក្នុងទសវត្សឆ្នាំ៨០ ដោយសារបរិមាណទឹកជាច្រើនបានហូរមកដល់ចំណុចនេះអ្នកស្រុកដែលរស់នៅម្តុំនោះបានកសាងទំនប់បេតុងមួយភ្ជាប់ទៅនឹងអាងទី ៦ ពង្រីកអាងនេះបួនប្រាំម៉ែត្រទៅក្រោមដើម្បីផ្ទុកទឹកឲ្យបានកាន់តែច្រើន ជាជាងជួសជុលអាងទឹកបុរាណ។

អាងទី៣និងទេសភាពជុំវិញ
© ហង់ ពៅ

កាលពីពេលថ្មីៗនេះ បារាយណ៍ពីរត្រូវបានគេរកឃើញនៅជិតរមណីយដ្ឋានប្រាសាទព្រះវិហារនៅជើងភ្នំតែម្តង

អាងផ្ទុកទឹកថ្មីមួយទៀតនៅជិតវត្តកែវសិខាគិរីស្វារៈត្រូវបានកសាងឡើងកាលពីពេលថ្មីៗនេះដោយអ្នកស្រុកដើម្បីទទួលទឹកដែលហូរមកពីជ្រុងខាងត្បូងឈៀងខាងលិចនៃប្រាសាទ។ ទិសនៃលំហូរទឹកចូលក្នុងអាងនេះមានបង្ហាញជូននៅក្នុងរូបភាព(សូមមើលរូបភាព)។ អាងផ្ទៃរងទឹកភ្លៀងដែលផ្តល់ទឹកដល់អាងទឹកនេះមានលក្ខណៈល្អប្រសើដោយសារមានដើមឈើដុះពេញនៅខាងក្នុងអាងផ្ទៃរងទឹកភ្លៀងដែលផ្តល់លទ្ធភាពក្នុងការស្តុកទឹកក្នុងដីនិងជ្រាបចេញជាបន្តបន្ទាប់មកក្រោយបានយូរជាងអាងផ្សេងទៀតនៅក្នុងតំបន់នេះ។

ប្រព័ន្ធបារាយណ៍

កាលពីពេលថ្មីៗនេះបារាយណ៍ពីរត្រូវបានគេរកឃើញនៅជិតរមណីយដ្ឋានប្រាសាទព្រះវិហារនៅជើងភ្នំតែម្តង។ បារាយណ៍មួយនៅខាងលិចមួយទៀតនៅខាងកើត តាមបណ្តោយអក្សប្រាសាទដែលគេហៅថាបារាយណ៍ខាងលិចនិងបារាយណ៍ខាងកើត។ បារាយណ៍ទាំងពីរមានទឹកហូរបំពេញដោយកូនអូរដែលហូរធ្លាក់ពីលើភ្នំមក។ របកគំហើញនេះអនុញ្ញាតឲ្យយើងធ្វើការសន្និដ្ឋានថាប្រាសាទព្រះវិហារប្រហែលជាត្រូវទទួលមនុស្សជាច្រើនដែលធ្វើដំណើរមកពីទូទាំងប្រទេស ជាពិសេសអ្នកធ្វើធម្មយាត្រាមកបន់ស្រន់ឬក៏គោរពចំពោះប្រាសាទនេះ។

បារាយណ៍ខាងលិចនៅជិតផ្លូវឡើងទៅលើកំពូលភ្នំ នៅខាងលិចគោបុរៈទី៥។ កន្លែងដែលទឹកហូរចូលពីបុរាណមកគឺនៅជិតជ្រុងខាងជើងឈៀងខាងកើតដូចដែលមានចង្អុលបង្ហាញស្រាប់តាមរយៈវត្តមានថ្មបាយក្រៀមមួយចំនួនដែលបុរាណវិទូរបស់អាជ្ញាធរជាតិព្រះវិហារបានរកឃើញ។ ដូចសព្វមួយដងដែរនៅក្នុងសម័យបុរាណចំណុចដែលទឹកហូរចូលគឺនៅត្រង់កន្លែងខ្ពស់ជាងគេនៃបារាយណ៍ដើម្បីប្រមូលនិងផ្ទុកទឹកឲ្យបានច្រើនបំផុតដែលអាចធ្វើទៅបាន។

រូបអាងទឹកទី៥និងទេសភាពជុំវិញ

អាជ្ញាធរជាតិព្រះវិហារបានស្តារបារាយណ៍ខាងលិចឡើងវិញនៅខែមិនា ឆ្នាំ២០១១ ដោយ

អាងទឹកទី៤និងតំបន់ជុំវិញ

© ហង់ ពៅ

បានសំអាតកំណកដីនៅបាតអាងនិងបានលើកទំនប់មួយដើម្បីបង្វែរទឹកបញ្ចូល។ ដើម្បីបង្វែរទឹកបញ្ចូលបំពេញបារាយណ៍ខាងលិច គេគួរតែអាចប្រើប្រាស់ទឹកដែលហូរយ៉ាងច្រើនមកពីផ្នែកខាងជើងឈៀងខាងកើតនៃបារាយណ៍។ ដើម្បីកសាងបាននូវប្រព័ន្ធធារាសាស្ត្របែបនេះ គេត្រូវសង្កេតតាមដានរំហូរទឹកឲ្យបានច្រើនឆ្នាំ (ធារទឹកនិងទិសដៅទឹកហូរ) ដើម្បីធ្វើសម្រង់ទិន្នន័យអំពីទឹក។ ការចុះទៅពិនិត្យនៅប្រាសាទផ្ទាល់បានអនុញ្ញាតឲ្យយើងធ្វើសេចក្តីសន្និដ្ឋានថាកូនអូរតូចៗទាំងនេះមានទឹកហូរតែក្នុងរដូវវស្សាប៉ុណ្ណោះ។ បច្ចុប្បន្ននេះ អាជ្ញាធរជាតិព្រះវិហារប្រើកូនអូរតូចៗពីរដែលមានទឹកហូរឆ្លងកាត់ក្រោមស្ពាននៅតាមផ្លូវរថយន្តឡើងទៅប្រាសាទ។ដោយសារយើងមិនទាន់មានទិន្នន័យទឹកនិងឧតុនិយមអំពីប្រាសាទនៅក្នុងដៃវាពិតជាមានការលំបាកក្នុងការពិពណ៌នាអំពីប្រតិកម្មរូបវ័ន្តនៃអាងផ្ទុកទឹករបស់កូនអូរតូចៗទាំងពីរនេះដែលលំហូរទឹកប្រែប្រួលទៅតាមកម្លាំងនៃទឹកភ្លៀង។

ការសិក្សាផ្អែកឋានលេខា បង្ហាញថាបារាយណ៍ខាងលិចមិនសូវជ្រៅទេហើយក៏មិនអាចផ្ទុកទឹកឲ្យបានពេញមួយឆ្នាំនោះដែរ។ បន្ទាប់ពីធ្វើការសិក្សាបុរាណវិទ្យារួចមកវានៅលំបាកក្នុងការកំណត់ថា ពេលណាដែលបារាយណ៍រីងស្ងួតទាំងស្រុង ហើយក៏មិនដឹងដែរថាវាត្រូវបានបញ្ចូលទឹកដោយរក្សាឲ្យបាននៅពេញមួយឆ្នាំដោយរបៀបណាដែរ។ ជម្រៅរបស់វានៅពេលបច្ចុប្បន្ននេះប្រែប្រួលប្រមាណជា ២ ម៉ែត្រពីជ្រុងខាងជើងឈៀងខាងកើតដែលខ្ពស់ជាងគេទៅជ្រុងដែលទាបជាងគេនៅខាងត្បូងឈៀងខាងលិច។ ដូច្នេះ យោងតាមស្ថានភាពជាក់ស្តែងនិងលក្ខខណ្ឌបរិស្ថានបរិមាណទឹកនៅសល់ក្នុងអាងពិតជាតិចជាងបរិមាណទឹកដែលបាត់បង់ដោយរំហួតនិងដោយជម្រាប។

បារាយណ៍ខាងលិចត្រូវបានកសាងឡើងដើម្បីផ្ទុកទឹកសម្រាប់ប្រើប្រាស់ប្រចាំឆ្នាំ។ គេអាចនិយាយម្យ៉ាងទៀតថាវាត្រូវមានទឹកហូរបំពេញជាប់ជានិច្ចដែលមានកូនអូរតូចៗទាំងនោះជាអ្នកផ្តល់ទឹកជាអចិន្ត្រៃយ៍ (ទឹកនៅតែហូរនៅរដូវប្រាំង)។ ការធានាឲ្យទឹកហូរនៅក្នុងអូរទាំងនេះគឺពឹងផ្អែកទៅលើព្រៃឈើនៅក្នុងតំបន់ដែលបង្កឲ្យមានសំណើមនិងកាត់បន្ថយរំហួតទឹកនៅក្នុងតំបន់ជិតៗនោះព្រមទាំងកាត់បន្ថយរំហួតទឹកចេញពីបារាយណ៍ផ្ទាល់។ ព្រៃឈើអាចជួយឲ្យមានទឹកជ្រាបកាន់តែខ្លាំងទៅក្នុងដីបណ្តាលឲ្យកម្រិតទឹកក្រោមដីខ្ពស់និងជ្រាបកាន់តែខ្លាំងទៅលើផ្ទៃដីផ្នែកខាងលើវិញនិងកាត់បន្ថយការបាត់បង់ទឹកក្នុងបារាយណ៍។

បារាយណ៍ខាងកើតនៅជិតជណ្តើរខាងកើតដែលគេប្រើក្នុងសម័យបុរាណ ដូចបារាយណ៍ខាងលិចដែរបារាយណ៍នេះនៅជិតមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចដែលអាជ្ញាធរជាតិព្រះវិហារទើបបានកសាងឡើងកាលពីពេលថ្មីៗនេះ។ យើងអាចបញ្ចូលទឹកចូលក្នុងបារាយណ៍ឲ្យមានទឹកសាជាថ្មីឡើងវិញ ដោយទាញយកទឹកពីកូនអូរជិតនោះ តាមរយៈកន្ទែងបញ្ចូលទឹកពីបុរាណនៅត្រង់ជ្រុងខាងជើងឈៀងខាងលិច។

អនុសាសន៍សម្រាប់ការអភិវឌ្ឍ

ដោយសារមូលហេតុនៃការផ្លាស់ប្តូរអាកាសធាតុនិងការរៀបចំដីធ្លីវាជាការចាំបាច់ដែលត្រូវធ្វើការគ្រប់គ្រងរួមនៃធនធានទឹកសម្រាប់រមណីយដ្ឋានប្រាសាទព្រះវិហារ ដោយគិតគូរដល់អនុសាសន៍ខ្លះៗដូចខាងក្រោមនេះ៖

- ត្រូវសាងសង់ស្ថានីយឧតុនិយមមួយនៅនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ
- ត្រូវធ្វើការសិក្សាស្រាវជ្រាវអំពីទិសដៅទឹកហូរនិងប្រភពទឹកដែលហូរមកចូលក្នុងអាងនិងបារាយណ៍ទាំងអស់នៅរដូវវស្សា
- ដើម្បីធានាថាប្រភពទឹកទាំងអស់ហូរបំពេញបារាយណ៍គេចាំបាច់ត្រូវការពារព្រៃឈើនិងដាំដើមឈើឡើងវិញនៅក្នុងតំបន់ទាំងមូល។ ព្រៃឈើអាចដើរតួនាទីមិនត្រឹមតែបង្កើតឡើងវិញនូវប្រភពទឹកនៅក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអេកូទេសចរណ៍ទៀតផង។

ការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធធារាសាស្ត្រនៅប្រាសាទព្រះវិហារបង្ហាញថា បុព្វបុរសខ្មែរពិតជាបានយល់យ៉ាងច្បាស់អំពីសារៈសំខាន់នៃទឹកហើយថាត្រូវគ្រប់គ្រងវាដោយរបៀបណា។ អាងទឹកនិងបារាយណ៍មិនមែនត្រូវបានគេកសាងឡើងដើម្បីជាការរៀបចំទេសភាពលំអប្រាសាទនោះឡើយ។ វាក៏មិនត្រូវបានគេកសាងឡើងក្នុងគោលបំណងរក្សាលំនឹងប្រាសាទដូចនៅអង្គរ ឬនៅតាមតំបន់វាលទំនាបផ្សេងទៀតនោះដែរ។ ផ្ទុយទៅវិញអាងទឹកនិងបារាយណ៍ទាំងនោះត្រូវបានគេកសាងឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃរបស់អ្នកគ្រប់គ្រងប្រាសាទនៅក្នុងរមណីយដ្ឋាននេះនិងភ្ញៀវដែលមកពីក្រៅ។ យើងសង្ឃឹមថាអាងទឹកនិងបារាយណ៍ទាំងអស់នឹងអាចត្រូវបានជួសជុលឡើងវិញដើម្បីឲ្យវាដើរតួនាទីសាជាថ្មីនៅក្នុងរមណីយដ្ឋាននេះដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយដែលកំពុងចាប់ផ្តើមទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើងៗ។

សារមន្ទីរធម្មជាតិសកលព្រះវិហារ

ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់មួយដែលពោរពេញទៅដោយសត្វនិងរុក្ខជាតិដ៏ល្អឯកនិងមានប្រវត្តិធម្មជាតិដ៏ចំណាស់មួយ។ ចាប់ពីពេលនេះតទៅ នៅក្នុងតំបន់វប្បធម៌ដ៏សំខាន់មួយនេះក៏មានសារមន្ទីរ "ធម្មជាតិសកល" មួយទៀតដែរដែលត្រូវបានកសាងឡើងដោយសារជំនួយដ៏ថ្លៃថ្លារបស់អង្គការយូណេស្កូ។ នៅក្នុងសារមន្ទីរនេះ ភ្ញៀវអាចស្វែងយល់អំពីប្រវត្តិធម្មជាតិនៃតំបន់នោះតាមរយៈការតាំងបង្ហាញបែបថ្មីមួយ ព្រមទាំងរបកគំហើញបុរាណវិទ្យាដ៏អស្ចារ្យនិងវត្ថុប្រើប្រាស់ជាច្រើនរបស់ប្រជាជន។

នៅក្នុងចំណោមរតនៈសម្បត្តិបុរាណវិទ្យាសំខាន់ៗនៅក្នុងសារមន្ទីរគេអាចលើកឡើងជាពិសេសអំពីព្រះកេសអប្សរាផ្តែរមួយនិងហោជាងមួយនៃប្រាសាទព្រះវិហារ គោនន្ទិនសម័យមុនអង្គរត្រូវបានគេឆ្លាក់រូចមួយផ្នែកដែលគេរកឃើញនៅជិតប្រាសាទព្រះវិហារនិងមានសិលាចារឹកដ៏កម្រមួយដែលគេរកឃើញនៅឆ្នាំ២០១០ នៅក្នុងប្រាសាទតាក្របីក្នុងខេត្តឧត្តរមានជ័យ គេគ្រោងថាវត្ថុផ្សេងទៀតដែលយកមកពីកោះកេរក៏ត្រូវដាក់តាំងនៅក្នុងសារមន្ទីរថ្មីនេះដែរ ដែលឈ្មោះពេញរបស់សារមន្ទីរនេះគឺ សារមន្ទីរធម្មជាតិសកលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។

នៅក្នុងសារមន្ទីរនេះ ក៏មានដាក់តាំងផងដែរនូវវត្ថុប្រើប្រាស់របស់អ្នកស្រុកដែលគេបានស្រាវជ្រាវរកឃើញកាលពីពេលថ្មីៗនេះ វាជាសាក្ខីកម្មបង្ហាញអំពីការផ្សារស្ទូដែកនៅក្នុងសម័យអង្គរបុរាណដោយជនជាតិគួយដែលរស់នៅក្នុងតំបន់នេះ ហើយដែលមានកេរ្តិ៍ឈ្មោះល្បីពូកែខាងស្ទូដែកនេះ។

បេសកកម្មចម្បងនៃសារមន្ទីរគឺការបង្ហាញអំពីវប្បធម៌ ប្រវត្តិសាស្ត្រ នរក្សវិទ្យានិងធម្មជាតិនៅក្រោមដំបូលតែមួយ សំដៅទៅបំភ្លឺអំពីសុខដុមរមណីយកម្មនិងតម្លៃដែលផ្សារភ្ជាប់រមណីយដ្ឋានប្រាសាទព្រះវិហារចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ទៅនឹងសោភណ្ឌភាពធម្មជាតិនៃតំបន់នេះនិងរបស់ប្រជាជន។

សារមន្ទីរធម្មជាតិសកលព្រះវិហារ

© រូបថតរបស់ ផេង សំអឿន

រូបចម្លាក់មកពីប្រាសាទបន្ទាយបី កោះកេរ

© រូបថតរបស់ ផេង សំអឿន

ព្រះកេសអប្សរាមកពីព្រះបាកាន្ត ព្រះខ័នកំពង់ស្វាយ

© រូបថតរបស់ ផេង សំអឿន



រូបចម្លាក់គោនន្ទិនដែលគេឆ្លាក់មិនទាន់រួច រកឃើញនៅអូរអង្គ្រង ជិតប្រាសាទព្រះវិហារ

© រូបថតរបស់ ផេង សំអឿន



ព្រះវិហារ និមិត្តរូបលោកធាតុសាស្ត្រតំបន់

ឯកឧត្តម **នុធ ណារាង**
ប្រវត្តិវិទូនិងបុរាណវិទូ
ឯកអគ្គរាជទូតកម្ពុជាប្រចាំយូនីស្កូ

ទិដ្ឋភាពពីប្រាសាទព្រះវិហារ

© Philippe Bierny

ប្រទេស កម្ពុជាមានទម្រង់រាងអក្សរ S ត្រង់ចុងជ្រោយឥណ្ឌូចិន ដែលចែកទីតាំងត្រង់កន្លែងនោះជាពីរផ្នែកជាប់គ្នា ខាងត្បូង គឺជាទីវាលទន្លេសាបដែលជាឈូងសមុទ្រចាស់ឯខាងជើងចាប់ពីជួរភ្នំដងរែកជាមាត់ច្រាំងសមុទ្រចាស់រហូតទៅដល់ព្រំប្រទល់ប្រទេសចិន សុទ្ធសឹងជាវាលទំនាបជ្រាបទៅដោយដៃទន្លេមេគង្គដឹកនាំចំណីដីល្បាប់ចិញ្ចឹមមនុស្សសត្វរុក្ខជាតិជាមូលដ្ឋានចេញចូលបម្រើមនុស្សម្នាបានងាយយ៉ាងក្រៃលែង។

អាកាសធាតុមូសសុងនៅអាស៊ីអាគ្នេយ៍នេះមានលក្ខណៈម៉្យាងដែលចែករដូវជាពីរផ្នែកក្នុងមួយឆ្នាំ។ ខ្យល់បក់ប្តូរទិសក្នុង៤ខែម្តង ហើយក៏នាំមកជាមួយនូវអាកាសធាតុស្ងួតពីខែវិច្ឆិកាទៅដល់ខែមេសា បានន័យថា ក្នុង៦ខែតមកទៀតគឺអាកាសធាតុសើមជារដូវភ្លៀង។ មានប្រភពពីឈូងសមុទ្រឥណ្ឌាមកខ្យល់មូសសុងនេះបានជះមកលើទីលានដីគោកទាំងមូល ហើយនាំឱ្យគេរុញច្រានជួយតាក់តែងប្រព័ន្ធសង្គមដោយឡែកមួយដែលគេហៅថាអរិយធម៌អាស៊ីខាងត្បូង។

នៅក្នុងចំណោមប្រព័ន្ធអាស៊ីខាងត្បូងនេះលក្ខណៈពិសេសរបស់ភូមិសាស្ត្របានរុញច្រានឱ្យមានភាពប្លែកៗ ដល់សង្គមមនុស្សដែលគេទ្រទ្រង់ហើយក៏បានបង្កឱ្យមានអរិយធម៌បុរាណធំៗ ចាស់ៗជាច្រើនដែលគេហៅថា អរិយធម៌មូលសុងនេះឯង។

ប្រព័ន្ធអាកាសធាតុប្រទេសកម្ពុជាចែកឆ្នាំជាពីររដូវខុសៗគ្នា។ មួយជារដូវដែលពោរពេញទៅដោយទឹកស្រោចមកលើប្រទេសទាំងមូល ទឹកជោរជនហើយប្រែប្រទេសកម្ពុជាឱ្យទៅជាវាលសមុទ្រមួយយ៉ាងធំ។ បន្ទាប់មកភ្លៀងក៏រាំងស្ងួតដើម្បីផ្ទេរតំណែងទៅឱ្យរដូវស្ងួតដែលពេលនោះទឹកស្រកអស់បន្តិចម្តងៗដីសស្ងួតក៏លេចឡើងសន្សឹមៗរហូតដល់ដីស្ងួតទូទាំងប្រទេស។ លក្ខណៈបែបនេះឯងហើយដែលនាំឱ្យគេទុកទន្លេមេគង្គជា"ម្តាយឬមេទឹក" ហើយរួមមកវិញតាមដំណើរនៃការផ្លាស់ប្តូរអាកាសធាតុទឹកឡើងទឹកស្រករបស់ទន្លេសាបប្រៀបបានទៅនឹងអាងទឹកធំមួយរបស់ទន្លេ។

ដូច្នេះប្រទេសកម្ពុជាជាប្រទេសដែលទទួលសម្គាល់លក្ខណៈតាក់តែងដោយដំណើរបែងចែករដូវជាពីរផ្នែកហើយរៀបចំទៅតាមគោលការណ៍ទឹកនិយម។ ប្រទេសព្រមទាំងសង្គមទាំងមូលក៏តែងតែឈរលើរបៀបគួបផ្សំគ្នារវាងភេទស្រីមេនិងភេទប្រុស បា ឬ ញី-ឈ្មោល ដែលយកលំនាំនីមួយៗទៅនឹងទឹកនិងដីដែលជាមូលដ្ឋានសំខាន់នៅតែស្ថាបហាប់រហូតមកដល់សព្វថ្ងៃ។

អាពាហ៍ពិពាហ៍រវាងទឹកនិងដីក៏បានសង្កត់

ទិដ្ឋភាពជណ្តើរឡើងពីផ្នែកខាងលើនៃប្រាសាទ

© Philippe Bierny

មានប្រភពដើមពីមហាសមុទ្រឥណ្ឌា ខ្យល់រដូវមូសុង បកឆ្លងកាត់ឧបទ្វីបនេះបានបង្កើតរចនាបទរួមរបស់វានិង ជាលក្ខណៈប្រព័ន្ធសង្គមមួយដែលឋិតថេររបស់អារ្យធម៌អូស្ត្រូ-អាស៊ី

ជាផ្លូវទៅលើផ្នត់គំនិតទំនៀមទម្លាប់ព្រមទាំងជំនឿផ្សេងៗតាំងពីទំហំលោកធាតុនៃអំណាចព្រះរាជារហូតដល់ទំហំយ៉ាងតូចបំផុតនៃជីវភាពប្រចាំថ្ងៃដែលគ្រប់ដណ្តប់ទៅលើដែនសាធារណៈក៏ដូចជាទៅលើដែនឯកជនដែរ។ ការរួមរក្សារវាង មេនិងបា ក៏បានទទួលនូវភាពអមតៈតាមរូបដំណាងពូជពង្សនៃសត្វនាគនោះឯង។ សត្វសស់នេះ ជាស្រីផងនិងប្រុសផងរស់នៅលើគោកផងនិងក្នុងទឹកផង ប្រកបដោយសំណាកនៅពេលចាស់បានផ្តល់ឱ្យវានូវលក្ខណៈអមតៈនេះឯង។

ប្រវត្តិសាស្ត្រដែលដឹកនាំដោយដំណើរឡើងចុះ

ប្រទេសកម្ពុជាកើតឡើងនៅចុងជ្រោយខាងត្បូងនៃឥណ្ឌូចិនក្នុងចំណោមឈូងសមុទ្រចាស់ៗទាំងឡាយដែលមានជួរភ្នំដងរែកជាមាត់សមុទ្រចាស់។ ដែនដីខ្មែរសព្វថ្ងៃជាទីលានទឹកប្រៃមុននឹងស្ងួតបន្តិចម្តងៗ ហើយបន្សល់ទុកនូវទីលានដែលមានលក្ខណៈដូចដែលយើងបានលើកពីខាងលើរួចមកហើយៗដែលកត្តារុញច្រានឱ្យសង្គមខ្មែរមានទម្រង់ជាដំបូងៗ ឥណ្ឌាភាវូបនីយកម្មដែលលាតសន្ធឹងមកក្រោយនេះ ក៏បាន

ជះឥទ្ធិពលខ្លាំងខ្លាលើសង្គមទាំងមូលតែមិនបានប៉ះពាល់ដល់ទិដ្ឋភាពសំខាន់ដែលជាមូលដ្ឋានបានមកពីភាពជាក់ស្តែងភូមិសាស្ត្រនោះឡើយ។

ជាមាត់ជ្រាំងអស់ជួរភ្នំដងរែកដែលមានរាងជាជ្រោះចោតខ្លាំងខ្ពស់ប្រហែលជាង១០០គ.ម បណ្តោយបានចែកដំបន់នោះជាពីរផ្នែកភូមិសាស្ត្រសំខាន់ៗ ហើយចងគ្នាមិនដាច់ឡើយ។ ផ្នែកខាងត្បូងដែលទឹកសមុទ្រស្រុតអស់ទៅគឺជាតំបន់ដីទំនាប ទីវាលដែលមានទន្លេសាបជាថ្នាលទ្រទ្រង់ប្រទេសកម្ពុជាសព្វថ្ងៃនេះ។ ផ្នែកខាងជើង គឺជាទីវាលខ្ពង់រាបបែរមុខចុះទៅខាងជើង ឆ្ពោះទៅរកទន្លេមេណាមនិងទន្លេសេលូអង្គខាងលិច។

តំបន់ទាំងពីរនេះចងគ្នាជារដឹកប្រៀបបានជាប្តីប្រពន្ធតាំងពីបុរាណនៃការកកកើតមនុស្សខ្មែរមក។ មនុស្សគ្រួសារនិងសង្គមខ្មែរ ក៏បានរៀបចំតាក់តែងឡើងសមស្របជាមួយនឹងទឹក(មេ) ហើយនិង (បា) ដើម្បីបង្កើតបានជាស្រុកមួយដែលផ្អែកលើលក្ខណៈច្បាស់លាស់មួយនិងប្រកបទៅដោយទេពកោសល្យផ្ទាល់ខ្លួនដែលរុញច្រានដំណើរការវិវត្តរបស់គេ។ នៅប្រទេសកម្ពុជា (វត្ថុជាតុ) ទាំងឡាយនេះគេឃើញមានប្រមូលផ្តុំនៅលើតួអង្គ អ្នកតាចាស់ទុំរបស់ប្រទេសដែលដឹកនាំសំណង់សង្គម ណែនាំការរៀបចំដែនដីសម្រេចចរិតមនុស្ស ហើយធានាអមតភាពជំនាន់មនុស្សខ្មែរដែលមានអ្នកមានសមត្ថភាពកសាងបានទូវអរិយធម៌ធំមួយចាប់ពី ស.វ. ទី៩ មក។ មរតកនៃអំណាចនេះក៏ក្លាយទៅជាផ្នែកមួយនៃបេតិកភណ្ឌពិភពលោកយើងនេះ។

អង្គរ បន្ទ បេនទ្បា ក៏ឡើងដល់កំពូលនៃអរិយធម៌ខ្មែរគ្រប់វិស័យ ទាំងសេដ្ឋកិច្ច ទាំងនយោបាយ ទាំងមនោគមន៍វិជ្ជា ហើយដែលឈរលើរចនាសម្ព័ន្ធមួយយ៉ាងមានប្រសិទ្ធភាពបំផុតគឺទេវរាជ (អាទិទេពនៃព្រះ)។ រចនាសម្ព័ន្ធនេះគឺនិមិត្តដោយប្រាសាទទាំងឡាយអំពីថ្ម ប្រកបដោយក្បាច់រចនាផ្ទួបគ្នាយ៉ាងប្រណិត ប្រកបទៅដោយសោភ័ណភាពឯក ហើយដែលធ្លាក់ទៅតាមប្រធានទេវកថា បង្ហាញឱ្យឃើញអំពីស្ថានសួគ៌លើលោកីយ៍នេះ។ ប្រាសាទភ្នំទាំងនេះជាលំនៅអស់ព្រះរាជាអំណាចទិព្វហើយក៏ជាដំណាងឱ្យភ្នំព្រះសុមេរុ អ័ក្សនៃលោក ហើយនឹងជាមណ្ឌលទីក្រុងទិព្វរបស់ខ្មែរដែលមានគូទឹក២ ជ្រុងហ៊ុំព័ទ្ធជុំវិញក្នុងការគោរពដល់គោលការណ៍មេ-បា។

ប្រាសាទភ្នំនេះគឺជាកន្លែងរបស់ស្តេចជាមួយនឹងអំណាចដ៏អាថ៌កំបាំង ហើយជាទីឋានតំណាងឲ្យភ្នំមេរុ

ចំណងរវាងខាងជើងនិងខាងត្បូង

ប្រាសាទព្រះវិហារ បានកសាងឡើងនៅលើប្រាសាទសិរៈចាស់ ដែលមានឈ្មោះថា ស្រីសិក្ខារេស្វរៈ(អាទិទេពកំពូលភ្នំ)។ការកសាងប្រាសាទពិសិដ្ឋនេះបានប្រព្រឹត្តទៅក្រោមបញ្ជារបស់ព្រះបាទយសោវរ្ម័ន នាឆ្នាំ ៩០០ ប៉ុន្តែមកដល់ព្រះបាទសុរិយាវរ្ម័នទី១ (១០០២-១០៥០) បែបប្រាសាទនេះមានទម្រង់ដូចសព្វថ្ងៃ ហើយមកដល់ក្រោមរាជ្យព្រះបាទសុរិយាវរ្ម័នទី២ ទើបបានសាងសង់ចប់។ ការងារទាំងអស់ត្រូវបានដឹកនាំក្រោមការបញ្ជារបស់ព្រះគ្រូដ៏ល្បីល្បាញម្នាក់ដែលមានអាយុរហូតដល់ ៨០ ឆ្នាំ តាំងពីព្រះបាទសុរិយាវរ្ម័នទី១ រហូតដល់ ព្រះបាទជ័យវរ្ម័នទី៦ (១០៨០-១១០៧) លោកទទួលគោរមងាជាអាចារ្យព្រះគ្រូ តាគ្រូ ឬស្រីទិវាការៈបណ្ឌិត។

ព្រះវិហារ គេសន្មតជាទីទ្រនំរបស់ព្រះ



ប្រាសាទព្រះវិហារ គោបុរៈទី៣

© C. Frank Starmer

អាទិទេពសក្ការៈមួយអង្គហៅថាអាទិទេពនៃកំពូលភ្នំដែលមានតួនាទីជាដំបូលសក្ការៈដើម្បីការពារព្រមទាំងសុខុមាលភាពដល់មនុស្សលោកនិងប្រទេសទាំងមូលតាមរយៈអំណាចព្រះរាជាដែលជំណាងដោយលិង្គជាជ្រេស្វារៈ ដែលគេបានយកមកពីរាជធានីអង្គរ។ ព្រះរាជាខ្មែរគ្រប់អង្គតែងតែយាងមកផ្តល់ពិធីគោរពបូជាដល់ជំនឿនេះផ្ទាល់តែម្តងឬក៏តាមបួជនីយ៍ទេសចរណ៍។ នៅបុណ្យរំលឹកម្តងៗគេតែងតែសម្បង់សង្រ្វង់ដល់ជានិច្ចជាកាល នាមព្រះបាទជ័យវរ្ម័នទី ២ ដែលព្រះអង្គជាក្សត្រចាប់ផ្តើមកសាងអង្គរ។

អាទិទេពនៃកំពូលភ្នំប្រមូលផ្តុំនូវអំណាចនិមិត្តរូបនៃប្រទេសកម្ពុជាទាំងមូលនៅជុំវិញមនោគមន៍វិជ្ជាថ្មីនៃព្រះសីវៈ។ ដូច្នេះប្រាសាទព្រះវិហារបានកសាងឡើងជាមណ្ឌលសក្ការៈយ៉ាងសំខាន់ជាប្រភពអំណាចផ្ទេរទៅព្រះរាជាក្រោយៗឱ្យព្រះអង្គរក្សាបាននូវចិរភាពរបស់អាណាចក្រក្នុងគំនិតដូច្នេះនេះដែរ សសរសីលាចារឹកវត្តភូ(នៅប្រទេសលាវសព្វថ្ងៃ) បានផ្តាំដល់ព្រះរាជាខ្មែរឱ្យថែរក្សាយ៉ាងប្រចាំនូវពូជរបស់ខ្លួនការពារយ៉ាងមុតមាំនូវលិង្គរាជ។ ដូច្នេះហើយទើបព្រះរាជាខ្មែរតែងតែយាង ហើយនូវបន្តយាងមកទីនេះជាបូជនីយេស៍ដើម្បីបួងសួងដល់អ្នកចាស់ទុំដែលសណ្ឋិតនៅក្នុងតួអង្គព្រះសីវៈជានាបាននូវអមតភាពរបស់ខ្មែរ។

ទីនេះហើយដែលជាអាសនៈខ្ពស់បំផុតរបស់ព្រះសិវៈអាទិទេពសំខាន់មួយក្នុងសាសនាដែលមានតួនាទីសំខាន់ក្នុងការទ្រទ្រង់ឯកភាពនិងនិរន្តរភាពនៃប្រទេសកម្ពុជាទោះជាមានការដាច់ភូមិសាស្ត្រគ្នាត្រង់ជួរភ្នំដងរែក រវាងទួលទំនាបខាងជើងនិងទីវាលទំនាបខាងត្បូងនៃទន្លេសាប។ ស្ថាបត្យកម្មខ្មែរស្វែងរកទីតាំងមួយសមស្របធ្វើយ៉ាងណាឱ្យនិមិត្តរូបឯកភាពអាចសម្រេចទៅបានប្រៀបបានទៅនឹងស្ពានទិព្វមួយចងគ្នាបានយ៉ាងប្រសិទ្ធភាពរវាងទន្លេសាបទៅនឹងទន្លេមូល(មូនជាភាសាសៀម)។

ដូច្នេះព្រះវិហារសណ្ឋកយ៉ាងខែងទៅតាមជម្រាលភ្នំត្រង់កន្លែងដែលខ្ពស់ជាងគេត្រង់នៃភ្នំដងរែកជ្រោះខ្ពស់យ៉ាងចោតបំផុតសង្កត់លើទីវាលខាងត្បូងបែរទៅរកបុរីអង្គរ។ ការតាក់តែងបែបនេះប្រៀបបានទៅនឹងបន្ទំព្រះសិវៈ ដែលអោបទៅដោយមន្តអាគមជាអង្គភាពតែមួយសុទ្ធសាធប្រទេសកម្ពុជាផ្នែកខាងត្បូងទៅនឹងប្រទេសកម្ពុជាផ្នែកខាងជើង។ បារម្មណ៍របស់ព្រះរាជាខ្មែររវាងខាងជើងនិងខាងត្បូង ក៏បានបង្ហាញឡើងដោយសំណង់គោពរៈទី១ សំខាន់ដែលគ្មានទ្វារហើយបិទជិត។ នេះបញ្ជាក់បង្ហាញថែមទៀតថាប្រាសាទព្រះវិហារជានិមិត្តនៃព្រះសិវៈក្បាលព្រះអង្គកើយទៅរកប្រាសាទអង្គរបុរីនៃមណ្ឌលនគរទៅខាងត្បូងឯជង្គង់ខ្លួនព្រះអង្គក៏ដេកបណ្តោយសណ្ឋកតាមជម្រាលទាបបែរទៅរកទិសខាងជើង។ ឯជើងរបស់ព្រះសិវៈនៅខាងជើងជាទ្វារចូលសំខាន់របស់ប្រាសាទដែលសន្ទឹងសន្សើមៗឡើងទៅរកប្រាសាទសំខាន់ៗរហូតដល់កំពូលដែលជាកំពូលសក្ការៈរបស់អាទិទេពសិក្ខារេស្វារៈឬអាទិទេពកំពូលភ្នំ។

ដូច្នេះប្រាសាទព្រះវិហារជាមណ្ឌលសំខាន់បំផុតមួយនៃការរៀបចំដែនដីនៃអាណាចក្រអង្គរនាសម័យរុងរឿងជាចំណុចថ្លឹងស្ទាបជញ្ជីងឱ្យបានស្មើគ្នារវាងតំបន់ខាងត្បូងទន្លេសាបនិងតំបន់ខាងជើងវាលនគររាជ(ភូរាត)។

ប្រាសាទព្រះវិហារគឺជាកន្លែងចាប់ផ្តើមដ៏សំខាន់សម្រាប់រៀបចំព្រះរាជាណាចក្រអង្គរឈានទៅដល់ចំណុចកំពូល

ព្រះឥស្វរ - បរិស្វរៈ ការជាប់ទាក់ទងរវាងប្រាសាទព្រះវិហារ ប្រាសាទវត្តភូនិងរមណីយដ្ឋាន មីសិន ដែលសុទ្ធតែត្រូវបានចាត់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

សាស្ត្រាចារ្យ សច្ចិដានន្ទ សាហៃ Sachchidanand Sahai
ទីប្រឹក្សាអាជ្ញាធរជាតិព្រះវិហារ

របាំព្រះឥស្វរ (ព្រះវិហារ)

© Sachchidanand Sahai

© Sachchidanand Sahai

ទេវតាដែលតំណាងឲ្យសម្បត្តិបេតិកភណ្ឌពិភពលោកនៃប្រាសាទព្រះវិហារមានព្រះនាមថា សិខារិស្វរៈដែលជាឈ្មោះមួយក្នុងចំណោមឈ្មោះជាងមួយពាន់របស់ព្រះឥសូរ

ព្រះអាទិទេព នៃប្រាសាទព្រះវិហារ

បេតិកភណ្ឌពិភពលោកមានព្រះនាមសិខារិស្វរៈ ដែលជាព្រះនាមមួយក្នុងចំណោមព្រះនាមរាប់រយពាន់របស់ព្រះឥសូរ។ព្រះនាមនេះមានន័យថា អាទិទេព(ស្វរៈ) នៃកំពូលភ្នំ (សិខារៈ)។ តាមពិត យោងតាមអក្សរសិល្ប៍ឥណ្ឌា ព្រះឥសូរគង់នៅលើកំពូលភ្នំកៃឡាស់ដែលជាកំពូលភ្នំមួយក្នុងចំណោមកំពូលភ្នំខ្ពស់ៗជាងគេនៅតាមជួរភ្នំហ៊ីម៉ាឡាយ៉ា។ ចំណែកឯទេវកថាខ្មែររៀបរាប់ថាជួរភ្នំដងរែកប្រៀបដូចជាជួរភ្នំ ហ៊ីម៉ាឡាយ៉ា នៃអាណាចក្រអង្គរ ហើយជ្រលងជ្រោះព្រះវិហារប្រៀបដូចជាភ្នំកៃឡាស់ពោលគឺជាទីឋានរបស់ព្រះឥសូរ។ ប្រាសាទព្រះវិហារក៏ធ្លាប់ជាទីឋាននៃទម្រង់មួយផ្សេងទៀតដ៏មានអំណាចខ្លាំងអស្ចារ្យរបស់ព្រះឥសូរដែរដែលមានព្រះនាមថាបរិស្វរៈ (អាទិទេពល្អ)។

ក្នុងនាមជាព្រះមហាក្សត្រសោយរាជ្យ ព្រះឥសូរដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គ ហើយប្រជារាស្ត្រក៏សន្យាថានឹងស្មោះត្រង់ចំពោះព្រះអង្គវិញដែរ។ ព្រះឥសូរគឺជាអាទិទេពនៃលោកសន្និវាសទាំងមូល។ អំណាចដ៏ខ្លាំងក្លាដែលព្រះអង្គមានចំពោះលោកសន្និវាសទាំងមូលធ្វើឲ្យព្រះឥសូរក្លាយជាអាទិទេពតែមួយអង្គគត់ដែលអាចបញ្ជាអ្វីៗបានទាំងអស់។ រាល់សារធាតុទាំងអស់ដែលផ្ដុំកើតចេញជាភពទាំងមូល (មានដី ភ្នំ ស្ទឹង សមុទ្រ ផ្កាយ ព្រមទាំងអាទិទេពផ្សេងទៀតរាល់ស្ងួតទេពនិងសត្វលោកមានជីវិតក្ដី គ្មានជីវិតក្ដី) មានអត្ថិភាព ឬគ្មានទៅតាមព្រះចេតនារបស់ព្រះអង្គ។

អំណាចរបស់ព្រះឥសូរ គឺជាប្រធានបទដែលគេឃើញហើយឃើញទៀតនៅប្រាសាទព្រះវិហារ។

យោងតាមសិលាចារឹកមួយដែលគេរកឃើញនៅក្នុងប្រាសាទ (សិលាចារឹក K380) រៀបរាប់ថា ព្រះអាទិទេពបរិស្វរៈនៃលិង្គបុរី(វត្តភូ) បានមកដល់សិខារិស្វរៈ (ព្រះវិហារ) នៅឆ្នាំ ១០៣៨ដើម្បីសម្ដែងនូវភាពមហស្ចារ្យនៃព្រះឥសូរក្នុងទម្រង់ជាពន្លឺ។ ម្យ៉ាងវិញទៀតកិរិយាស័ព្ទខ្មែរមក គឺសំដៅជាពិសេសទៅការមកដល់របស់អាទិទេព។ ព្រះមហាក្សត្រនាសម័យនោះក៏បានបញ្ជាឲ្យប្រជាជននៅតាមទីកន្លែងផ្សេងៗ ស្បថរក្សាភាពស្មោះត្រង់ចំពោះអាទិទេព។ អនុលោមទៅតាមបញ្ជារបស់ព្រះឥសូរ សមាជិកក្រុមបះបោរប៉ាខ្មៅត្រូវបានផាត់ចេញពីសម្បថនេះ។

បរិស្វរៈគឺជាអាទិទេពថែរក្សាបូជនីយដ្ឋានមីសិន ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកដែរ។ រមណីយដ្ឋាននេះបង្ហាញអំពីវប្បធម៌ចាមនៅភូមិភាគកណ្ដាល នៃប្រទេសវៀតណាមបច្ចុប្បន្ន។ នៅសតវត្សទី៥ ព្រះមហាក្សត្រមួយអង្គរបស់ប្រទេសចំប៉ា ព្រះនាម ដេវ៉ានិកា បានយាងទៅដល់លីងហ្គាប៉ាវ៉ាតា នៅវត្តភូ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ) ដើម្បីបង្កើតដែនដីដ៏សុខសាន្តមួយសម្រាប់គរុក្សត្រានៅតាមដងទន្លេមេគង្គ។ បន្តិចម្ដងៗ ការគោរពបូជាបរិស្វរៈបានក្លាយជា ការគោរពដ៏មានប្រជាប្រិយភាពនៅវត្តភូ (ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូដែរ) ហើយបរិស្វរៈក៏បានក្លាយជាអាទិទេពថែរក្សាអាណាចក្រខ្មែរនៅសម័យមុនអង្គរ។ ព្រះមហាក្សត្រអង្គរបានបន្តគោរពទម្រង់ដ៏មានអំណាចខ្លាំងក្លានៃព្រះឥសូរនេះ។ ប្រាសាទភ្នំដ៏ល្បីល្បាញគឺប្រាសាទប្រែរូប ដែលត្រូវបានកសាងឡើងដើម្បីឧទ្ទិសដល់រាចិន្ទ្របរិស្វរៈ។

បន្ទាប់មកព្រះបរិស្វរៈបានយាងពីមីសិនទៅវត្តភូ បន្ទាប់មកពីវត្តភូទៅព្រះវិហារ។ រមណីយដ្ឋានទាំងបីនេះផ្សារភ្ជាប់គ្នាដោយប្រវត្តិសាស្ត្ររយៈពេល១៥០០ឆ្នាំ អាចនឹងត្រូវផ្សារភ្ជាប់គ្នាសាជាថ្មីឡើងវិញ តាមរយៈគម្រោងកិច្ចសហ



របាំព្រះឥសូរ (បន្ទាយស្រី)

© Sachchidanand Sahai



ព្រះអាទិត្យលិចនៅព្រះវិហារ

© Sachchidanand Sahai

ប្រតិបត្តិការសម្រាប់ជាប្រយោជន៍សម្បត្តិបេតិកភណ្ឌពិភពលោក។ ជាឧទាហរណ៍ ដំណើរយាងរបស់ព្រះបរិស្វរៈគួរត្រូវធ្វើពិធីរំលឹកដើម្បីជួយជំរុញឲ្យមានការផ្លាស់ប្តូរគំនិតគ្នា មានកិច្ចសហការទៅវិញទៅមកនិងទាក់ទាញភ្ញៀវទេសចរ។ ការផ្តួចផ្តើមគំនិតជាច្រើនក៏គួរអាចត្រូវធ្វើឡើងដើម្បីធ្វើឲ្យទិសដៅវប្បធម៌ដែលផ្សារភ្ជាប់រមណីយដ្ឋានព្រះវិហារ វត្តភូនិងមីសិន ក្លាយជាចំណងទំនាក់ទំនងផ្លូវការក្នុងកម្រិតរដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាល។

កាឡា

កាឡាតំណាងឲ្យពេលវេលាដាច់ខាត។ តាមពិតកាឡា គឺជាព្រះនាមមួយផ្សេងទៀតរបស់ព្រះឥសូរដែលត្រូវបានពិពណ៌នាថា ដូចជាអាទិទេពបង្កើតពេលវេលា។ ព្រះឥសូរបញ្ចប់របាំបំផ្លាញលោកនៅខាងលើជ្រោះព្រះវិហារចំណែកឯព្រះនារាយណ៍ដែលធ្វើអ្វីៗក្រោមការគ្រប់គ្រងរបស់ព្រះអង្គ (គោបុរៈ២) ក៏ចូលរួមនៅខាងក្រោមក្នុងដំណើរបង្កើតលោកឡើងវិញ។

របាំព្រះឥសូរ

ហោជាងនៅលើក្លោងទ្វារខាងជើងដែលនាំអ្នកដំណើរចូលទៅក្នុងបូជនីយដ្ឋានធំនៃប្រាសាទព្រះវិហារមានឆ្លាក់រូបព្រះឥសូរ មានដៃ១០ កំពុងរេរាំនៅលើក្បាលដំរីមួយ។ ឥរិយាបថនៃក្បាលសត្វដំរីបញ្ជាក់យ៉ាងច្បាស់ថា វាត្រូវបានបង្ក្រាបដោយព្រះឥសូរ៖ គេឃើញដំរីចំពីមុខ ត្រចៀកបើកនិងប្រមោយបត់កោងទៅលើកាឡា។ រូបចម្លាក់នេះគឺជារូបព្រះឥសូរមិនអាចប្រកែកបានឡើយ។ នៅត្រង់នេះអាទិទេពត្រូវបានឆ្លាក់ជារូបគង់នៅលើក្បាលមារក្នុងទម្រង់ជាដំរីមួយក្បាលហើយព្រះអង្គកំពុងសម្លាប់ដំរីនោះ។ មើលទៅទិដ្ឋភាពដ៏កាចសាហាវរបស់ព្រះឥសូរដែលកំពុងផ្តាញ់មារនេះ ហាក់ដូចជាត្រូវបានគេគោរពនៅព្រះវិហារ ដូចការដែលមកដល់របស់បរិស្វរៈព្រះឥសូរនៅវត្តភូទៅដល់សិខារិស្វរៈជាសក្ខីភាពស្រាប់ការលេចឡើងនូវភាពដ៏អស្ចារ្យរបស់ព្រះឥសូរក្រោមព្រះនាមសិខារិស្វរៈ ការបះបោររបស់ក្រុមប៉ុល្ពតនៅក្នុងតំបន់ព្រះវិហារនិងការកសាងសន្តិភាពនៅតាមតំបន់ជួរភ្នំដងរែក តាមរយៈសម្បថរក្សាភាពស្មោះត្រង់ចំពោះសិខារិស្វរៈ មានលក្ខណៈដូចៗគ្នាជាច្រើន។

របាំលោកធាតុរបស់ព្រះឥសូរ

ព្រះឥសូរ រាំជារៀងរហូតនៅលើមេឃស្រឡះដែលមានពួកយោគីជាអ្នកទស្សនា។ នៅលើជ្រោះព្រះវិហារព្រះឥសូររាំនៅលើក្បាលដំរីក្រោមលំហមេឃ។ ជាងចម្លាក់បានឆ្លាក់ឈុតរបាំលោកធាតុនៃការបំផ្លាញលោកនៅក្នុងលំហគ្មានដែនកំណត់ដោយឆ្លាក់រូបព្រះឥសូរមានដៃ១០នៅក្នុងជំហរមួយហោះទៅលើមេឃ។

ខណៈដែលព្រះឥសូររាំក្នុងពេលព្រះសុរិយារៀបអស្តង្គត បន្ទាប់ពីបានបង្ក្រាបមារក្នុងទម្រង់ជាដំរីពិភពលោកទាំងមូលក៏រាំជាមួយព្រះអង្គដែរ។ ក្នុងរយៈពេលមួយពាន់ឆ្នាំព្រះអាទិត្យអស្តង្គតក្នុងពន្លឺក្រហមឆ្អៅធម្មជាតិដែលនៅក្រោមពន្លឺនោះ ព្រះឥសូររាំលើកទីមួយនៅក្នុងអតីតកាលបែបព្រេងនិទាន។ ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកស្មោះស្ម័គ្រនឹងព្រះអង្គ គយគន់របាំអត្តាធីនភាពនៅក្រោមពន្លឺ នៃការស្ទើររៀបអស្តង្គតរបស់ព្រះអាទិត្យ។ ខ្ញុំផ្ទាល់ធ្លាប់មានសំណាងបានទស្សនាព្រះអាទិត្យ រៀបអស្តង្គតជាច្រើនដងនៅលើកំពូលជ្រោះព្រះវិហារ រង់ចាំរបាំព្រះឥសូរ។

របាំព្រះឥសូរនៅបន្ទាយស្រី

នៅបន្ទាយស្រី ព្រះឥសូររាំនៅក្នុងក្បាច់ចម្លាក់រាងជាផ្កា។ ជាចម្លាក់បានឆ្លាក់រូបព្រះអង្គនៅក្នុងបរិយាកាសមួយដ៏ស្ងប់ស្ងាត់ ដែលក្នុងនោះ ព្រះអង្គកំពុងរាំរបាំសុភមង្គលនៅក្នុងសាលសម្បជញ្ញៈ។ បើប្រៀបធៀបទៅនឹងរបាំនេះ អត្ថន័យនៃរបាំនៅព្រះវិហារពិតជាមិនអាចប្រកែកបានឡើយ៖ នៅទីនោះ អាទិទេពត្រូវបានឆ្លាក់ជាទម្រង់ដ៏សាហាវបំផុតដើម្បីរាំតាមចង្វាក់មួយដ៏ព្រៃផ្សៃ គឺជាចង្វាក់នៃការបំផ្លាញលោក។ បើនិយាយអំពីចម្លាក់ព្រះឥសូរមានដៃ១០នៅព្រះវិហារត្រូវនឹងរូបនៅខាងមុខប្រាសាទ។ មុននឹងឈានជើងចូលដល់ក្នុងបន្ទប់ដើម្បីគោរពបូជារូបលិង្គរបស់ព្រះអង្គ អ្នកទស្សនាឬក៏អ្នកដែលមានភក្តីភាពចំពោះព្រះអង្គត្រូវបានប្រាប់ជាមុនអំពីទម្រង់របស់ព្រះអង្គដែលពួកគេនឹងឃើញនៅក្នុងបូជនីយដ្ឋាន។ ចក្ខុវិស័យរបស់ព្រះឥសូររាក្នុងទម្រង់បំផ្លាញកម្លាំងមារសត្រូវតំណាងឲ្យការសម្រេចបាននៃការធ្វើដំណើរដ៏លំបាកដើម្បីឈានទៅដល់កម្រិតកំពូល។

ខណៈដែលព្រះអាទិត្យចាប់ផ្តើមលិចបាត់នៅម្ខាងទៀតនៃជ្រោះធ្វើឲ្យទីស្ថានធ្លាក់ចូលទៅ



ឥសី

© Sachchidanand Sahai

ឥសីគឺជារូបចម្លាក់ដែលគេឃើញញឹកញាប់នៅក្នុងចម្លាក់លើប នៃប្រាសាទព្រះវិហារ

ក្នុងទីងងឹតប្រកបដោយភាពអាថ៌កំបាំង ពពកខ្មៅប្រមូលផ្តុំនៅពីខាងលើប្រាសាទដ៏ទ្រុឌទ្រោមៗ មេឃខ្មៅដ៏ធំល្វឹងល្វើយធ្វើឲ្យគេមានអារម្មណ៍ដ៏ចម្លែក៖ រូបរាងរបស់ព្រះឥសូរហាក់ដូចជាកំរើក ដៃសំពះរបស់ព្រះអង្គក៏លើកឡើងសំដៅទៅលើមេឃ។ បរិយាកាសទាំងមូលហាក់ដូចជាញ័រទៅតាមចង្វាក់នៃអំណាចសំឡេងស្គរដែលប្រគំដោយគោនន្ទដ៏ស្មោះស្ម័គ្ររបស់ព្រះអង្គ។ ព្រះអាទិទេពគង់នៅលើជើងទម្រពីរជាប់គ្នាដែលមួយគឺជាក្បាលដំរីនិងមួយទៀតគឺជាក្បាលកាឡា។ តាមរយៈរបាំនេះ ព្រះអង្គដើរតួជាអាទិទេពនៃពេលវេលាជារៀងរហូតផងនិងជាអាទិទេពបំផ្លាញមារផង។ នៅក្នុងសំឡេងស្គរចុងក្រោយ គ្របាំបញ្ចប់វដ្តនៃការបំផ្លាញលោក។ បន្ទាប់មក ដោយបញ្ចេញស្នាមញញឹមទៅកាន់អ្នកមើលតែមួយរូបគត់របស់ព្រះអង្គនោះ ព្រះឥសូរបក់ដៃអញ្ជើញទស្សនិកជន របស់ព្រះអង្គឲ្យអានសិលាចារឹកនៅលើជញ្ជាំងប្រាសាទព្រះវិហារ ដើម្បីស្វែងយល់អំពីអាថ៌កំបាំងនៃសិខាស្វរៈ។

ព្រះវិហារ គឺជាទីកន្លែងមួយដែលវត្តមានរបស់ព្រះឥសូរពិតជាមានច្រើនអនេកតាមរយៈទម្រង់លិង្គទាំងបួនរបស់ព្រះអង្គ៖ រូបលិង្គនីកាឡាអាទិទេពសុរ្យវរ្ម័ន (សូរិយវរ្មស្វរៈ) បរិស្វរៈនិងសិខាស្វរៈ។ រមណីយដ្ឋានជាទីសក្ការៈនេះក៏រំលឹកផងដែរ អំពីទិដ្ឋភាពដ៏ឃោរឃៅរបស់ព្រះឥសូរក្នុងនាមជាអាទិទេពផ្ចាញ់មារ ខុសពីលក្ខណៈទូទៅ ដែលប្រជារាស្ត្រខ្មែរច្រើនស្រឡាញ់ចូលចិត្តនិងគោរពបូជាព្រះឥសូរក្នុងទម្រង់ជាអាទិទេពស្ងប់ស្ងាត់។ លក្ខណៈនេះផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងតួនាទីពិសេសដែលព្រះឥសូរមាននៅក្នុងតំបន់ជួរភ្នំដងរែកដើម្បីប្រឈមទៅនឹងការប្រឆាំងដែលមាននៅក្នុងអារ្យធម៌ខ្មែរ។ ម្យ៉ាងទៀត ក្រុមបះបោរប៉ាខ្មៅពន្យល់អំពីទិដ្ឋភាពដ៏សាហាវរបស់ព្រះឥសូរ។ បរិស្វរៈគឺជាអាទិទេពល្អ ជាព្រះដែលប្រសិទ្ធពរជ័យដល់អ្នកមានភក្តីភាពចំពោះព្រះអង្គនិងធ្វើទារុណកម្មដល់កម្លាំងមារសត្រូវ។

ឥសី

ជួរភ្នំដងរែក គឺជាកន្លែងសម្រាប់ធ្វើការភាវនាធម៌។ ម្យ៉ាងទៀតឥសីគឺជារូបចម្លាក់ដែលគេឃើញញឹកញាប់នៅក្នុងចម្លាក់លើបនៃប្រាសាទព្រះវិហារ។ ព្រះមហាក្សត្រសុរិយវរ្ម័នទី១ប្រកាសថាគឺដោយសារកម្លាំងនៃភាពជាឥសីរបស់ព្រះអង្គនេះហើយដែលព្រះបរិស្វរៈនៃលិង្គបុរីបានយាងមកសោយរាជ្យនៅសិខាស្វរៈ។ នៅសម័យអង្គរ ជួរភ្នំដងរែកពោរពេញទៅដោយអាស្រមឥសីនិងជារមណីយដ្ឋានសម្រាប់ធ្វើការភាវនាធម៌។

មហាអាចារ្យនៃព្រះមហាក្សត្រសុរិយវរ្ម័នទី២ ឈ្មោះ ឌីវគរបណ្ឌិត បានកសាងរូបចម្លាក់លាបពណ៌មាសនៃរបាំព្រះឥសូរនៅព្រះវិហារ។ រូបនេះត្រូវបានពិពណ៌នាជាភាសាខ្មែរថា ជាអាទិទេពដែលរាំ ជារូបដែលលាបពណ៌មាសជាជាងការពិពណ៌នា ដោយប្រើពាក្យសំស្រ្កឹតថា ណាតរាជ្យ។ របាំលោកធាតុបុរាណនៃអរិយធម៌អង្គរនេះ ឬហៅថារបាំ កៃឡាស់ ឬរបាំភ្នំកៃឡាស់ នាពេលបច្ចុប្បន្នអាចធ្វើឲ្យរស់ឡើងវិញ ដើម្បីបញ្ចូលទៅក្នុងទេសភាពនៃប្រាសាទព្រះវិហារ ចំណែកឯជ្រោះនៅខាងលើ អាចធ្វើជាកន្លែងសម្តែងល្ខោនគ្មានដំបូលដែលភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានជាទីសក្ការៈនេះអាចគយគន់របាំលោកធាតុរបស់ព្រះឥសូរ។

ភ្ញៀវទេសចរក៏អាចគយគន់ផងដែរនូវសំណង់ដ៏ស្រស់ឆើតឆាយល្អឯក នៃប្រាសាទព្រះវិហារ ផ្ទាំងថ្មធំៗជាច្រើននៅក្នុងរមណីយដ្ឋានដែលរំលឹកដល់ចម្លាក់រស់រវើក រូងភ្នំដែលតំណាងឲ្យការស្វែងរកកម្លាំងនិងសុខសន្តិភាពក្នុងខ្លួនរបស់មនុស្ស ហើយទឹកជ្រោះដ៏អស្ចារ្យផ្តល់ជូននូវសំឡេងតន្ត្រីដ៏ស្រទន់ ឮពីចម្ងាយ កំដររបាំលោកធាតុរបស់ព្រះឥសូរ។ ជាការពិត ការបង្ហាញជូនប្រាសាទព្រះវិហារជារមណីយដ្ឋានបុរាណវិទ្យាឬស្ថាបត្យកម្មតែមួយមុខ មិនឆ្លើយតបទៅនឹងចក្ខុវិស័យនៃអរិយធម៌អង្គរនោះទេ។ ដូចដែលយើងស្នើឡើងនៅពេលនេះការរៀបចំបង្កើតទំនាក់ទំនងបុរាណដែលផ្សារភ្ជាប់រមណីយដ្ឋានមីសិន វត្តភូនិងព្រះវិហារតាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការនឹងអនុញ្ញាតឲ្យមានការបន្តប្រពៃណីនិងជំនឿរបស់ដូនតាយើង។

តំបន់ក្នុងបញ្ជីបម្រុង



ប្រាសាទធំនៅកោះកេរ
© Guillen Perez



កោះកែរ
ប្រាសាទចិននិងចម្លាក់នៅក្នុងប្រាសាទនេះ

បណ្ឌិត **អេរិក បួរដូណូ Éric Bourdonneau**
សាស្ត្រាចារ្យសាលាបារាំងចុងបូព៌ាប្រទេស ក្រុងប៉ារីស

ឌួរយ៉ូដាណា មកពីប្រាសាទចិននិងជើងទម្ររបស់វា

© រូបភាពឌួរយ៉ូដាណា បានមកពីសារៈមន្ទីរ Guimet និងជើងទម្រ ថតដោយ Eric Bourdonneau

ប្រាសាទ ចិនអាចត្រូវបានចាត់ទុកជាប្រាសាទដ៏ធំមួយដែលឧទ្ទិសដល់ព្រះនរាយណ៍នៅក្នុងរមណីយដ្ឋានវប្បធម៌ដ៏ធំល្វឹងល្វើយដែលគេកសាងឡើងនៅចំកណ្តាលរាជបុរីកោះកែរដែលជារាជធានីមួយមានអាយុកាលខ្លី មានឈ្មោះល្បីលប់មហាកិត្តិនាមនៃក្រុងអង្គរអស់រយៈពេល២០ឆ្នាំក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (ព្រះអង្គសោយរាជ្យពីឆ្នាំ៩២១ដល់ឆ្នាំ៩៤១)។

ចម្លាក់ក្នុងប្រាសាទនេះឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអំណាចនៃអាណាចក្រទៅក្រៅតំបន់វាលទំនាបនៃតំបន់សៀមរាប។ បូជនីយដ្ឋាននេះនៅតែគ្មានបូជនីយដ្ឋានណាផ្សេងប្រៀបបានឡើយក្នុងសម័យអង្គរទាំងមូល។ នៅក្នុងប្រាសាទនេះរូបក្នុងរឿងនិទានដែលដកស្រង់ចេញពីទេវកថាឥណ្ឌាមិនត្រូវបានឆ្លាក់ជាចម្លាក់លិបដូចដែលគេឃើញនៅលើហោជាងនិងផ្តែរនៃប្រាសាទផ្សេងៗឡើយ ប៉ុន្តែត្រូវបានគេឆ្លាក់ជាចម្លាក់ទាំងមូលៗទំហំស្មើនឹងរូបមនុស្សពិត ឬក៏អាចនិយាយថាជាចម្លាក់ឯក ពោលគឺជាការដែលចង់ឲ្យមានអារម្មណ៍ថាពិតៗ។ សំណង់ទាំងពីរនៅតាមផ្លូវចូលត្រង់កំពែងទីមួយនៃប្រាសាទចិនផ្ទុកទៅដោយរូបចម្លាក់តំណាងឲ្យការប្រយុទ្ធគ្នានៃគូសត្រូវដែលដកស្រង់ចេញពីរឿងរាមកេរ្តិ៍គូសត្រូវទាំងពីរគឺស្តេចស្វា វាលិននិងសុគ្រីព និងសង្គ្រាមស្លាប់រស់រវាង ប៊ីម៉ានិងឌូរយ៉ូដាណា ដកស្រង់ចេញពីសៀវភៅភាគទី៩នៃទេវកថា មហាបារ៉ាតា។

នៅក្នុងករណីទាំងពីរ រូបចម្លាក់ទាំងអស់ (ដែលសម័យមុនមានលាបពណ៌) ស្ថិតនៅពេញខាងក្នុងប្រាសាទ ដែលធ្វើឲ្យទីនេះក្លាយទៅជាឆាកល្ខោនជាច្រើន ដែលឆាកនីមួយៗតំណាងដោយជើងទម្រ ដែលសុទ្ធតែមានតួសម្តែងនៅពីលើ។ ប្រហែលជានៅក្នុងសំណង់ត្រង់ក្លោងទ្វារចូលខាងលិចដែលគេឆ្លាក់រូបប៊ីម៉ានិងឌូរយ៉ូដាណាទំហំដ៏ធំអស្ចារ្យនៃរូបចម្លាក់នៅកោះកែរទាំងនេះមានលក្ខណៈប្លែកនិងថ្មីជាងគេ។ នៅចំកណ្តាលនៃរូបចម្លាក់តំណាងឲ្យតួអង្គចំនួន៧ រូប (មានបងប្អូនប៉ាន់ដាវ៉ា ទាំងបួនអង្គ រួមនឹងគ្រឹស្នា ពលរាមនិង ជ្រស្តាយុមនា) វីរៈបុរសពីរជាចម្លាក់អង្គុយនៅក្នុងពេលការប្រយុទ្ធមានសភាពខ្លាំងក្លាដល់កម្រិតកំពូល ដែលគេនិទានឡើងនៅក្នុងរឿងមហាបារ៉ាតា៖ ឌូរយ៉ូដាណាហោះលឿនស្ទើរទៅលើអាកាស ចំណែកឯប៊ីម៉ាសង្កត់លើជើងរបស់ឌូរយ៉ូដាណា បង្វិលព្រះកាយបម្រុងនឹងកាច់បំបាក់ជើងដោយ វាយយ៉ាងខ្លាំងនឹងដំបងរបស់ព្រះអង្គ។

នៅត្រង់នេះគេត្រូវយកចិត្តទុកដាក់ទៅលើកិច្ចការដ៏ល្អឯកអំពីការរក្សាលំនឹងនៃដងខ្លួននិងអវៈយវៈ ដើម្បីស្វែងយល់អំពីទេពកោសល្យដ៏

ប៊ីមាមកពីប្រាសាទចិន កោះកែរ

© Norton Simon Art Foundation

ជើងទម្ររបស់ប៊ីមា កោះកែរ

© Eric Bourdonneau

ការប្រយុទ្ធរវាង ឌូរយ៉ូដាណានិងប៊ីមាដែលមានប៉ាដាវ៉ាលុតជង្គង់បីរូបជាសាក្សី (អាជូណា សហទេពនិងណានកុល) មកពីប្រាសាទចិន កោះកែរ

© រៀបចំដោយ Eric Bourdonneau

កំពូលរបស់ជាងចម្លាក់នៅកោះកែរ។ គ្មានកន្លែងណាផ្សេងក្នុងសម័យនោះ ដែលគេឃើញមានសិល្បករឈានដល់កម្រិតខ្ពស់បែបនេះក្នុងការឆ្លាក់រូបឲ្យមានចលនាដូចជារូបចម្លាក់ឱ្សរយ៉ូដាណាហោះទៅលើអាកាសនោះឡើយ។ គ្មានកន្លែងណាផ្សេង ដែលគេអាចឃើញរូបចម្លាក់សម័យអង្គរមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងរូបស្រង់ចេញពីរឿងល្ខោនបែបនេះឡើយ! គេឃើញនៅក្នុងជំហានថយក្រោយមួយនេះនូវការទប់ជំហរជាន់លើជើងប៉ាន់ដាវ៉ាបង្ហាញពីកម្រិតនៃកម្លាំងវាយលុកដែលគេប្រុងនឹងធ្វើឡើង៖ នៅក្នុងប្រវែងប្រមាណសង់ទីម៉ែត្រនេះកែងជើងប៊ីម៉ាលៀនចេញផុតពីផ្ទៃនៃជើងទម្រវាសង្វើបនិងប្រមូលផ្តុំនូវកម្លាំងដ៏រស់រវើកនៃឈុតឆាកមួយនេះ។

ហើយចុងក្រោយ គេអាចបន្ថែមទៀតថា គ្មានកន្លែងណាផ្សេងដែលគេអាចឃើញការគាស់កកាយ យកវត្ថុបុរាណក្នុងសម័យថ្មីនៅតាមបូជនីយដ្ឋានអង្គរ(ឬក៏អាចនិយាយឲ្យច្បាស់ជាងនេះថា ជាការកាប់គាស់យកវត្ថុបុរាណនាសម័យថ្មី ពីព្រោះការកាប់គាស់នេះបានកើតឡើងក្រោយឆ្នាំ១៩៧០) មានលក្ខណៈស្វ័យប្រវត្តិនិងស៊ើបដំណឹងបានយ៉ាងល្អដូច្នេះឡើយ។ គ្មានរូបចម្លាក់ណាមួយក្នុងចំណោមក្រុមចម្លាក់ប៊ីម៉ានិងឱ្សរយ៉ូដាណា ត្រូវបានគេរកឃើញនៅកន្លែងដើមឡើយ (ករណីដូចគ្នានេះកើតឡើងចំពោះរូបចម្លាក់ចម្បាំងរវាងវ៉ាលីននិងសុគ្រីព)។ នាពេលបច្ចុប្បន្ននេះ គេឃើញនៅសល់តែជើងទម្រដែលពួកចោរបានកាត់ផ្នែកខាងលើចេញបាត់ នេះពិតជាគួរឲ្យសោកស្តាយយ៉ាងខ្លាំងចំពោះចម្លាក់បុរាណដែលជាមហាស្នាដៃដ៏ធំ ហើយដែលកម្ពុជាសម័យបុរាណបានបន្សល់ទុកជូនបេតិកភណ្ឌមនុស្សជាតិ។ ប៉ុន្តែបំណែកដែលនៅសេសសល់ក៏នៅតែមានតម្លៃមិនអាចកាត់ថ្លៃបានពីព្រោះវានឹងជួយឲ្យគេរកឃើញចម្លាក់ទាំងឡាយដែលបានបាត់បង់ទៅដោយគ្មានការសង្ស័យឡើយ។ រូបចម្លាក់ប៊ីម៉ា នៅពេលបច្ចុប្បន្ននេះស្ថិតនៅក្នុងសារមន្ទីរ ន័រតុន សាយមន នៅប៉ាសាដេណា ក្នុងរដ្ឋកាលីហ្វកញ៉ា រូបចម្លាក់ឱ្សរយ៉ូដាណា បច្ចុប្បន្ននេះស្ថិតនៅក្នុងវិចិត្រសាលសុតប៊ីហ្ស៍ (ក្រុងញូវយ៉ក) ដែលជាកម្មសិទ្ធិរបស់អ្នកធ្វើសមុច្ច័យឯកជនម្នាក់ ចម្លាក់នេះបានក្លាយជាប្រធានបទនៃបណ្តឹងរបស់ការិយាល័យព្រះរាជអាជ្ញាក្រុងញូវយ៉ក ដើម្បីធ្វើយ៉ាងណាឲ្យគេប្រគល់រូបចម្លាក់នេះជូនកម្ពុជាវិញ។ រូបចម្លាក់ ប៉ាន់ដាវ៉ា ទាំងពីរស្ថិតនៅក្នុង សារមន្ទីរសិល្បៈមេត្រូប៉ូលីតាំង ក្រុងញូវយ៉កហើយរូបចម្លាក់ផ្សេងទៀតស្ថិតនៅតាមសារមន្ទីរផ្សេងៗដូចជា សារមន្ទីរ ក្លេវឡែននិងដិនវ័រ ក៏ដូចជានៅក្នុងសមុច្ច័យឯកជនផ្សេងៗ។

ព័ត៌មាន

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ សារមន្ទីរសិល្បៈមេត្រូប៉ូលីតាំងនៃក្រុងញូវយ៉កបានប្រកាសថាខ្លួននឹងដឹកយករូបចម្លាក់បងប្អូនប៉ាន់ដាវ៉ាទាំងពីរដែលមានប្រភពមកពីប្រាសាទចិននិងដែលកំពុងស្ថិតនៅក្នុងសមុច្ច័យរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៩០មកប្រគល់ជូនកម្ពុជាវិញ។

នាយកសារមន្ទីរលោក តូម៉ាស កំបែល បានប្រកាសដូច្នេះថា៖ "វាជាករណីមួយដែលព័ត៌មានបន្ថែមពាក់ព័ន្ធនឹងរូបចម្លាក់ "អ្នកបម្រើលត់ជង្គង់" បានធ្វើឲ្យសារមន្ទីរគិតដល់ព្រឹត្តិការណ៍ដែលគេមិនបានដឹងកាលពីសម័យទទួលបានចម្លាក់ទាំងនេះនិងចាត់វិធានការ..."។

រាជរដ្ឋាភិបាលកម្ពុជាបានសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះកាយវិការនេះ ហើយសូមអំពាវនាវឲ្យសារមន្ទីរផ្សេងទៀតក៏ដូចជាអ្នកធ្វើសមុច្ច័យសិល្បៈដែលកំពុងរក្សាទុកនូវរូបចម្លាក់ផ្សេងទៀតទាំងប៉ុន្មាន សូមឲ្យពួកគេយកគំរូតាមឧទាហរណ៍នេះ ហើយនៅក្នុងក្របខណ្ឌនៃការអំពាវនាវក្នុងពិភពលោកសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ សូមប្រគល់រតនសម្បត្តិដែលគេបានលួចទៅនេះជូនម្ចាស់ដើមដោយស្របច្បាប់វិញ។

© Metropolitan Museum of Art

© Metropolitan Museum of Art

កិច្ចប្រជុំពេញអង្គលើកទី ៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពិធីប្រគល់និងទទួលរូបចម្លាក់ពីសារមន្ទីរមេត្រូប៉ូលីតែន

សម្តេចតេជោ ហ៊ុន សែន គោរពនិងស្វាគមន៍ការត្រឡប់មកវិញនូវរូបចម្លាក់បងប្អូនប៉ាន់ដាវ៉

© ទីស្តីការគណៈរដ្ឋមន្ត្រី

ពិធីប្រគល់រូបថតជានិមិត្តរូបនៃការប្រគល់ជាផ្លូវការនូវរូបចម្លាក់សហទេពនិងណានកុល ពីសារមន្ទីរមេត្រូប៉ូលីតែន

© ទីស្តីការគណៈរដ្ឋមន្ត្រី

រមណីយដ្ឋានសម្បូរព្រៃគុក ក្រុងប្រាសាទបុរាណ

អគ្គនាយកដ្ឋានបេតិកភណ្ឌ
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



ប្រាសាទសម្បូណ៌ : ប្រាង្គ N7

© អគ្គនាយកដ្ឋានបេតិកភណ្ឌ-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ឦសានបុរៈ ជា រាជធានីបុរាណដែលកសាងឡើងនៅសតវត្សទី៧នៃគ្រិស្តសករាជក្នុងសន្តតិវង្ស ចេនឡា ហើយបានបន្តជាមជ្ឈមណ្ឌលសាសនាដ៏សំខាន់ក្នុងសម័យមុនអង្គរនិងសម័យអង្គរ។ បច្ចុប្បន្ន សំណល់បុរាណដ្ឋាន ជាច្រើនរបស់រាជធានីនេះស្ថិតនៅក្នុងរមណីយដ្ឋានសម្បូរណ៍ព្រៃគុក មានជាអាទិ៍ ប្រាសាទតដ្ឋកសំណាទឹក កំពែង សំណង់ធារាសាស្ត្រសម្រាប់ការប្រើប្រាស់និងជំនឿសាសនា។ រមណីយដ្ឋាននេះកសាងឡើងជាបន្តបន្ទាប់អស់រយៈពេលជាង ៥០០ ឆ្នាំ ដែលរំលេចទៅដោយតួប្រាសាទនិងស្នាដៃសិល្បៈជាច្រើនស្ថិតនៅកណ្ដាលព្រៃស្ងាត់ជិតក្រុងកំពង់ធំ ប្រហែលពាក់កណ្ដាលផ្លូវពីភ្នំពេញទៅសៀមរាប-អង្គរ។ រមណីយដ្ឋានប្រាសាទសម្បូរណ៍ព្រៃគុកត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ការផ្លាស់ប្ដូរវប្បធម៌ជាមួយចិននិងឥណ្ឌា

រមណីយដ្ឋានសម្បូរណ៍ព្រៃគុកជាប្រភពព័ត៌មានដ៏សំខាន់អំពីប្រវត្តិសាស្ត្រអាស៊ី-អាគ្នេយ៍នាអំឡុងពាក់កណ្ដាលសហសវត្សទី១ នៃគ្រិស្តសករាជ។ សិលាចារឹកនិងសំណល់បុរាណវិទ្យាទាំងឡាយបានផ្ដល់ការយល់ដឹងទាក់ទងទៅនឹងសម័យកាលដ៏សំខាន់នេះ មុនការកើតឡើងនៃអាណាចក្រខ្មែរ។ សម្បូរណ៍ព្រៃគុកទំនងជាកើតឡើងពីការរួមបញ្ចូលគ្នារវាងសាសនា សិល្បៈនិងស្ថាបត្យកម្មរបស់ឥណ្ឌាជាមួយនឹងការរៀបចំក្រុងរបស់ចិនឲ្យក្លាយទៅជាការរៀបចំក្រុងថ្មីមួយបែបខ្មែរដែលជាមូលដ្ឋានគ្រឹះសម្រាប់ការសាងសង់ក្រុងខ្មែរនាសម័យក្រោយៗ។ រមណីយដ្ឋាននេះជាសញ្ញាបញ្ជាក់ពីការកកើតនៃក្រុងធារាសាស្ត្របូរដ្ឋសាសនាមួយដ៏ពិសេសដែលជាគំរូសម្រាប់អាណាចក្រខ្មែរសម័យអង្គរ។

សម្បូរណ៍ព្រៃគុកមានវឌ្ឍនភាពឡើងក្នុងរាជ្យព្រះបាទឦសានវរ្ម័នទី១ ដែលព្រះអង្គបានបង្រួបបង្រួមដែនដីទាំងមូល។ ក្នុងរាជ្យរបស់ព្រះអង្គសំណង់ប្រាសាទសំខាន់ៗជាច្រើននៅសម្បូរណ៍ព្រៃគុកត្រូវបានស្ថាបនាឡើង។ សំណង់ប្រាសាទទាំងនេះជាស្នាដៃឯកដ៏ល្អវិចិត្រនៃសិល្បៈខ្មែរបុរាណ រួមមាន ចម្លាក់ក្រឡោតលើតដ្ឋតួប្រាង្គរាង៨ជ្រុងចម្លាក់លើកំពោរបាយអនិងចម្លាក់សិល្បៈក្បាច់គុននៅលើក្បាច់លម្អរាងមេដាយ។ វឌ្ឍនភាពនៃរាជធានីឦសានបុរៈនិងធនធានដ៏ច្រើនរបស់ព្រះបាទឦសានវរ្ម័នទី១ បង្ហាញឲ្យឃើញតាមរយៈទំហំ ចំនួននិងគុណភាពនៃសំណង់ប្រាសាទទាំងអស់នេះ។ វិសាលភាព


កូនប្រាសាទអណ្ដែត : ប្រាង្គ T1

© អគ្គនាយកដ្ឋានបេតិកភណ្ឌ-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

នៃសំណង់ទឹកជាភស្តុតាងបន្ថែមទៀតដែលបង្ហាញពីសារៈសំខាន់របស់រាជធានីនិងពីសមិទ្ធផលបច្ចេកវិទ្យារបស់ស្ថាបត្យករនិងវិស្វករនាសម័យនោះ។

ទោះបីជាមានការផ្លាស់ប្តូររាជធានីទៅកន្លែងផ្សេងៗក៏ដោយក៏សម្បូណ៌ព្រៃគុកនៅជាមជ្ឈមណ្ឌលសំខាន់មួយរហូតដល់សម័យអង្គរ ដោយមានការកសាងសំណង់សាសនាបន្ថែម និងជួសជុលសំណង់ចាស់ពីមុនៗ ប្រាសាទនិងបដិមាជាច្រើននៅរមណីយដ្ឋាននេះបង្ហាញពីសម័យកាលខុសៗគ្នាចាប់តាំងពីការធ្លាក់ចុះនៃសន្តតិវង្សចេនឡារហូតដល់ការកកើតអាណាចក្រអង្គរ។ រចនាបថសិល្បៈនិងស្ថាបត្យកម្មនៃរមណីយដ្ឋានសម្បូណ៌ព្រៃគុកផ្តល់នូវភស្តុតាងដ៏មានតម្លៃពីការផ្លាស់ប្តូរវប្បធម៌ជាមួយចិននិងឥណ្ឌា។

នាចន្លោះពីសតវត្សទី១១និងចុងសតវត្សទី១៩ មានព័ត៌មានតិចតួចណាស់ដែលអាចឲ្យដឹងពីតួនាទីនិងសារៈសំខាន់នៃសម្បូណ៌ព្រៃគុកដែលជារាជធានីទីកន្លែងប្រតិបត្តិសាសនានិងតំបន់កសិកម្ម។ បច្ចុប្បន្ន ផ្ទះឈើទាំងឡាយនាសម័យបុរាណបានបាត់បង់រូបរាងទាំងស្រុង បន្សល់ទុកតែប្រាង្គប្រាសាទទិដ្ឋភាពទេសភាពនិងសំណង់ទឹកប៉ុណ្ណោះជាភស្តុតាង។ ក្នុងខណៈដែលប្រាសាទជាច្រើនបានដួលរលំក៏មានប្រាសាទសំខាន់ៗមួយចំនួននៅសេសសល់ដែរ បើទោះជាមានការរាតត្បាតពីព្រៃឈើមានការគម្រាមកំហែងពីអាកាសធាតុការបំផ្លិចបំផ្លាញពីសង្គ្រាមនិងការបោះបង់ចោលអស់ជាច្រើនសតវត្សក៏ដោយ។ សំណល់ប្រាសាទទាំងនេះ នៅតែមានតួនាទីយ៉ាងសំខាន់ខាងផ្នែកជំនឿសាសនាសម្រាប់សហគមន៍ក្នុងតំបន់។

ការការពារទ្រព្យសម្បត្តិដ៏មានតម្លៃពេលក្រោយសង្គ្រាម

នាសម័យសង្គ្រាមនៅ អាស៊ី-អាគ្នេយ៍ រមណីយដ្ឋានសម្បូណ៌ព្រៃគុកបានទទួលរងនូវការខូចខាតពីការវាយប្រយុទ្ធគ្នា។ ក្នុងអំឡុងពេលនោះ ការស្រាវជ្រាវការថែទាំនិងការការពារប្រាសាទនិងបុរាណវត្ថុបានទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ នៅឆ្នាំ១៩៩២ រាជរដ្ឋាភិបាលកម្ពុជាបានត្រួតពិនិត្យតំបន់នេះឡើងវិញដោយមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងពាក់ព័ន្ធដទៃទៀតបានចាប់ផ្តើមបំពេញការងាររបស់ខ្លួនដើម្បីការពារទ្រព្យសម្បត្តិដ៏មានតម្លៃនេះ។ ការខិតខំប្រឹងប្រែងថែទាំរមណីយដ្ឋាននាពេលនោះនៅមានកម្រិតដោយសារថវិកាស្តួចស្តើងនិងកង្វះខាតអ្នកជំនាញផ្នែកអភិរក្សជួសជុលនិងគ្រប់គ្រងក៏ប៉ុន្តែការងារទាំងអស់នោះពិតជាមានតម្លៃណាស់។ បច្ចុប្បន្នតួប្រាសាទទាំងឡាយទេសភាពនិងតំបន់ដ៏ធំទូលាយនេះកំពុងបើកទទួលភ្ញៀវទេសចរណ៍និងអ្នកជំនាញចូលទស្សនាក៏ដូចជាភស្តុតាងនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិរក្សនិងការពាររមណីយដ្ឋានសម្បូណ៌ព្រៃគុក។

រមណីយដ្ឋាននេះ គឺជាឯកសារដ៏សំខាន់ក្នុងដំណើរវិវត្តនៃប្រវត្តិសាស្ត្រ វប្បធម៌និងសាសនាដែលធ្វើឲ្យអាណាចក្រខ្មែររីកចម្រើនឡើងដល់កំពូល បង្ហាញឲ្យឃើញពីប្រវត្តិសាស្ត្រមួយលាតសន្ធឹងទាំងនៅក្នុងសម័យមុនអង្គរនិងសម័យអង្គរ។ សិលាចារឹក បុរាណវត្ថុនិងសំណង់ប្រាសាទទាំងឡាយនេះ ជាឯកសារប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់បំផុតបង្ហាញពីសង្គមខ្មែរនាសម័យនោះ។ ការសិក្សាស្រាវជ្រាវបុរាណវិទ្យាដែលកំពុងដំណើរការត្រូវតែបន្តធ្វើដើម្បីលាតត្រដាងឲ្យដឹងពីអាថ៌កំបាំងថ្មីៗនៅក្នុងរមណីយដ្ឋានបេតិកភណ្ឌដ៏អស្ចារ្យមួយនេះ។

ប្រាសាទយាយព័ន្ធ : ប្រាង្គ S1

© អគ្គនាយកដ្ឋានបេតិកភណ្ឌ-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

រមណីយដ្ឋាននេះ គឺជាឯកសារដ៏សំខាន់ក្នុងដំណើរវិវត្តនៃប្រវត្តិសាស្ត្រ វប្បធម៌និងសាសនាដែលធ្វើឲ្យអាណាចក្រខ្មែររីកចម្រើនឡើងដល់កំពូល

កិច្ចប្រជុំពេញអង្គលើកទី ៣៧
នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក
ពិធីបើកកិច្ចប្រជុំជាផ្លូវការ

ការសម្តែងសិល្បៈក្នុងពិធីបើកសម័យប្រជុំពេញអង្គជាផ្លូវការ

© ទីស្តីការគណៈរដ្ឋមន្ត្រី

ការអានសេចក្តីថ្លែងការដោយតំណាងវេទិកាយុវជនបេតិកភណ្ឌពិភពលោក

© ទីស្តីការគណៈរដ្ឋមន្ត្រី

បេតិកភណ្ឌអរូបីយ

រូបថតផ្តល់ឲ្យដោយសប្បុរស Anders Jiras



ល្ខោនស្បែកធំ

© Anders Jiras

របាំព្រះរាជទ្រព្យនៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

របាំព្រះរាជទ្រព្យ អប្សរា មេរា ២០១២

© Anders Jiras

© Anders Jiras

របាំព្រះរាជទ្រព្យនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន ស្គាល់ថាជារបាំខ្មែរបុរាណដែលបានផ្សារភ្ជាប់ជាមួយនឹងព្រះរាជវាំង ជាងមួយពាន់ឆ្នាំមកហើយ

របាំព្រះរាជទ្រព្យកម្ពុជា ឬហៅថា របាំក្បាច់បុរាណខ្មែរដែលល្បីល្បាញខាងកាយវិការដៃរាំដ៏ប៉ិនប្រសប់និងសម្លៀកបំពាក់ដ៏ទាក់ទាញអារម្មណ៍នេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះរាជវាំងខ្មែរអស់រយៈពេលជាង១០០០ឆ្នាំមកហើយ។

ជាប្រពៃណីការសម្តែងរបាំព្រះរាជទ្រព្យធ្វើឡើងសម្រាប់ព្រះរាជពិធីនិងពិធីបុណ្យនានាដូចជាពិធីគ្រងរាជ្យ ពិធីរៀបអភិសេក ពិធីបុណ្យសពឬក្នុងឱកាសបុណ្យទានផ្សេងៗរបស់ប្រជាជនខ្មែរ។ ទម្រង់សិល្បៈនេះដែលរួចផុតពីការបំផ្លាញនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ត្រូវបានទទួលការស្រឡាញ់ពេញចិត្តពីប្រជាជនខ្មែរជាច្រើននិងត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូនៅក្នុងឆ្នាំ២០០៨។

ដោយរួមបញ្ចូលនូវទម្រង់សក្ការៈនិងនិមិត្តរូបផងនោះ របាំព្រះរាជទ្រព្យតំណាងនូវតម្លៃពិតខាងស្មារតី សេចក្តីគោរពប្រណិប័តន៍និងប្រណិតភាព។ ឈុតរឿងនៃរបាំផ្សារភ្ជាប់ជាមួយរឿងព្រេងទាក់ទងនឹងដើមកំណើតរបស់ជនជាតិខ្មែរ។ ប្រជាជនខ្មែរបានផ្តល់តម្លៃខ្ពស់លើទម្រង់សិល្បៈបុរាណនេះជាយូរលង់មកហើយដោយចាត់ទុកជានិមិត្តរូបនៃវប្បធម៌ខ្មែរ។ តួអង្គសំខាន់បួននៅក្នុងរបាំនេះ គឺ តួនាង តួនាយរោង តួយក្សនិងតួស្វា។ តួនីមួយៗមានលក្ខណៈពិសេសរបស់ខ្លួនទាំងពណ៌សម្លៀកបំពាក់ ការតុបតែងមុខនិងរបាំងមុខៗ តាមរយៈកាយវិការនិងក្បាច់រាំដែលសិល្បករត្រូវហ្វឹកហាត់យ៉ាងខ្ជាប់ខ្ជួនអស់រយៈពេលច្រើនឆ្នាំនោះបានអន្ទងអារម្មណ៍មនុស្សពីសេចក្តីខ្លាចនិងកំហឹងទៅជាសេចក្តីស្រឡាញ់និងរីករាយ។ សិល្បករសម្តែងកាយវិការក្បាច់រាំនិងមនោសញ្ចេតនាតាមដំណើររឿងដែលជាអ្នកនាំសាររបស់ព្រះរាជាថ្វាយព្រះអាទិទេពនិងជូនបុព្វការីជនដោយមានវង់ភ្លេងពិណពាទ្យប្រគុំកំដរនិងក្រុមចម្រៀងនារីច្រៀងរៀបរាប់អំពីសាច់រឿង។

របាំព្រះរាជទ្រព្យបានរលាយស្ទើរទាំងស្រុងនៅក្រោមរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានសម្លាប់គ្រូរបាំនិងតន្ត្រីករស្ទើរតែទាំងអស់។ ក្រោយពីការដួលរលំនៃរបបប៉ុលពតនៅឆ្នាំ១៩៧៩ មកភ្លាម ក្រុមរបាំបានប្រមូលផ្តុំគ្នានិងបន្តសម្តែងរឿងបុរាណឡើងវិញ។ របាំព្រះរាជទ្រព្យបានស្តារឡើងវិញនូវភាពត្រចះត្រចង់របស់ខ្លួនដោយសារការខិតខំប្រឹងប្រែងរបស់សម្តេចព្រះរៀម បុប្ផាទេវី និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ៕

ស្បែកធំ ល្ខោនស្រមោលខ្មែរ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ល្ខោនស្បែកធំ ពិធីបុណ្យមហោស្រពយុវវ័យខ្មែរ ២០១០

© Anders Jiras

ល្ខោនស្បែកធំ Flying Circus នៅវត្តរាជបូ សៀមរាប ២០១០

© Anders Jiras

តាមប្រពៃណីការសម្ដែងត្រូវរៀបចំឡើងនៅពេលយប់ នៅទីហាលវាលតាមវាលស្រែឬនៅទីធ្លាវត្តអារាម

ល្ខោនស្បែកធំគឺជាល្ខោនស្រមោលរបស់ខ្មែរដែលគេឆ្លាក់រូបតួអង្គធ្វើពីស្បែកគោមានកម្ពស់រហូតដល់ពីរម៉ែត្រនិងជារូបនឹងថ្កល់មិនអាចកម្រើកដៃជើងនិងមាត់បានឡើយ។ ល្ខោនស្បែកធំមានដើមកំណើតតាំងពីមុនសម័យអង្គរមកម្លេះ ដូចរបាំព្រះរាជទ្រព្យនិងល្ខោនខោលផងដែរដែលត្រូវបានចាត់ទុកជាទម្រង់សិល្បៈសក្ការៈ។

ល្ខោននេះគេសម្ដែងដើម្បីឧទ្ទិសថ្វាយដល់អទិទេពដែលធ្វើឡើងក្នុងឱកាសពិសេសតែប៉ុណ្ណោះ ពីបីទៅបួនដងក្នុងមួយឆ្នាំ ដូចជាក្នុងពេលចូលឆ្នាំខ្មែរ បុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រឬសម្រាប់ការគោរពដល់ឥស្សរជនសំខាន់ៗ។

ល្ខោនស្បែកធំបានចុះខ្សោយ ក្រោយពីការធ្លាក់ចុះនៃអរិយធម៌អង្គរនាសតវត្សទី១៦នៃគ្រិស្តសករាជ។ ក៏ប៉ុន្តែក្រោយមកល្ខោននេះបានវិវត្តលើសពីការសម្ដែងសម្រាប់តែពិធីសក្ការៈទៅជាទម្រង់សិល្បៈដ៏វិចិត្រមួយដោយរក្សាបាននូវទិដ្ឋភាពជំនឿសាសនា។ ល្ខោនស្បែកធំបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ កាលពីឆ្នាំ២០០៨។

រូបស្បែកធំត្រូវបានគេឆ្លាក់លើស្បែកគោមួយផ្ទាំងហើយការឆ្លាក់នេះធ្វើឡើងដោយមានការរៀបចំកិច្ចពិធី ពិសេសសម្រាប់រូបតួអង្គនីមួយៗ។ ឧទាហរណ៍ រូបតួអង្គព្រះឥសូរនិងព្រះនារាយណ៍ត្រូវបានឆ្លាក់លើស្បែកគោដែលងាប់ដោយប្រការចៃដន្យឬងាប់ដោយធម្មជាតិនិងត្រូវឆ្លាក់ឲ្យរួចរាល់ក្នុងរយៈពេលមួយថ្ងៃក្រោមកិច្ចសាសនាពិសេសមួយ។ ស្បែកគោទាំងអស់ត្រូវបានលាបជ័រសំបកដើមកណ្ដោល។ ដំបូងសិល្បករគូររូបតួអង្គនៅលើស្បែកគោ បន្ទាប់មកឆ្លាក់ទម្លុះឲ្យចេញជារូបរាងតួអង្គនោះរួចលាបពណ៌មុនភ្ជាប់រូបស្បែកទៅនឹងចម្រៀកឫស្សីពីរដើមសម្រាប់លើកកាន់នៅពេលសម្ដែង។

ជាប្រពៃណី ល្ខោនស្បែកធំគេសម្ដែងនៅពេលយប់នៅទីហាលវាលតាមវាលស្រែឬនៅក្នុងទីធ្លាវត្តអារាម។ គេចងផ្ទាំងសំពត់សធំមួយភ្ជាប់ទៅនឹងបង្គោលឫស្សីខ្ពស់ពីរដើម នៅពីមុខគំនរភ្លើងឬនៅសម័យបច្ចុប្បន្នគេប្រើអំពូលភ្លើងបញ្ចាំងដើម្បីរំលេចស្រមោលរូបស្បែកនៅលើផ្ទាំងសំពត់សនោះ។ សិល្បករជាអ្នកធ្វើឲ្យរូបស្បែកមានជីវិតតាមរយៈការធ្វើចលនារូបស្បែកទៅតាមកាយវិការនៃក្បាច់រាំ។ ការសម្ដែងធ្វើឡើងដោយមានវង់ភ្លេងពិណពាទ្យប្រគុំកំដរជាមួយនឹងអ្នកពោលពីរនាក់។ ការសម្ដែងរឿងរាមកេរ្តិ៍ត្រូវការពេលអស់ជាច្រើនយប់និងប្រើផ្ទាំងរូបស្បែករហូតដល់១៦០ផ្ទាំងក្នុងឈុតនីមួយៗ។

ស្បែកធំត្រូវបានបំផ្លាញស្ទើរតែបាត់បង់នៅក្រោមរបបខ្មែរក្រហម ប៉ុន្តែ ក្រោយឆ្នាំ១៩៧៩មក ល្ខោនស្បែកធំបានរស់ឡើងវិញដោយសារគុណូបការៈរបស់សិល្បករមួយចំនួនតូចដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ ផ្ទាំងរូបស្បែកធំជាច្រើនត្រូវបានកម្ទេចចោលស្ទើរបាត់បង់ទាំងស្រុង ប៉ុន្តែក្រោយមកគេចាប់ផ្ដើមធ្វើឡើងវិញ ហើយក្រុមសម្ដែងល្ខោនស្បែកធំក៏កើតឡើងវិញផងដែរ។ ទោះជាយ៉ាងណាក៏ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានខិតខំជំរុញឲ្យមានការផ្ទេរចំណេះដឹងបច្ចេកទេសនិងចំណេះធ្វើជាពិសេសទាក់ទងនឹងការផលិតរូបស្បែក៕

ប្រវត្តិជោគជ័យនៃអាងជីវៈចម្រុះបឹងទន្លេសាប

លោក ប៉ូល អេវើរីងហាំ Paul Everingham
មជ្ឈមណ្ឌលថែរក្សាជីវិតសត្វព្រៃនិងបរិស្ថាន ខេត្តកោះកុង
(សូមថ្លែងអំណរគុណដល់ក្រសួងបរិស្ថានកម្ពុជា)

ព្រៃលិចទឹកក្នុងបឹងទន្លេសាប

© C. Frank Starmer

ទន្លេសាប គឺជាបឹងដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍ និងជាប្រព័ន្ធអេកូសាស្ត្រដ៏ធំមួយក្នុងចំណោមប្រព័ន្ធអេកូសាស្ត្រធំៗនានានៅតាមតំបន់ដីសើមក្នុងពិភពលោកដោយសារលក្ខណៈបរិស្ថានដ៏ល្អឯកនិងជីវៈចម្រុះដ៏ពិសេសនៃបឹងនេះ។

ភាពសម្បូរបែបដ៏អស្ចារ្យនៃសត្វមានជីវិតនៅក្នុងបឹងទន្លេសាបត្រូវបានគេកត់ត្រាជាឯកសារតាំងពីសតវត្សទី១៣ ដោយអ្នកប្រាជ្ញចិនមួយរូបឈ្មោះ ជីវ តាក្វាន់។ លោកបានកត់ត្រាអំពីភាពសម្បូរបែបនៃត្រី កង្កែប អណ្តើកទឹកនិងអណ្តើកគោក ជីងចក់ ក្រពើ សិប្បជាតិ ដូចជាខ្យង គ្រំនៅក្នុងទន្លេនិងនៅតាមតំបន់ជុំវិញទន្លេ។ ចម្លាក់លើបនៅតាមជញ្ជាំងប្រាសាទអង្គរ ដូចជាប្រាសាទបាយ័ន ក៏មានឆ្លាក់រូបសត្វជាច្រើនដែលមាននៅក្នុងបឹងទន្លេសាបជាពិសេសគឺត្រី ក្រពើ អណ្តើកនិងសត្វស្លាបផ្សេងៗជាច្រើនទៀត។

សត្វនិងរុក្ខជាតិរួមមានថនិកសត្វក៏ដូចជាសត្វស្លាបនិងសត្វល្មូនពិតជាមានប្រភេទដ៏ច្រើនសម្បូរបែបឥតគណនា ប៉ុន្តែប្រភេទខ្លះកំពុងឈានទៅរកការបាត់បង់ទាំងស្រុង។ រុក្ខជាតិជាច្រើនប្រភេទនិងព្រៃឈើច្រើនបែបយ៉ាងបានធ្វើឲ្យបឹងនេះមានលក្ខណៈឯកដែលសម្របខ្លួនបានទៅតាមការផ្លាស់ប្តូររដូវនិងលក្ខខណ្ឌធារាសាស្ត្រដែលប្រែប្រួលយ៉ាងខ្លាំង។

ទន្លេដែលហូរបញ្ច្រាសទិស

រៀងរាល់ឆ្នាំនៅរដូវវស្សាកម្រិតទឹកក្នុងទន្លេមេគង្គបានឡើងនិងហូរចូលក្នុងទន្លេសាប។ ទឹកនៅក្នុងទន្លេមិនហូរចេញដូចដែលគេឃើញនៅក្នុងរដូវប្រាំងនោះទេ ប៉ុន្តែបែរជាត្រូវប្តូរទិសហូរឡើងចូលក្នុងបឹងទៅវិញដោយសារបាតុភូតបែបនេះហើយទើបទន្លេសាប គឺជាទន្លេដ៏ធំតែមួយគត់នៅក្នុងពិភពលោកដែលមានទឹកហូរបញ្ច្រាសទិសគ្នាទៅតាមរដូវទាំងពីររៀងរាល់ឆ្នាំ។ នៅរដូវទឹកឡើងកម្រិតទឹកក្នុងបឹងប្តូរពីកម្ពស់១ម៉ែត្រឬ១ម៉ែត្រកន្លះ ទៅដល់៨ម៉ែត្រឬ១០ម៉ែត្រ ហើយធ្វើឲ្យផ្ទៃបឹងត្រូវគុណទ្វេរឡើងប្រាំដង ទឹកក៏ហូរលិចវាលទំនាបទាំងឡាយដែលនៅជុំវិញបឹង។

គេទទួលស្គាល់ថាបឹងទន្លេសាបគឺជាកន្លែងនេសាទត្រីទឹកសាបដ៏ធំមួយនៅក្នុងពិភពលោក។ ចរន្តទឹកឡើងរៀងរាល់ឆ្នាំបណ្តាលឲ្យត្រីជាច្រើនធ្វើបន្លាស់ទីចេញចូលក្នុងលក្ខណៈយ៉ាងស្មុគស្មាញក្នុងនោះមានទាំងពងត្រី កូនត្រី ឬក៏ត្រីធំៗជាដើម។ ពងត្រីនិងត្រីទាំងអស់ធ្វើបន្លាស់ទីទៅតាមស្ទឹងនិងអូរនានានៅតាមវាលទំនាបខាងលិចនិងខាងត្បូងប្រទេសកម្ពុជាតាមជួរភ្នំជិតៗនិងតាមទឹកទន្លេមេគង្គដែលមានស្ទឹងបឹងបួរតភ្ជាប់នឹងវាលទំនាបដ៏ធំល្វឹងល្វើយ។

ប្រជាជនកម្ពុជាប្រមាណពីរលាននាក់ពឹងផ្អែកផ្ទាល់ទៅនឹងផលនេសាទនៃបឹងទន្លេសាបដើម្បីរស់។ម្យ៉ាងវិញទៀត តម្រូវការជីវជាតិប្រូតេអ៊ីនចំនួនពាក់កណ្តាលនៅប្រទេសកម្ពុជាមានប្រភពមកពីផលនេសាទ ត្រីដែលមានបរិមាណជាង២៥០ពាន់តោនក្នុងមួយឆ្នាំ។

ការការពារសត្វស្លាប

បឹងទន្លេសាបសម្បូរទៅដោយសត្វស្លាបជាច្រើនប្រភេទដែលកាលពីមុនរស់នៅពាសពេញក្នុងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ នៅក្នុងខែខ្លះគេឃើញមានសត្វស្លាបដ៏ល្អឯករាប់រយពាន់ក្បាលដូចជាសត្វកុក ក្រសា ត្រាល ត្រដក់ក្ង ជាដើម។ បឹងទន្លេសាបជាជម្រកសត្វស្លាបប្រមាណជា១៧ប្រភេទដែលកំពុងឈានទៅរកការបាត់បង់ទាំងស្រុង ហើយចំនួនដែលនៅសេសសល់នេះពិតជាមានអត្ថន័យសំខាន់យ៉ាងខ្លាំងសម្រាប់ពិភពលោកទាំងមូល សត្វស្លាបជាច្រើនប្រភេទផ្សេងទៀតពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់តំបន់នេះ។ ការកើនឡើងនូវចំនួនសត្វស្លាបទាំងនេះតាំងពីមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការត្រួតពិនិត្យការពារដែលបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩៩ គឺជាជោគជ័យមួយក្នុងចំណោមជោគជ័យដ៏ធំៗនៅក្នុងពិភពលោកក្នុងការថែរការពារនិងអភិរក្ស។

បឹងទន្លេសាបនិងវាលទំនាបលិចទឹកជុំវិញត្រូវបានបញ្ចូលចាប់តាំងពីខែតុលា ឆ្នាំ១៩៩៧ ទៅក្នុងចំណោមបឹងជីវៈចម្រុះនៅក្នុងក្របខណ្ឌនៃកម្មវិធីមនុស្សនិងជីវៈចម្រុះរបស់អង្គការ

បក្សីទឹកនៅភូមិដូនស្វង់ ទន្លេធ្មារ

© Heng Sokrith/CI



ទុង

© Simon Mahood/WCS

ទន្លេសាបត្រូវបានគេទទួលស្គាល់ថាជាទន្លេមួយក្នុងចំណោមទន្លេដែលមានធនធានត្រីទឹកសាបយ៉ាងសំខាន់ក្នុងពិភពលោក

យូណេស្កូ ហើយបន្ទាប់មកបឹងនេះត្រូវបានការពារដោយច្បាប់កម្ពុជាមួយដែលបានចូលជាធរមាននៅឆ្នាំ២០០១។

បឹងជីវៈចម្រុះនេះចែកចេញជាតំបន់ការពារធំៗចំនួន៣ (តំបន់នីមួយៗតំណាងឲ្យប្រព័ន្ធអេកូសាស្ត្រល្អឯកខុសៗគ្នា ដែលគេបែងចែកដើម្បីការពារនិងអភិរក្សក្នុងរយៈពេលវែង) មានជម្រកត្រីចំនួន៦កន្លែងតំបន់ការពារជីវៈចម្រុះចំនួន៤និងតំបន់សំខាន់ៗសម្រាប់ការអភិរក្សសត្វស្លាបចំនួន៩ កន្លែងដែលត្រូវបានគេទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ។ តំបន់ទាំងនេះសុទ្ធតែស្ថិតនៅក្នុងតំបន់ទ្រនាប់និងតំបន់ឆ្លងកាត់។

គ្របខណ្ឌនៃបឹងជីវៈចម្រុះ

បឹងជីវៈចម្រុះគឺជាតំបន់ដែលកំណត់ដោយប្រទេសជាម្ចាស់និងទទួលស្គាល់ដោយអង្គការយូណេស្កូសម្រាប់ជួយលើកស្ទួយនិងរិះរកវិធីសាស្ត្រថ្មីៗ អនុញ្ញាតឲ្យមានការផ្សារភ្ជាប់រវាងការអភិវឌ្ឍប្រកបដោយចីរភាព ជីវៈចម្រុះនិងវប្បធម៌។ កិច្ចខិតខំប្រឹងប្រែងត្រូវបានផ្តោតទៅលើការគ្រប់គ្រងរួមស្វែងរកការអភិវឌ្ឍនិងសម្របសម្រួលនយោបាយល្អ។ ធានានូវការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពឲ្យមានការចូលរួមពីប្រជាពលរដ្ឋនិងប្រើវិធីសាស្ត្រវិទ្យាសាស្ត្រស្អាតស្អំ។

ការចុះបញ្ជីដែលមានការគោរពនិងទទួលស្គាល់ដ៏ខ្ពង់ខ្ពស់ពីអង្គការយូណេស្កូបានទាក់ទាញវិភាគទានដ៏មានប្រយោជន៍ពីបណ្តាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិពីវិទ្យាស្ថានវិទ្យាសាស្ត្រនិងអ្នកផ្តល់ជំនួយផ្សេងៗ។ ការងារសម្របសម្រួលដ៏ចាំបាច់រវាងក្រសួងពាក់ព័ន្ធនានារវាងលិខិតុបករណ៍រដ្ឋាភិបាលនិងអង្គភាពខាងក្រៅត្រូវបានពង្រឹងយ៉ាងខ្លាំងនៅក្នុងក្របខណ្ឌនៃបឹងជីវៈចម្រុះ។ ការងារសម្របសម្រួលបានធ្វើឲ្យការងារកាន់តែមានលក្ខណៈសកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងនិងសមត្ថភាពនៃការអនុវត្តនៅក្នុងកម្រិតមូលដ្ឋាននិងបានធានាឲ្យមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងគ្រប់កម្រិតក្នុងការធ្វើសេចក្តីសម្រេចនានា។

នៅគ្រប់ទីកន្លែងទីតាំងធម្មជាតិបានទទួលរងនូវសម្ពាធដ៏ធ្ងន់ដែលបណ្តាលមកពីការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជននិងតម្រូវការម្ហូបអាហារក្នុងជីវិតប្រចាំថ្ងៃ។ កំណត់សម្គាល់នេះពិតជាត្រឹមត្រូវចំពោះតំបន់សើមសំបូរទៅដោយសត្វនិងរុក្ខជាតិដែលងាយនឹងប្រឈមមុខនឹងការធ្វើអាជីវកម្មហួសហេតុលើសអំពីសមត្ថភាពផលិតកម្មធម្មជាតិនិងសេដ្ឋកិច្ច។ ប៉ុន្តែទោះបីជាមានទំនោរបែបនេះក្តីប្រព័ន្ធអេកូសាស្ត្រនៃអាងជីវៈចម្រុះបឹងទន្លេសាបបានបង្ហាញនូវសក្តិភាពនៃការទ្រាំទ្របានគួរឲ្យស្ងើចសរសើរ។

ផលិតកម្មត្រីបានចាប់ផ្តើមចុះថយដោយសារកម្រិតនេសាទខ្ពស់ហួសហេតុ ប៉ុន្តែ ក៏មិនទាន់ឈានដល់កម្រិតដូចដែលតំបន់នេសាទច្រើនហួសហេតុផ្សេងធ្លាប់បានទទួលរងគ្រោះដែរ។ ថនិកសត្វមួយចំនួននៅតែកំពុងឈានទៅរកការបាត់បង់ ប៉ុន្តែសត្វប្រភេទផ្សេងទៀត ដូចជាសត្វស្លាបរស់នៅលើទឹកបែរជាកើនចំនួនទៅវិញ។ តំបន់ដែលមានព្រៃលិចទឹកធំៗនិងជម្រកសត្វព្រៃផ្សេងទៀតកំពុងស្ថិតនៅក្នុងស្ថានភាពល្អនៅឡើយ។

បណ្តាញពិភពលោកនៃបឹងជីវៈចម្រុះរបស់អង្គការយូណេស្កូ ជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ វិទ្យាសាស្ត្រនិងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពពិតជាបានផ្តល់នូវក្របខណ្ឌដ៏ល្អមួយសម្រាប់អនុញ្ញាតឲ្យកម្ពុជាបន្តឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនខ្លួន ហើយទន្ទឹមនឹងនោះក៏ធានាបាននូវការការពាររតនសម្បត្តិមួយក្នុងចំណោមរតនសម្បត្តិធម្មជាតិធំៗ ទាំងឡាយនៅក្នុងពិភពលោក។

ស្មារតីចងចាំនៃពិភពលោករបស់កម្ពុជា

បណ្ឌិត ហេឡិន ចារីស Helen Jarvis
ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា
សមាជិកនៃគណៈកម្មាធិការទីប្រឹក្សាអន្តរជាតិនៃកម្មវិធីស្មារតីចងចាំនៃពិភពលោករបស់យូណេស្កូ

កន្ទ្រង់តាំងពិព័ណ៌រូបថត

© ការិយាល័យរបស់យូណេស្កូប្រចាំនៅរាជធានីភ្នំពេញ

ស្មារតីចងចាំនៃពិភពលោកគឺជាកម្មវិធីមួយនៃអង្គការ UNESCO ដែលបានបង្កើតឡើងនៅឆ្នាំ១៩៩២ក្នុងគោលបំណងទទួលស្គាល់ការពារនិងឲ្យតម្លៃឯកសារបេតិកភណ្ឌនៃមនុស្សជាតិដើម្បីងាយស្រួលក្នុងការប្រើប្រាស់ឯកសារទាំងនោះផង។ កម្មវិធីនេះបានបំពេញអនុសញ្ញាពីរបន្ថែមទៀតពីអង្គការ UNESCO គឺអនុសញ្ញាបេតិកភណ្ឌពិភពលោកនិងបេតិកភណ្ឌអរូបីនៃវប្បធម៌មនុស្សជាតិ។

ប្រទេសកម្ពុជាមានវប្បធម៌ក្នុងការសរសេរគួរឲ្យគោរពមិនត្រឹមតែនៅក្នុងសម័យនគរភ្នំទេគឺមានមុនគ្រិះសក្ករាជទី៤ទៀត ផ្ទាំងសិលាដែលបានបន្សល់ទុកយូរលង់ណាស់មកហើយ (ចារជាភាសាសំស្រ្កឹតចាស់ជំនាន់មុនយូរលង់ណាស់មកហើយ) ដែលមានកាលបរិច្ឆេទពីសតវត្សទី៦ មុនគ្រិះសក្ករាជ សូម្បីតែអត្ថបទដែលត្រូវបានសរសេរដំបូងនៅលើអត្ថបទផ្ទាំងសិលា ក៏បានបង្ហាញអំពីការសរសេរលើផ្ទាំងស្បែកសត្វផងដែរ ប៉ុន្តែផ្ទាំងស្បែកសត្វនេះមិនបានបន្សល់ទុកឡើយ។

ថ្វីបើការសិក្សាស្រាវជ្រាវពីការប្រើប្រាស់សាស្ត្រាស្លឹករឹតក្នុងសម័យអង្គរមិនបានរកឃើញក៏ដោយក៏សាស្ត្រាស្លឹករឹតដែលមានវ័យចំណាស់បំផុត មានអាយុកាលចាប់ពីពាក់កណ្តាលសតវត្សទី១៩ដែរ ប៉ុន្តែ ដោយសារឯកសារទាំងនេះជានិច្ចកាលបានទទួលការកត់ចម្លងឡើងវិញ (រាប់បញ្ចូលទាំងច្បាប់ឬមាត្រាមួយចំនួនផងដែរ) ហើយផ្នែកខ្លះនៃច្បាប់ ឬមាត្រានេះអាចមានអាយុកាលពីសតវត្សទី១២។ ឯកសារទាំងអស់នេះត្រូវបានរក្សាទុកចម្លងដើម្បីប្រកាសពីច្បាប់រាជវង្សបទបញ្ញានិងស្នាដៃរបស់បុព្វបុរសដើម្បីថែរក្សានិងភ្ជាប់ទៅនឹងគម្ពីរសាសនានិងអត្ថបទផ្សេងៗទៀត។

អក្សរសាស្ត្រខ្មែរត្រូវបានជឿថាមានប្រភពមកពីអក្សរសាស្ត្រព្រាហ្មញ្ញសាសនានៃឥណ្ឌាភាគខាងត្បូង (ដូចជា មនជំនាន់ដើម ជ្វា ចាម និងបន្ទាប់មកថៃ ឡាវ ដែលមានប្រភពចេញពីអក្សរសាស្ត្រខ្មែរ ហើយមីយ៉ាន់ម៉ា មានប្រភពពីអក្សរសាស្ត្រមននិងភាសាដទៃទៀតជាច្រើនរបស់ឥណ្ឌា)។ ខ្មែរមានប្រវត្តិសាស្ត្ររបស់ខ្លួនជាអក្សរឯករាជ្យច្រើនជាង១១០០ឆ្នាំមកហើយ។

ក្រដាសឯកសារជាច្រើនដែលបានសរសេរដោយទឹកខ្មៅត្រូវបានជឿជាក់ថាបានបង្កើតឡើងនៅកំឡុងដើមសតវត្សទី១៩ ហើយភាគច្រើនសម្រាប់ការកត់ត្រាកិច្ចការរាជវាំងខណៈអក្សរសាស្ត្រប្រើជាមួយផលិតផលបានលេចរូបរាងក្នុងក្រុងភ្នំពេញពីពីរទសវត្សដំបូងនៃសតវត្សទី២០។ អក្សរពុម្ពខ្មែរត្រូវបានបង្កើតឡើងជាលើកដំបូងនៅប្រទេសបារាំងក្នុងឆ្នាំ១៨៧៧។

ក្នុងសតវត្សទី២០ ទម្រង់ថ្មីនៃបច្ចេកវិទ្យាព័ត៌មានដ៏ទំនើបបានចូលមកប្រទេសនេះរួមមានហ្វីល (microfilm) កាសែតម៉ាញ៉េ កាសែតវីដេអូកុន ទូរទស្សន៍ ហើយរឿងកំប្លែងនៅក្នុងទសវត្ស១៩៥០ ហើយនៅទសវត្ស១៩៦០ ព្រះមហាវីរៈក្សត្រ នរោត្តមសីហនុ បានដឹកនាំថតភាពយន្តវប្បធម៌ដ៏រំភើបនិងស្ថានីយវិទ្យុជាតិ (ក្រោយមកទូរទស្សន៍ជាតិ) របស់កម្ពុជាក៏មានការរីកចម្រើនដែរ។

នៅពេលដែលសង្គ្រាមបានបញ្ចប់នៅជុំវិញទីក្រុងភ្នំពេញ ការបោះពុម្ពផ្សាយ ក៏ដូចជាសហគ្រាសនានាត្រូវបានបិទ។ កំឡុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ស្ទើរតែមិនមានការបោះពុម្ពផ្សាយបើទោះបីជាចម្រៀង កំណាព្យនិងរឿងខ្លីៗមួយចំនួនពិតជានៅក្នុងសារព័ត៌មានផ្លូវការរបស់របបនេះប៉ុណ្ណោះប៉ុន្តែព្រលឹងអ្នកក្លាហានខ្លះ បានបង្ហាញយ៉ាងច្បាស់លាស់ក្នុងការបន្តសរសេរ និពន្ធជាសម្ងាត់ផងដែរនាសម័យនោះ។

ក្រោយការផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី ៧ មករា ១៩៧៩ ការទ្រទ្រង់ត្រូវបានបង្កើត

បណ្ណសារ

© ការិយាល័យរបស់យូណេស្កូប្រចាំនៅរាជធានីភ្នំពេញ

សៀវភៅរឿងខ្មែរ

© UNESCO Phnom Penh Office

ហ្វិល

© ការិយាល័យរបស់យូណេស្កូប្រចាំនៅរាជធានីភ្នំពេញ

ឡើងមានការបង្កើតសង្គមប្រជាជនកម្ពុជាឡើងវិញហេដ្ឋារចនាសម្ព័ន្ធនិងការជួសជុលឯកសារជាសម្បត្តិបេតិកភណ្ឌពិភពលោក។

បណ្ណសារសារមន្ទីរទួលស្លែង

លើការចុះក្នុងបញ្ជីអន្តរជាតិនៃស្មារតីចងចាំពិភពលោកប្រទេសកម្ពុជាកំពុងដំណើរការបង្កើតគណៈកម្មាធិការជាតិស្មារតីចងចាំពិភពលោក ប៉ុន្តែសកម្មភាពការងារនិងការចូលរួមក្នុងការទាក់ទងសកម្មភាពថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់អន្តរជាតិ យើងបានចូលរួមរួចរាល់អស់ហើយ។

ក្នុង ខែកក្កដា ឆ្នាំ២០០៩ បណ្ណសារសារមន្ទីរទួលស្លែងបានបញ្ចូលជាស្មារតីចងចាំពិភពលោកថ្នាក់អន្តរជាតិដោយយោងទៅតាមការចុះបញ្ជីថ្នាក់អាស៊ីប៉ាស៊ីហ្វិកឆ្នាំ ២០០៨ ហើយនេះគឺជាបណ្ណសារទីមួយនិងជាបណ្ណសារតែមួយគត់របស់ប្រទេសកម្ពុជា។

បណ្ណសារសារមន្ទីរទួលស្លែងបានផ្ទុកនូវរូបថត ឯកសារ ដែលបានបន្សល់ទុកពីកន្លែង ស-២១ (ជាគុកមជ្ឈឹម) ហើយជាមជ្ឈមណ្ឌលមួយសម្រាប់ធ្វើទារុណកម្មនៃរបបខ្មែរក្រហមតាមការប៉ាន់ស្មានមានប្រហែលជាង១៥ ០០០ នាក់បានជាប់ឃុំឃាំងនៅអតីតវិទ្យាល័យ។ បណ្ណសារសារមន្ទីរទួលស្លែងផ្ទុករូបថតច្រើនជាង៥ ០០០ សន្លឹកនៃរូបភាពអ្នកទោសនិងចម្លើយសារភាពផងដែរ មានការដកស្រង់ជាច្រើនទៀតក្រោមការធ្វើទារុណកម្ម ឯកសារកំណត់ត្រាប្រវត្តិរូបអ្នកទោសសន្តិសុខយាមគុកនិងសម្ភារៈសម្រាប់ការងារសន្តិសុខផ្សេងទៀត។

បណ្ណសារសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបានផ្ទុកឯកសារសំខាន់នានាដែលបង្ហាញពិភពលោកអំពីសោកនាដកម្មនៃបទឧក្រិដ្ឋដែលបានកើតឡើងនៅប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥-១៩៧៩

បណ្ណសារសារមន្ទីរទួលស្លែងជាឯកសាររូបភាពដ៏ពេញលេញមួយដើម្បីបង្ហាញពីប្រព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យហើយក្រោមរបបនេះបានធ្វើឲ្យប្រជាជនពី ២-៣ លាននាក់(២៥ ទៅ ៣០ ភាគរយនៃចំនួនប្រជាជនសរុប) បានបាត់បង់ជីវិតក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ ថ្ងៃ។ សព្វថ្ងៃនេះឯកសារត្រូវបានប្រើប្រាស់ផ្តល់ជូនជាភស្តុតាងក្នុងការកាត់ទោសថ្នាក់ដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងបទឧក្រិដ្ឋធ្ងន់ធ្ងរក្រោមការដឹកនាំរបស់អង្គជំនុំជំរះវិសមញ្ញនៃតុលាការកម្ពុជា ហើយសារៈសំខាន់របស់វាបានមកពីមរតកសាសន៍នៃអំពើឃោរឃៅរបស់មនុស្សទៅលើមនុស្សជាតិនិងឯកសាររបស់វាដែលជាឧទាហរណ៍ដ៏សម្បើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងសតវត្សទី២០ នេះជាមួយនឹងផលប៉ះពាល់ចម្បងក្នុងប្រវត្តិសាស្ត្រពិភពលោក។

បណ្ណសារសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងបានសម្រេចនិមិត្តសញ្ញាឋានៈជាលក្ខណៈអន្តរជាតិតំណាងឲ្យសោកនាដកម្មនៃបទឧក្រិដ្ឋលើទឹកដីប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ ដែលមានមនុស្សជាច្រើនបានប្រើប្រាស់រូបភាពទាំងនេះនៅលើគម្របសៀវភៅ ផ្ទាំងរូបភាព កូនសៀវភៅផ្សព្វផ្សាយគៀវទេសចរនិងសៀវភៅបង្ហាញពីព័ត៌មាន។ បណ្ណសារសារមន្ទីរទួលស្លែងក្រោមការជួសជុលនិងថែរក្សារបស់នាយកដ្ឋានសារមន្ទីរនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

CAMBODIA
WHC 37th 2013

United Nations
Educational, Scientific and
Cultural Organization

World
Heritage
Convention

Layout & Printing by **Graphic Roots:** www.graphicroots.net